ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**កំពង់ផែស្វយ័តក្រុងព្រះសីហនុ**

**Sihanoukville Autonomous Port**



# របាយការណ៍ ប្រចាំឆ្នាំ ២០១៩







# ទស្សនវិស័យ

ក្លាយជាមជ្ឈមណ្ឌលផ្គត់ផ្គង់ និងចែកចាយឈានមុខគេនៅកម្ពុជា។

# បេសកកម្ម

ធានាបំពេញតាមតម្រូវការរបស់អតិថិជន តាមរយៈការបង្កើនគុណភាពសេវាកម្ម ប្រតិបត្តិការឆាប់រហ័ស និងតម្លៃសមស្រប។



# ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| ស្ថានភាពហិរញ្ញវត្ថុ | | ៣១ ធ្នូ ២០១៩ (ពាន់រៀល) | ៣១ ធ្នូ ២០១៨ (ពាន់រៀល) (បានរាយការណ៍ឡើងវិញ) | ៣១ ធ្នូ ២០១៧ (ពាន់រៀល) |
|---|---|---|---|---|
| ទ្រព្យសកម្មសរុប | | ១.៣៧២.២៦៦.២២១ | ១.៣២៨.១៩០.៤៨៨ | ១.២៨០.៥១០.០៣៨ |
| បំណុលសរុប | | ៦៨៩.៧៤១.៣៨១ | ៦៧៨.៦៨០.២៥៤ | ៦៣៣.៨៩៩.៤៨៤ |
| មូលធនសរុប | | ៦៨២.៥២៤.៨៤០ | ៦៤៩.៥១០.២៣៤ | ៦៤៦.៦១០.៥៥៤ |
| **លទ្ធផលហិរញ្ញវត្ថុ** | | **ឆ្នាំ២០១៩ (ពាន់រៀល)** | **ឆ្នាំ២០១៨ (ពាន់រៀល)** | **ឆ្នាំ២០១៧ (ពាន់រៀល)** |
| ចំណូលសរុប | | ៣៣៣.៩១៣.៣៧៧ | ២៧៥.៥៧៥.៦៤៥ | ២២៧.៣៩៧.៨៣៥ |
| ចំណេញមុនបង់ពន្ធ | | ៦៥.១៨៥.៤២៨ | ៤៨.៧០២.៧៨៧ | ៣៧.៨៥៤.៦៣២ |
| ចំណេញសុទ្ធក្នុងការិយបរិច្ឆេទ | | ៤៣.៤៦៣.៥០០ | ៤៥.១៦៥.៧៧២ | ២៥.១៣៩.៣១៦ |
| លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ | | ៤២.៨០២.៥០០ | ១៦.០០៨.៧៧២ | ២៥.១៣៩.៣១៦ |
| **អនុបាតហិរញ្ញវត្ថុ** | | **៣១ ធ្នូ ២០១៩** | **៣១ ធ្នូ ២០១៨** | **៣១ ធ្នូ ២០១៧** |
| អនុបាតសាធនភាព | | ១០,៧៨% | ១០,៨២% | ៧,៩៥% |
| អនុបាតបំណុលធៀបនឹងមូលធន | | ១,០១ | ១,០៤ | ០,៩៨ |
| អនុបាតសន្ទនីយភាព | អនុបាតចរន្ត | ២,៧៣ | ៣,២៧ | ២,៥០ |
| | អនុបាតចរន្តលឿន | ២,៥១ | ៣,០៨ | ២,៣៨ |
| | | **ឆ្នាំ២០១៩** | **ឆ្នាំ២០១៨** | **ឆ្នាំ២០១៧** |
| អនុបាតចំណេញភាព | ផលចំណេញក្នុងមួយឯកតាទ្រព្យសកម្ម | ៣,១៧% | ៣,៤០% | ១,៩៦% |
| | ផលចំណេញក្នុងមួយឯកតាមូលធន | ៦,៣៧% | ៦,៩៥% | ៣,៨៩% |
| | គំលាតចំណេញដុល | ២៤,៣៧% | ២៣,២៦% | ២៥,៦៨% |
| | គំលាតចំណេញភាព | ១៣,០២% | ១៦,៣៩% | ១១,០៦% |
| | ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ(រៀល) | ៥០៦,៧៣ | ៥២៦,៥៨ | ២៩៣,០៩ |
| អនុបាតលទ្ធភាពសងការប្រាក់ | | ៦.៧០ | ៥.៩៤ | ៥.២២ |
| ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (រៀល) | | - | ៤០៣ | ៤០៣ |

# ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេបប្រចាំឆ្នាំ២០១៩









## ភាគហ៊ុនិករបស់ កសស

| ល.រ | ប្រភេទមូលបត្រកម្មសិទ្ធិ | ភាគហ៊ុនិក | ចំនួនមូលបត្រកាន់កាប់ | ភាគរយ |
|---|---|---|---|---|
| ១ | មូលបត្រកម្មសិទ្ធិគ្មានសិទ្ធបោះឆ្នោតប្រភេទ “ក” | រដ្ឋតំណាងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ៣៦៤.៥៣០.៨៦១ | ៨០,៩៥% |
| ២ | មូលបត្រកម្មសិទ្ធិមានសិទ្ធបោះឆ្នោតប្រភេទ “ខ” | រដ្ឋតំណាងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ៦៤.៣២៨.៩៧៥ | ១៤,២៩% |
| ៣ | មូលបត្រកម្មសិទ្ធិមានសិទ្ធបោះឆ្នោតប្រភេទ “គ” | ឯកជន | ២១.៤៤២.៩៩២ | ៤,៧៦% |
| សរុប | | | ៤៥០.៣០២.៨២៨ | ១០០% |

## ភាគហ៊ុនិកកាន់កាប់មូលបត្រកម្មសិទ្ធិប្រភេទ «គ» របស់ កសស

| ល.រ | ភាគហ៊ុនិក | ចំនួនមូលបត្រកាន់កាប់ | ភាគរយ |
|---|---|---|---|
| ១ | ESOP | ២.១៤៤.២៩៩ | ១០% |
| ២ | KAMIGUMI CO., LTD | ១១.១៥០.៣២៤ | ៥២% |
| ៣ | KOBE-OSAKA International Port Corporation | ២.១៤៤.៣០០ | ១០% |
| ៤ | ភាគហ៊ុនិកឯកជនដទៃទៀត | ៦.០០៤.០៦៩ | ២៨% |
| សរុប | | ២១.៤៤២.៩៩២ | ១០០% |



## បំរែបំរួលថ្លៃភាគហ៊ុន និងទំហំជួញដូរ






# ស្ថិតិសង្ខេបប្រចាំឆ្នាំពីលទ្ធផលប្រតិបត្តិការ

| បរិយាយ | ឯកត្តា | ផែនការ ២០១៩ | ឆ្នាំ២០១៩ | ឆ្នាំ២០១៨ | ឆ្នាំ២០១៧ | ប្រៀបធៀប | | |
|---|---|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | (២-១)/១ | (២-៣)/៣ | (២-៤)/៤ |
| **បរិមាណទំនិញឆ្លងកាត់** | **តោន** | **៥,៩០៨,០០០** | **៦,៥៤៧,៧៥៦** | **៥,៣២៨,៣៤៨** | **៤,៣៦៤,៦៣៩** | **១០.៨៣%** | **២២.៨៩%** | **៥០.០២%** |
| ជាកុងតឺន័រ | _ | | ៤,១៤៨,៧២៩ | ៣,៣៨៨,៩២៣ | ២,៨៨២,៣១៦ | | ២២.៤២% | ៤៣.៩៤% |
| ទំនិញរាយ | _ | | ៥២០,៦៨៣ | ៣៥៦,៧៧៦ | ២០៨,៦៧៥ | | ៤៥.៩៤% | ១៤៩.៥២% |
| ជាប្រេង | _ | | ១,៨៧៨,៣៤៤ | ១,៥៨២,៦៤៩ | ១,២៧៣,៦៤៨ | | ១៨.៦៨% | ៤៧.៤៨% |
| **បរិមាណទំនិញនាំចូល** | _ | **៤,៣១៧,០០០** | **៥,១២១,៧១៣** | **៣,៩១៦,៩៥៨** | **៣,១៨៦,៨៩២** | **១៨.៦៤%** | **៣០.៧៦%** | **៦០.៧១%** |
| **បរិមាណទំនិញនាំចេញ** | _ | **១,៥៩១,០០០** | **១,៤២៦,០៤៣** | **១,៤១១,៣៩០** | **១,១៧៧,៧៤៧** | **-១០.៣៧%** | **១.០៤%** | **២១.០៨%** |
| **បរិមាណទំនិញលើករៀប** | _ | **៧,៩០៤,០០០** | **៨,៦៦០,៥២៦** | **៧,១៩២,៤៥៣** | **៥,៩៩២,៣៤៥** | **៩.៥៧%** | **២០.៤១%** | **៤៤.៥៣%** |
| ប្រគល់ផ្ទាល់ | _ | ៣៤៧,០០០ | ៤៦៤,៤៣៥ | ២៧៨,៧៥៩ | ១៩៧,១១៥ | | ៦៦.៦១% | ១៣៥.៦២% |
| ឆ្លងកាត់ឃ្លាំង និងទីលាន | _ | ៧,៥៥៧,០០០ | ៨,១៩៦,០៩១ | ៦,៩១៣,៦៩៤ | ៥,៧៩៥,២៣០ | | ១៨.៥៥% | ៤១.៤៣% |
| **បរិមាណកុងតឺន័រឆ្លងកាត់** | TEUs | **៥៩០,០០០** | **៦៣៩,២១១** | **៥៤១,២២៨** | **៤៥៩,៨៣៩** | **៨.៣៤%** | **១៨.១០%** | **៣៩.០១%** |
| នាំចូល | _ | ៣០៣,០០០ | ៣៣០,០២០ | ២៧៦,៧៥៣ | ២៣៣,៦២៣ | ៨.៩២% | ១៩.២៥% | ៤១.២៦% |
| នាំចេញ | _ | ២៨៧,០០០ | ៣០៩,១៩១ | ២៦៤,៤៧៥ | ២២៦,២១៦ | ៧.៧៣% | ១៦.៩១% | ៣៦.៦៨% |
| **ចំនួននាវាចូលចត** | **គ្រឿង** | **១,៤៩២** | **១,៦៦២** | **១,៤៥១** | **១,៣០៥** | **១១.៣៩%** | **១៤.៥៤%** | **២៧.៣៦%** |
| **ចំណុះផ្ទុកនាវា** | **តោន** | **១៦,០៨៨,០០០** | **១៧,៥០១,៨៩៣** | **១៥,៧៣០,៩៤៩** | **១៣,៥៩០,២៨២** | **០.០០%** | **១១.២៦%** | **២៨.៧៨%** |

# សមាសភាពក្រុមប្រឹក្សាភិបាល



ឯកឧត្តម លូ គឹមឈន់
ប្រធានអគ្គនាយក



ឯកឧត្តម ស៊ិយ សាន
តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន



ឯកឧត្តម ផាន់ ផល្លា
តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



ឯកឧត្តម សុខ សុភ័ក្រ្ត
តំណាងក្រសួងពាណិជ្ជកម្ម



លោក ហ៊ុន មុន្នីវណ្ណ
អភិបាលឯករាជ្យ



លោក Hidetoshi KUME
អភិបាលមិនប្រតិបត្តិ
តំណាងភាគហ៊ុនិកឯកជន



លោក លូ លីខេង
តំណាងនិយោជិតកម្មករ
កំពង់ផែស្វយ័តក្រុងព្រះសីហនុ



# សេចក្តីថ្លែងរបស់ប្រធានអគ្គនាយក

"ជួសមុខឱ្យក្រុមប្រឹក្សាភិបាលរបស់ កំពង់ផែស្វយ័តក្រុងព្រះសីហនុ (**កសស**) ខ្ញុំមានកិត្តិយស និងក្តីសោមនស្សរីករាយក្នុងការបង្ហាញជូននូវរបាយការណ៍អាជីវកម្ម និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០១៩ របស់ **កសស** សម្រាប់ការិយបរិច្ឆេទដែលបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១៩"។

ដោយមានការគាំទ្រយ៉ាងមុតមាំពីរាជរដ្ឋាភិបាល ក៏ដូចជាក្រសួងអាណាព្យាបាលទាំងពីរ **កសស** បានបន្តការវិវឌ្ឍន៍យ៉ាងខ្លាំងក្លាដើម្បីបម្រើសកម្មភាពធុរកិច្ចរបស់ខ្លួន ជាលទ្ធផលនៅក្នុងឆ្នាំ២០១៩ នេះ **កសស** ទទួលបានប្រាក់ចំណូលសរុបចំនួន ៣៣៣.៩១៣.៣៧៧.០០០ រៀល និងទទួលបានប្រាក់ចំណេញសុទ្ធក្រោយបង់ពន្ធក្នុងការិយបរិច្ឆេទចំនួន ៤៣.៤៦៣.៥០០.០០០ រៀល បើប្រៀបធៀបនឹងឆ្នាំ២០១៨ ប្រាក់ចំណូលបានកើនឡើងចំនួន ៥៨.៣៣៧.៧៣២.០០០ រៀល គឺស្មើនឹង ២១,១៧% ចំណែកប្រាក់ចំណេញសុទ្ធក្រោយបង់ពន្ធមានការថយចុះចំនួន ១.៧០២.២៧២.០០០ រៀល គឺស្មើនឹង ៣,៧៧%។ លទ្ធផលនេះបណ្តាលមកពីបរិមាណទំនិញ និងកុងតឺន័រឆ្លងកាត់ **កសស** មានការកើនឡើង ប៉ុន្តែដោយមានការកើនឡើងលើចំណាយពន្ធពន្យារលើប្រាក់ចំណេញ ធ្វើអោយចំណេញសុទ្ធក្រោយបង់ពន្ធមានការថយចុះ ជាលទ្ធផលចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធមានចំនួន ៥០៦,៧៣ រៀល សម្រាប់ឆ្នាំ២០១៩ នេះ។ ដោយឡែកក្នុងឆ្នាំ២០១៩ នេះ កុងតឺន័រ ដែលបានឆ្លងកាត់ **កសស** មានចំនួន ៦៣៩.២១១ TEUs ពោលគឺ កើនចំនួន ៩៧.៩៨៣ TEUs ស្មើនឹង ១៨,១០% បើធៀបនឹងឆ្នាំ២០១៨ ។

**កសស** នឹងបន្តកិច្ចខិតខំប្រឹងប្រែង ដើម្បីបំពេញសេវាកម្ម អាជីវកម្មឱ្យកាន់តែប្រសើរ និងសម្រេចបានលទ្ធផលខ្ពស់ជាប្រយោជន៍ដល់ភាគហ៊ុនិករបស់ខ្លួន។ **កសស** បានពង្រឹងប្រសិទ្ធភាពការងារ និងការកសាងហេដ្ឋារចនាសម្ព័ន្ធបន្ថែមទៀត ដើម្បីឆ្លើយតបនឹងកំណើនតម្រូវការសេវាកម្មរបស់អតិថិជន និងការរីកចម្រើនសេដ្ឋកិច្ចជាតិ។ ជាក់ស្តែង ការអភិវឌ្ឍចំណតផែពហុបំណងសម្រេចបាន ១០០,០០% និងត្រូវបានសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនាថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៨ នេះ ក្រោមអធិបតីភាព **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ ចំណតផែពហុបំណងមានគោលដៅចូលរួមលើកកម្ពស់វិស័យ កសិកម្ម កសិឧស្សាហកម្ម ឧស្សាហកម្ម ពាណិជ្ជកម្ម និងពិសេសដើម្បីគាំទ្រដល់ការនាំចេញផលិតផល កសិកម្មរបស់កម្ពុជាដូចជា អង្ករ ចំណិតដំឡូងមីស្ងួត និងទំនិញរាយ ដែលជាការឆ្លើយតបចំពោះយុទ្ធសាស្ត្រពង្រីកទីផ្សារនាំអង្ករចេញរបស់រាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាការផ្តល់សេវាភស្តុភាដល់ការ

រុករកប្រេងក្នុងដែនសមុទ្រកម្ពុជា។ ក្រៅពីនេះ ចំណតផែពហុបំណងក៏មានគោលដៅលើការនាំចូលធ្យូងថ្មដែលប្រើប្រាស់ក្នុងការផលិតថាមពលអគ្គិសនី និងស៊ីម៉ងត៍ផងដែរ ។

## ➢ ដើម្បីឆ្លើយតបនឹងការកើនឡើងនៃបរិមាណទំនិញឆ្លងកាត់ ក៏ដូចជាតម្រូវការសេវាកម្មរបស់អតិថិជន កសស មានទិសដៅការងារចម្បងៗដូចខាងក្រោម៖

- អនុវត្តបន្តការងារតាមផែនការដែលបានគ្រោងទុកសម្រាប់ឆ្នាំ២០១៩
- រក្សានូវឧត្តមភាពនៃភាពប្រកួតប្រជែងរបស់ខ្លួន ដោយធានានូវគុណភាពសេវាកម្ម តម្លៃប្រកួតប្រជែង ប្រសិទ្ធភាពការងារ និងការកសាងទំនុកចិត្តជូនអតិថិជន
- ពង្រឹងសមត្ថភាពបុគ្គលិកលើការគ្រប់គ្រង និងបច្ចេកទេស ដើម្បីឆ្លើយតបឱ្យបានទាន់ពេលវេលាចំពោះកំណើនតំរូវការសេវាកម្មរបស់កំពង់ផែ
- ជួសជុល ថែទាំ និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផែ និងគ្រឿងចក្របន្ថែមទៀត ដើម្បីរក្សាឧត្តមភាពប្រកួតប្រជែង និងលើកកំពស់សមត្ថភាពលើកដាក់ទំនិញរបស់ខ្លួន
- ពង្រឹងកិច្ចសហប្រតិបត្តិការជាយុទ្ធសាស្ត្រជាមួយកំពង់ផែក្នុងប្រទេស និងក្នុងតំបន់
- ពង្រឹងអភិបាលកិច្ចគ្រប់គ្រងតាមរយៈការបង្កើតគណៈកម្មាធិការសំខាន់ៗ
- ចូលរួមក្នុងសកម្មភាពអភិវឌ្ឍសហគមន៍មូលដ្ឋាន និងលើកកំពស់សុខមាលភាពសង្គម

## ➢ ការអនុវត្តការងាររបស់ក្រុមប្រឹក្សាភិបាល

នៅក្នុងឆ្នាំ២០១៩ នេះ ក្រុមប្រឹក្សាភិបាលបានធ្វើការជួបប្រជុំចំនួន ០៤ លើក និងបានសម្រេចការងារដូចខាងក្រោម៖

**សម័យប្រជុំក្រុមប្រឹក្សាភិបាល អាណត្តិទី៧ លើកទី៣ នាថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៩**

កិច្ចប្រជុំបានពិនិត្យ ពិភាក្សា និងសម្រេចលើចំនុចដូចខាងក្រោម៖

- ក្រុមប្រឹក្សាភិបាលបានឯកភាពលើលទ្ធផលកិច្ចប្រជុំក្រុមប្រឹក្សាភិបាល អាណត្តិទី៧ លើកទី២ កាលពីថ្ងៃទី ០១ ខែតុលា ឆ្នាំ២០១៨ និងស្នើអោយ ដាក់បញ្ចូលបញ្ហារៀបចំ Disaster Recovery Data Centre ក្នុងRisk Management ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ និងឯកភាពលើរបាយការណ៍របស់ គណៈកម្មាធិការ គ្រប់គ្រងហានិភ័យ (Risk Committee) និងគណៈកម្មាធិការសវនកម្ម (Audit Committee) ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តលើរបាយការណ៍បូកសរុបលទ្ធផលការងារអាជីវកម្ម **កសស** ២០១៨ ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ត្រីមាសទី៣ ឆ្នាំ២០១៨ ដែលបានត្រួតពិនិត្យដោយក្រុមហ៊ុនសវនកម្មឯករាជ្យ PWC (Financial Performance Review) ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ និងអនុម័តលើសំណើសុំជម្រះបញ្ជីអចលនទ្រព្យ (គ្រឿងចក្រ និងរថយន្តចាស់ៗ) ដោយរៀបចំនីតិវិធីសមស្រប ។

- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តលើសំណើសុំកែសម្រួលផែថ្មី (៣៥០ម៉ែត្រ សាងសង់ឆ្នាំ១៩៦៧) ទៅជាចំណតផែកុងតឺន័រប្រវែង ២៤៣ម៉ែត្រ និងបំពាក់គ្រឿងចក្រលើកដាក់កុងតឺន័រ (QC) ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តលើសំណើសុំតបណ្តាញអគ្គីសនីកម្លាំង 2x20 MW ចូលកំពង់ផែស្វយ័តក្រុងព្រះសីហនុ និងតំបន់សេដ្ឋកិច្ចពិសេស **កសស** ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តលើគោលការណ៍គាំទ្រ Concept របស់ Free Port Policy និងស្នើសុំអោយ **JICA** និង **កសស** ជួយសិក្សាបន្ថែម ។
- សេចក្តីផ្សេងៗ ៖
  - ក្រុមប្រឹក្សាភិបាលបានពិនិត្យ និងពិភាក្សា ដោយមិនឯកភាពអោយនាវាឈ្មោះ Ji Mei របស់ក្រុមហ៊ុន ស្តារហាប៊ើរ អ៊ីនធើណេសិនណល ត្រាវែល ឯ.ក (Star Harbor International Travel Company Limited) បន្តកិច្ចសន្យាជួលចំណតផែ របស់ **កសស** ។
  - ក្រុមប្រឹក្សាភិបាលបានពិនិត្យ និងពិភាក្សា ហើយឯកភាពជាគោលការណ៍គាំទ្រនូវសំណើសុំផ្លាស់ប្តូរទីលំនៅរបស់ប្រជាជននៅតំបន់ទំនប់រលក ។
  - ក្រុមប្រឹក្សាភិបាលបានពិនិត្យ និងពិភាក្សា ហើយឯកភាពជាគោលការណ៍អោយ **កសស** ពិនិត្យកិច្ចព្រមព្រៀងក្របខណ្ឌស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការយុទ្ធសាស្ត្ររវាង **កសស** និងកំពង់ផែ **Qingdao** ក្នុងគោលបំណងដើម្បីជួយសម្រួលដល់ការដឹកជញ្ជូនទំនិញពីកំពង់ផែ **Qingdao** មក **កសស** ប៉ុណ្ណោះ ។

**សម័យប្រជុំក្រុមប្រឹក្សាភិបាល អាណត្តិទី៧ លើកទី៤ នាថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៩**

កិច្ចប្រជុំបានពិនិត្យ ពិភាក្សា និងសម្រេចលើចំនុចដូចខាងក្រោម៖

- ក្រុមប្រឹក្សាភិបាលបានឯកភាពលើលទ្ធផលដែលបានសម្រេចបាន និងកំពុងអនុវត្តបន្តឆ្លើយតបទៅនឹងលទ្ធផលសម័យប្រជុំក្រុមប្រឹក្សាភិបាល អាណត្តិទី៧ លើកទី៣ កាលពីថ្ងៃទី ០៤ ខែមករា ឆ្នាំ២០១៩ កន្លងមក ។
- ក្រុមប្រឹក្សាភិបាលបានពិភាក្សាមាន សំនួរ-ចម្លើយ និងថ្លែងអំណរគុណដល់តំណាងក្រុមហ៊ុន PWC ដែលបានធ្វើបទបង្ហាញអំពីដំណើរការនៃការធ្វើសវនកម្ម ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងឯកភាពលើរបាយការណ៍របស់គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងគណៈកម្មាធិការសវនកម្ម ដែលបានស្នើឡើង និងការរៀបចំការបញ្ចុះតម្លៃឈ្នួលផែដោយចាប់ពីថ្ងៃទី ០១ ខែឧសភា ឆ្នាំ២០១៩ ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តដោយឯកភាពលើរបាយការណ៍បូកសរុបលទ្ធផលការងារអាជីវកម្ម ៣ខែ ដើមឆ្នាំ២០១៩ ។

- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តដោយឯកភាពលើរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ត្រីមាសទី៤ និងសម្រាប់ដំណាច់ការិយបរិច្ឆេទ ១២ខែ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ ដែលបានត្រួតពិនិត្យដោយក្រុមហ៊ុនសវនកម្មឯករាជ្យ PWC ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តដោយឯកភាពលើការបែងចែកភាគលាភ (Dividend) ការកំណត់កាលបរិច្ឆេទកំណត់ទុកដែលត្រូវបែងចែកភាគលាភ (Record Date) និងកាលបរិច្ឆេទចាប់ផ្តើមទូទាត់ភាគលាភ (Payment Date) ជូនភាគហ៊ុនិកសម្រាប់ការិយបរិច្ឆេទ ឆ្នាំ២០១៨។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តដោយឯកភាពលើកាលបរិច្ឆេទមហាសន្និបាតភាគហ៊ុនិក លើកទី២ ឆ្នាំ២០១៩ នៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៩ នៅសាលប្រជុំធំ កំពង់ផែស្វយ័តក្រុងព្រះសីហនុ ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តលើសេចក្តីព្រាងលក្ខន្តិកៈ (AOI) ដែលស្នើសុំកែសម្រួល ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តដោយឯកភាពអោយ លប់បំណុលថ្លៃជួលទីតាំងស្តុកចំណាំងឈើអាកាស្យានាំចេញ របស់ក្រុមហ៊ុន ADONIS International Group Ltd ដែលនៅជំពាក់ចំនួន ៧១.២៥០ ដុល្លារ តាំងពីឆ្នាំ២០១៣ ចេញពីបញ្ជីការគណនេយ្យរបស់ **កសស** ។
- សេចក្តីផ្សេងៗ ៖
  - ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តលើកាលបរិច្ឆេទរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាភិបាលដើម្បីពិនិត្យ និងសម្រេចលើរបាយការណ៍ហិរញ្ញវត្ថុរៀងរាល់ត្រីមាសនីមួយៗ ។
  - ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តអោយ **កសស** សហការជាមួយ JICA ដើម្បីសិក្សាពី New Business Model ឬបន្ថែមលើ Function របស់ SEZ និងឯកភាពឱ្យមានវិធានការបន្តអំពី "Free Port Concept" ដើម្បីធ្វើអោយប្រសើរឡើងនូវភាពប្រកួតប្រជែងរបស់ **កសស** ។

**សម័យប្រជុំក្រុមប្រឹក្សាភិបាល អាណត្តិទី៧ លើកទី៥ នាថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៩**

កិច្ចប្រជុំបានពិនិត្យ ពិភាក្សា និងសម្រេចលើចំនុចដូចខាងក្រោម៖

- ក្រុមប្រឹក្សាភិបាលបានឯកភាពលើលទ្ធផលដែលបានសម្រេចបាន និងកំពុងអនុវត្តបន្តឆ្លើយតបទៅនឹងលទ្ធផលសម័យប្រជុំក្រុមប្រឹក្សាភិបាល អាណត្តិទី៧ លើកទី៤ កាលពីថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៩ កន្លងមក ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងថ្លែងអំណរគុណដល់តំណាងក្រុមហ៊ុន PWC ដែលបានធ្វើបទបង្ហាញអំពីការងារ Result of reviewing and reporting timelines និងបានធ្វើការសម្រេចទៅលើ៖
  - ការអនុវត្តតាមប្រកាសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពីការទូទាត់ប្រាក់បំណាច់អតីតភាពការងារជូននិយោជិតសម្រាប់ឆ្នាំ២០១៩ ។

- ឯកភាពលើ Reporting timetable ដែលបានស្នើឡើងខាងលើដោយក្រុមហ៊ុនសវនករឯករាជ្យ PWC និងសូមអោយនាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ សហការជាមួយ PWC ដើម្បីរៀបចំរបាយការណ៍ហិរញ្ញវត្ថុអោយបានទាន់ពេលវេលា និងជូនដំណឹងទៅលេខាធិការដ្ឋាន ដើម្បីស្នើសុំកំណត់កាលបរិច្ឆេទកិច្ចប្រជុំក្រុមប្រឹក្សាភិបាល។

- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តដោយឯកភាពលើរបាយការណ៍ហិរញ្ញវត្ថុត្រីមាសទី២ និងឆមាសទី១ ឆ្នាំ២០១៩ ដែលបានត្រួតពិនិត្យដោយក្រុមហ៊ុនសវនកម្មឯករាជ្យ PWC ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងឯកភាពលើរបាយការណ៍របស់គណៈកម្មាធិការសវនកម្ម និងគណៈកម្មាធិការគ្រប់គ្រងហានិភ័យ ដែលបានលើកឡើង។ ទន្ទឹមហ្នឹងនេះផងដែរ អង្គប្រជុំបានស្នើសុំអោយ Mr. KUME ធ្វើការបន្តជាមួយ JICA ដើម្បីប្រែក្លាយប្រាក់បំណុលជប៉ុន ODA Loan ពីយ៉េនជប៉ុន ទៅដុល្លារអាមេរិក និងចរចារធ្វើយ៉ាងណាទទួលបានអត្រាការប្រាក់ទាបនៅពេលដែលបំណុល Convert មកជាប្រាក់ដុល្លារអាមេរិក។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តដោយឯកភាពលើរបាយការណ៍បូកសរុបលទ្ធផលការងារអាជីវកម្ម **កសស** ៧ខែ ដើមឆ្នាំ២០១៩ ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តដោយឯកភាពលើវិធានការដោះស្រាយលើស្ថានភាពកំពង់ផែបច្ចុប្បន្ន និងការកែសម្រួលតារាងថ្លៃស្តុកកុងតឺន័រ ហើយអង្គប្រជុំបានសម្រេច និងជម្រុញបន្ថែមទៅលើចំណុចដូចខាងក្រោម ៖
  - បន្តជម្រុញនូវវិធានការជាបន្ទាន់របស់ **កសស** ក្នុងការកែសម្រួលចំណតផែទំនិញទូទៅនៅមុខឃ្លាំងលេខ៥ ទៅជាចំណតផែកុងតឺន័របន្ថែមប្រវែង ២៤៣ ម៉ែត្រ និងការបំពាក់គ្រឿងចក្របន្ថែមអោយសម្រេចបានឆាប់រហ័ស និងទាន់ពេលវេលា ។
  - ជម្រុញការតបណ្តាញអគ្គិសនី ៤0 មេហ្គាវ៉ាត់ (ពីអគ្គិសនីកម្ពុជា - EDC) ចូល **កសស** និងតំបន់សេដ្ឋកិច្ចពិសេស **កសស** ។
  - ពង្រីកទីលានស្តុកកុងតឺន័រ និងមធ្យោបាយលើកដាក់អោយកាន់តែមានប្រសិទ្ធភាព ដោយត្រៀមដោះស្រាយកំណើនកុងតឺន័រពីបច្ចុប្បន្នរហូតដល់ពាក់កណ្តាលឆ្នាំ២០២៤ (ផែកុងតឺន័រថ្មីធ្វើហើយ)។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តដោយឯកភាពលើបទបញ្ជា និងនីតិវិធីស្តីពីការជ្រើសតាំងតំណាងនិយោជិត កំពង់ផែស្វយ័តក្រុងព្រះសីហនុ ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តដោយអនុញ្ញាតអោយ **កសស** ពិភាក្សាដោយផ្ទាល់ជាមួយក្រុមហ៊ុនឯកជន ដែលមានបំណងចង់វិនិយោគលើទីតាំងដីសេះស ដែលស្ថិតនៅភូមិ៣ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ដោយក្រុមហ៊ុនត្រូវរៀបចំផែនការអភិវឌ្ឍន៍

(Master Plan) ផែនការអាជីវកម្ម (Business Plan) និងកិច្ចសន្យាវិនិយោគអោយបានច្បាស់លាស់ ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងអនុម័ត និងគោរពជម្រាបស្នើសុំគោលការណ៍សម្រេចពីឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តដោយឯកភាពអោយ **កសស** លក់ដីចំនួន ០១ កន្លែង ដែលស្ថិតនៅភូមិគគីរ ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ដើម្បីយកថវិកាមកវិនិយោគ និងពង្រីកសមត្ថភាពកំពង់ផែបន្ថែមទៀត ។

**សម័យប្រជុំក្រុមប្រឹក្សាភិបាល អាណត្តិទី៧ លើកទី៦ នាថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៩**

កិច្ចប្រជុំបានពិនិត្យ ពិភាក្សា និងសម្រេចលើចំនុចដូចខាងក្រោម៖

- ក្រុមប្រឹក្សាភិបាលបានឯកភាពលើលទ្ធផលដែលបានសម្រេចបាន និងកំពុងអនុវត្តបន្តឆ្លើយតបទៅនឹងស្មារតីសម័យប្រជុំក្រុមប្រឹក្សាភិបាល អាណត្តិទី៧ លើកទី៥ កាលពីថ្ងៃទី ០៩ ខែសីហា ឆ្នាំ ២០១៩ កន្លងមក ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងឯកភាពទៅលើរបាយការណ៍ស្តីពីស្ថានភាពបច្ចុប្បន្នរបស់ **កសស** និងតំបន់សេដ្ឋកិច្ចពិសេស និងស្នើអោយ **កសស** បន្តជម្រុញអនុវត្តនូវវិធានការដោះស្រាយនានាដែលបានលើកឡើង ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តដោយឯកភាពលើរបាយការណ៍ហិរញ្ញវត្ថុត្រីមាសទី៣ ឆ្នាំ២០១៩ ដែលបានត្រួតពិនិត្យ ដោយក្រុមហ៊ុនសវនកម្មឯករាជ្យ PWC ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តដោយឯកភាពលើរបាយការណ៍បូកសរុបលទ្ធផលការងារអាជីវកម្ម **កសស** ៩ខែ ដើមឆ្នាំ២០១៩ ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងឯកភាពតាមរបាយការណ៍របស់ គណៈកម្មាធិការសវនកម្ម និងគណៈកម្មាធិការគ្រប់គ្រងហានិភ័យ ដែលបានលើកឡើងដោយស្នើអោយ **កសស** ត្រូវបន្តជម្រុញអនុវត្ត៖
  - លទ្ធផលរបស់គណៈកម្មាធិការសវនកម្ម និងគណៈកម្មាធិការគ្រប់គ្រងហានិភ័យ ដែលបានស្នើឡើង
  - រៀបចំលិខិតគោរពស្នើស្នើសុំគោលការណ៍សម្រេចដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** លើបញ្ហាបំណុលដែលក្រុមហ៊ុន អយស្ម័យយាន ថូល-រ៉ូយ៉ាល់ (Toll Royal (Cambodia)) ជំពាក់ **កសស**
  - ពិនិត្យ និងកែសម្រួលតារាងតម្លៃ (Tariff) របស់តំបន់សេដ្ឋកិច្ចពិសេសកំពង់ផែស្វយ័តក្រុងព្រះសីហនុ អោយស្របតាមស្ថានភាពវិវឌ្ឍន៍របស់ខេត្តព្រះសីហនុ ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តដោយឯកភាពលើគម្រោងផែនការអាជីវកម្ម (សេវាកម្ម) ហិរញ្ញវត្ថុ **កសស** ឆ្នាំ២០២០ ។

- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តដោយឯកភាពលើ ៖
  - កែសម្រួល នាយកដ្ឋានបច្ចេកទេស សម្ភារៈ-សំណង់ ទៅជានាយកដ្ឋានចំនួន ០២ គឺនាយកដ្ឋានបច្ចេកទេស-សម្ភារៈ និងនាយកដ្ឋានសំណង់- វិស្វកម្ម
  - តែងតាំង **លោក ទី សាគុណ** ជានាយក នាយកដ្ឋានបច្ចេកទេស-សម្ភារៈ
  - តែងតាំង **លោក មាន គឹង** ជានាយក នាយកដ្ឋានសំណង់-វិស្វកម្ម ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តដោយឯកភាពបង្កើតគណៈកម្មាធិការតែងតាំង និងលាភការ ដោយតែងតាំង **ឯកឧត្តម សុខ សុភ័ក្ត្រ** តំណាងក្រសួងពាណិជ្ជកម្ម ជាប្រធាន ។

## សេចក្ដីថ្លែងអំណរគុណ

ជាថ្មីម្ដងទៀត យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាលកម្ពុជា ដែលដឹកនាំដោយ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងអាណាព្យាបាលទាំងពីរ គឺក្រសួងសាធារណៈការ និងដឹកជញ្ជូន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលជានិច្ចកាលតែងតែគាំទ្រ និងទុកចិត្តដល់សកម្មភាពការងាររបស់ **កសស** រៀងរហូតមក ។

ជាចុងក្រោយនេះ ខ្ញុំសូមថ្លែងអំណរគុណដល់បុគ្គលិក និងកម្មករ កំពង់ផែស្វយ័តក្រុងព្រះសីហនុទាំងអស់ដែលតែងតែខិតខំប្រឹងប្រែងបំពេញភារកិច្ចរបស់ខ្លួន ។

ថ្ងៃព្រហស្បតិ៍ ៣កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

ខេត្តព្រះសីហនុ, ថ្ងៃទី២៦ ខែមីនា គ.ស ២០២០

**ប្រធានអគ្គនាយក**

PORT AUTONOME DE SIHANOUKVILLE

**លូ_គឹមឈន់**

# មាតិកា


ទស្សនវិស័យ បេសកកម្ម ........ i

ព័ត៌មានហិរញ្ញវត្ថុសង្ខេប ........ ii

ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប. ........ iii

ស្ថិតិប្រចាំឆ្នាំសង្ខេបពីលទ្ធផលប្រតិបត្តិការ ........ vii

សមាសភាពក្រុមប្រឹក្សាភិបាល ........ viii

សេចក្តីថ្លែងរបស់ប្រធានអគ្គនាយក ........ ix

**ផ្នែកទី១: ព័ត៌មានទូទៅពាក់ព័ន្ធនឹងកំពង់ផែស្វយ័តក្រុងព្រះសីហនុ** ........ ០១

ក- អត្តសញ្ញាណកំពង់ផែស្វយ័តក្រុងព្រះសីហនុ ........ ០២

ខ- លក្ខណៈនៃធុរកិច្ច ........ ០២

គ- សម្ព័ន្ធភាពកំពង់ផែស្វយ័តក្រុងព្រះសីហនុ. ........ ០៤

ឃ- ព្រឹត្តិការសំខាន់ៗប្រចាំឆ្នាំ. ........ ០៤

ង- ស្ថានភាពទីផ្សារ ........ ០៥

ច- ស្ថានភាពប្រកួតប្រជែង ........ ០៨

ឆ- ផែនការអនាគត ........ ០៩

ជ- កត្តាហានិភ័យ. ........ ១៧

**ផ្នែកទី២: ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច** ........ ១៩

ក- លទ្ធផលប្រតិបត្តិការធុរកិច្ច ........ ២០

ខ- រចនាសម្ព័ន្ធចំណូល ........ ២៤

**ផ្នែកទី៣: ព័ត៌មានអំពីអភិបាលកិច្ចសាជីវកម្ម** ........ ២៥

ក- អង្គការលេខ ........ ២៦

ខ- ក្រុមប្រឹក្សាភិបាល ........ ២៧

គ- បុគ្គលិកជាន់ខ្ពស់ ........ ៣៨

**ផ្នែកទី៤: ព័ត៌មានអំពីការជួញដូរមូលបត្រ និងភាគហ៊ុនិករបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ** ........ ៦៦

ក- ព័ត៌មានអំពីមូលបត្រ ........ ៦៧

ខ- ថ្លៃ និងបរិមាណជួញដូរមូលបត្រ ........ ៦៧

គ- ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធបោះឆ្នោតចំនួនច្រើនលើសលប់. ........ ៦៨

ឃ- ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធបោះឆ្នោតចំនួនច្រើន ........................................ ៦៨
ង- ព័ត៌មានអំពីការបែងចែកភាគលាភក្នុងរយៈពេល ៣ (បី)ឆ្នាំចុងក្រោយ .................................... ៦៨
**ផ្នែកទី៥: របាយការណ៍សវនកម្មរបស់សវនករផ្ទៃក្នុងលើការត្រួតពិនិត្យផ្ទៃក្នុង** ......... ៦៩
**ផ្នែកទី៦: របាយការណ៍ហិរញ្ញវត្ថុដែលធ្វើសវនកម្មដោយសវនករឯករាជ្យ** ............... ៩៧
**ផ្នែកទី៧: ព័ត៌មានអំពីប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ និងទំនាស់ផលប្រយោជន៍** ....... ១៦៦
ក- ប្រតិបត្តិការសំខាន់ៗជាមួយភាគហ៊ុនិកដែលមានភាគហ៊ុនចាប់ពី៥(ប្រាំ)ភាគរយឡើងទៅ ........ ១៦៧
ខ- ប្រតិបត្តិការសំខាន់ៗជាមួយអភិបាល និងបុគ្គលិកជាន់ខ្ពស់............................................... ១៦៧
គ- ប្រតិបត្តិការជាមួយអភិបាល និងភាគហ៊ុនិកពាក់ព័ន្ធនឹងការទិញ-លក់ទ្រព្យសកម្ម និងសេវាកម្ម ... ១៦៧
ឃ- ប្រតិបត្តិការសំខាន់ៗជាមួយសមាជិកគ្រួសារផ្ទាល់របស់អភិបាល បុគ្គលិកជាន់ខ្ពស់ និងភាគហ៊ុនិកដែលមានភាគហ៊ុនចាប់ពី ៥ (ប្រាំ) ភាគរយឡើងទៅ........................................................ ១៦៧
ង- ប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលដែលមានទំនាក់ទំនងជាមួយអភិបាលរបស់ កំពង់ផែស្វយ័តក្រុងព្រះសីហនុ ក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនហូលឌីងរបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ ........ ១៦៧
ច- ប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលធ្លាប់ជាអភិបាល ឬបុគ្គលជាប់ពាក់ព័ន្ធជាមួយបុគ្គលធ្លាប់ជាអភិបាល .................................................................................................... ១៦៧
ឆ- ប្រតិបត្តិការសំខាន់ៗជាមួយអភិបាលដែលកាន់មុខតំណែងណាមួយនៅក្នុងសមាគម ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ ឬនៅក្នុងក្រុមហ៊ុនណាមួយផ្សេងទៀតក្រៅពីកំពង់ផែស្វយ័តក្រុងព្រះសីហនុ ......
ជ- ប្រតិបត្តិការសំខាន់ៗជាមួយអភិបាល ដែលទទួលបានផលប្រយោជន៍ពីកំពង់ផែស្វយ័តក្រុងព្រះសីហនុ ទោះជាហិរញ្ញវត្ថុ ឬមិនមែនហិរញ្ញវត្ថុ ..................................................... ១៦៧
**ផ្នែកទី៨: ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង** ........................................ ១៦៨
ក- ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ ......................................................................... ១៦៩
ខ- កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ .......................................................... ១៧៩
គ- ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល ........................................................ ១៧៩
ឃ- ផលប៉ះពាល់នៃការប្តូររូបិយបណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ ........................................ ១៨០
ង- ផលប៉ះពាល់នៃអតិផរណា.............................................................................. ១៨០
ច- គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុ របស់រាជរដ្ឋាភិបាល................................ ១៨០
**ផ្នែកទី៩: ព័ត៌មានចាំបាច់ផ្សេងទៀតសម្រាប់ការពារវិនិយោគិន** ................................ ១៨២
ហត្ថលេខាអភិបាលរបស់កំពង់ស្វយ័តក្រុងព្រះសីហនុ ................................................... ១៨៨

# ផ្នែកទី ១
# ព័ត៌មានពាក់ព័ន្ធនឹង
# កំពង់ផែស្វយ័តក្រុងព្រះសីហនុ

## ក- អត្តសញ្ញាណកំពង់ផែស្វយ័តក្រុងព្រះសីហនុ

ឈ្មោះក្រុមហ៊ុនជាអក្សរខ្មែរ៖ **កំពង់ផែស្វយ័តក្រុងព្រះសីហនុ (កសស)**

ឈ្មោះក្រុមហ៊ុនជាអក្សរ (ឡាតាំង)៖ PORT AUTONOME DE SIHANOUKVILLE "PAS"

ឈ្មោះក្រុមហ៊ុនជាអក្សរ (អង់គ្លេស)៖ SIHANOUKVILLE AUTONOMOUS PORT

លេខកូដស្តង់ដារ ៖ KH1000060009

អាសយដ្ឋាន៖ **តិរៈវិថីសម្តេចអគ្គមហាសេនាបតីតេជោហ៊ុនសែន សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ព្រះរាជាណាចក្រកម្ពុជា។**

លេខទូរស័ព្ទ៖ **(៨៥៥) ៣៤ ៩៣៣ ៤១៦ /៩៣៣ ៥១១**

លេខទូរសារ៖ **(៨៥៥) ៣៤ ៩៣ ៣ ៦៩៣**

គេហទំព័រ៖ www.pas.gov.kh

អ៊ីម៉ែល៖ pasinfo@pas.gov.kh

លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម៖ Co.៤៧៨៤ Et / **២០១៧** កាលបរិច្ឆេទ៖ **២១ កុម្ភៈ ២០១៧**

លេខអាជ្ញាបណ្ណអាជីវកម្ម៖ **០១៥៩ ពណ.ចបព** កាលបរិច្ឆេទ៖ **២២ កុម្ភៈ ២០១៧** ដែលចេញដោយក្រសួងពាណិជ្ជកម្ម

សេចក្តីសម្រេចអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានលេខ៖ **០៥៨/១៧/គ.ម.ក/ស.ស.រ**

កាលបរិច្ឆេទ៖ **០៩ ឧសភា ២០១៧**

ឈ្មោះបុគ្គលតំណាងបុគ្គលបោះផ្សាយ៖ **ឯកឧត្តម លូ គឹមឈន់**

## ខ- លក្ខណៈនៃធុរកិច្ច

កំពង់ផែស្វយ័តក្រុងព្រះសីហនុ គឺជាកំពង់ផែសមុទ្រអន្តរជាតិទឹកជ្រៅតែមួយគត់នៅព្រះរាជាណាចក្រកម្ពុជា ដែលកំពុងធ្វើអាជីវកម្មលើផ្ទៃដីប្រមាណ ១២៥ ហិកតា។ ដោយស្ថិតនៅតាមបណ្តោយឆ្នេរនៃព្រះរាជាណាចក្រកម្ពុជាក្នុងឈូងសមុទ្រថៃ **កសស** ទទួលបានភាពអនុគ្រោះពីធម្មជាតិ និងលក្ខខណ្ឌប្រតិបត្តិការយ៉ាងរលូនពេញមួយឆ្នាំ ដោយមានទឹកសមុទ្រស្ងប់ស្ងាត់ល្អ និងពុំមានព្យុះធំៗឡើយ ។

**កសស** ត្រូវបានតភ្ជាប់ដោយបណ្តាញដឹកជញ្ជូនចំរុះ។ តាមផ្លូវគោក **កសស** ត្រូវបានតភ្ជាប់ដោយផ្លូវជាតិសំខាន់ៗពីរ គឺផ្លូវជាតិលេខ៤ ដែលមានប្រវែង ២២៦ គីឡូម៉ែត្រ ពីរាជធានីភ្នំពេញមកក្រុងព្រះសីហនុ និងផ្លូវជាតិលេខ៣ ដែលកាត់តាមទីរួមខេត្តកំពត ដែលមានប្រវែង ២៤៤ គីឡូម៉ែត្រ។ **កសស** ក៏ត្រូវបានតភ្ជាប់ដោយខ្សែរថភ្លើងភាគខាងត្បូង ពីភ្នំពេញកាត់តាមខេត្តកំពត ដែលមានប្រវែង ២៦៤ គីឡូម៉ែត្រ។ ចំណែកតាមផ្លូវអាកាស **កសស** ត្រូវបានតភ្ជាប់ទៅខេត្តសៀមរាប និងរាជធានីភ្នំពេញដោយអាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ។

ក្នុងនាមជាប្រតិបត្តិករផែ **កសស** ត្រូវបំពេញអាជីវកម្ម និងសេវាកម្មដូចខាងក្រោម៖

- កណ្តាធារកិច្ច នាំនាវាចេញ-ចូល និងផ្តល់ភស្តុភាដល់នាវា
- លើកដាក់ ផ្ទេរ-ផ្ទុក ទំនិញ

- ស្តុកទំនិញ នៅឃ្លាំង និងទីលាន
- ដឹកជញ្ជូនទំនិញ
- តំបន់សេដ្ឋកិច្ចពិសេស

**កសស មានចំណតផែសរុបប្រវែង ១.៨៦០ ម៉ែត្រ ដោយចែកជា ១៣ ចំណតដូចខាងក្រោម៖**

| ល.រ | ឈ្មោះស្ថានីយ៍ | ប្រភេទទំនិញ | បណ្តោយ (ម៉ែត្រ) | ទទឹង (ម៉ែត្រ) | ចំណត |
|---|---|---|---|---|---|
| ១ | ស្ថានីយ៍ផែអ្នកដំណើរ (ចំណតផែចាស់) | អ្នកដំណើរ និងទំនិញរាយ | ២៩០ | ២៨ | លេខ ១ និង លេខ ៣៖ ជម្រៅ ៩ ម៉ែត្រ ដល់ ១៣ ម៉ែត្រ សម្រាប់នាវា ដែលមានជម្រៅបាត ៨,៥ ម៉ែត្រ ចូលចតបាន។ លេខ ២ និង លេខ ៤៖ ជម្រៅ ៦,៥ ម៉ែត្រ ដល់ ៨ ម៉ែត្រ សម្រាប់នាវា ដែលមានជម្រៅបាត ៧ ម៉ែត្រ ចូលចតបាន។ |
| ២ | ស្ថានីយ៍ផែថ្មី | កុងតឺន័រ | ៣៥០ | ៥០០ | លេខ ៥ (ផ្នែកខាងលិច) និង លេខ ៦ (ផ្នែកខាងកើត)៖ ជម្រៅ ១០ ម៉ែត្រ សម្រាប់នាវា ដែលមាន ជម្រៅបាតក្រោម ៨,៥ ម៉ែត្រ ចូលចតបាន។ |
| ៣ | ស្ថានីយ៍ផែកុងតឺន័រ | កុងតឺន័រ | ៤០០ | ៣៥០ | លេខ ៧ និង លេខ ៨៖ ជម្រៅ ១១ ម៉ែត្រ សម្រាប់នាវាដែលមានជម្រៅបាតក្រោម ៨,៥ ម៉ែត្រ ចូលចតបាន។ |
| ៤ | ស្ថានីយ៍ផែពហុបំណង | ពហុបំណង | ៣៣០ | ២០០ | ផែពហុបំណង មានប្រវែង ៣៣០ ម៉ែត្រ និងជម្រៅទឹក -១៣,៥ ម៉ែត្រ សម្រាប់ប្រតិបត្តិការលើកដាក់ទំនិញរាយ និង ទំនិញទូទៅ ដែលអាចអនុញ្ញាតឱ្យនាវាចំណុះ ៥០.០០០ DWT ចូលចតបាន និងចំណតផែមូលដ្ឋាន ផ្គត់ផ្គង់ការរុករករ៉ែប្រេងក្នុងដែនសមុទ្រ មានប្រវែង |

| | | | | | |
|---|---|---|---|---|---|
| | | | | | ២០០ ម៉ែត្រ និងជម្រៅទឹក -៧,៥ ម៉ែត្រ ដើម្បីបម្រើសេវាភស្តុភារកម្ម សម្រាប់ការរុករកប្រេងក្នុងដែនសមុទ្រកម្ពុជា។ |
| ៥ | ស្ថានីយ៍ផែថ្ម | ដឹកប្រេង | ៥៣ | ៥ | ចំណតផែប្រេង៖ ជម្រៅ ៤,៥ ម៉ែត្រ ហើយមានប្រវែង សរុបក្រោម ៨០ ម៉ែត្រ។ ឧបករណ៍ទាក់ពួរកែច្នៃ ត្រូវបានរៀបចំសម្រាប់ នាវាប្រេងដែលមានជម្រៅបាតក្រោម ៦ ម៉ែត្រ និងប្រវែងក្រោម ១១០ ម៉ែត្រ ធ្វើការចូលចតបាន ។ |

- **ស្ថានីយ៍រថភ្លើងដឹកកុងតឺន័រ**

ក្រៅពីចំណតផែខាងលើ ដោយសហការជាមួយក្រុមហ៊ុន Royal Railway Co., Ltd **កសស** ក៏មានប្រតិបត្តិការប្រព័ន្ធផ្លូវដែក និងទីលានផ្ទុកទំនិញកុងតឺន័រក្នុងបរិវេណកំពង់ផែដើម្បីឱ្យអតិថិជន ឬម្ចាស់ទំនិញអាចដឹកជញ្ជូនទៅវិញទៅមកពី **កសស** ទៅភ្នំពេញ។ **កសស** បានជួលដីបរិវេណនេះទៅឱ្យក្រុមហ៊ុន Royal Railway Co., Ltd ហើយផ្តល់សេវាកម្មលើកដាក់កុងតឺន័រទៅលើ និងចុះពីរថភ្លើង ។

- **តំបន់សេដ្ឋកិច្ចពិសេសកំពង់ផែស្វយ័តក្រុងព្រះសីហនុ**

ក្រៅពីអាជីវកម្ម សេវាកម្មខាងលើ **កសស** ក៏មានប្រតិបត្តិដំណើរការតំបន់សេដ្ឋកិច្ចពិសេសកំពង់ផែស្វយ័តក្រុងព្រះសីហនុដែលមានទំហំផ្ទៃដីប្រមាណ ៦៤ ហិកតា បានកសាងឡើងតាមបទដ្ឋានប្រទេសជប៉ុន។

## គ- សម្ព័ន្ធភាពកំពង់ផែស្វយ័តក្រុងព្រះសីហនុ

**កសស** មិនមានក្រុមហ៊ុនបុត្រសម្ព័ន្ធ បុត្រសម្ព័ន្ធនៃក្រុមហ៊ុនបុត្រសម្ព័ន្ធ ក្រុមហ៊ុនហូលឌីង ឬក្រុមហ៊ុនពាក់ព័ន្ធដទៃទៀតទេ ។

## ឃ- ព្រឹត្តិការណ៍សំខាន់ៗប្រចាំឆ្នាំ២០១៩

ក្នុងឆ្នាំ២០១៩ នេះ កំពង់ផែស្វយ័តក្រុងព្រះសីហនុ បានរៀបចំមហាសន្និបាតភាគហ៊ុនិកលើកទី២ កាលពីថ្ងៃព្រហស្បតិ៍ ទី២៣ ខែឧសភា ឆ្នាំ២០១៩ នៅសាលប្រជុំធំ នៃអគារទីចាត់ការកំពង់ផែស្វយ័តក្រុងព្រះសីហនុ ក្រោមអធិបតីភាព ឯកឧត្តម **លូ គឹមឈន់** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាប្រធានអគ្គនាយក និងជាប្រធានមហាសន្និបាតភាគហ៊ុនិកលើកទី២ របស់កំពង់ផែស្វយ័តក្រុងព្រះសីហនុបានសម្រេចលទ្ធផលការងារដូចខាងក្រោម៖

១. របាយការណ៍ លទ្ធផលអាជីវកម្ម-សេវាកម្ម ឆ្នាំ២០១៨ ធៀបនឹងឆ្នាំ២០១៧
២. របាយការណ៍ លទ្ធផលអាជីវកម្ម-សេវាកម្ម ៨ខែ ដើមឆ្នាំ២០១៩ ធៀបនឹង ៨ខែ ដើមឆ្នាំ២០១៨
៣. របាយការណ៍ ហិរញ្ញវត្ថុ សម្រាប់ដំណាច់ការិយបរិច្ឆេទ ៣១ ធ្នូ ២០១៨ (បានធ្វើសវនកម្ម)
៤. ផែនការអភិវឌ្ឍន៍ របស់ **កសស** សម្រាប់ឆ្នាំ ២០១៩

## ខ- ស្ថានភាពទីផ្សារ

ស្ថានភាពទីផ្សាររបស់ **កសស** គឺពឹងផ្អែកយ៉ាងខ្លាំងទៅលើចរាចរណ៍កុងតឺន័រ យើងសង្កេតឃើញថា សម្រាប់ឆ្នាំ២០១៩ នេះ មានលក្ខណៈល្អប្រសើរបើប្រៀបធៀបនឹងឆ្នាំ២០១៨ បរិមាណកុងតឺន័រ (TEUs) គឺមានកំណើន ១៨,១០% ស្មើនឹង ៩៧.៩៨៣ TEUs បើធៀបនឹង ឆ្នាំ២០១៧ វិញមានកំណើនប្រមាណ ៣៩,០១% ស្មើនឹង ១៧៩.៣៧២ TEUs ។ បើពិនិត្យមើលទៅលើបរិមាណកុងតឺន័រនាំចេញ និងនាំចូលឆ្លងកាត់ **កសស** វិញ កុងតឺន័រនាំចេញសម្រាប់ឆ្នាំ២០១៩ មានកំណើន ៤៤.៧១៦ TEUs ស្មើនឹង ១៦,៩១% ចំណែកបរិមាណកុងតឺន័រនាំចូលមានកំណើន ៥៣.២៦៧ TEUs ស្មើនឹង ១៩,២៥% បើធៀបនឹងឆ្នាំ២០១៨ ។




បើពិនិត្យទៅលើបរិមាណសរុបទំនិញ (តោន) ចរាចរណ៍ឆ្លងកាត់ **កសស** វិញ សម្រាប់ឆ្នាំ២០១៩ មានបរិមាណសរុប ៦.៥៤៧.៧៥៦ តោន ដែលមានកំណើន ២២,៨៩% ស្មើនឹង ១.២១៩.៤០៨ តោន ធៀបនឹងឆ្នាំ ២០១៨ បើប្រៀបធៀបនឹងបរិមាណទំនិញ ឆ្នាំ២០១៧ វិញ មានកំណើន ២.១៨៣.១១៧ តោន ស្មើនឹង ៥០,០២% ។ ក្នុងនោះទំនិញជាកុងតឺន័រសម្រាប់ឆ្នាំ២០១៩ មានការកើនឡើងប្រមាណ ២២,៤២% ស្មើនឹង

៧៥៩.៨០៦តោន ទំនិញរាយមានកំណើន ៤៥,៩៤% ស្មើនឹង១៦៣.៩០៧តោន និងទំនិញជាប្រេងមាន កំណើន ១៨.៦៨% ស្មើនឹង ២៩៥.៦៩៥តោន បើធៀបនឹងឆ្នាំ២០១៨ ។




ចាប់តាំងពីឆ្នាំ២០១៥ រហូតដល់បច្ចុប្បន្ន មានចរាចរកុងតឺន័រមួយចំនួនដឹកតាមរយៈរថភ្លើងឆ្លងកាត់ **កសស** ដែលបានជួយសម្រួលមួយផ្នែកលើស្ថានភាពចរាចរណ៍ផ្លូវជាលេខ ៤ ក៏ដូចជាផ្តល់នូវជម្រើសសម្រាប់អតិថិជនរបស់ **កសស** ក្នុងការដឹកទំនិញចេញ-ចូលកំពង់ផែ។ យើងសង្កេតឃើញថា បរិមាណកុងតឺន័រដឹកតាមរថភ្លើងឆ្លងកាត់ **កសស** សម្រាប់ឆ្នាំ២០១៩ មានកំណើន៤,៥៨% ស្មើនឹង ១.៧៧២ TEUs បើធៀបនឹងឆ្នាំ ២០១៨ ។




សង្កេតទៅលើប្រភេទទំនិញនាំចេញប្រចាំឆ្នាំ២០១៩ មានបរិមាណសរុបចំនួន ១.៤២៦.០៤៣ តោន ដោយមានកំណើន ១,០៤ % ស្មើនឹង ១៤.៦៥៣ តោន ធៀបនឹងឆ្នាំ២០១៨ ។ សម្រាប់ឆ្នាំ២០១៩ នេះ ទំនិញនាំចេញជាប្រភេទក្រណាត់ សំលៀកបំពាក់មានច្រើនជាងគេមានចំនួន ៣០,៩៣% ស្មើនឹង៤៤១.១២២ តោន

និងទំនិញជាប្រភេទអង្ករមានចំនួន ២៩,៧៩% ស្មើនឹង ៤២៤.៧៥២ តោននៃទំនិញនាំចេញសរុប ។ រីឯទំនិញទូទៅមាន ២៤,៣៩% ហើយទំនិញជាឈើកែច្នៃមាន ៤,៧៣% គ្រឿងចក្រមាន ៤,៣៧% ស្ករសរមាន ៣,៥៧% និងស្បែកជើង/ស្រោមជើងមាន ២,២១% នៃបរិមាណទំនិញនាំចេញសរុបរបស់ **កសស** ក្នុងឆ្នាំ ២០១៩ ។




ចំណែកទំនិញនាំចូលសរុបសម្រាប់ឆ្នាំ២០១៩ ដែលឆ្លងកាត់ **កសស** វិញមានបរិមាណ ៥.១២១.៧១៣ តោន មានកំណើន ៣០,៧៦% ស្មើនឹង១.២០៤.៧៥៥ តោន បើធៀបនឹងឆ្នាំ២០១៨ ។ ក្នុងទំនិញនាំចូលនេះ ទំនិញទូទៅមានចំនួន ៤២,៨៦% ប្រេងឥន្ធនៈមាន ៣៦,៦៧% និងក្រណាត់ សំលៀកបំពាក់មានប្រមាណ ៦,២២% នៃបរិមាណទំនិញនាំចូលសរុប ។ រីឯទំនិញប្រភេទជាគ្រឿងចក្រមាន ៥,៤៩% រថយន្ត ម៉ូតូ កង់មាន ៤,៣១% លោហៈធាតុមាន ២,១៩% ផ្សូងថ្មមាន ១,២៧% និងបារីមាន ១,00% នៃទំនិញនាំចូលសរុបសម្រាប់ឆ្នាំ២០១៩ នេះ។




## ច- ស្ថានភាពប្រកួតប្រជែង

**កសស** នៅតែរក្សាបានឧត្តមភាពប្រកួតប្រជែងរបស់ខ្លួន ដោយសារកត្តាមួយចំនួនដូចខាងក្រោម៖

- លក្ខណៈអំណោយផលនៃទីតាំងភូមិសាស្ត្រ
  - **កសស** ស្ថិតក្នុងឆកសមុទ្រខេត្តព្រះសីហនុ ដែលផ្តល់ភាពងាយស្រួលក្នុងការដឹកជញ្ជូនទៅកាន់ទីផ្សារអន្តរជាតិសំខាន់ៗ។ ការដឹកជញ្ជូនពី **កសស** ទៅកាន់កំពង់ផែក្នុងអាស៊ីប៉ាស៊ីហ្វិច ពុំចាំបាច់ឆ្លងកាត់ចំណតផែមេក្នុងតំបន់ឡើយ ពោលគឺការដឹកជញ្ជូនអាចធ្វើឡើងដោយផ្ទាល់តែម្តង។ ក្រៅពីនេះការដឹកជញ្ជូនក៏មានភាពងាយស្រួលផងដែរទៅកាន់កំពង់ផែហុងកុង ឬសិង្ហបុរី ដែលជាច្រកទ្វារទៅកាន់ទីផ្សារអឺរ៉ុប និងសហរដ្ឋអាមេរិក ។
  - មិនងាយរងគ្រោះដោយកត្តាធម្មជាតិ ដូចជា ព្យុះធំៗ រញ្ជួយដីជាដើម ដោយសារឆកសមុទ្រនេះមានអំណោយផលស្រាប់ពីធម្មជាតិ ។
  - ចំណតឆ្នេរមិនតម្រូវឱ្យមានការបូមស្តារខ្សាច់ ឬកករច្រើនឡើយ ដែលនេះអាចធ្វើឱ្យ **កសស** មិនចាំបាច់ចំណាយច្រើនលើការបូមស្តារឃ្លង ឬផ្លូវនាវាឡើយ ។
- ហេដ្ឋារចនាសម្ព័ន្ធសម្បូរបែប និងទំនើប
  - **កសស** មានបំពាក់នូវគ្រប់ហេដ្ឋារចនាសម្ព័ន្ធសម្រាប់បំរើឱ្យប្រតិបត្តិការអាជីវកម្មរបស់ខ្លួន ដូចជាប្រព័ន្ធគ្រប់គ្រងចរាចរណ៍នាវា VTMS ជាដើម។ បច្ចុប្បន្នសមត្ថភាពលើកដាក់កុងតឺន័ររបស់ **កសស** បានកើនឡើងរហូតដល់ ៦៥០.០០០ TEUs ក្រោយពីបំពាក់រថស្ទូចចល័តលើគែមផែ (QC) ចំនួន ០២ គ្រឿង បន្ថែមទៀត។ កត្តានេះបានជំរុញផលិតភាពរបស់ **កសស** ឱ្យកើនជាងមុន និងកាត់បន្ថយពេលវេលាកកស្ទះទំនិញ។

- **លើកកំពស់ប្រសិទ្ធភាពការងារ**
  - ប្រសិទ្ធការងារត្រូវបានលើកកម្ពស់ តាមរយៈការពង្រឹងការគ្រប់គ្រង ដោយអនុវត្តអភិបាលកិច្ចល្អ ក្រោយពេលចុះបញ្ជីលក់មូលបត្រ ។
  - ការប្រើប្រាស់បច្ចេកវិទ្យាទំនើបក្នុងការអនុវត្តការងារ ដោយមានការគាំទ្រពីបំពាក់បបនីយកណ្ដផែ បន្ថែមដូចជា រថចល័តលើទីលានផែ និងរថចល័តលើគែមផែជាដើម ។
  - ការបណ្ដុះបណ្ដាល និងការលើកទឹកចិត្តរបស់ថ្នាក់ដឹកនាំចំពោះបុគ្គលិក និយោជិក ពិសេសអនុវត្តការងារផ្ទាល់ដើម្បីពង្រឹងស្មារតី និងកំលាំងចិត្តក្នុងកិច្ចខិតខំប្រឹងប្រែងបំពេញសេវាកម្មជូនអតិថិជន។
- **តម្លៃសេវាកម្មមានលក្ខណៈប្រកួតប្រជែង**
  - **កសស** នៅរក្សារតម្លៃសេវាកម្មរបស់ខ្លួនឱ្យមានលក្ខណៈប្រកួតប្រជែង ជាការទាក់ទាញអតិថិជន គួបផ្សំនឹងការពង្រឹងគុណភាពសេវាកម្មរបស់ខ្លួន ។
- **រក្សាទំនាក់ទំនងល្អជាមួយភាគីពាក់ព័ន្ធ**
  - **កសស** បានរក្សាទំនាក់ទំនងល្អជាមួយអតិថិជនរបស់ខ្លួន ដោយព្យាយាមបំពេញតាមតម្រូវការរបស់អតិថិជន ទទួលយកយោបល់និងការរិះគន់ក្នុងន័យស្ថាបនា ដើម្បីស្វែងយល់ពីចំនុចខ្វះខាតរបស់ខ្លួនក្នុងទិសដៅកែលម្អបន្ថែមទៀត ។
  - **កសស** ក៏រក្សាកិច្ចសហប្រតិបត្តិការជាមួយកំពង់ផែក្នុងតំបន់ក្នុងការចែកចាយព័ត៌មាន និងបទពិសោធន៍គ្នាទៅវិញទៅមក ដើម្បីលើកស្ទួយសេវាកម្មរបស់ខ្លួន ។

## ឆ- ផែនការអនាគត

## ទស្សនទាន នៃការអភិវឌ្ឍន៍ កសស រយៈពេល១០ឆ្នាំ (២០២០-២០៣០)

**ផែនការអភិវឌ្ឍន៍រយៈពេលខ្លី-មធ្យម-វែង របស់ កសស រួមមាន៖**

❖ **គម្រោងបំពាក់គ្រឿងចក្រលើកដាក់កុងតឺន័រធុនធ្ងន់**

ចាប់ពីឆ្នាំ២០១៩ ដល់ ឆ្នាំ២០២០ **កសស** បានកំពុងដំណើរការបំពាក់គ្រឿងចក្រលើកដាក់កុងតឺន័រធុនធ្ងន់ប្រភេទរថស្ទូចចល័តលើគែមផែ (QC) ចំនួន ០១ គ្រឿង និងរថស្ទូចចល័តនៅទីលាន (RTG) ចំនួន ០២ គ្រឿង គ្រឿងចក្រលើកដាក់កុងតឺន័រទទេ (Empty Reach Stacker) ចំនួន ០៤ គ្រឿង បន្ថែមទៀត។ បន្ទាប់ពី **កសស** បានបំពាក់គ្រឿងចក្រលើកដាក់កុងតឺន័រធុនធ្ងន់ប្រភេទ QC ចំនួន ០១ គ្រឿង RTG ចំនួន ០២ គ្រឿង និង Empty Reach Stacker ចំនួន ០៤ គ្រឿង រួចហើយ ធ្វើឱ្យសមត្ថភាពលើកដាក់កុងតឺន័ររបស់ **កសស** ឈានដល់ ៨០០.០០០ TEUs ក្នុង ១ឆ្នាំ ចាប់ពីឆ្នាំ២០២០ នេះ ។

| សេចក្ដីសង្ខេបគម្រោង | |
|---|---|
| រយៈពេលនៃគម្រោង | ឆ្នាំ២០១៩ ដល់ឆ្នាំ២០២០ |
| គោលបំណងនៃគម្រោង | បង្កើនសមត្ថភាពលើកដាក់កុងតឺន័ររបស់ទីលាន **កសស** |
| លទ្ធផលរំពឹងទុក | បង្កើនសមត្ថភាពលើកដាក់កុងតឺន័ររហូតដល់ ៨០០.០០០ TEUs ក្នុង ១ឆ្នាំ |

| | |
|---|---|
| | ចាប់ពីឆ្នាំ២០២០ នេះ |
| ធាតុសំខាន់ៗ<br>នៃគម្រោង | • បំពាក់ QC ០១ គ្រឿង RTG ០២ គ្រឿង និង Empty Reach Stacker ចំនួន ០៤ គ្រឿង នៅឆ្នាំ២០២០ ដើម្បីបង្កើនសមត្ថភាពលើកដាក់កុងតឺន័រនៅទីលានឱ្យបានដល់ ៨០០.០០០ TEUs ក្នុង ១ឆ្នាំ (បានកំពុងអនុវត្ត)<br>• សាងសង់ទីលានកុងតឺន័រសាច់ ទំហំ ២.៨ ហិកតា នៅក្នុងកំពង់ផែ និងទីលានសំបក ទំហំ ៤ ហិកតា នៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ដើម្បីបង្កើនសមត្ថភាពលើកដាក់កុងតឺន័រនៅទីលានឱ្យបានដល់ ៨០០.០០០ TEUs ក្នុង ១ឆ្នាំ (បានកំពុងអនុវត្ត) |
| ទីភ្នាក់ងារអនុវត្តគម្រោង | **កសស** ជាអ្នកអនុវត្ត |
| ប្រភពថវិកា | ថវិកា **កសស** ផ្ទាល់ និងថវិកាពីការបោះផ្សាយមូលបត្ររបស់ **កសស** |
| តម្លៃប៉ាន់ស្មានគម្រោង | USD ១២.៥០០.០០០,០០ |

### ❖ គម្រោងសាងសង់ចំណតផែកុងតឺន័រថ្មី (ជំហានទី១) ប្រវែង ៣៥០ ម៉ែត្រ ជម្រៅ -១៤,៥ ម៉ែត្រ

ចាប់ពីឆ្នាំ២០២០ ដល់ឆ្នាំ២០២៣ គឺជាគម្រោងអភិវឌ្ឍន៍ផែកុងតឺន័រថ្មី (ជំហានទី១) ប្រវែង ៣៥០ ម៉ែត្រ និងមានជម្រៅទឹក -១៤,៥ ម៉ែត្រ រួមបញ្ចូលទាំងការបំពាក់គ្រឿងចក្រលើកដាក់កុងតឺន័រទំនើបប្រភេទ QC ចំនួន ០៣ គ្រឿង និងប្រភេទ RTG ចំនួន ០៩ គ្រឿង និងឧបករណ៍លើកដាក់ទំនិញកុងតឺន័រមួយចំនួន។ ល។

គម្រោងនេះទទួលបានហិរញ្ញប្បទានសម្បទានពីទីភ្នាក់ងារ JICA ដែលគ្រោងនឹងចាប់ផ្តើមការងារសាងសង់នៅពាក់កណ្តាលឆ្នាំ២០២១ ហើយបញ្ចប់ការងារសាងសង់នៅពាក់កណ្តាលឆ្នាំ២០២៤ ។

| សេចក្តីសង្ខេបគម្រោង | |
|---|---|
| រយៈពេល<br>នៃគម្រោង | ឆ្នាំ២០២០ ដល់ឆ្នាំ២០២៤ |
| គោលបំណង<br>នៃគម្រោង | បង្កើនសមត្ថភាពលើកដាក់កុងតឺន័រនៅកំពង់ផែក្រុងព្រះសីហនុ ដែលជាកំពង់ផែសមុទ្រទឹកជ្រៅតែមួយរបស់ប្រទេសកម្ពុជា និងប្រសិទ្ធិភាពផ្នែកភស្តុភារកម្ម ប្រទេសកម្ពុជា ដោយការសាងសង់ចំណតផែកុងតឺន័រថ្មី ប្រវែង ៣៥០ ម៉ែត្រ ជម្រៅទឹក -១៤,៥ ម៉ែត្រ ព្រមទាំងអភិវឌ្ឍន៍បបនីយកណ្ឌផ្សេងទៀត និងអនុញ្ញាតឱ្យនាវាដឹកជញ្ជូនកុងតឺន័រធុនធំក្នុងតំបន់ ចូលចតនៅ **កសស** បាន ដែលនឹងធ្វើឱ្យឧបសគ្គអំពីជម្រៅទឹកសម្រាប់កំពង់ផែត្រូវបានដោះស្រាយព្រមទាំងតម្លៃដឹកជញ្ជូនតាមសមុទ្រ (Ocean Freight Cost) មានតម្លៃប្រហាក់ប្រហែលបណ្តាប្រទេសជិតខាង និងក្នុងតំបន់ ព្រមទាំងចូលរួមចំណែកដល់ការជួយសម្រួលផ្នែកពាណិជ្ជកម្ម និងការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកម្ពុជា ។ |
| លទ្ធផល<br>រំពឹងទុក | សមត្ថភាពលើកដាក់កុងតឺន័រដល់ ១.១៥០.០០០ TEUs ក្នុង ១ឆ្នាំ នៅពេល ដែលចំណតផែកុងតឺន័រនេះដាក់ឱ្យប្រតិបត្តិការនៅ ឆ្នាំ២០២៤ ខាងមុខ។ |

| | |
|---|---|
| ធាតុសំខាន់ៗនៃគម្រោង | • សាងសង់ចំណតផែកុងតឺន័រថ្មី ប្រវែង ៣៥០ ម៉ែត្រ ជម្រៅទឹក -១៤,៥ ម៉ែត្រ ទីលានកុងតឺន័រ និងឋបនីយភ័ណ្ឌផែ ព្រមទាំងការងារបូមស្តារអាងនាវា និងឃ្លូងនាវា ប្រវែង ៤គីឡូម៉ែត និងជម្រៅ -១៣.៥ ម៉ែត្រ។ ល។<br>• បំពាក់ឋបនីយភណ្ឌដែលមាន QC ០៣ គ្រឿង RTG ០៩ គ្រឿង រថលើកកុងតឺន័រទទេ (Empty Reach Stacker) ចំនួន ០២ គ្រឿង ក្បាលសណ្តោងកុងតឺន័រ ចំនួន ១៦ គ្រឿង និងប្រព័ន្ធគ្រប់គ្រងចំណតផែកុងតឺន័រស្វ័យប្រវត្តិកម្ម ០១ កម្ពេ ។ ល។ |
| ទីតាំងគម្រោង | ស្ថិតនៅភាគខាងកើត នៃ ចំណតផែកុងតឺន័រមានស្រាប់ ស្ថិតលើផ្ទៃទឹកសមុទ្រក្បែរទំនប់រលកចំងាយប្រមាណ ៣០០ម៉ែត្រ ពីច្រាំងសមុទ្រ និងមានស្ពានភ្ជាប់ពីដីគោកទៅកាន់ទីលានផែកុងតឺន័រ ។ ផ្ទៃដីសរុបទំហំ ១៧,៥ ហិកតា ។ |
| ទីភ្នាក់ងារអនុវត្តគម្រោង | **កសស** ជាទីភ្នាក់ងារអនុវត្តគម្រោង ហើយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាម្ចាស់គម្រោង (Employer) ។ |
| ប្រភពថវិកា និងចំនួនថវិកា | ប្រាក់កម្ចីពី JICA (លេខៈ CP-P21) តាមរយៈប្រាក់កម្ចីបន្តពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ |
| តម្លៃប៉ាន់ស្មានគម្រោង | JPY ២៣.៥០២.០០០.០០០ ប្រហាក់ប្រហែលនឹង USD ២០៣.០០០.០០០,០០ |
| ដំណាក់កាលនៃការអនុវត្តន៍គម្រោង | **ដំណាក់កាលទី១ ៖ ការសិក្សាបុរេសមិទ្ធិលទ្ធភាព និងការរៀបចំហិរញ្ញវត្ថុ (ឆ្នាំ២០១៦ ដល់ ឆ្នាំ២០១៧)**<br>-ដំហ៊ានទី១ (ឆ្នាំ២០១៦ ដល់ឆ្នាំ២០១៧)៖ ក្រុមសិក្សា JICA បានចុះមកសិក្សា និងរៀបចំរបាយការណ៍ស្តីពីការសិក្សាបុរេសមិទ្ធិលទ្ធភាព នៃគម្រោងអភិវឌ្ឍន៍ចំណតផែកុងតឺន័រថ្មីកំពង់ផែក្រុងព្រះសីហនុ ។<br>-ដំហ៊ានទី២ (ឆ្នាំ២០១៦ ដល់ឆ្នាំ២០១៧)៖ ទីភ្នាក់ងារ JICA បានចុះមកសិក្សា និងវាយតម្លៃផ្នែកហិរញ្ញវត្ថុលើគម្រោងអភិវឌ្ឍន៍ចំណតផែកុងតឺន័រថ្មី កំពង់ផែស្វយ័តក្រុងព្រះសីហនុ ដោយសម្រេចចុះកិច្ចព្រមព្រៀងហិរញ្ញប្បទាន សម្បទាន លេខៈ CP-P21 នៅថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៧ ។<br>**ដំណាក់កាលទី២៖ ការងារជ្រើសរើសកុងស៊ុលតង់គម្រោង (ឆ្នាំ២០១៨ ដល់ឆ្នាំ២០១៩)**<br>ការងារជ្រើសរើសកុងស៊ុលតង់នេះ ត្រូវបានអនុវត្តតាមនីតិវិធី Single Source Selection (SSS)។ ក្នុងដំណាក់កាលនីមួយៗ ត្រូវមានការឯកភាពជាគោលការណ៍ពីក្រសួងអាណាព្យាបាលទាំងពីរ (MEF & MPWT) និងទីភ្នាក់ងារ JICA ។ សេវាកុងស៊ុលតង់នេះរួមមាន ការងារសិក្សាគំនូសផ្នែកវិស្វកម្ម សំណង់ស៊ីវិល និងការងារផ្គត់ផ្គង់គ្រឿងចក្រលើកដាក់កុងតឺន័រធុនធ្ងន់ព្រមទាំងការងារត្រួតពិនិត្យក្នុងអំឡុងពេលសាងសង់ជាដើម ។<br>-ក្រុមហ៊ុន Nippon-Koei & Oriental Consultants Global JV (ក្រុមហ៊ុនជប៉ុន) ត្រូវបានចុះកិច្ចសន្យាជាមួយ កសស នៅខែកក្កដា ឆ្នាំ២០១៩ ។ |

| | |
|---|---|
| | **ដំណាក់កាលទី៣៖ ការរៀបចំគំនូសប្លង់វិស្វកម្ម និងជំនួយការផ្នែកដេញថ្លៃជ្រើសរើសក្រុមហ៊ុនម៉ៅការសាងសង់ និងក្រុមហ៊ុនផ្គត់ផ្គង់គ្រឿងចក្រលើកដាក់កុងតឺន័រធុនធ្ងន់ (ឆ្នាំ២០១៩ ដល់ឆ្នាំ២០២០)**<br>-**ជំហ៊ានទី១** (ឆ្នាំ២០១៩ ដល់ឆ្នាំ២០២០)៖ ការរៀបចំគំនូសប្លង់វិស្វកម្មសម្រាប់ ①ការងារសំណង់ស៊ីវិល (Package-1) និង ②ការងារផ្គត់ផ្គង់គ្រឿងចក្រលើកដាក់កុងតឺន័រធុនធ្ងន់ (Package-2) ។<br>-ក្រុមហ៊ុនកុងស៊ុលតង់ NK-OCG JV បានចាប់ដំណើរការការងារផ្នែកគំនូសប្លង់វិស្វកម្ម និងរៀបចំឯកសារដេញថ្លៃសម្រាប់ជ្រើសរើសក្រុមហ៊ុនម៉ៅការសាងសង់ តាំងពីខែកក្កដា ឆ្នាំ២០១៩ កន្លងមក ។<br>-**ជំហ៊ានទី២** (ឆ្នាំ២០១៩ ដល់ឆ្នាំ២០២០)៖ ①ការជ្រើសរើសក្រុមហ៊ុនសាងសង់ចំណតផែកុងតឺន័រថ្មី (Packag-1) (ឆ្នាំ២០២០ ដល់ឆ្នាំ២០២១) និង ②ការជ្រើសរើសក្រុមហ៊ុនផ្គត់ផ្គង់គ្រឿងចក្រលើកដាក់កុងតឺន័រធុនធ្ងន់ (Packag-2) (ឆ្នាំ២០២១ ដល់ឆ្នាំ២០២២)។ ចំពោះនីតិវិធីជ្រើសរើសក្រុមហ៊ុនសាងសង់ និងក្រុមហ៊ុនផ្គត់ផ្គង់ត្រូវអនុវត្តតាមនីតិវិធីនៃការដេញថ្លៃមានលក្ខណៈប្រកួតប្រជែងជាសាធារណៈ (ICB) ហើយត្រូវមានការឯកភាពជាគោលការណ៍ពីក្រសួងអាណាព្យាបាលទាំងពីរ (MEF & MPWT) និងទីភ្នាក់ងារ JICA។<br>**ដំណាក់កាលទី៤៖ ដំណាក់កាលសាងសង់ចំណតផែកុងតឺន័រថ្មី និងផ្គត់ផ្គង់គ្រឿងចក្រលើកដាក់កុងតឺន័រធុនធ្ងន់ (ឆ្នាំ២០២១ ដល់ឆ្នាំ២០២៤)**<br>-ជំហ៊ានទី១ (ឆ្នាំ២០២១ ដល់ឆ្នាំ២០២៤)៖ ការងារសាងសង់ចំណតផែកុងតឺន័រថ្មីគ្រោងនឹងចាប់ផ្តើមនៅពាក់កណ្តាល ឆ្នាំ២០២១ ហើយបញ្ចប់ការងារនៅឆ្នាំ២០២៤ (៣៦ខែ) ។<br>-ជំហ៊ានទី២ (ឆ្នាំ២០២២ ដល់ឆ្នាំ២០២៤)៖ ការងារផ្គត់ផ្គង់គ្រឿងចក្រលើកដាក់កុងតឺន័រធុនធ្ងន់គ្រោងនឹងចាប់ផ្តើមនៅឆ្នាំ២០២២ ហើយគ្រោងបញ្ចប់ការងារនៅឆ្នាំ២០២៤ (២៨ខែ)។<br>**ដំណាក់កាលទី ៥៖ រយៈពេលធានាជួសជុលថែទាំ (LDP) (ឆ្នាំ២០២៤ ដល់ឆ្នាំ២០២៥)**<br>រយៈពេលធានាជួសជុលថែទាំគម្រោងមានរយៈពេល១ឆ្នាំ ដូចខាងក្រោម៖<br>-ការងារសាងសង់ចំណតផែកុងតឺន័រថ្មី (ឆ្នាំ២០២៤ ដល់ឆ្នាំ២០២៥)<br>-ការងារផ្គត់ផ្គង់គ្រឿងចក្រលើកដាក់កុងតឺន័រធុនធ្ងន់ (ឆ្នាំ២០២៤ ដល់ឆ្នាំ២០២៥។ |
| វឌ្ឍនភាពគម្រោង | -កិច្ចព្រមព្រៀងប្រាក់កម្ចី បានចុះហត្ថលេខានៅថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៧ ។<br>-កិច្ចព្រមព្រៀងប្រាក់កម្ចី ចូលជាធរមាន នៅថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០១៧ ។<br>-កិច្ចព្រមព្រៀងប្រាក់កម្ចី បញ្ចប់សុពលភាព នៅថ្ងៃទី៧ ខែសីហា ឆ្នាំ២០២៥ ។<br>-កិច្ចសន្យាផ្នែកសេវាកុងស៊ុលតង់ រវាង កសស និងក្រុមហ៊ុន NK-OCG JV ចុះថ្ងៃទី ០៨ ខែសីហា ឆ្នាំ២០១៩ ។<br>-សេវាកុងស៊ុលតង់ផ្នែកគំនូសប្លង់វិស្វកម្ម និងរៀបចំឯកសារដេញថ្លៃសម្រាប់ជ្រើសរើសក្រុមហ៊ុនម៉ៅការសាងសង់ បានចាប់ផ្តើមនៅខែកក្កដា ឆ្នាំ២០១៩ ហើយនឹងបញ្ចប់នៅខែមិថុនា ឆ្នាំ២០២០នេះ ។ |

## គំនូសប្លង់ទូទៅៈ គម្រោងអភិវឌ្ឍន៍ចំណតផែកុងតឺន័រថ្មីកំពង់ផែក្រុងព្រះសីហនុ-ជំហ៊ានទី១




## គំនូសប្លង់មើលពីអាកាស គម្រោងអភិវឌ្ឍន៍ចំណតផែកុងតឺន័រថ្មីកំពង់ផែក្រុងព្រះសីហនុ-ជំហ៊ានទី១



## ❖ គម្រោងសាងសង់ចំណតផែកុងតឺន័រថ្មី-ជំហានទី២ (ប្រវែង ៤១០ ម៉ែត្រ ជម្រៅទឹក -១៦ ម៉ែត្រ) និងជំហានទី៣ (ប្រវែង ៤៤០ ម៉ែត្រ ជម្រៅទឹក -១៧.៥ ម៉ែត្រ) រួមគ្នា

ជាទស្សនទាននៃការអភិវឌ្ឍន៍រយៈពេល ១០ឆ្នាំ (២០៣០-២០២០)ទៅមុខ មានគោលបំណងចង់ឱ្យ កសស ដែលជាកំពង់ផែសមុទ្រទឹកជ្រៅក្លាយជាមាត់ច្រកសេដ្ឋកិច្ចដ៏សំខាន់ សម្រាប់ប្រទេសកម្ពុជា មានគោលដៅច្បាស់លាស់ដោយប្រើប្រាស់នូវ **យុទ្ធសាស្ត្រកម្លាំងសរុប និងមធ្យោបាយសរុប** ឈានសម្រេចបាននូវមាត្រដ្ឋានសេដ្ឋកិច្ចមួយ ដែលកុងតឺន័រមួយចំនួនធំអាចដឹកជញ្ជូនពី អាមេរិក អឺរ៉ុប ទៅមក កម្ពុជា ដោយពុំចាំបាច់-ឆ្លងកាត់កំពង់ផែធំៗនានា សំដៅកាត់បន្ថយពេលវេលា និងតម្លៃឡូជិស្ទិក ជាពិសេសតម្លៃដឹកជញ្ជូនតាមផ្លូវសមុទ្រ ។

ហេតុដូច្នេះ កសស ត្រូវការអភិវឌ្ឍចំណតផែកុងតឺន័រថ្មីទាំងពីរជំហានរួមគ្នា ឱ្យបានរួចរាល់នៅឆ្នាំ២០២៦ តាមលក្ខណៈបច្ចេកទេសដូចខាងក្រោម ៖

**១ ចំណតផែកុងតឺន័រថ្មី-(ជំហានទី២) ប្រវែង ៤១០ម៉ែត្រ និងជម្រៅទឹក -១៦ម៉ែត្រ**

(សមត្ថភាពនាវាចំណុះ 100,000DWT ផ្ទុកកុងតឺន័រ 7,300-7,500TEUs ចូលចតបាន)

តម្លៃប៉ាន់ស្មានគម្រោង-៖ **USD 230,000,000** រួមទាំងការបំពាក់គ្រឿងចក្រលើកដាក់កុងតឺន័រ

**២ ចំណតផែកុងតឺន័រថ្មី-(ជំហានទី៣) ប្រវែង ៤៤០ម៉ែត្រ និងជម្រៅទឹក -១៧៥ម៉ែត្រ.**

(សមត្ថភាពនាវាចំណុះ 140,000DWT ផ្ទុកកុងតឺន័រ 11,500-12,700TEUs ចូលចតបាន)

តម្លៃប៉ាន់ស្មានគម្រោង-៖ **USD 270,000,000** រួមទាំងការបំពាក់គ្រឿងចក្រលើកដាក់កុងតឺន័រ ។

| សេចក្តីសង្ខេបគម្រោង | |
|---|---|
| រយៈពេលនៃគម្រោង | ឆ្នាំ២០២០ ដល់ឆ្នាំ២០២៦ |
| គោលបំណងនៃគម្រោង | ដើម្បីចូលរួមគាំទ្រដល់កិច្ចសម្រួលពាណិជ្ជកម្ម និង ធុរកិច្ចនៅកម្ពុជា កាត់បន្ថយពេលវេលា និងតម្លៃឡូជិស្ទិក ដែលធានាបាននូវនិរន្តរភាព នៃលំហូរទំនិញចេញ-ចូលប្រកបដោយលក្ខណៈប្រកួតប្រជែង គុណភាពសេវា និងមិនកកស្ទះចរាចរទំនិញនាពេលអនាគត ឆ្លើយតបបាននូវ **គោលនយោបាយ អភិវឌ្ឍវិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥ - ២០២៥** នោះ **កសស** ត្រូវអភិវឌ្ឍន៍ និងសាងសង់ចំណតផែកុងតឺន័រថ្មី -ជំហានទី២ (ប្រវែង ៤១០ ម៉ែត្រ ជម្រៅទឹក -១៦ ម៉ែត្រ) និងជំហានទី៣ (ប្រវែង ៤៤០ ម៉ែត្រ ជម្រៅទឹក -១៧.៥ ម៉ែត្រ) រួមគ្នា ក្នុងគោលដៅច្បាស់លាស់ឈានសម្រេចបាននូវមាត្រដ្ឋានសេដ្ឋកិច្ចមួយ ដែលកុងតឺន័រមួយចំនួនធំអាចដឹកជញ្ជូនពីអាមេរិក អឺរ៉ុប ទៅមក កម្ពុជា ដោយពុំចាំបាច់-ឆ្លងកាត់កំពង់ផែធំៗនានា សំដៅកាត់បន្ថយពេលវេលា និងតម្លៃឡូជិស្ទិក ជាពិសេសតម្លៃដឹកជញ្ជូនតាមផ្លូវសមុទ្រ ។ |
| លទ្ធផលរំពឹងទុក | សមត្ថភាពលើកដាក់កុងតឺន័រឈានដល់ ២.២៣០.០០០TEUs ក្នុង ១ឆ្នាំ នៅពេលដែលចំណតផែកុងតឺន័រថ្មី ជំហានទី២ និងជំហានទី៣ នេះ ដាក់ឱ្យប្រតិបត្តិការនៅ |

| | |
|---|---|
| | ឆ្នាំ២០២៧ ខាងមុខ។ |
| ធាតុសំខាន់ៗ នៃគម្រោង | **១ ចំណតផែកុងតឺន័រថ្មី-(ជំហានទី២) ប្រវែង ៤១០ម៉ែត្រ និងជម្រៅទឹក -១៦ម៉ែត្រ**<br>(សមត្ថភាពនាវាចំណុះ 100,000 DWT ផ្ទុកកុងតឺន័រ 7,300-7,500TEUs ចូលចតបាន)<br>តម្លៃប៉ាន់ស្មានគម្រោង-៖ **USD 230,000,000** រួមទាំងការបំពាក់មធ្យោបាយគ្រឿងចក្រលើកដាក់កុងតឺន័រទំនើប<br>**២ ចំណតផែកុងតឺន័រថ្មី-(ជំហានទី៣) ប្រវែង ៤៤០ម៉ែត្រ និងជម្រៅទឹក -១៧៥. ម៉ែត្រ**<br>(សមត្ថភាពនាវាចំណុះ 140,000DWT ផ្ទុកកុងតឺន័រ 11,500-12,700TEUs ចូលចតបាន)<br>តម្លៃប៉ាន់ស្មានគម្រោង-៖ **USD 270,000,000** រួមទាំងការបំពាក់មធ្យោបាយគ្រឿងចក្រលើកដាក់កុងតឺន័រទំនើប |
| ទីតាំងគម្រោង | បន្តពីចំណតផែកុងតឺន័រប្រវែង ៣៥០ ម៉ែត្រ ស្ថិតលើផ្ទៃទឹកសមុទ្រក្បែរទំនប់រលកចំងាយប្រមាណ ៦៥០ ម៉ែត្រ ពីច្រាំងសមុទ្រ និងមានស្ពានភ្ជាប់ពីដីគោកទៅទីលានផែកុងតឺន័រ។ ផ្ទៃដីសរុបទំហំ ៤២.៥ ហិកតា ។ |
| ភ្នាក់ងារអនុវត្តគម្រោង | **កសស** ជាទីភ្នាក់ងារអនុវត្តគម្រោង ហើយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាម្ចាស់គម្រោង (Employer) ។ |
| ប្រភពថវិកា | ពីដៃគូរអភិវឌ្ឍន៍គម្រោង (JICA) |
| តម្លៃប៉ាន់ស្មានគម្រោង | ប្រមាណ USD ៥00.000.000,00 |
| ដំណាក់កាលនៃគម្រោង | **ដំណាក់កាលទី១៖ ការសិក្សាបុរេសមិទ្ធិលទ្ធភាព និងការរៀបចំហិរញ្ញវត្ថុ (ឆ្នាំ២០២០ ដល់ឆ្នាំ២០២១)**<br>-ឆ្នាំ២០២០ ដល់ឆ្នាំ២០២១)៖ ក្រុមសិក្សាដៃគូរអភិវឌ្ឍន៍ នឹងចុះសិក្សា និងរៀបចំរបាយការណ៍ស្ដីពីការសិក្សាបុរេសមិទ្ធិលទ្ធភាពនៃគម្រោងអភិវឌ្ឍន៍ ចំណតផែកុងតឺន័រ ថ្មី-ជំហ៊ានទី២ និងជំហានទី៣រួមគ្នាព្រមទាំងធ្វើការវាយតម្លៃផ្នែកហិរញ្ញវត្ថុលើគម្រោងអភិវឌ្ឍន៍ចំណតផែកុងតឺន័រថ្មីទាំងពីរជំហានរួមគ្នា ដើម្បីផ្ដល់ប្រាក់កម្ចីសម្បទាន ។<br>**ដំណាក់កាលទី២៖ ការងារជ្រើសរើសក្រុមហ៊ុនកុងស៊ុលតង់ (ឆ្នាំ២០២១ ដល់ឆ្នាំ២០២២)**<br>ការងារជ្រើសរើសកុងស៊ុលតង់នេះ ត្រូវបានអនុវត្តតាមនីតិវិធី នៃការដេញថ្លៃមានលក្ខណៈប្រកួតប្រជែងជាសាធារណៈ (ICB)។ សេវាកុងស៊ុលតង់នេះរួមមាន ការងារសិក្សាគំនូសប្លង់ផ្នែកវិស្វកម្មសំណង់ស៊ីវិល និងជំនួយការរៀបចំឯកសារដេញថ្លៃសម្រាប់ជ្រើសរើសក្រុមហ៊ុនម៉ៅការសាងសង់ និងការងារផ្គត់ផ្គង់គ្រឿងចក្រលើកដាក់កុងតឺន័រធុនធ្ងន់ ព្រមទាំងការងារត្រួតពិនិត្យក្នុងអំឡុងពេលសាងសង់ជាដើម ។ |

| | |
|---|---|
| | **ដំណាក់កាលទី៣៖ ការរៀបចំគំនូសប្លង់វិស្វកម្ម និងជំនួយការផ្នែកដេញថ្លៃជ្រើសរើសក្រុមហ៊ុនម៉ៅការសាងសង់ និងក្រុមហ៊ុនផ្គត់ផ្គង់គ្រឿងចក្រលើកដាក់កុងតឺន័រទំនើប (ឆ្នាំ២០២៣ ដល់ឆ្នាំ២០២៤)**<br>-ជំហ៊ានទី១ (ឆ្នាំ២០២២ ដល់ឆ្នាំ២០២៣)៖ ការរៀបចំគំនូសប្លង់វិស្វកម្មសម្រាប់ ①ការងារសំណង់ស៊ីវិល (Package-1) និង②ការងារផ្គត់ផ្គង់គ្រឿងចក្រលើកដាក់កុងតឺន័រទំនើប (Package-2) ។<br>-ជំហ៊ានទី២ (ឆ្នាំ២០២៣ ដល់ឆ្នាំ២០២៤)៖ ①ការជ្រើសរើសក្រុមហ៊ុនសាងសង់ចំណតផែកុងតឺន័រថ្មី-ជំហានទី២ និងជំហានទី៣ (Package-1) និង②ការជ្រើសរើសក្រុមហ៊ុនផ្គត់ផ្គង់គ្រឿងចក្រលើកដាក់កុងតឺន័រទំនើប-ជំហានទី២ និងជំហានទី៣ (Package-2) ។<br>ចំពោះនីតិវិធីជ្រើសរើសក្រុមហ៊ុនសាងសង់ និងក្រុមហ៊ុនផ្គត់ផ្គង់ត្រូវអនុវត្តតាមនីតិវិធីនៃការដេញថ្លៃមានលក្ខណៈប្រកួតប្រជែងជាសាធារណៈ (ICB) ។<br>**ដំណាក់កាលទី៤៖ ដំណាក់កាលសាងសង់ចំណតផែកុងតឺន័រថ្មី-ជំហ៊ានទី២ និងជំហានទី៣ និងផ្គត់ផ្គង់គ្រឿងចក្រលើកដាក់កុងតឺន័រទំនើប (ឆ្នាំ២០២៤ ដល់ឆ្នាំ២០២៧)**<br>-ជំហ៊ានទី១ (ឆ្នាំ២០២៤ ដល់ឆ្នាំ២០២៦) (៣៦ខែ)៖ ការងារសាងសង់ចំណតផែកុងតឺន័រថ្មី-ជំហានទី២ (ប្រវែង ៤១០ ម៉ែត្រ ជម្រៅទឹក -១៦ ម៉ែត្រ) និងជំហានទី៣ (ប្រវែង ៤៤០ ម៉ែត្រ ជម្រៅទឹក -១៧.៥ ម៉ែត្រ) រួមគ្នា ។<br>-ជំហ៊ានទី២ (ឆ្នាំ២០២៥ ដល់ឆ្នាំ២០២៧)៖ ការងារផ្គត់ផ្គង់គ្រឿងចក្រលើកដាក់កុងតឺន័រទំនើបទាំងពីរជំហានរួមគ្នា ដោយគ្រោងបញ្ចប់ការងារ និងដាក់ឱ្យប្រតិបត្តិការនៅឆ្នាំ២០២៧ (២៨ខែ) ។<br>**ដំណាក់កាលទី៥៖ រយៈពេលធានាជួសជុលថែទាំ (LDP) (ឆ្នាំ២០២៧ ដល់ឆ្នាំ២០២៨)**<br>រយៈពេលធានាជួសជុលថែទាំគម្រោងមានរយៈពេល១ឆ្នាំ ។ |
| វឌ្ឍនភាពគម្រោង | កសស បានកំពុងស្នើសុំការគាំទ្រ ពីក្រសួងអាព្យាបាលទាំងពីរ (MPWT & MEF) ដើម្បីអន្តរាគមន៍ស្នើសុំថវិកាពីដៃគូអភិវឌ្ឍន៍) JICA (សម្រាប់ការអភិវឌ្ឍន៍ និងសាងសង់ចំណតផែកុងតឺន័រថ្មី (ជំហានទី២ និងជំហានទី៣) រួមគ្នា។ |

គំនូសប្លង់មើលពីអាកាសៈ គម្រោងអភិវឌ្ឍន៍
ចំណតផែកុងតឺន័រថ្មីកំពង់ផែក្រុងព្រះសីហនុ
ជំហ៊ានទី២ និង ជំហានទី៣



❖ **ផែនការអភិវឌ្ឍន៍កំពង់ផែស្វយ័តក្រុងព្រះសីហនុ រយៈពេលវែង៖**

១ ចំណតផែកុងតឺន័រថ្មី-(ជំហានទី៤) ប្រវែង ៤៧០ម៉ែត្រ និងជម្រៅទឹក -១៨.៥ ម៉ែត្រ

២ ចំណតផែកុងតឺន័រថ្មី-(ជំហានទី៥) ប្រវែង ៤៨០ម៉ែត្រ និងជម្រៅទឹក -១៩០ម៉ែត្រ.




## ៥- កត្តាហានិភ័យ

កត្តាហានិភ័យមួយចំនួនរបស់ **កសស** រួមមាន ៖

❖ ហានិភ័យលើអត្រាប្តូរប្រាក់ដោយ **កសស** មានប្រាក់កម្ចីជាប្រាក់យ៉េនជប៉ុន

❖ ហានិភ័យលើនិរន្តភាពធនធានមនុស្ស

- បុគ្គលិកវ័យចំណាស់មានចំនួនច្រើន
- កង្វះលើបុគ្គលិកជំនាញបច្ចេកទេស ជាពិសេសលើបុគ្គលិកបើកបរ និងជួសជុលថែទាំគ្រឿងចក្រធន់ធ្ងន់
- កង្វះលើធនធានកណ្តាល

- កង្វះអ្នកបច្ចេកទេសផ្នែកព័ត៌មានវិទ្យាសំរាប់ Logical Security ដើម្បីទប់ស្កាត់ការការលុកលុយពី Hacker ។

❖ ហានិភ័យលើប្រព័ន្ធប្រើប្រាស់របស់ **កសស**

- បញ្ហាប្រព័ន្ធ Single Window ដែលជាប្រព័ន្ធប្រតិបត្តិការចេញ វិក្កយបត្រ លើសេវាកម្ម **កសស** គួររកនីតិវិធីចេញវិក្កយបត្រក្រៅពី Single Window បាន ករណីដែលប្រព័ន្ធមានបញ្ហា
- ការបាត់បង់ទិន្នន័យសំខាន់ៗ ដែលបង្ករឡើងដោយ Hacker ជ្រៀតចូលប្រព័ន្ធគិតប្រាក់ Single Window , CTMS

❖ ហានិភ័យលើគ្រឿងចក្រ

- ការងារជួសជុលគ្រឿងចក្រត្រូវប្រើប្រាស់ពេលវេលាយូរ អាចធ្វើឲ្យប៉ះពាល់លើប្រតិបត្តិការរបស់ **កសស**
- ខ្វះឧបករណ៍ចាំបាច់មួយចំនួនសម្រាប់ត្រួតពិនិត្យ និងវាយតម្លៃគុណភាពផ្សេងៗរបស់គ្រឿងចក្រ
- ការផ្គត់ផ្គង់គ្រឿងបន្លាស់ត្រូវការពេលវេលាយូរ

# ផ្នែកទី ២
# ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច

## ក- លទ្ធផលប្រតិបត្តិការធុរកិច្ច

| បរិយាយ | ឯកត្តា | ផែនការ ២០១៩ | ឆ្នាំ២០១៩ | ឆ្នាំ២០១៨ | ឆ្នាំ២០១៧ | ប្រៀបធៀប | | |
|---|---|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | (២-១)/១ | (២-៣)/៣ | (២-៤)/៤ |
| **បរិមាណទំនិញឆ្លងកាត់** | តោន | ៥,៩០៨,000 | ៦,៥៤៧,៧៥៦ | ៥,៣២៨,៣៤៨ | ៤,៣៦៤,៦៣៩ | ១០.៨៣% | ២២.៨៩% | ៥០.០២% |
| ជាកុងតឺន័រ | _ | | ៤,១៤៨,៧២៩ | ៣,៣៨៨,៩២៣ | ២,៨៨២,៣១៦ | | **២២.៤២%** | **៤៣.៩៤%** |
| ទំនិញរាយ | _ | | ៥២០,៦៨៣ | ៣៥៦,៧៧៦ | ២០៨,៦៧៥ | | **៤៥.៩៤%** | **១៤៩.៥២%** |
| ជាប្រេង | _ | | ១,៨៧៨,៣៤៤ | ១,៥៨២,៦៤៩ | ១,២៧៣,៦៤៨ | | **១៨.៦៨%** | **៤៧.៤៨%** |
| **បរិមាណទំនិញនាំចូល** | _ | **៤,៣១៧,000** | **៥,១២១,៧១៣** | **៣,៩១៦,៩៥៨** | **៣,១៨៦,៨៩២** | **១៨.៦៤%** | **៣០.៧៦%** | **៦០.៧១%** |
| ជាកុងតឺន័រ | _ | | ២,៧៧៥,៣៨៦ | ២,០៥២,001 | ១,៧១២,៥៧៩ | | **៣៥.២៥%** | **៦២.០៦%** |
| ទំនិញរាយ | _ | | ២,៣៤៦,៣២៧ | ១,៨៦៤,៩៥៧ | ១,៤៧៤,៣១៣ | | **២៥.៨១%** | **៥៩.១៥%** |
| **បរិមាណទំនិញនាំចេញ** | _ | **១,៥៩១,000** | **១,៤២៦,០៤៣** | **១,៤១១,៣៩០** | **១,១៧៧,៧៤៧** | **-១០.៣៧%** | **១.០៤%** | **២១.០៨%** |
| ជាកុងតឺន័រ | _ | | ១,៣៧៣,៣៤៣ | ១,៣៣៦,៩២២ | ១,១៦៩,៧៣៧ | | **២.៧២%** | **១៧.៤១%** |
| ទំនិញរាយ | _ | | ៥២,៧00 | ៧៤,៤៦៨ | ៨,010 | | **-២៩.២៣%** | **៥៥៧.៩៧%** |
| **បរិមាណទំនិញលើករៀប** | _ | **៧,៩០៤,000** | **៨,៦៦០,៥២៦** | **៧,១៩២,៤៥៣** | **៥,៩៩២,៣៤៥** | **៩.៥៧%** | **២០.៤១%** | **៤៤.៥៣%** |
| ប្រគល់ផ្ទាល់ | _ | ៣៤៧,000 | ៤៦៤,៤៣៥ | ២៧៨,៧៥៩ | ១៩៧,១១៥ | | **៦៦.៦១%** | **១៣៥.៦២%** |
| ឆ្លងកាត់ឃ្លាំងនិងទីលាន | _ | ៧,៥៥៧,000 | ៨,១៩៦,០៩១ | ៦,៩១៣,៦៩៤ | ៥,៧៩៥,២៣០ | | **១៨.៥៥%** | **៤១.៤៣%** |
| **បរិមាណកុងតឺន័រឆ្លងកាត់** | TEUs | **៥៩០,000** | **៦៣៩,២១១** | **៥៤១,២២៨** | **៤៥៩,៨៣៩** | **៨.៣៤%** | **១៨.១០%** | **៣៩.០១%** |
| **នាំចូល** | _ | ៣០៣,000 | **៣៣០,០២០** | **២៧៦,៧៥៣** | **២៣៣,៦២៣** | **៨.៩២%** | **១៩.២៥%** | **៤១.២៦%** |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| មានទំនិញ | _ | | ៣១២,៩៦១ | ២៤៨,៧៥០ | ២០៦,៧៣៤ | | **២៥.៨១%** | **៥១.៣៨%** |
| គ្មានទំនិញ | _ | | ១៧,០៥៩ | ២៨,០០៣ | ២៦,៨៨៩ | | -៣៩.០៨% | -៣៦.៥៦% |
| **នាំចេញ** | _ | ២៨៧,០០០ | **៣០៩,១៩១** | **២៦៤,៤៧៥** | **២២៦,២១៦** | ៧.៧៣% | ១៦.៩១% | ៣៦.៦៨% |
| មានទំនិញ | _ | | ១៧៩,៤៧៦ | ១៧៣,៤៣៨ | ១៤៨,០៩៦ | | ៣.៤៨% | **២១.១៩%** |
| គ្មានទំនិញ | _ | | ១២៩,៧១៥ | ៩១,០៣៧ | ៧៨,១២០ | | **៤២.៤៩%** | **៦៦.០៥%** |
| **ចំនួននាវាចូលចត** | **គ្រឿង** | **១,៤៩២** | **១,៦៦២** | **១,៤៥១** | **១,៣០៥** | **១១.៣៩%** | **១៤.៥៤%** | **២៧.៣៦%** |
| **ចំណុះផ្ទុកនាវា** | **តោន** | **១៦,០៨៨,០០០** | **១៧,៥០១,៨៩៣** | **១៥,៧៣០,៩៤៩** | **១៣,៥៩០,២៨២** | 0.00% | ១១.២៦% | **២៨.៧៨%** |
| នាវាដឹកកុងតឺន័រ | គ្រឿង | | ៦២១ | ៥៨១ | ៥៣១ | | ៦.៨៨% | ១៦.៩៥% |
| ចំណុះនាវាដឹកកុងតឺន័រ | តោន | | ៨,៨៧៦,៧៩៥ | ៨,៨៤៦,២៥១ | ៧,៧៨១,៣៧៤ | | 0.៣៥% | ១៤.0៨% |
| នាវាដឹកប្រេង | គ្រឿង | | ៦៧១ | ៥៨២ | ៤៦១ | | **១៥.២៩%** | ៤៥.៥៥% |
| ចំណុះនាវាដឹកប្រេង | តោន | | ២,២៤៥,៣៦៨ | ១,៩៥៩,២៧៨ | ១,៦៧០,២៧៥ | | **១៤.៦០%** | ៣៤.៤៣% |
| នាវាដឹកទំនិញទូទៅ | គ្រឿង | | ៣២២ | ២៥១ | ២៨៣ | | **២៨.២៩%** | **១៣.៧៨%** |
| ចំណុះនាវាដឹកទំនិញទូទៅ | តោន | | ២,៩១៨,១៤២ | ២,៣៣៨,២៣១ | ២,២៩២,៥១២ | | **២៤.៨០%** | **២៧.២៩%** |
| នាវាទេសចរណ៍ | គ្រឿង | | ៤៨ | ៣៧ | ៣០ | | **២៩.៧៣%** | ៦0.00% |
| នាវាទេសចរណ៍ | តោន | | ៣,៤៦១,៥៨៨ | ២,៥៨៧,១៨៩ | ១,៨៤៦,១២១ | | **៣៣.៨០%** | **៨៧.៥១%** |
| ចំនួនទេសចរ | នាក់ | | ៥១,៤៧៩ | ៤០,៥៩៨ | ២៥,៥៣៨ | | **២៦.៨០%** | ១០១.៥៨% |



ចំណុះផ្ទុកនាវាចូលចត កសស
១០,០០០,០០០
៨,០០០,០០០
៦,០០០,០០០
៤,០០០,០០០
២,០០០,០០០
0
៨,៨៧៦,៧៩៥
៨,៨៤៦,២៥១
៧,៧៨១,៣៧៤
២,២៤៥,៣៦៨
១,៩៥៩,២៧៨
១,៦៧០,២៧៥
២,៩១៨,១៤២
២,៣៣៨,២៣១
២,២៩២,៥១២
៣,៤៦១,៥៨៨
២,៥៨៣,១៨៩
១,៨៤៦,១២១
នាវាកុងតឺន័រ
នាវាប្រេង
នាវាទំនិញទូទៅ
នាវាទេសចរណ៍
ឆ្នាំ២០១៩
ឆ្នាំ២០១៨
ឆ្នាំ២០១៧




ចំនួននាវាចូលចត កសស
៦២១
៥៨១
៥៣១
៦៧១
៥៨២
៤៦១
៣២២
២៥១
២៨៣
៤៨
៣៧
៣០
នាវាកុងតឺន័រ
នាវាប្រេង
នាវាទំនិញទូទៅ
នាវាទេសចរណ៍
ឆ្នាំ២០១៩
ឆ្នាំ២០១៨
ឆ្នាំ២០១៧


បរិមាណកុងតឺន័រឆ្លងកាត់ កសស (TEUs)
នាំចេញគ្មានទំនិញ
នាំចេញមានទំនិញ
នាំចូលគ្មានទំនិញ
នាំចូលមានទំនិញ
៧៨,១២០
៩១,០៣៧
១២៩,៧១៥
១៤៨,០៩៦
១៧៣,៤៣៨
១៧៩,៤៧៦
២៦,៨៨៩
២៨,០០៣
១៧,០៥៩
២០៦,៧៣៤
២៤៨,៧៥០
៣១២,៩៦១
០
៦០,០០០
១២០,០០០
១៨០,០០០
២៤០,០០០
៣០០,០០០
៣៦០,០០០
ឆ្នាំ២០១៧
ឆ្នាំ២០១៨
ឆ្នាំ២០១៩


បរិមាណទំនិញនាំចេញ នាំចូល ឆ្លងកាត់ កសស (តោន)
បរិមាណទំនិញនាំចូល
បរិមាណទំនិញនាំចេញ
៥,១២១,៧១៣
១,៤២៦,០៤៣
៣,៩១៦,៩៥៨
១,៤១១,៣៩០
៣,១៨៦,៨៩២
១,១៧៧,៧៤៧
ឆ្នាំ២០១៩
ឆ្នាំ២០១៨
ឆ្នាំ២០១៧

## ខ- រចនាសម្ព័ន្ធចំណូល

| បរិយាយ | សម្រាប់ការិយបរិច្ឆេទឆ្នាំ ២០១៩ | | សម្រាប់ការិយបរិច្ឆេទឆ្នាំ ២០១៨ | |
|---|---|---|---|---|
| | ពាន់រៀល | ភាគរយធៀបនឹងចំណូលសរុប | ពាន់រៀល | ភាគរយធៀបនឹងចំណូលសរុប |
| ចំណូលលើកដាក់ពីនាវាទៅទីលាន (Stevedoring) | ១៥១.១៥៣.៧១៧ | ៤៥,២៧% | ១២៧.០៨៧.៥៣៨ | ៤៦,១២% |
| ចំណូលលើកដាក់លើទីលាន (LOLO) | ៩០.៨៧៧.០៧៦ | ២៧,២២% | ៧៥.១៣៨.៩៧៨ | ២៧,២៧% |
| ចំណូលពីសេវាកម្មនាវាចរ | ៦៥.៧១៩.៤៥២ | ១៩,៦៨% | ៥៧.៦៩៤.០៣៤ | ២០,៩៤% |
| ចំណូលស្តុក ឃ្លាំង និងទីលាន | ២១.២៤៨.១២២ | ៦,៣៦% | ១០.១៨១.១០២ | ៣,៦៩% |
| ចំណូលដឹកជញ្ជូន | ១០២.០៨១ | ០,០៣% | ៦៨០.០០០ | ០,២៥% |
| ចំណូលនាវាទេសចរណ៍ | ៨២៣.៥៤៧ | ០,២៥% | ៦៤០.៥០៧ | ០,២៣% |
| ចំណូលពីតំបន់ សេដ្ឋកិច្ចពិសេស | ២.៧៥១.៤៩៤ | ០,៨២% | ៣.០១៦.៣៦៥ | ១,០៩% |
| ចំណូលជួលទីតាំង | ៩១៤.០៧០ | ០,២៧% | ៧៦១.៦៧៧ | ០,២៨% |
| ចំណូលផ្សេងៗទៀត | ៣២៣.៨១៨ | ០,១០% | ៣៧៥.៤៤៤ | ០,១៤% |
| **ចំណូលសរុប** | **៣៣៣.៩១៣.៣៧៧** | **១០០,០០%** | **២៧៥.៥៧៥.៦៤៥** | **១០០,០០%** |

# ផ្នែកទី ៣

# ព័ត៌មានអំពីអភិបាលកិច្ចសាជីវកម្ម

## ក- អង្គការលេខ

### រចនាសម្ព័ន្ធរបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ



# ខ- ក្រុមប្រឹក្សាភិបាល



## ឯកឧត្តម លូ គឹមឈន់

### ប្រធានអគ្គនាយក

### ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាប្រធានអគ្គនាយកកំពង់ផែស្វយ័តក្រុងព្រះសីហនុ

ឯកឧត្តម កើតនៅថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៥៦ សញ្ជាតិ ខ្មែរ ទីកន្លែងកំណើត ភូមិព្រៃកពោធិ ឃុំព្រៃកពោធិ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ។

- **ប្រវត្តនៃការសិក្សា**

នៅឆ្នាំ១៩៨១ ដល់ឆ្នាំ១៩៨៦ ឯកឧត្តមបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ លើជំនាញសំណង់ក្នុងទឹក និងកំពង់ផែ នៅប្រទេសរុស្ស៊ី។ ពីឆ្នាំ២០០៤ ដល់ឆ្នាំ២០០៦ ឯកឧត្តមបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ លើជំនាញពាណិជ្ជសាស្ត្រ នៅសាកលវិទ្យាល័យជាតិគ្រប់គ្រង ប្រទេសកម្ពុជា។ ហើយពីឆ្នាំ២០០៦ ដល់ឆ្នាំ២០០៨ ឯកឧត្តមបានបញ្ចប់ថ្នាក់បណ្ឌិត លើជំនាញវិទ្យាសាស្ត្រសេដ្ឋកិច្ច នៅសាកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យា ប្រទេសកម្ពុជា។

- **បទពិសោធន៍ការងារ**

ឯកឧត្តមបានចូលបម្រើការងារនៅកំពង់ផែស្វយ័តក្រុងព្រះសីហនុ នៅក្នុងអំឡុងឆ្នាំ ១៩៨៦ មានតួនាទីជាបុគ្គលិកវិស្វករសំណង់ នៃនាយកដ្ឋានបច្ចេកទេសសម្ភារៈសំណង់។ ហើយនៅឆ្នាំ១៩៩០ ដល់ឆ្នាំ១៩៩២ ឯកឧត្តមមានតួនាទីជាអនុប្រធានកំពង់ផែស្វយ័តក្រុងព្រះសីហនុ និងនៅឆ្នាំ១៩៩២ ដល់ឆ្នាំ១៩៩៩ ឯកឧត្តមមានតួនាទីជាប្រធានកំពង់ផែស្វយ័តក្រុងព្រះសីហនុ។ នៅក្នុងឆ្នាំ១៩៩៩ ដល់ឆ្នាំ២០០៨ ឯកឧត្តមទទួលបានតួនាទីជាប្រធានអគ្គនាយកកំពង់ផែក្រុងព្រះសីហនុ និងចាប់ពីឆ្នាំ២០០៨ រហូតមកដល់បច្ចុប្បន្នឯកឧត្តមជាប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាប្រធានអគ្គនាយកកំពង់ផែស្វយ័តក្រុងព្រះសីហនុ ។



# ឯកឧត្តម ស៊ុយ សាន
## សមាជិកក្រុមប្រឹក្សាភិបាល
## តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន

ឯកឧត្តម កើតនៅថ្ងៃទី២៨ ខែមីនា ឆ្នាំ១៩៥៨ សញ្ជាតិ ខ្មែរ ទីកន្លែងកំណើត ភូមិបំណក់ ឃុំឈើគុំ ស្រុកក្រគរ ខេត្តពោធិសាត់ ។

- **ប្រវត្តនៃការសិក្សា**

នៅឆ្នាំ១៩៩៤ ឯកឧត្តមបានបញ្ចប់ថ្នាក់បណ្ឌិត លើជំនាញវិទ្យាសាស្ត្រសេដ្ឋកិច្ច ។

- **បទពិសោធន៍ការងារ**

នៅក្នុងអំឡុងឆ្នាំ ១៩៧៩ ដល់ ឆ្នាំ១៩៨១ ឯកឧត្តមបានចូលបម្រើការងារនៅសាលាខេត្តពោធិសាត់ ដែលមានតួនាទីគ្រប់គ្រងរដ្ឋបាល ហើយនៅឆ្នាំ១៩៨១ ដល់ ឆ្នាំ១៩៩៤ ឯកឧត្តមមានតួនាទីជាអនុប្រធានគណៈកម្មធិការផែនការ ខេត្តពោធិសាត់។ នៅឆ្នាំ១៩៩៤ ដល់ឆ្នាំ១៩៩៨ ឯកឧត្តមមានតួនាទីជាជំនួយការ រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ហើយនៅឆ្នាំ១៩៩៨ ដល់ឆ្នាំ២០០៣ ឯកឧត្តមទទួលបានតួនាទីជាអភិបាលរងខេត្តសៀមរាប។ ពីឆ្នាំ២០០៣ ដល់ឆ្នាំ២០០៨ ឯកឧត្តមបានចូលបម្រើការងារនៅក្រសួងសាធារណការ និងដឹកជញ្ជូន មានតួនាទីជានាយកខុទ្ទកាល័យ។ នៅឆ្នាំ២០០៨ ដល់ឆ្នាំ២០១៣ ឯកឧត្តមទទួលបានតួនាទីជាជំនួយការទេសរដ្ឋមន្ត្រី។ ឆ្នាំ២០១៣ ដល់ឆ្នាំ២០១៦ ឯកឧត្តមមានតួនាទីជានាយកខុទ្ទកាល័យក្រសួងពាណិជ្ជកម្ម ហើយចាប់ពីឆ្នាំ២០១៦ មកដល់បច្ចុប្បន្ន ឯកឧត្តមទទួលបានតួនាទីជាអនុរដ្ឋលេខាធិកា និងជានាយកខុទ្ទកាល័យក្រសួងសាធារណការ និងដឹកជញ្ជូន ។



# ឯកឧត្តម ផាន់ ផល្លា
## សមាជិកក្រុមប្រឹក្សាភិបាល
## តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ឯកឧត្តម កើតនៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៧៣ សញ្ជាតិ ខ្មែរ ។

- **ប្រវត្តនៃការសិក្សា**

នៅឆ្នាំ១៩៩៤ ដល់ឆ្នាំ១៩៩៦ ឯកឧត្តមបានបញ្ចប់ថ្នាក់បរិញ្ញាបត្រ លើជំនាញរដ្ឋបាលពាណិជ្ជកម្ម នៅសាកលវិទ្យាល័យ Hawaii Pacific សហរដ្ឋអាមេរិក។ ឆ្នាំ១៩៩៩ ឯកឧត្តមបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ លើជំនាញពាណិជ្ជកម្ម នៅសាកលវិទ្យាល័យ New South Wales ប្រទេសអូស្ត្រាលី ។ ហើយនៅឆ្នាំ២០០៣ ឯកឧត្តមបានបញ្ចប់ថ្នាក់បណ្ឌិត លើជំនាញសេដ្ឋកិច្ច នៅសាកលវិទ្យាល័យ Wollonggong ប្រទេសអូស្ត្រាលី ។

- **បទពិសោធន៍ការងារ**

ពីឆ្នាំ២០០៨ ដល់ឆ្នាំ២០១៣ ឯកឧត្តមមានតួនាទីជាប្រធាននាយកដ្ឋានព័ត៌មានវិទ្យា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ នៅឆ្នាំ២០១៣ ដល់ឆ្នាំ២០១៦ ឯកឧត្តមមានតួនាទីជាអគ្គនាយក នៃអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងចាប់ពីឆ្នាំ២០១៦ ដល់បច្ចុប្បន្ន ឯកឧត្តមទទួលបានតួនាទីជាអនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។



# ឯកឧត្តម សុខ សុភ័ក្រ្ត
## សមាជិកក្រុមប្រឹក្សាភិបាល
## តំណាងក្រសួងពាណិជ្ជកម្ម

ឯកឧត្តម កើតនៅថ្ងៃទី០៩ ខែមករា ឆ្នាំ១៩៥៨ សញ្ជាតិ ខ្មែរ ។

- **ប្រវត្តិនៃការសិក្សា**

នៅឆ្នាំ១៩៨៦ ឯកឧត្តមបានបញ្ចប់ថ្នាក់បរិញ្ញាបត្ររង លើជំនាញបច្ចេកទេសអគ្គិសនី នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ប្រទេសកម្ពុជា។ នៅឆ្នាំ១៩៩២ ឯកឧត្តមបានបញ្ចប់ថ្នាក់បរិញ្ញាបត្រ លើជំនាញសេដ្ឋកិច្ច នៅវិទ្យាស្ថានវិទ្យាសាស្ត្រសេដ្ឋកិច្ច ប្រទេសកម្ពុជា។ នៅឆ្នាំ១៩៩៧ ឯកឧត្តមបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ លើជំនាញសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅសាកលវិទ្យាល័យ London ប្រទេសអង់គ្លេស ហើយនៅឆ្នាំ២០០០ ឯកឧត្តមបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ លើជំនាញគោលនយោបាយសាធារណៈ នៅសាកលវិទ្យាល័យ Saitama ប្រទេសជប៉ុន ។

- **បទពិសោធន៍ការងារ**

ក្នុងអំឡុងឆ្នាំ១៩៨៦ ដល់ឆ្នាំ១៩៨២ ឯកឧត្តមបានចូលបម្រើការងារនៅអាជ្ញាធរអគ្គិសនីខេត្តកោះកុង ទទួលបន្ទុកជាប្រធានអាជ្ញាធរអគ្គិសនីខេត្ត។ នៅចុងឆ្នាំ១៩៩២ ឯកឧត្តមបានផ្លាស់មកបម្រើការងារនៅក្រសួងពាណិជ្ជ ទទួលបន្ទុកជាសមាជិកក្រុមជំនួយការនៃរដ្ឋមន្ត្រី។ នៅក្នុងឆ្នាំ១៩៩៩ ឯកឧត្តមត្រូវបានតែងតាំងជាប្រធាននាយកដ្ឋានអាស៊ាន និងអង្គការអន្តរជាតិ ហើយមានតួនាទីយ៉ាងសំខាន់ក្នុងនាមជាសមាជិកក្រុមអ្នកចរចាពាណិជ្ជកម្ម សម្រាប់ការធ្វើសមាហរណកម្មកម្ពុជានៅក្នុងក្របខ័ណ្ឌអាស៊ាន កិច្ចព្រមព្រាងពាណិជ្ជកម្មសេរីអាស៊ានបូកមួយ និងអង្គការពាណិជ្ជកម្មពិភពលោក (WTO)។ ឆ្នាំ២០០៤ ដល់ឆ្នាំ២០០៧ ឯកឧត្តមមានតួនាទីជាអគ្គនាយករង នៃអគ្គនាយកដ្ឋានបច្ចេកទេស ក្រសួងពាណិជកម្ម។ ពីឆ្នាំ២០០៧ ដល់ឆ្នាំ២០១៤ ឯកឧត្តមទទួនបានតួនាទីជាអគ្គនាយក នៃអគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ ក្រសួងពាណិជ្ជកម្ម។ នៅឆ្នាំ២០១៤ ដល់ឆ្នាំ២០១៦ ឯកឧត្តមមានតួនាទីជាអគ្គនាយក នៃអគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម ក្រសួងពាណិជ្ជកម្ម និងពីឆ្នាំ២០១៦ ដល់ឆ្នាំ២០១៧ ឯកឧត្តមទទួលបានតួនាទីជាអនុរដ្ឋលេខធិការក្រសួងពាណិជ្ជកម្ម ចាប់ឆ្នាំ២០១៨ មកដល់បន្ទុប្បន្នឯកឧត្តមទទួលបានតួនាទីជារដ្ឋលេខធិការក្រសួងពាណិជ្ជកម្ម ទទួលបន្ទុកលើប្រតិបត្តិការ និងការកែទំរង់របស់អគ្គនាយកដ្ឋានគាំទ្រសេវាពាណិជ្ជកម្ម និងគោលនយោបាយពាណិជ្ជកម្មអន្តរជាតិ ។



# លោក ហ៊ុន មុន្នីវណ្ណ
## អភិបាលឯករាជ្យ

លោក ហ៊ុន មុន្នីវណ្ណ កើតនៅថ្ងៃទី២២ ខែមករា ឆ្នាំ១៩៧៣ សញ្ជាតិ ខ្មែរ ទីកន្លែងកំណើត ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ។

➢ **ប្រវត្តនៃការសិក្សា**

នៅឆ្នាំ១៩៩៣ ដល់ឆ្នាំ១៩៩៧ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រគ្រប់គ្រង លើជំនាញគណនេយ្យនៅសាកលវិទ្យាល័យ វេទមហាឥសី ប្រទេសកម្ពុជា។ ពីឆ្នាំ២០១៧ ដល់បច្ចុប្បន្ន លោកកំពុងបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ លើជំនាញគ្រប់គ្រងអាជីវកម្មតាមអនឡាញ នៅសាកលវិទ្យាល័យក្រុងឡុងដ៍ ចក្រភពអង់គ្លេស ។

➢ **បទពិសោធន៍ការងារ**

ក្នុងអំឡុងឆ្នាំ១៩៨៩ ដល់ឆ្នាំ១៩៩២ លោកបានចូលបម្រើការងារនៅអង្គភាពនយោបាយ T88 កងប្រដាប់អាវុធនៃកម្ពុជា មានតួនាទីជាជំនួយការប្រធានអង្គភាព។ ឆ្នាំ១៩៩៧ ដល់ឆ្នាំ២០០០ លោកជា សវនករជាន់ខ្ពស់នៃ Ernst & Young រាជធានីភ្នំពេញ ប្រទេសកម្ពុជា។ នៅឆ្នាំ២០០០ ដល់ឆ្នាំ២០០៨ លោកជាប្រធានហិរញ្ញវត្ថុនៃសិប្បករអង្គរ ខូ.,អិលធីឌី., ហើយក្នុងឆ្នាំ២០០៣ លោកទទួលបានតួនាទីជាក្រុមប្រឹក្សាភិបាលសិប្បករអង្គរ ខូ.,អិលធីឌី., តំណាងឱ្យបុគ្គលិក។ នៅក្នុងឆ្នាំ២០០៦ ដល់ឆ្នាំ២០០៨ លោកជាអភិបាលឯករាជ្យ និងជាប្រធានគណៈកម្មាធិការសវនកម្មនៃស្ថាបនា លីមីតធីត ពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១៣ លោកមានតួនាទីជាប្រធានក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការសវនកម្មនៃស្ថាបនា លីមីតធីត។ នៅខែសីហា ឆ្នាំ២០០៨ ដល់ខែធ្នូ ឆ្នាំ២០១១ លោកមានតួនាទីជាប្រធានចាត់ការទូទៅនៃកសិករីករាយ ខូ.,អិលធីឌី.,។ ហើយនៅឆ្នាំ២០១១ ដល់ឆ្នាំ២០១៣ លោកជាក្រុមប្រឹក្សាភិបាលនៃសមាគមសហគ្រិនវ័យក្មេងនៅកម្ពុជា (YEAC)។ ខែមិថុនា ឆ្នាំ២០១១ ដល់បច្ចុប្បន្ន លោកជាអនុប្រធានសភាពាណិជ្ជកម្ម ខេត្តសៀមរាប និងឧត្តរមានជ័យ (SROCC)។ នៅឆ្នាំ២០១១ ដល់ឆ្នាំ២០១៤ លោកជាប្រធានសមាគមអតីតនិស្សិត IATSS កម្ពុជា (CIAA)។ ពីឆ្នាំ២០១៣ ដល់បច្ចុប្បន្ន លោកជាអនុប្រធាន និងក្រុមប្រឹក្សានៃក្លឹបវិនិយោគិនកម្ពុជា (CIC Investment Plc.) ហើយលោកក៏ជាប្រធានក្រុមប្រឹក្សាភិបាលនៃមេហ្គា លីស៊ីង ភីអិលស៊ី ផងដែរ។ រហូតដល់ឆ្នាំ២០១៤ លោកមានតួនាទីជានាយកប្រតិបត្តិ នៃអចលនទ្រព្យសកម្មប្រទេសកម្ពុជា ខូ.,អិលធីឌី។ នៅឆ្នាំ២០១៦ លោកជាអភិបាលឯករាជ្យ និងជាប្រធានគណៈកម្មាធិការសវនកម្មនៃធនាគារស្ថាបនា ភីអិលស៊ី ហើយពីឆ្នាំ២០១៧ ដល់បច្ចុប្បន្ន លោកជាមាជិកវិទ្យាស្ថានអូស្ត្រាលី នៃនាយកក្រុមហ៊ុន (AICD) និងជាប្រធានគណៈកម្មការសវនកម្ម កំពង់ផែស្វយ័តក្រុងព្រះសីហនុ ។



# លោក Hidetoshi KUME
# អភិបាលមិនប្រតិបត្តិ
# តំណាងភាគហ៊ុនិកឯកជន

លោក Hidetoshi KUME កើតនៅថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៧៥ សញ្ជាតិ ជប៉ុន ។

➢ **ប្រវត្តនៃការសិក្សា**

នៅឆ្នាំ១៩៨០ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រពីសាកលវិទ្យាល័យ Kyusgshu លើជំនាញវិស្វករប្រត្តិកម្មប្រព័ន្ធទឹកកខ្វក់។ នាឆ្នាំ១៩៨២ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ពីសាកលវិទ្យាល័យ Kyusgshu លើជំនាញវិស្វករប្រត្តិកម្មប្រព័ន្ធទឹកកខ្វក់ ប្រទេសជប៉ុន ។

➢ **បទពិសោធន៍ការងារ**

ក្នុងអំឡុងឆ្នាំ១៩៨២ លោកបានចូលបម្រើការងារជាមន្ត្រីបច្ចេកទេស ផ្នែកអភិវឌ្ឍន៍កំពង់ផែ និងសមុទ្រនៅក្រសួងដឹកជញ្ជូន។ ចាប់ពីឆ្នាំ១៩៨៩ ដល់ឆ្នាំ១៩៩០ លោកជាមន្ត្រីភ្នាក់ងារដែនដី ទទួលបន្ទុកខាងគម្រោង, ផ្នែកអភិវឌ្ឍន៍តំបន់រាជធានី (តំបន់ Kansai) និងឆ្នាំ១៩៩០ ដល់ឆ្នាំ១៩៩២ លោកមានតួនាទីជាប្រធានផ្នែកគម្រោងនៅវិទ្យាស្ថានស្រាវជ្រាវ ផ្នែកកំពង់ផែ និងសមុទ្រនៃក្រសួងដឹកជញ្ជូន ទទួលបន្ទុករួមក្នុងកិច្ចសហប្រតិបត្តិការបច្ចេកទេសជាមួយសិក្ខាកាមមកពីក្រៅប្រទេស ដែលកាន់ផ្នែកកំពង់ផែ និងអាកាសយាន្តដ្ឋាន។ នៅឆ្នាំ១៩៩៣ ដល់ឆ្នាំ១៩៩៦ លោកមានតួនាទីជាលេខាទីមួយនៃនាយកដ្ឋានសេដ្ឋកិច្ចរបស់ស្ថានទូតជប៉ុនប្រចាំប្រទេសភីលីពីន ទទួលបន្ទុកជាជំនួយការផ្នែកសេដ្ឋកិច្ចនៃរដ្ឋាភិបាលជប៉ុន នៅក្នុងប្រទេសភីលីពីន។ ឆ្នាំ១៩៩៦ ដល់ ឆ្នាំ១៩៩៨ លោកមានតួនាទីជាប្រធានការិយាល័យកំពង់ផែ Takamatsu និងការសាងសង់អាកាសយាន្តដ្ឋាននៃការិយាល័យសាងសង់កំពង់ផែទី៣ និងឆ្នាំ១៩៩៩ ដល់ឆ្នាំ២០០១ លោកជាប្រធានការិយាល័យសាងសង់កំពង់ផែទី២ក្នុងស្រុក នៅក្រសួងដឹកជញ្ជូន។ នៅឆ្នាំ១៩៩៧ ដល់ ឆ្នាំ១៩៩៩ លោកជាអ្នកស្រាវជ្រាវជាន់ខ្ពស់ការិយាល័យគម្រោងនៅវិទ្យាស្ថានអភិវឌ្ឍន៍តំបន់ឆ្នេរសមុទ្រ ទទួលបន្ទុកលើការសិក្សាពីយុទ្ធសាស្ត្រការអភិវឌ្ឍន៍កំពង់ផែ ដែលជាគោលនយោបាយទី១ របស់គម្រោង JICA ក្នុងការអភិវឌ្ឍន៍តំបន់កំពង់ផែ។ ពីឆ្នាំឆ្នាំ២០០២ ដល់ឆ្នាំ២០០៤ លោកជាអភិបាលខេត្ត Okinawa មានតួនាទីជាទីប្រឹក្សាផ្នែកសាងសង់។ ឆ្នាំ២០០៣ ដល់ឆ្នាំ២០០៥ លោកមានតួនាទីជានាយករង នៃនាយកដ្ឋានកំពង់ផែ និងសមុទ្រ នៅក្រសួងដែនដី ហេដ្ឋារចនាសម្ព័ន្ធ និងដឹកជញ្ជូន ទទួលបន្ទុកផ្នែកផ្សព្វផ្សាយ និងការពារគ្រោះមហន្តរាយឯកជន។ នៅឆ្នាំ២០០៥ ដល់ ឆ្នាំ២០០៧ លោកមានតួនាទីជាអភិបាលក្រុង Fukuoka និងជាទីប្រឹក្សានាយកដ្ឋានកំពង់ផែ និងសមុទ្រផងដែរ។ ឆ្នាំ២០០៧ ដល់ឆ្នាំ២០០៩ លោកមានតួនាទីជាអ្នកស្រាវជ្រាវជាន់ខ្ពស់ គម្រោងស្រាវជ្រាវអន្តរ

ជាតិ "ការផ្លាស់ប្តូរអាកាសធាតុ និងយុទ្ធសាស្ត្រដឹកជញ្ជូនតាមផ្លូវអាកាស" នៅវិទ្យាស្ថានការសិក្សាគោលនយោបាយដឹកជញ្ជូន។ ពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១០ លោកមានតួនាទីជានាយករង នៃក្រសួងដែនដីហេដ្ឋារចនាសម្ព័ន្ធ និងដឹកជញ្ជូន ពីឆ្នាំ២០១០ ដល់ឆ្នាំ២០១២ លោកមានតួនាទីជានាយកនៃនាយកដ្ឋានសិក្សាស្រាវជ្រាវ នៅវិទ្យាស្ថានការសិក្សាគោលនយោបាយដឹកជញ្ជូន។ ហើយនៅឆ្នាំ២០១២ ដល់ឆ្នាំ២០១៤ លោកជានាយកនៅមជ្ឈមណ្ឌលកែលម្អបរិស្ថានតំបន់ឆ្នេរ Osa Bay។ ខែឧសភា ឆ្នាំ២០១៤ ដល់ ខែមីនា ឆ្នាំ២០១៨ អ្នកជំនាញការនៅក្រសួងសាធារណការនិងដឹកជញ្ជូន នៃប្រទេសកម្ពុជា មានតួនាទីជាទីប្រឹក្សាគោលការណ៍ផ្នែកដឹកជញ្ជូន និងចាប់ពីខែមិថុនា ឆ្នាំ២០១៨ លោកមានតួនាទីជានាយកនៃនាយកដ្ឋានដឹកជញ្ជូនតាមផ្លូវសមុទ្រ។



# លោក លូ លីខេង
# សមាជិកក្រុមប្រឹក្សាភិបាល
# តំណាងនិយោជិត កសស

លោក លូ លីខេង កើតថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៧៤ សញ្ជាតិ ខ្មែរ ទីកន្លែងកំណើត ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។

- **ប្រវត្តនៃការសិក្សា**

នៅឆ្នាំ១៩៩៦ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រ លើជំនាញគីមីចំណីអាហារ។ ហើយនៅឆ្នាំ២០០៦ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ លើជំនាញពាណិជ្ជសាស្ត្រ។

- **បទពិសោធន៍ការងារ**

លោកបានចូលបម្រើការងារនៅកំពង់ផែស្វយ័តក្រុងព្រះសីហនុ នៅឆ្នាំ២០០៣ មានតួនាទីជាបុគ្គលិកកត់ត្រាទំនិញកុងតឺន័រពីទីលាន។ ហើយនៅឆ្នាំ២០០៨ ដល់ឆ្នាំ២០១១ លោកមានតួនាទីជាប្រធានផ្នែកត្រួតពិនិត្យ រៀបចំកុងតឺន័រដាក់តាម Lane។ ពីឆ្នាំ២០១១ ដល់ឆ្នាំ២០១៥ លោកទទួលបានតួនាទីជានាយករងទទួលបន្ទុករួមចាត់ចែងត្រួតពិនិត្យភារកិច្ចទូទៅ នៃនាយកដ្ឋានប្រតិបត្តិការទំនិញទូទៅ។ ចាប់ពីឆ្នាំ២០១៥ ដល់បច្ចុប្បន្ន លោកទទួលបានតួនាទីជានាយក នៃនាយកដ្ឋានប្រតិបត្តិការទំនិញទូទៅ ។

## ឃ-សេចក្តីសម្រេច និងលទ្ធផលការងាររបស់ក្រុមប្រឹក្សាភិបាល

នៅក្នុងឆ្នាំ២០១៩ នេះ ក្រុមប្រឹក្សាភិបាលមិនបានធ្វើការជួបប្រជុំទេ ដោយរង់ចាំការតែង តាំងសមាសភាពក្រុមប្រឹក្សាភិបាលថ្មី។

## ង-ការបណ្តុះបណ្តាលអភិបាល

គិតត្រឹមឆ្នាំ២០១៩ នេះ **កសស** ពុំមានការបណ្តុះបណ្តាលក្រុមប្រឹក្សាភិបាលទេ។

## ច-គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាភិបាល

### ច-១-គណៈកម្មាធិការសវនកម្ម

### ច-១-១-សមាសភាព

| ល.រ | ឈ្មោះ | តួនាទី | តំណែង | កាលបរិច្ឆេទតែងតាំង |
|---|---|---|---|---|
| ១ | លោក ហ៊ុន មុន្នីវណ្ណ | អភិបាលឯករាជ្យ | ប្រធាន | ៣០-១០-២០១៨ |
| ២ | ឯកឧត្តម សុខ សុភ័ក្ត្រ | តំណាងក្រសួងពាណិជ្ជកម្ម | អនុប្រធាន | ៣០-១០-២០១៨ |
| ៣ | លោក Hidetoshi KUME | អភិបាលតំណាងភាគហ៊ុនិកឯកជន | សមាជិក | ៣០-១០-២០១៨ |
| ៤ | លោក ព្រំ សេង | មន្ត្រីត្រួតពិនិត្យរដ្ឋ | សមាជិក | ៣០-១០-២០១៨ |
| ៥ | លោក ទី សាគុណ | នាយក បច្ចេកទេស សម្ភារៈ-សំណង់ | សមាជិក | ៣០-១០-២០១៨ |
| ៦ | លោក ម៉ែន ចាន់ | នាយក សវនកម្មផ្ទៃក្នុង | សមាជិក | ៣០-១០-២០១៨ |

### ច-១-២-សកម្មភាពការងារ

គណៈកម្មាធិការសវនកម្មបានបើកអង្គប្រជុំមួយ ស្តីពីការពិនិត្យកំណត់ហេតុប្រជុំគណៈកម្មាធិការសវនកម្ម កាលពីថ្ងៃទី ០៣ ខែមករា ឆ្នាំ២០១៩ ដោយសម្រេចបានរបៀបវារៈដូចខាងក្រោម៖

១. រៀបចំរបាយការណ៍សវនកម្មអោយបានរួចរាល់ក្នុងរយៈពេល ១៥ ថ្ងៃ បន្ទាប់ពីការបញ្ចប់ការិយបរិច្ឆេទនីមួយៗ និងត្រូវដាក់ស្នើសុំការឯកភាពពីគណៈកម្មាធិការសវនកម្ម ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងសម្រេចចុងក្រោយ។

២. រៀបចំផែនការសវនកម្មឆ្នាំ២០១៩ សម្រាប់គ្រប់នាយកដ្ឋាន ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ **កសស** និងត្រូវធ្វើសវនកម្មយ៉ាងតិច ០១ ដង/នាយកដ្ឋាន/ឆ្នាំ ។

៣. រៀបចំស្នើសុំមន្ត្រីសវនកម្មបន្ថែមចំនួន ០៥ នាក់ និងស្នើសុំធ្វើការបណ្តុះបណ្តាលរួមគ្នាជាមួយមន្ត្រីសវនកម្ម ដែលកំពុងបំពេញភារកិច្ចបន្ទាប់ពីជ្រើសរើសថ្មីត្រូវបានបញ្ចប់រួចរាល់។

៤. រាយការណ៍ជូនក្រុមប្រឹក្សាភិបាលពិនិត្យ ដើម្បីស្នើសុំរាជរដ្ឋាភិបាលកាត់បន្ថយចំនួនស្ថាប័នដែលចុះមកធ្វើសវនកម្មនៅ **កសស** ។

៥. ពិនិត្យលទ្ធភាពស្នើសុំ **កសស** បង្កើតក្រុម ឬនាយកដ្ឋានច្បាប់ និងក្រុម ឬនាយកដ្ឋានហានិភ័យ។

៦. ស្នើសុំអង្គប្រជុំបន្តពិនិត្យ និងសម្រេចលក្ខខណ្ឌ (Term of Reference) នៃលក្ខន្តិកៈរបស់គណៈកម្មាធិការសវនកម្ម ដើម្បីស្នើសុំការឯកភាព និងហត្ថលេខា **ឯកឧត្តមប្រធានក្រុមប្រឹក្សាភិបាល** ។

### ច-១-៣-បញ្ហាប្រឈម

គិតត្រឹមឆ្នាំ២០១៩ នេះ គណកម្មាធិការសវនកម្ម ពុំមានបញ្ហាប្រឈមនោះទេ។

## ច-២-គណៈកម្មាធិការគ្រប់គ្រងហានិភ័យ

### ច-២-១-សមាសភាព

| ល.រ | ឈ្មោះ | តួនាទី | តំណែង | កាលបរិច្ឆេទតែងតាំង |
|---|---|---|---|---|
| ១ | ឯកឧត្តម ផាន់ ផល្លា | តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន | ៣០-១០-២០១៨ |
| ២ | ឯកឧត្តម ស៊ុយ សាន | តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន | អនុប្រធាន | ៣០-១០-២០១៨ |
| ៣ | លោក Hidetoshi KUME | អភិបាលតំណាងភាគហ៊ុនិកឯកជន | អនុប្រធាន | ៣០-១០-២០១៨ |
| ៤ | ឯកឧត្តម សុខ សុភ័ក្រ្ត | តំណាងក្រសួងពាណិជ្ជកម្ម | សមាជិក | ៣០-១០-២០១៨ |
| ៥ | លោក ហ៊ុន មុន្នីវណ្ណ | អភិបាលឯករាជ្យ | សមាជិក | ៣០-១០-២០១៨ |
| ៦ | លោក ព្រំ សេង | មន្ត្រីត្រួតពិនិត្យរដ្ឋ | សមាជិក | ៣០-១០-២០១៨ |

### ច-២-២-សកម្មភាពការងារ

គិតត្រឹមឆ្នាំ២០១៩ នេះ គណៈកម្មាធិការហានិភ័យ ពុំទាន់មានសកម្មភាពការងារនោះទេ ។

### ច-២-៣-បញ្ហាប្រឈម

គិតត្រឹមឆ្នាំ២០១៩ នេះ គណៈកម្មាធិការហានិភ័យ ពុំមានបញ្ហាប្រឈមនោះទេ។

## ច-៣-គណៈកម្មាធិការតែងតាំង

### ច-៣-១-សមាសភាព

គិតត្រឹមឆ្នាំ២០១៩ នេះ **កសស** ពុំទាន់បានបង្កើតគណៈកម្មាធិការតែងតាំងទេ។

### ច-៣-២-សកម្មភាពការងារ

គិតត្រឹមឆ្នាំ២០១៩ នេះ គណៈកម្មាធិការតែងតាំង ពុំមានសកម្មភាពការងារនោះទេ។

### ច-៣-៣-បញ្ហាប្រឈម

គិតត្រឹមឆ្នាំ២០១៩ នេះ គណៈកម្មាធិការតែងតាំង ពុំមានបញ្ហាប្រឈមនោះទេ។

## ច-៤-គណៈកម្មាធិការផ្សេងទៀត

### ច-៤-១-សមាសភាព

គិតត្រឹមឆ្នាំ២០១៩ នេះ **កសស** ពុំទាន់បានបង្កើតគណៈកម្មាធិការផ្សេងទៀតនៅឡើយទេ។

### ច-៤-២-សកម្មភាពការងារ

គិតត្រឹមឆ្នាំ២០១៩ នេះ គណៈកម្មាធិការផ្សេងទៀត ពុំទាន់មានសកម្មភាពការងារនោះទេ។

### ច-៤-៣-បញ្ហាប្រឈម

គិតត្រឹមឆ្នាំ២០១៩ នេះ គណៈកម្មាធិការផ្សេងទៀត ពុំមានបញ្ហាប្រឈមនោះទេ។

# គ- បុគ្គលិកជាន់ខ្ពស់



## ឯកឧត្តម លូ គឹមឈន់

### ប្រធានអគ្គនាយក

### ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាប្រធានអគ្គនាយកកំពង់ផែស្វយ័តក្រុងព្រះសីហនុ

ឯកឧត្តម **លូ គឹមឈន់** កើតនៅថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៥៦ សញ្ជាតិ ខ្មែរ ទីកន្លែងកំណើត ភូមិព្រៃកពោធិ ឃុំព្រៃកពោធិ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ។

- **ប្រវត្តនៃការសិក្សា**

នៅឆ្នាំ១៩៨១ ដល់ឆ្នាំ១៩៨៦ ឯកឧត្តមបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ លើជំនាញសំណង់ក្នុងទឹក និងកំពង់ផែ នៅប្រទេសរុស្ស៊ី។ ពីឆ្នាំ២០០៤ ដល់ឆ្នាំ២០០៦ ឯកឧត្តមបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ លើជំនាញពាណិជ្ជសាស្ត្រ នៅសាកលវិទ្យាល័យជាតិគ្រប់គ្រង ប្រទេសកម្ពុជា។ ហើយពីឆ្នាំ២០០៦ ដល់ឆ្នាំ២០០៨ ឯកឧត្តមបានបញ្ចប់ថ្នាក់បណ្ឌិត លើជំនាញវិទ្យាសាស្ត្រសេដ្ឋកិច្ច នៅសាកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យា ប្រទេសកម្ពុជា។

- **បទពិសោធន៍ការងារ**

ឯកឧត្តមបានចូលបម្រើការងារនៅកំពង់ផែស្វយ័តក្រុងព្រះសីហនុ នៅក្នុងអំឡុងឆ្នាំ១៩៨៦ មានតួនាទីជាបុគ្គលិកវិស្វករសំណង់ នៃនាយកដ្ឋានបច្ចេកទេសសម្ភារៈសំណង់។ ហើយនៅឆ្នាំ១៩៩០ ដល់ឆ្នាំ១៩៩២ ឯកឧត្តមមានតួនាទីជាអនុប្រធានកំពង់ផែស្វយ័តក្រុងព្រះសីហនុ និងនៅឆ្នាំ១៩៩២ ដល់ឆ្នាំ១៩៩៩ ឯកឧត្តមមានតួនាទីជាប្រធានកំពង់ផែស្វយ័តក្រុងព្រះសីហនុ។ នៅក្នុងឆ្នាំ១៩៩៩ ដល់ឆ្នាំ២០០៨ ឯកឧត្តមទទួលបានតួនាទីជាប្រធានអគ្គនាយកកំពង់ផែក្រុងព្រះសីហនុ និងចាប់ពីឆ្នាំ២០០៨ រហូតមកដល់បច្ចុប្បន្នឯកឧត្តមជាប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាប្រធានអគ្គនាយកកំពង់ផែស្វយ័តក្រុងព្រះសីហនុ ។



# លោក ព្រុំ សេង
# មន្ត្រីត្រួតពិនិត្យរដ្ឋអមកំពង់ផែស្វយ័តក្រុងព្រះសីហនុ

លោក **ព្រុំ សេង** កើតនៅថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៦០ សញ្ជាតិ ខ្មែរ ទីកន្លែងកំណើត ឃុំស្វាយទាប ស្រុកចំការលើ ខេត្តកំពង់ចាម។

- **ប្រវត្តនៃការសិក្សា**

នៅឆ្នាំ១៩៨៥ ដល់ឆ្នាំ១៩៨៩ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រ លើជំនាញហិរញ្ញវត្ថុ-ធនាគារ នៅមហាវិទ្យាល័យហិរញ្ញវត្ថុ-គណនេយ្យ ទីក្រុងហូជីមិញ ប្រទេសវៀតណាម និងនៅឆ្នាំ២០០២ ដល់ឆ្នាំ២០០៤ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ លើជំនាញហិរញ្ញវត្ថុ-ធនាគារ នៅសាលកវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា ប្រទេសកម្ពុជា។

- **សញ្ញាបត្រផ្សេងៗ**

នៅឆ្នាំ ២០០៩ លោកបានសិក្សាវគ្គបណ្តុះបណ្តាលស្តីពីពន្ធដារកម្ពុជា។

នៅឆ្នាំ ២០១០ លោកបានសិក្សាវគ្គបណ្តុះបណ្តាលស្តីពីស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ។

នៅឆ្នាំ ២០១៤ លោកបានសិក្សាវគ្គបណ្តុះបណ្តាលស្តីពីគណនេយ្យអន្តរជាតិវិស័យសាធារណៈ។

នៅឆ្នាំ ២០១៥ លោកបានសិក្សាវគ្គបំពាក់បំប៉នស្តីពីជំនាញលទ្ធកម្មសាធារណៈ។

- **បទពិសោធន៍ការងារ**

នៅថ្ងៃទី០១ ខែមករា ឆ្នាំ១៩៩៩ រហូតមកដល់បច្ចុប្បន្ន លោកជាសាស្ត្រាចារ្យបង្រៀនផ្នែកគណនេយ្យ-ហិរញ្ញវត្ថុ នៅសកលវិទ្យាល័យ ន័រតុន និងបៀលប្រាយ។ ហើយនៅថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០០១ មកដល់បច្ចុប្បន្ននេះ លោកទទួលបានតួនាទីជាមន្ត្រីត្រួតពិនិត្យរដ្ឋអមកំពង់ផែស្វយ័តក្រុងព្រះសីហនុ។ នៅថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៦ ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៩ លោកមានតួនាទីជាសវនកម្មផ្ទៃក្នុង (អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា) ហើយលោកជាអ្នកគ្រប់គ្រង់អនុវត្តទូទៅ និងសវនកម្មហិញ្ញវត្ថុ ធ្វើហានិភ័យផ្នែកផ្សេងៗ និងសវនកម្មដទៃទៀតដែលទាក់ទងនឹងគម្រោង។



# លោក ថៃ ឫទ្ធី

## អគ្គនាយករងអាជីវកម្ម

លោក **ថៃ ឫទ្ធី** កើតនៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ១៩៧១ សញ្ជាតិ ខ្មែរ ទីកន្លែងកំណើត ភូមិព្រែកពោធិ ឃុំព្រែកពោធិ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ។

- **ប្រវត្តនៃការសិក្សា**

នៅឆ្នាំ១៩៨៦ ដល់ ឆ្នាំ១៩៨៩ លោកបានបញ្ចប់ថ្នាក់វិទ្យាល័យព្រះសីហនុ ខេត្តកំពង់ចាម ប្រទេសកម្ពុជា និងនៅឆ្នាំ១៩៩០ ដល់ ឆ្នាំ១៩៩៥ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រ ផ្នែកវិស្វករគីមីចំណីអាហារ នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ប្រទេសកម្ពុជា។ ហើយនៅឆ្នាំ២០០៥ ដល់ឆ្នាំ២០០៧ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ លើជំនាញគ្រប់គ្រងធុរកិច្ច នៅសាកលវិទ្យាល័យជាតិគ្រប់គ្រង ប្រទេសកម្ពុជា ។

- **សញ្ញាបត្រផ្សេងៗ**

នៅឆ្នាំ ១៩៩៨ លោកទទួលបានវិញ្ញាបនបត្រ លើជំនាញគ្រប់គ្រងស្ថានីយ៍កុងតឺន័រ ប្រទេសជប៉ុន។

នៅឆ្នាំ ២០០៤ លោកទទួលបានវិញ្ញាបនបត្រ Train for Trade and Development។

នៅឆ្នាំ ២០០៩ លោកទទួលបានវិញ្ញាបនបត្រ Port Management ប្រទេសសិង្ហបុរី។

- **បទពិសោធន៍ការងារ**

លោកបានចូលបម្រើការងារនៅកំពង់ផែស្វយ័តក្រុងព្រះសីហនុក្នុងអំឡុងឆ្នាំ១៩៩៥ លោកជាបុគ្គលិកនាយកដ្ឋានឃ្លាំង និងទីលាន មានតួនាទីជាអ្នកគ្រប់គ្រងស្ថិតិ។ ពីឆ្នាំ១៩៩៨ ដល់ឆ្នាំ២០០០ លោកមានតួនាទីជាប្រធានការិយាល័យគ្រប់គ្រងស្ថិតិ និងគ្រប់គ្រងសន្និធិឃ្លាំង និងទីលាន។ ហើយនៅឆ្នាំ២០០០ ដល់ឆ្នាំ២០១៥ លោកមានតួនាទីជានាយករង ទទួលបន្ទុករួមនៃនាយកដ្ឋានអាជីវកម្ម គ្រប់គ្រងកិច្ចការ Billing។ ចាប់ពីឆ្នាំ២០១៥ ដល់បច្ចុប្បន្នលោកទទួលបានតួនាទីជាអគ្គនាយករង ទទួលបន្ទុកផ្នែកអាជីវកម្ម ។



# លោក ឈុន ហុង
## អគ្គនាយករងរដ្ឋបាល-គ្រប់គ្រង

លោក **ឈុន ហុង** កើតនៅថ្ងៃទី០៧ ខែធ្នូ ឆ្នាំ១៩៥៥ សញ្ជាតិ ខ្មែរ ទីកន្លែងកំណើតនៅ ភូមិតាព្រហ្ម ឃុំព្រែកឯង ស្រុកកៀនស្វាយ ខេត្តកណ្តាល។

- **ប្រវត្តនៃការសិក្សា**

នៅឆ្នាំ២០០៣ ដល់ឆ្នាំ២០០៥ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ លើជំនាញវិទ្យាសាស្រ្តនយោបាយ នៅសាកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យា ប្រទេសកម្ពុជា។ ហើយនៅឆ្នាំ២០០៧ ដល់ឆ្នាំ២០១០ លោកបានបញ្ចប់ថ្នាក់បណ្ឌិតលើជំនាញ វិទ្យាសាស្រ្តសេដ្ឋកិច្ច នៅសាកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យា ប្រទេសកម្ពុជា។

- **បទពិសោធន៍ការងារ**

ក្នុងអំឡុងឆ្នាំ១៩៧៩ លោកបានចូលបម្រើការងារជាកម្មករនៅកំពង់ផែស្វយ័តក្រុងព្រះសីហនុ ហើយនៅឆ្នាំ១៩៨២ ដល់ឆ្នាំ១៩៨៥ លោកមានតួនាទីជាប្រធានកម្មករ។ នាឆ្នាំ១៩៨៥ ដល់ឆ្នាំ១៩៨៨ លោកជាបុគ្គលិកការិយាល័យលើកដាក់ទំនិញទូទៅ ហើយនៅឆ្នាំ១៩៨៨ ដល់ឆ្នាំ១៩៩០ លោកមានតួនាទីជាអនុប្រធានការិយាល័យលើកដាក់ទំនិញទូទៅ។ ពីឆ្នាំ១៩៩០ ដល់ឆ្នាំ២០០០ លោកមានតួនាទីជាប្រធានការិយាល័យលើកដាក់ទំនិញទូទៅ ហើយពីឆ្នាំ២០០០ ដល់ឆ្នាំ២០០៨ លោកទទួលបានតួនាទីជានាយកលើកដាក់ទំនិញទូទៅ។ នៅឆ្នាំ២០០៨ ដល់ឆ្នាំ២០១៥ លោកទទួលបានតួនាទីជានាយក នៃនាយកដ្ឋានប្រតិបត្តិការទំនិញទូទៅ គ្រប់គ្រងប្រតិបត្តិការលើកដាក់ទំនិញ ដឹកជញ្ជូនទំនិញ និងស្តុកទុក។ ចាប់ពីឆ្នាំ២០១៥ ដល់បច្ចុប្បន្ន លោកទទួលបានតួនាទីជាអគ្គនាយករង ទទួលបន្ទុកផ្នែករដ្ឋបាល-គ្រប់គ្រង។



# លោក ជា យុទ្ធឌីកា
## អគ្គនាយករងបច្ចេកទេស

លោក **ជា យុទ្ធឌីកា** កើតនៅថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៥៦ សញ្ជាតិ ខ្មែរ ទីកន្លែងកំណើត ខេត្តកំពង់ស្ពឺ។

➢ **ប្រវត្តនៃការសិក្សា**

នៅឆ្នាំ២០០៦ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រ លើជំនាញគ្រប់គ្រងសេដ្ឋកិច្ច នៅសាកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យា ប្រទេសកម្ពុជា។ ហើយនៅឆ្នាំ២០០៧ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នៅសាកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យា លើជំនាញវិទ្យាសាស្រ្តនយោបាយ ប្រទេសកម្ពុជា។

➢ **បទពិសោធន៍ការងារ**

ក្នុងអំឡុងឆ្នាំ១៩៨៣ ដល់ឆ្នាំ១៩៩៥ លោកបានចូលបម្រើការងារនៅកំពង់ផែស្វយ័តក្រុងព្រះសីហនុ មានតួនាទីជាអនុប្រធានការិយាល័យបច្ចេកទេសសម្ភារៈ និងសំណង់ ហើយនាឆ្នាំ១៩៩៥ ដល់ឆ្នាំ២០០៣ លោកមានតួនាទីជាប្រធានការិយាល័យបច្ចេកទេសសម្ភារៈ និងសំណង់ ទទួលខុសត្រូវក្នុងការគ្រប់គ្រងថែរក្សា និងផ្គត់ផ្គង់សម្ភារៈបន្លាស់ និងបរិក្ខារផ្សេងៗទៅតាមបទដ្ឋានបច្ចេកទេស។ ឆ្នាំ២០០៣ ដល់ឆ្នាំ២០១៥ លោកមានតួនាទីជានាយក នៃនាយកដ្ឋានបច្ចេកទេសសម្ភារៈ និងសំណង់ គ្រប់គ្រងពីលក្ខណៈបច្ចេកទេស គ្រឿងចក្រ ឧបករណ៍ប្រើប្រាស់ បរិក្ខារ និងលក្ខណៈបច្ចេកទេសសំណង់ ដែលចាំបាច់សម្រាប់តម្រូវការរបស់កំពង់ផែ។ ចាប់ពីឆ្នាំ២០១៥ ដល់បច្ចុប្បន្ន លោកទទួលបានតួនាទីជាអគ្គនាយករង ទទួលបន្ទុកផ្នែកបច្ចេកទេស។



## លោក រ័ត្ន សិលា
## ប្រធាននាយកដ្ឋាន
## រដ្ឋបាល-ធនធានមនុស្ស

លោក **រ័ត្ន សិលា** កើតនៅថ្ងៃទី០៩ ខែតុលា ឆ្នាំ ៩៦៩ សញ្ជាតិ ខ្មែរ ទីកន្លែងកំណើត ភូមិថ្មី ឃុំកណ្តាល ស្រុកកំពត ខេត្តកំពត។

- **ប្រវត្តនៃការសិក្សា**

នៅឆ្នាំ១៩៨៧ លោកបានបញ្ចប់ថ្នាក់វិទ្យាល័យកំពត ខេត្តកំពត ប្រទេសកម្ពុជា។ នៅឆ្នាំ២០០០ ដល់ឆ្នាំ២០០៤ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រ លើជំនាញគ្រប់គ្រងពាណិជ្ជកម្ម នៅសាកលវិទ្យាល័យបៀលប្រាយ នៅទីក្រុងភ្នំពេញ ប្រទេសកម្ពុជា។ ហើយនៅឆ្នាំ២០០៤ ដល់ឆ្នាំ២០០៧ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ លើជំនាញនីតិសាស្រ្ត នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច នៅទីក្រុងភ្នំពេញ ប្រទេសកម្ពុជា។

- **បទពិសោធន៍ការងារ**

ក្នុងអំឡុងឆ្នាំ១៩៨៧ ដល់ឆ្នាំ២០០០ លោកបានចូលបម្រើការងារនៅកំពង់ផែស្វយ័តក្រុងព្រះសីហនុ មានតួនាទីជាបុគ្គលិកការិយាល័យរដ្ឋបាល-បុគ្គលិក។ នាឆ្នាំ២០០០ ដល់ឆ្នាំ២០១០ លោកមានតួនាទីជាប្រធានផ្នែករដ្ឋបាល និងជាជំនួយការប្រធានការិយាល័យរដ្ឋបាល-បុគ្គលិក ទទួលបន្ទុកការងាររដ្ឋបាល។ ពីឆ្នាំ២០១០ ដល់ឆ្នាំ២០១៤ លោកមានតួនាទីជាប្រធានការិយាល័យរដ្ឋបាល ទទួលបន្ទុកការងារគ្រប់គ្រង រៀបចំឯកសារ និងលិខិតផ្សេងៗ ។ នៅឆ្នាំ២០១៤ ដល់ឆ្នាំ២០១៥ លោកមានតួនាទីជានាយករង នៃនាយកដ្ឋានរដ្ឋបាល-ធនធានមនុស្ស ទទួលបន្ទុកការងារទូទៅការងារក្នុងនាយកដ្ឋាន។ ចាប់ពីឆ្នាំ២០១៥ ដល់បច្ចុប្បន្ន លោកទទួលបានតួនាទីជានាយក នៃនាយកដ្ឋានរដ្ឋបាល-ធនធានមនុស្ស គ្រប់គ្រងចាត់ចែង និងសម្របសម្រួលសកម្មភាពរដ្ឋបាលគ្រប់ផ្នែក។



# លោក ប៉ាត សិត
# ប្រធាននាយកដ្ឋាន
# គណនេយ្យ-ហិរញ្ញវត្ថុ

លោក **ប៉ាត សិត** កើតនៅថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ១៩៥៨ សញ្ជាតិ ខ្មែរ ទីកន្លែងកំណើត ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល។

➢ **ប្រវត្តនៃការសិក្សា**

នៅឆ្នាំ១៩៦៥ ដល់ឆ្នាំ១៩៧៥ លោកបានបញ្ចប់ថ្នាក់វិទ្យាល័យនៅស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ។ នាឆ្នាំ១៩៩៤ លោកទទួលនបានវិញ្ញាបនបត្របញ្ជាក់ការសិក្សាវគ្គ គណនេយ្យអ៊ឺរ៉ុប នៅក្រសួងសាធារណៈការ និងដឹកជញ្ជូន។ ពីឆ្នាំ២០០៦ ដល់ឆ្នាំ២០០៧ លោកទទួលបានវិញ្ញាបនបត្របញ្ជាក់ការសិក្សាវគ្គវិក្រិត ការនៅក្រសួងសាធារណៈការ និងដឹកជញ្ជូន។ ហើយនៅឆ្នាំ២០០៥ ដល់ឆ្នាំ២០០៧ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ លើជំនាញរដ្ឋបាលសាធារណៈ នៅសាកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យា ប្រទេសកម្ពុជា។

➢ **បទពិសោធន៍ការងារ**

ក្នុងអំឡុងឆ្នាំ១៩៩០ ដល់ឆ្នាំ២០០៦ លោកបានចូលបម្រើការងារនៅកំពង់ផែស្វយ័តក្រុងព្រះសីហនុ មានតួនាទីជាអនុប្រធានគណនេយ្យ។ ពីឆ្នាំ២០០៧ ដល់ឆ្នាំ២០១០ លោកមានតួនាទីជាប្រធានការិយាល័យគណនេយ្យ និងជាជំនួយការលោកនាយកគណនេយ្យ-ហិរញ្ញវត្ថុ ទទួលបន្ទុកការងារគណនេយ្យ។ នៅឆ្នាំ២០១០ ដល់ឆ្នាំ២០១៥ លោកមានតួនាទីជានាយករងគណនេយ្យ-ហិរញ្ញវត្ថុ ទទួលបន្ទុករួមគ្រប់គ្រងការងារទូទៅក្នុងនាយកដ្ឋាន និងជាជំនួយការលោកនាយកគណនេយ្យ-ហិរញ្ញវត្ថុ។ ពីឆ្នាំ២០១៥ ដល់បច្ចុប្បន្ន លោកទទួលបានតួនាទីជានាយក នៃនាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ ។



# លោក សូ សៀង
# ប្រធាននាយកដ្ឋាន
# ផែនការ-លទ្ធកម្ម និងស្ថិតិ

លោក **សូ សៀង** កើតនៅថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧៥ សញ្ជាតិ ខ្មែរ។

➢ **ប្រវត្តិនៃការសិក្សា**

នាឆ្នាំ១៩៨០ ដល់ឆ្នាំ១៩៩២ លោកបានបញ្ចប់ថ្នាក់វិទ្យាល័យ នៅវិទ្យាល័យស្រីសន្ធរ ខេត្តកំពង់ចាម ។ នៅឆ្នាំ១៩៩២ ដល់ឆ្នាំ១៩៩៧ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រ នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ លើជំនាញអក្សរសាស្ត្រ និងមនុស្សសាស្ត្រ ប្រទេសកម្ពុជា។ ពីឆ្នាំ១៩៩៧ ដល់ឆ្នាំ២០០១ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រលើជំនាញនិតិសាធារណៈ នៅសាកលវិទ្យាល័យន័រតុន ប្រទេសកម្ពុជា។ ហើយនៅឆ្នាំ២០០១ ដល់ឆ្នាំ២០០៣ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ លើជំនាញនិតិសាធារណៈ នៅសាកលវិទ្យាល័យបៀលប្រាយប្រទេសកម្ពុជា។

➢ **បទពិសោធន៍ការងារ**

នៅអំឡុងឆ្នាំ១៩៩៨ ដល់ឆ្នាំ២០០២ លោកបានចូលបម្រើការងារជាមន្ត្រីនៅកំពង់ផែស្ងួតភ្នំពេញ CWT ។ ពីឆ្នាំ២០០២ ដល់ឆ្នាំ២០០៥ លោកមានតួនាទីជានាយករងនៃនាយកដ្ឋានផែស្ងួតភ្នំពេញ ទទួលបន្ទុកប្រតិបត្តិការទូទៅឃ្លាំងទំនិញ។ នៅឆ្នាំ២០០៥ ដល់ឆ្នាំ២០១០ លោកមានតួនាទីជានាយកនៃនាយកដ្ឋានផែស្ងួតភ្នំពេញ។ ហើយនៅឆ្នាំ២០១០ ដល់ឆ្នាំ២០១៥ លោកមានតួនាទីជានាយករងនៃនាយកដ្ឋានសវនកម្មផ្ទៃក្នុង។ ចាប់ពីឆ្នាំ២០១៥ ដល់បច្ចុប្បន្ន លោកទទួលបានតួនាទីជានាយក នៃនាយកដ្ឋានផែនការ-លទ្ធកម្ម និងស្ថិតិ ។



# លោក ទី សាគុណ
## ប្រធាននាយកដ្ឋាន
## បច្ចេកទេសសម្ភារៈ-សំណង់

លោក **ទី សាគុណ** កើតនៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ១៩៦០ សញ្ជាតិ ខ្មែរ ទីកន្លែងកំណើត ភូមិព្រៃគារ ឃុំកំពង់ចក ស្រុករំដួល ខេត្តស្វាយរៀង ។

- **ប្រវត្តនៃការសិក្សា**

នៅឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៨២ លោកបានបញ្ចប់ថ្នាក់វិទ្យាល័យ នៅវិទ្យាល័យដូនពេញ ទីក្រុងភ្នំពេញ ប្រទេសកម្ពុជា។ នៅឆ្នាំ១៩៨២ ដល់ឆ្នាំ១៩៨៨ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រ លើជំនាញវិស្វករសំណង់ផ្លូវទឹក និងកំពង់ផែ នៅសាកលវិទ្យាល័យបច្ចេកទេស ទីក្រុង DRESDEN ប្រទេសអាល្លឺម៉ង់។ ហើយលោកបានបញ្ចប់ថ្នាក់បរិញ្ញា បត្រជាន់ខ្ពស់នៅឆ្នាំ២០០៦ លើជំនាញពាណិជ្ជសាស្ត្រ នៅសាកលវិទ្យាល័យជាតិគ្រប់គ្រង ប្រទេសកម្ពុជា។

- **បទពិសោធន៍ការងារ**

ក្នុងអំឡុងឆ្នាំ១៩៨៨ ដល់ឆ្នាំ១៩៩១ លោកបានចូលបម្រើការងារជាមន្ត្រីវិស្វករ នៃនាយយកដ្ឋានបច្ចេកទេស-វិទ្យាសាស្ត្រ នៅក្រសួងគមនាគមន៍,ដឹកជញ្ជូន និងប្រៃសណីយ៍។ នៅឆ្នាំ១៩៩២ ដល់ឆ្នាំ១៩៩៣ លោកមានតួនាទីជាលេខាផ្ទាល់ ឯកឧត្តម សូរ យុន រដ្ឋមន្ត្រីក្រសួងគមនាគមន៍,ដឹកជញ្ជូន និងប្រៃសណីយ៍។ ហើយនៅឆ្នាំ១៩៩៣ ដល់ឆ្នាំ១៩៩៧ លោកបានចូលមកបម្រើការងារនៅកំពង់ផែស្វយ័តក្រុងព្រះសីហនុវិញ ដែលមានតួនាទីជាមន្ត្រីវិស្វករ សេវាដ្ឋានបច្ចេកទេស សម្ភារៈ និងសំណង់។ ពីឆ្នាំ១៩៩៧ ដល់ឆ្នាំ២០១១ លោកមានតួនាទីជាប្រធានការិយាល័យសំណង់ នៃនាយកដ្ឋានបច្ចេកទេសសម្ភារៈ-សំណង់។ ឆ្នាំ២០១១ ដល់ឆ្នាំ២០១៥ លោកមានតួនាទីជានាយករង នៃនាយកដ្ឋានបច្ចេកទេសសម្ភារៈ-សំណង់ និងទទួលខុសត្រូវខាងផ្នែកបច្ចេកទេសទូទៅ។ ចាប់ពីឆ្នាំ២០១៥ ដល់បច្ចុប្បន្ន លោកទទួលបានតួនាទីជានាយក នៃនាយកដ្ឋានបច្ចេកទេសសំភារ:-សំណង់ នៅកំពង់ផែស្វយ័តក្រុងព្រះសីហនុ។



# លោកស្រី ជ័យ សុគន្ធា
## នាយិកាទីផ្សារ

លោកស្រី **ជ័យ សុគន្ធា** កើតនៅថ្ងៃទី០៥ ខែឧសភា ឆ្នាំ១៩៧៥ សញ្ជាតិ ខ្មែរ ទីកន្លែងកំណើត ឃុំទឹកល្អក់ ស្រុកកំពត ខេត្រកំពត ។

➢ **ប្រវត្តនៃការសិក្សា**

នៅឆ្នាំ១៩៨៦ ដល់ឆ្នាំ១៩៩១ លោកស្រីបានបញ្ចប់ថ្នាក់វិទ្យាល័យ នៅវិទ្យាល័យក្រុងព្រះសីហនុ ប្រទេសកម្ពុជា។ នៅឆ្នាំ២០០១ ដល់ឆ្នាំ២០០៤ លោកស្រីបានបញ្ចប់ថ្នាក់បរិញ្ញាបត្រ លើជំនាញគ្រប់គ្រងពាណិជ្ជកម្ម នៅសាកលវិទ្យាល័យវ៉េនលែន ខេត្តព្រះសីហនុ ប្រទេសកម្ពុជា។ ហើយនៅឆ្នាំ២០០៥ ដល់ឆ្នាំ២០០៧ លោកស្រីបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ លើជំនាញគ្រប់គ្រងពាណិជ្ជកម្ម នៅសាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច ប្រទេសកម្ពុជា។

➢ **សញ្ញាបត្រផ្សេងៗ**

នៅឆ្នាំ២០១៥ លោកស្រីបានទៅសិក្សាវគ្គ Women in Port management, France ។

នៅឆ្នាំ២០១៦ ដល់ឆ្នាំ២០១៧ លោកស្រីបានទៅសិក្សាវគ្គ Modern Port Management, UNCTAD, Ireland ។

➢ **បទពិសោធន៍ការងារ**

នៅក្នុងអំឡុងឆ្នាំ២០០២ ដល់ឆ្នាំ២០០៥ លោកស្រីបានចូលបម្រើការងារនៅកំពង់ផែស្វយ័តក្រុងព្រះសីហនុ មានតួនាទីជាបុគ្គលិកនាយកដ្ឋានប្រតិបត្តិការទីលានកុងតឺន័រ ទទួលបន្ទុកគ្រប់គ្រងការងារឯកសារនៅឃ្លាំង និងទីលានសម្រាប់សេវាស្តុកទំនិញកុងតឺន័រ។ ពីឆ្នាំ២០០៥ ដល់ឆ្នាំ២០១០ លោកស្រីមានតួនាទីជាបុគ្គលិក នៃនាយកដ្ឋានទីផ្សារ ទទួលបន្ទុកផ្នែកសេវាកម្មផ្សព្វផ្សាយ ទំនាក់ទំនងអតិថិជន ការអភិវឌ្ឍន៍ និងស្រាវជ្រាវផ្នែកទីផ្សារ។ នៅឆ្នាំ២០១០ ដល់ឆ្នាំ២០១៤ លោកស្រីមានតួនាទីជានាយិការង នៃនាយកដ្ឋានទីផ្សារ ទទួលបន្ទុកជាអ្នកសម្របសម្រួលទទួលភ្ញៀវ និងចម្ងល់របស់អតិថិជន។ ពីឆ្នាំ២០១៤ ដល់ឆ្នាំ២០១៥ លោកស្រីមានតួនាទីជានាយិការង ទទួលបន្ទុករួមនៃនាយកដ្ឋានទីផ្សារ ទទួលបន្ទុកផ្នែកផ្សព្វផ្សាយ និងជម្រុញការលើកកម្ពស់គុណភាព សេវាកម្ម របស់ **កសស** និងជួបប្រជុំសំខាន់ផ្សេងៗ ។ ចាប់ពីឆ្នាំ២០១៥ ដល់បច្ចុប្បន្ន លោកស្រីទទួលបានតួនាទីជានាយិកា នៃនាយកដ្ឋានទីផ្សារ ។



# លោក ជីវ ច័ន្ទសុផល
## ប្រធាននាយកដ្ឋាន
## តំបន់សេដ្ឋកិច្ចពិសេស

លោក **ជីវ ច័ន្ទសុផល** កើតនៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៧៦ សញ្ជាតិ ខ្មែរ ទីកន្លែងកំណើត សង្កាត់លេខ៣ រាជធានីភ្នំពេញ។

- **ប្រវត្តនៃការសិក្សា**

នៅឆ្នាំ១៩៨៩ ដល់ឆ្នាំ១៩៩២ លោកបានបញ្ចប់ការសិក្សាថ្នាក់វិទ្យាល័យ នៅវិទ្យាល័យក្រុងព្រះសីហនុ ប្រទេសកម្ពុជា។ នៅឆ្នាំ១៩៩៣ ដល់ឆ្នាំឆ្នាំ២០០០ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រស្ថាបត្យកម្ម លើជំនាញស្ថាបត្យកម្ម និងនគរូបនីយកម្ម នៅរាជធានីភ្នំពេញ ប្រទេសកម្ពុជា ។

- **សញ្ញាបត្រផ្សេងៗ**

នៅឆ្នាំ២០០៩ លោកបានទៅសិក្សា Certificate on Sustainable Port Development and Planning, Yokohama ប្រទេសជប៉ុន។

នៅឆ្នាំ២០១១ ដល់ឆ្នាំ២០១៣ លោកបានសិក្សាវគ្គមធ្យមសិក្សា ផ្នែកហិរញ្ញវត្ថុ និងវិនិយោគ នៅរាជធានីភ្នំពេញ ប្រទេសកម្ពុជា។

នៅឆ្នាំ២០១៣ លោកបានទៅសិក្សាវគ្គ Certificate on Strategic Port Administration and Management, Yokohama ប្រទេសជប៉ុន។

នៅឆ្នាំ២០១៧ លោកបានទៅសិក្សាថ្នាក់វិញ្ញាបនបត្រ នៅទីក្រុង Tokyo ប្រទេសជប៉ុន លើជំនាញ Promoting Foreign Direct Investment For SEZ ។

**បទពិសោធន៍ការងារ**

ក្នុងអំឡុងឆ្នាំ២០០០ ដល់ឆ្នាំ២០០៣ លោកបានចូលបម្រើការងារនៅកំពង់ផែស្វយ័តក្រុងព្រះសីហនុ មានតួនាទីជាបុគ្គលិកនៅនាយកដ្ឋានបច្ចេកទេស-សម្ភារៈ និងសំណង់។ នៅឆ្នាំ២០០៣ ដល់ឆ្នាំ២០០៩ លោកមានតួនាទីជាបុគ្គលិកស្ថាបត្យករ និងបច្ចេកទេសកំពង់ផែ។ ពីឆ្នាំ២០១០ ដល់ឆ្នាំ២០១៤ លោកមានតួនាទីជានាយករង នៃនាយកដ្ឋានសវនកម្មផ្ទៃក្នុង ទទួលបន្ទុកត្រួតពិនិត្យលើប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង និងលើប្រតិបត្តិការរបស់កំពង់ផែ។ ឆ្នាំ២០១២ ដល់ឆ្នាំ២០១៤ លោកទទួលបន្ទុកផ្នែក Project supervisor នៃអង្គភាពគ្រប់គ្រងគំរោង (PMU) និងនៅឆ្នាំ២០១៤ ដល់ឆ្នាំ២០១៨ លោកទទួលបន្ទុកផ្នែកTechnical Team supervisor នៃអង្គភាពគ្រប់គ្រងគំរោង (PMU) ។ ពីឆ្នាំ២០១៤ ដល់ឆ្នាំ២០១៥ លោកមានតួនាទីជានាយករងទទួលបន្ទុករួមសម្របសម្រួលការងារក្នុងតំបន់ និងពង្រីកសក្តានុពលវិនិយោគ នៃនាយកដ្ឋានតំបន់សេដ្ឋកិច្ចពិសេស។ ចាប់ពីឆ្នាំ២០១៥ ដល់បច្ចុប្បន្នលោកទទួលបានតួនាទីជានាយក នៃនាយកដ្ឋានតំបន់សេដ្ឋកិច្ចពិសេស កំពង់ផែស្វយ័តក្រុងព្រះសីហនុ។



# លោក ពិត ប្រាកដ
# ប្រធាននាយកដ្ឋាន
# អាជីវកម្ម

លោក **ពិត ប្រាកដ** កើតនៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៧៤ សញ្ជាតិ ខ្មែរ ទីកន្លែងកំណើត សង្កាត់លេខ ៥ ក្រុងភ្នំពេញ។

➢ **ប្រវត្តនៃការសិក្សា**

នៅឆ្នាំ១៩៨៤ ដល់ឆ្នាំ១៩៩០ លោកបានបញ្ចប់ថ្នាក់វិទ្យាល័យ នៅសាលាមធ្យមសិក្សាទួលទំពូង ប្រទេសកម្ពុជា។ នៅឆ្នាំ១៩៩៩ ដល់ឆ្នាំ២០០៣ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រ លើជំនាញវិទ្យាសាស្ត្រសេដ្ឋកិច្ច នៅសាកលវិទ្យាល័យន័រតុន ប្រទេសកម្ពុជា។ ហើយនៅឆ្នាំ២០០៤ ដល់ឆ្នាំ២០០៧ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ លើជំនាញគ្រប់គ្រងពាណិជ្ជកម្ម នៅសាកលវិទ្យាល័យ បៀលប្រាយ ប្រទេសកម្ពុជា ប្រទេសកម្ពុជា។

➢ **បទពិសោធន៍ការងារ**

ក្នុងអំឡុងឆ្នាំ១៩៩២ ដល់ឆ្នាំ២០០០ លោកបានចូលបម្រើការងារជាបុគ្គលិកការិយាល័យរដ្ឋបាល-បុគ្គលិក នៅកំពង់ផែស្វយ័តក្រុងព្រះសីហនុ។ នាឆ្នាំ២០០០ ដល់ឆ្នាំ២០១០ លោកមានតួនាទីជាប្រធានផ្នែកបណ្តុះបណ្តាល មានតួនាទីរៀបចំប្រាក់បៀវត្សរ៍ និងបណ្តុះបណ្តាលបុគ្គលិក កម្មករ និងជាជំនួយការលោកប្រធានការិយាល័យរដ្ឋបាល-ធនធានមនុស្ស។ ពីឆ្នាំ២០១០ ដល់ឆ្នាំ២០១៤ លោកមានតួនាទីជាប្រធានការិយាល័យធនធានមនុស្ស និងព័ត៌មានវិទ្យា ទទួលបន្ទុកគ្រប់គ្រងការងារ IT ប្រព័ន្ធ SWSS, Server, Email, Network។ នៅឆ្នាំ២០១៤ ដល់ឆ្នាំ២០១៥ លោកមានតួនាទីជានាយករង នៃនាយកដ្ឋានរដ្ឋបាល-ធនធានមនុស្ស ទទួលបន្ទុកកសាងផែនការអាជីវកម្ម សេវាកម្ម ហិរញ្ញវត្ថុ គ្រប់គ្រងធនធានមនុស្ស ប្រាក់បៀវត្សរ៍ និងបណ្តុះបណ្តាលបុគ្គលិក កម្មករ គ្រប់គ្រងប្រព័ន្ធ IT, CTMS, SESS, CCTV, VTMS ។ នៅខែកម្ភៈ ដល់ខែធ្នូ ឆ្នាំ២០១៥ លោកមានតួនាទីជានាយករងនៃនាយកដ្ឋានអាជីវកម្ម ទទួលបន្ទុករួមកសាងតម្លៃ Port Tariff និងយុទ្ធសាស្ត្រ Logistic គិតប្រាក់គ្រប់ប្រភេទជាមួយ Shipping Line ។ ចាប់ពីឆ្នាំ២០១៥ ដល់បច្ចុប្បន្ន លោកទទួលបានតួនាទីជានាយក នៃនាយកដ្ឋានអាជីវកម្ម។



# លោក ស្រី ណារិទ្ធ
# ប្រធាននាយកដ្ឋាន
# ប្រតិបត្តិការទីលានកុងតឺន័រ

លោក **ស្រី ណារិទ្ធ** កើតនៅថ្ងៃទី០៥ ខែកក្កដា ឆ្នាំ១៩៥៦ សញ្ជាតិ ខ្មែរ ទីកន្លែងកំណើត ភូមិបញ្ញាជី ឃុំត្បូងក្រពើ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ។

- **ប្រវត្តនៃការសិក្សា**

នៅឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥ លោកបានបញ្ចប់ថ្នាក់វិទ្យាល័យ នៅខេត្តកំពង់ធំ ប្រទេសកម្ពុជា។ ពីឆ្នាំ២០០៣ ដល់ឆ្នាំ២០០៥ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រ លើជំនាញរដ្ឋបាលសាធារណៈ នៅសាកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យា ប្រទេសកម្ពុជា។ ហើយចាប់ពីឆ្នាំ២០០៥ ដល់ឆ្នាំ២០០៧ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកវិទ្យាសាស្ត្រនយោបាយ នៅសាកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យា ប្រទេសកម្ពុជា។

- **សញ្ញាបត្រផ្សេងៗ**

លោកបានទៅសិក្សាថ្នាក់បរិញ្ញាបត្រគ្រប់គ្រងទីលានកុងតឺន័រ ប្រទេសសិង្ហបុរី ។

- **បទពិសោធន៍ការងារ**

ក្នុងអំឡុងឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៨០ លោកបានចូលបម្រើការងារនៅកំពង់ផែស្វយ័តក្រុងព្រះសីហនុ មានតួនាទីជាប្រធានកងកម្មករទី៦ ទទួលបន្ទុកត្រួតពិនិត្យតាមដានតោនលើកដាក់របស់កម្មករ។ នាឆ្នាំ១៩៨០ ដល់ឆ្នាំ១៩៨៧ លោកមានតួនាទីជាបុគ្គលិកការិយាល័យគណនេយ្យ ទទួលបន្ទុកកាន់ស្តុកឃ្លាំងទំនិញ។ នៅឆ្នាំ១៩៨៧ ដល់១៩៨៩ លោកមានតួនាទីជាប្រធានការិយាល័យឃ្លាំងទំនិញកំពង់ផែ ទទួលបន្ទុកគ្រប់គ្រង និងអនុវត្តក្នុងការថែរក្សាទំនិញក្នុងឃ្លាំង។ ពីឆ្នាំ១៩៨៩ ដល់បច្ចុប្បន្ន លោកទទួលបានតួនាទីជានាយក នៃនាយកដ្ឋានប្រតិបត្តិការទីលានកុងតឺន័រ។



# លោក លូ លីខេង
# ប្រធាននាយកដ្ឋាន ប្រតិបត្តិការទំនិញទូទៅ

លោក **លូ លីខេង** កើតថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៧៤ សញ្ជាតិ ខ្មែរ ទីកន្លែងកំណើត ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។

➢ **ប្រវត្តនៃការសិក្សា**

នៅឆ្នាំ១៩៩៦ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រ លើជំនាញគីមីចំណីអាហារ។ ហើយនៅឆ្នាំ២០០៦ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ លើជំនាញពាណិជ្ជសាស្រ្ត។

➢ **បទពិសោធន៍ការងារ**

លោកបានចូលបម្រើការងារនៅកំពង់ផែស្វយ័តក្រុងព្រះសីហនុ នៅឆ្នាំ២០០៣ ជាបុគ្គលិកកត់ត្រាទំនិញកុងតឺន័រពីទីលាន។ ហើយនៅឆ្នាំ២០០៨ ដល់ឆ្នាំ២០១១ លោកមានតួនាទីជាប្រធានផ្នែកត្រួតពិនិត្យរៀបចំកុងតឺន័រដាក់តាម Lane។ ពីឆ្នាំ២០១១ ដល់ឆ្នាំ២០១៥ លោកទទួលបានតួនាទីជានាយករង ទទួលបន្ទុករួមចាត់ចែងត្រួតពិនិត្យភារកិច្ចទូទៅ នៃនាយកដ្ឋានប្រតិបត្តិការទំនិញទូទៅ។ ចាប់ពីឆ្នាំ២០១៥ ដល់បច្ចុប្បន្ន លោកទទួលបានតួនាទីជានាយក នៃនាយកដ្ឋានប្រតិបត្តិការទំនិញទូទៅ ។



# លោក ថោង វីរ៉ូ
# ប្រធាននាយកដ្ឋាន
# នាវាចរ-កណ្ណធារ

លោក **ថោង វីរ៉ូ** កើតនៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ១៩៦៨ សញ្ជាតិ ខ្មែរ ទីកន្លែងកំណើត ទីក្រុងភ្នំពេញ ។

➢ **ប្រវត្តនៃការសិក្សា**

នៅឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៨២ លោកបានបញ្ចប់ថ្នាក់វិទ្យាល័យ នៅទីក្រុងភ្នំពេញ ប្រទេសកម្ពុជា។ នៅឆ្នាំ១៩៩៨២ ដល់ឆ្នាំ១៩៨៧ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រ លើជំនាញបើកនាវា ប្រទេសរុស្សី។ ហើយនៅឆ្នាំ២០០៤ ដល់ឆ្នាំ២០០៥ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ លើជំនាញគ្រប់គ្រង នៅវិទ្យាស្ថាន RIT ប្រទេសថៃ។

➢ **បទពិសោធន៍ការងារ**

ក្នុងអំឡុងឆ្នាំ ១៩៨៨ ដល់ឆ្នាំ២០០៤ លោកបានចូលបម្រើការងារនៅកំពង់ផែស្វយ័តក្រុងព្រះសីហនុ មានតួនាទីជាបុគ្គលិកកណ្ណធារ នាំនាវាចេញ-ចូលកំពង់ផែ។ នាឆ្នាំ២០០៤ ដល់ឆ្នាំ២០១០ លោកមានតួនាទីជាប្រធានការិយាល័យសន្តិសុខ និងកណ្ណធារ ទទួលបន្ទុកគ្រប់គ្រងសន្តិសុខ និងនាំនាវាចេញ-ចូល។ ពីឆ្នាំ២០១០ ដល់ឆ្នាំ២០១៣ លោកមានតួនាទីជានាយករងរដ្ឋបាល-ធនធានមនុស្ស និងកណ្ណធារ ទទួលបន្ទុកការងារសន្តិសុខ និងនាំនាវាចេញ-ចូល។ នៅឆ្នាំ២០១៣ ដល់ឆ្នាំ២០១៤ លោកមានតួនាទីជានាយករង ទទួលរួមនៃនាយកដ្ឋាននាវាចរ-កណ្ណធារ គ្រប់គ្រងទូទៅនៃនាយកដ្ឋាននាវាចរ និងគ្រប់គ្រងសន្តិសុខ។ ចាប់ពីឆ្នាំ២០១៤ ដល់បច្ចុប្បន្នលោកទទួលបានតួនាទីជានាយក នៃនាយកដ្ឋាននាវាចរ-កណ្ណធារ។



# លោក នាក់ សុហ៊ីយ៉ាន
## ប្រធាននាយកដ្ឋាន
## គ្រឿងចក្រ

លោក **នាក់ សុហ៊ីយ៉ាន** កើតនៅថ្ងៃទី៣១ ខែមីនា ឆ្នាំ១៩៥៨ សញ្ជាតិ ខ្មែរ ទីកន្លែងកំណើត ភូមិកំពង់លួង ឃុំកំពង់លួង ស្រុកពញាឮ ខេត្តកណ្តាល។

- **ប្រវត្តិនៃការសិក្សា**

នៅឆ្នាំ១៩៦៧ ដល់ឆ្នាំ១៩៧៣ លោកបានបញ្ចប់ថ្នាក់វិទ្យាល័យ នៅវិទ្យាល័យបឹងត្របែក ប្រទេសកម្ពុជា។ នៅឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៨២ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រ លើជំនាញគ្រប់គ្រងពាណិជ្ជកម្ម នៅសាកលវិទ្យាល័យ OLLU, Texas សហរដ្ឋអាមេរិក។ ឆ្នាំ១៩៨៤ ដល់ឆ្នាំ១៩៨៥ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ លើជំនាញគ្រប់គ្រងពាណិជ្ជកម្ម នៅសាកលវិទ្យាល័យ Troy State, Alabama សហរដ្ឋអាមេរិក។ ហើយនៅឆ្នាំ១៩៨៥ ដល់ឆ្នាំ១៩៨៧ លោកបានបញ្ចប់ថ្នាក់បណ្ឌិត លើជំនាញគ្រប់គ្រងរដ្ឋបាលសាធារណៈ នៅសាកលវិទ្យាល័យ Troy State, Alabama សហរដ្ឋអាមេរិក។

- **បទពិសោធន៍ការងារ**

នៅក្នុងអំឡុងឆ្នាំ២០០៦ ដល់ឆ្នាំ២០០៩ លោកបានចូលបម្រើការងារនៅកំពង់ផែស្វយ័តក្រុងព្រះសីហនុ មានតួនាទីជាប្រធានការិយាល័យ ទទួលបន្ទុកគ្រប់គ្រងបណ្ណាល័យនៃនាយកដ្ឋានរដ្ឋបាល-ធនធានមនុស្ស ។ ពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១១ លោកមានតួនាទីជាប្រធានការិយាល័យសិក្សាស្រាវជ្រាវ នៃនាយកដ្ឋានគ្រឿងចក្រ។ ពីឆ្នាំ២០១១ ដល់ឆ្នាំ២០១៥ លោកមានតួនាទីជានាយករងទទួលបន្ទុករួម នៃនាយកដ្ឋានគ្រឿងចក្រ។ ចាប់ពីឆ្នាំ២០១៥ ដល់បច្ចុប្បន្ន លោកទទួលបានតួនាទីជានាយក នៃនាយកដ្ឋានគ្រឿងចក្រ។



# លោក ម៉ែន ចាន់
## ប្រធាននាយកដ្ឋាន
## សវនកម្មផ្ទៃក្នុង

លោក **ម៉ែន ចាន់** កើតនៅថ្ងៃទី០៣ ខែឧសភា ឆ្នាំ១៩៦៨ សញ្ជាតិ ខ្មែរ ទីកន្លែងកំណើត ឃុំកុមាររាជា ស្រុកបាទី ខេត្តតាកែវ ។

➤ **ប្រវត្តិនៃការសិក្សា**

នៅឆ្នាំ១៩៨២ ដល់ឆ្នាំ១៩៨៨ លោកបានបញ្ចប់ថ្នាក់វិទ្យាល័យ នៅវិទ្យាល័យសន្ធរម៉ុក ភ្នំពេញ ប្រទេសកម្ពុជា។ នៅឆ្នាំ២០០១ ដល់ឆ្នាំ២០០៥ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រ លើជំនាញគ្រប់គ្រងពាណិជ្ជកម្ម នៅសាកលវិទ្យាល័យបៀលប្រាយ ខេត្តព្រះសីហនុ ប្រទេសកម្ពុជា។ ហើយនៅឆ្នាំ២០០៥ ដល់ឆ្នាំ២០០៨ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ លើជំនាញគ្រប់គ្រងពាណិជ្ជកម្ម នៅសាកលវិទ្យាល័យបៀលប្រាយ ខេត្តព្រះសីហនុ ប្រទេសកម្ពុជា ។

➤ **សញ្ញាបត្រផ្សេងៗ**

នៅឆ្នាំ១៩៩៩ លោកបានទៅសិក្សា Certificate - Port Administration & Management, Japan។

នៅថ្ងៃទី០២ ខែតុលា ឆ្នាំ២០០៥ លោកបានទៅសិក្សា Certificate - Port Facility Security, Japan ។

នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៥ លោកបានទៅសិក្សា Certificate UNCTAD Port Training Program ។

➤ **បទពិសោធន៍ការងារ**

ក្នុងអំឡុងឆ្នាំ១៩៨៨ ដល់ឆ្នាំ១៩៩៥ លោកបានចូលបម្រើការងារនៅកំពង់ផែស្វយ័តក្រុងព្រះសីហនុ មានតួនាទីជាបុគ្គលិកនាយកដ្ឋានឃ្លាំងទំនិញ។ ពីឆ្នាំ១៩៩៥ ដល់ឆ្នាំ១៩៩៩ លោកមានតួនាទីជាបុគ្គលិកនាយកដ្ឋានរដ្ឋបាល-បុគ្គលិក បកប្រែភាសាអង់គ្លេស។ ពីឆ្នាំ១៩៩៩ ដល់ឆ្នាំ២០០៩ លោកមានតួនាទីជាបុគ្គលិកនាយកដ្ឋានរដ្ឋបាល-បុគ្គលិក និងជាជំនួយការផ្ទាល់ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល។ នៅឆ្នាំ២០១០ លោកមានតួនាទីជាប្រធានការិយាល័យ សវនកម្មផ្ទៃក្នុង។ នៅឆ្នាំ២០១៤ លោកមានតួនាទីជានាយករង នៃនាយកដ្ឋានសវនកម្មផ្ទៃក្នុង។ ពីឆ្នាំ២០១៥ ដល់បច្ចុប្បន្ន លោកទទួលបានតួនាទីជានាយក នៃនាយកដ្ឋានសវនកម្មផ្ទៃក្នុង និងជាជំនួយការផ្ទាល់ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាប្រធានអគ្គនាយក។



# លោក សោម ករណី
# ប្រធាននាយកដ្ឋាន
# ព័ត៌មានវិទ្យា

លោក **សោម ករណី** កើតនៅថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៨៣ សញ្ជាតិខ្មែរ ទីកន្លែងកំណើត ភូមិ៣ សង្កាត់៣ ខណ្ឌមិត្តភាព ខេត្តព្រះសីហនុ។

- **ប្រវត្តនៃការសិក្សា**

នៅឆ្នាំ១៩៩៩ លោកបានបញ្ចប់ថ្នាក់វិទ្យាល័យ នៅវិទ្យាល័យក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ប្រទេសកម្ពុជា។ នៅឆ្នាំ២០០៣ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រ លើជំនាញភាសាអង់គ្លេស នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ នៅឆ្នាំ២០០៣ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រ លើជំនាញធានាគារហិរញ្ញវត្ថុ នៅវិទ្យាស្ថានជាតិគ្រប់គ្រងហើយនៅឆ្នាំ២០០៥ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ វិស្វករកុំព្យូទ័រ នៅសាកលវិទ្យាល័យ Assumption University ប្រទេសថៃ។

- **សញ្ញាបត្រផ្សេងៗ**

នៅឆ្នាំ២០០៧ លោកបានបញ្ចប់ការសិក្សា Certificate – Port Facility Security Japan។

នៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១១ លោកបានបញ្ចប់ការសិក្សា Certificate –Sustainable Port Development Japan ។

នៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៧ លោកបានបញ្ចប់ការសិក្សា Advanced Open Water Diver 30m Depth ។

- **បទពិសោធន៍ការងារ**

ក្នុងអំឡុងឆ្នាំ២០០៦ លោកបានចូលបម្រើការងារនៅកំពង់ផែស្វយ័តក្រុងព្រះសីហនុ មានតួនាទីជាបុគ្គលិករដ្ឋបាលធនធានមនុស្ស។ ពីឆ្នាំ២០១០លោកមានតួនាទីប្រធានផ្នែកព័ត៌មានវិទ្យា។ ពីឆ្នាំ២០១៨ ដល់បច្ចុប្បន្ន លោកទទួលបានតួនាទីជានាយក នៃនាយកដ្ឋានព័ត៌មានវិទ្យា។



# លោក មាន គឹង
# ប្រធាននាយកដ្ឋាន សំណង់-វិស្វកម្ម

លោក **មាន គឹង** កើតថ្ងៃទី០៦ ខែកក្កដា ឆ្នាំ១៩៧០ សញ្ជាតិ ខ្មែរ ទីកន្លែងកំណើត ភូមិស្វាយម៉ូ ឃុំព្រៃកដំបូក ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ប្រទេសកម្ពុជា ។

- **ប្រវត្តិនៃការសិក្សា**

នៅចន្លោះឆ្នាំ១៩៨១ ដល់ឆ្នាំ១៩៨៥ លោកបានបញ្ចប់ថ្នាក់មធ្យមសិក្សាសាលាស្រីសន្ធរ ខេត្តកំពង់ចាម ប្រទេសកម្ពុជា។ នៅឆ្នាំ១៩៨៦ ដល់ឆ្នាំ១៩៨៩ លោកបានបញ្ចប់ថ្នាក់វិទ្យាល័យ នៅសាលាបឹងត្របែក ភ្នំពេញ ប្រទេសកម្ពុជា។ នៅឆ្នាំ១៩៨៩ ដល់ឆ្នាំ១៩៩៥ លោកបានបញ្ចប់ថ្នាក់បរិញ្ញាប័ត្រស្ថាបត្យកម្ម នៅសាលាភូមិន្ទវិចិត្រសិល្បៈ ប្រទេសកម្ពុជា។ នៅឆ្នាំ១៩៩៥ ដល់ឆ្នាំ១៩៩៦ លោកបានបញ្ចប់ថ្នាក់អនុបណ្ឌិតផ្នែកស្ថាបត្យកម្ម និងនគរូបនីយកម្ម នៅសាលាភូមិន្ទវិចិត្រសិល្បៈ ប្រទេសកម្ពុជា ។

- **បទពិសោធន៍ការងារ**

ក្នុងអំឡុងឆ្នាំ១៩៩៥ លោកបានចូលរួមបម្រើការងារនៅកំពង់ផែស្វយ័តក្រុងព្រះសីហនុ ជាបុគ្គលិកបណ្តែត និងចូលរួមធ្វើគំរោងអភិវឌ្ឍន៍នៅតំបន់បិតត្រាំង  ដល់ឆ្នាំ១៩៩៦ លោកជាបុគ្គលិកពេញសិទ្ធិ។ នៅឆ្នាំ២០១៤ ដល់ឆ្នាំ២០១៧ លោកមានតួនាទីជាប្រធានការិយាល័យស្ថាបត្យកម្ម នៃនាយកដ្ឋានបច្ចេកទេសសម្ភារៈ និងសំណង់។ នៅឆ្នាំ២០១៧ ដល់ ឆ្នាំ២០១៩ លោកមានតួនាទីជានាយករង នៃនាយកដ្ឋានបច្ចេកទេសសម្ភារៈ និងសំណង់។ ចាប់ពីឆ្នាំ២០១៩ ដល់បច្ចុប្បន្នលោកមានតួនាទីជានាយក នៃនាយកដ្ឋានសំណង់ និងវិស្វកម្ម។

## ខ-តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់បុគ្គលិកជាន់ខ្ពស់

តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់បុគ្គលិកជាន់ខ្ពស់របស់ **កសស** មានដូចខាងក្រោម៖

### ខ.១. ឯកឧត្តម លូ គឹមឈន់ ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាប្រធានអគ្គនាយក៖

ឯកឧត្តម **លូ គឹមឈន់** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាប្រធានអគ្គនាយកមានតួនាទី និងភារកិច្ច ទទួលបន្ទុកដឹកនាំការងាររួមដឹកនាំត្រួតពិនិត្យនិងតាមដានជំរុញការអនុវត្តការងារលើគ្រប់វិស័យរបស់កំពង់ផែរួមមានការងារ អាជីវកម្ម សេវាកម្មការងារសាងសង់ពង្រីកមូលដ្ឋានតាមផែនការអភិវឌ្ឍន៍កំពង់ផែ និងជាពិសេសការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្រ្តចតុកោណរបស់រាជរដ្ឋាភិបាល លើរាល់ចំណុច ដែលពាក់ព័ន្ធនឹងវិស័យកំពង់ផែ។

ចំពោះនាយកដ្ឋាននឹងអង្គភាពដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ ឯកឧត្តមប្រធានអគ្គនាយករួមមាន៖

- នាយកដ្ឋាន ផែនការ ស្ថិតិ និងលទ្ធកម្ម
- នាយកដ្ឋាន គណនេយ្យ-ហិរញ្ញវត្ថុ
- នាយកដ្ឋាន ទីផ្សារ
- នាយកដ្ឋាន សវនកម្មផ្ទៃក្នុង
- លេខាធិការដ្ឋាន

### ខ.២. លោក ថៃ ឬទ្ធី អគ្គនាយករងអាជីវកម្ម៖

លោក **ថៃ ឬទ្ធី** អគ្គនាយករងអាជីវកម្ម មានតួនាទី និងភារកិច្ចជាជំនួយការអោយឯកឧត្តមប្រធានអគ្គនាយក និងទទួលបន្ទុកការងារអាជីវកម្ម និងជួយឯកឧត្តមប្រធានអគ្គនាយកក្នុងការតាមដាននឹងត្រួតពិនិត្យការអនុវត្តទិសដៅរបស់រាជរដ្ឋាភិបាលដែលមានពាក់ព័ន្ធនឹងការអនុវត្តផែនការរបស់ **កសស** ជាពិសេសការងារអាជីវកម្ម ។

ចំពោះនាយកដ្ឋាន ដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ លោកអគ្គនាយករងអាជីវកម្ម រួមមាន៖

- នាយកដ្ឋាន អាជីវកម្ម
- នាយកដ្ឋាន ប្រតិបត្តិការទីលានកុងតឺន័រ
- នាយកដ្ឋាន ប្រតិបត្តិការទំនិញទូទៅ

### ខ.៣. លោក ឈុន ហុង អគ្គនាយករងរដ្ឋបាល-គ្រប់គ្រង៖

លោក **ឈុន ហុង** អគ្គនាយករងរដ្ឋបាល-គ្រប់គ្រងមានតួនាទី និងភារកិច្ចជាជំនួយការអោយឯកឧត្តមប្រធានអគ្គនាយក ទទួលបន្ទុកការងាររដ្ឋបាល-គ្រប់គ្រង និងនាវាចរ-កណ្ណធារ និងជួយឯកឧត្តមប្រធានអគ្គនាយកក្នុងការតាមដាន និងត្រួតពិនិត្យការអនុវត្តទិសដៅរបស់រាជរដ្ឋាភិបាលដែលមានពាក់ព័ន្ធនឹងការអនុវត្តផែនការរបស់ **កសស** ជាពិសេសការងាររដ្ឋបាល-គ្រប់គ្រង ។

ចំពោះនាយកដ្ឋានដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់លោកអគ្គនាយករង រដ្ឋបាល-គ្រប់គ្រង រួមមាន៖

- នាយកដ្ឋាន រដ្ឋបាល-ធនធានមនុស្ស
- នាយកដ្ឋាន នាវាចរ-កណ្ណធារ

## ខ.៤. លោក ជា យុទ្ធឌីកា អគ្គនាយករងបច្ចេកទេស៖

លោក **ជា យុទ្ធឌីកា** អគ្គនាយករង បច្ចេកទេសមានតួនាទី និងភារកិច្ចជាជាជំនួយការអោយ ឯកឧត្តម ប្រធានអគ្គនាយកទទួលបន្ទុកការងារបច្ចេកទេសសាងសង់ និងជួយប្រធានអគ្គនាយកក្នុងការតាមដាន និង ត្រួតពិនិត្យការអនុវត្តទិសដៅរបស់រាជរដ្ឋាភិបាល ដែលមានពាក់ព័ន្ធនឹងការអនុវត្តផែនការរបស់ **កសស** ជាពិសេសការងារបច្ចេកទេស និងសំណង់ ។

ចំពោះនាយកដ្ឋានដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់លោកអគ្គនាយករងបច្ចេកទេសរួមមាន៖

- នាយកដ្ឋាន បច្ចេកទេស សម្ភារៈ-សំណង់
- នាយកដ្ឋាន គ្រឿងចក្រ

## ខ.៥. លោក រ័ត្ន សិលា នាយករដ្ឋបាល-ធនធានមនុស្ស ៖

លោក **រ័ត្ន សិលា** នាយក រដ្ឋបាល-ធនធានមនុស្ស មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- គ្រប់គ្រង និងសម្របសម្រួលនូវរាល់សកម្មភាពពាក់ព័ន្ធនឹងការងាររដ្ឋបាល និងធនធានមនុស្ស
- រៀបចំប្រាក់បៀវត្សរ៍ ប្រាក់ឧបត្ថម្ភ ប្រាក់សោធននិវត្តន៍ ជូនមន្ត្រី និយោជិត កម្មករ
- គ្រប់គ្រង និងរៀបចំឯកសាររដ្ឋបាល លិខិតអនុញ្ញាតច្បាប់ លិខិតបង្គាប់ការ លិខិតបញ្ជាបេសកកម្ម និងត្រារបស់អង្គភាព
- ទទួលរៀបចំបដិសណ្ឋារកិច្ចភ្ញៀវជាតិ និងអន្តរជាតិ
- គ្រប់គ្រងរាល់ការងារពាក់ព័ន្ធនឹងធនធានមនុស្ស ការបណ្តុះបណ្តាលក្នុង-ក្រៅប្រទេស និងការងារ APA
- គ្រប់គ្រងប្រព័ន្ធពត៌មានវិទ្យា ប្រព័ន្ធទូរស័ព្ទ អ៊ីនធើណេត និងអ៊ីម៉ែល
- គ្រប់គ្រង ជួសជុល និងផ្តល់ប្រេងឥន្ធនៈ ដល់មធ្យោបាយដឹកជញ្ជូន ដែលបម្រើឱ្យការងាររដ្ឋបាល និងរថយន្តបង្ការអគ្គីភ័យ
- គ្រប់គ្រងជួសជុល កែលម្អអគារ ទីស្នាក់ការ បណ្តាអង្គភាព និងនាយកដ្ឋាននានា
- គ្រប់គ្រងផ្គត់ផ្គង់សម្ភារៈ និងឧបករណ៍ការិយាល័យរដ្ឋបាល អេឡិចត្រូនិច និងទូរស័ព្ទ
- រៀបចំតួនាទីភារកិច្ច និងកែសម្រួលរចនាសម្ព័ន្ធតាមស្ថានភាពជាក់ស្តែង
- គ្រប់គ្រងការងារសង្គម របស់មន្ត្រី និយោជិត កម្មករ
- រៀបចំបែបបទទាក់ទងនឹងធានារ៉ាប់រងសង្គមចំពោះមន្ត្រីចូលមរណភាព និងការឧបត្ថម្ភកូនកំព្រា
- គ្រប់គ្រង ការងារ ថែទាំសុខភាព ព្យាបាល និងផ្គត់ផ្គង់ឱសថជូនដល់ មន្ត្រី និយោជិត កម្មករ
- គ្រប់គ្រងការងារសំអាត អនាម័យ និងបរិស្ថានកំពង់ផែ
- កសាងគម្រោងចំណាយរដ្ឋបាលរយៈពេលខ្លី វែង ជូនថ្នាក់ដឹកនាំ
- បំពេញភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន

## ខ.៦. លោក ប៉ាត សិត នាយកគណនេយ្យ-ហិរញ្ញវត្ថុ៖

លោក **ប៉ាត សិត** នាយកគណនេយ្យ-ហិរញ្ញវត្ថុ មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- រៀបចំ និងគ្រប់គ្រងអនុវត្តការងារគណនេយ្យ-ហិរញ្ញវត្ថុ ឱ្យត្រឹមត្រូវសមស្របតាមគោលការណ៍គណនេយ្យកម្ពុជា ដែលដាក់ឱ្យប្រើដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- គ្រប់គ្រង និងកត់ត្រាជាប្រចាំនូវសាលាកប័ត្រ និងបញ្ជីការគណនេយ្យ ស្របទៅតាមច្បាប់គណនេយ្យ-ហិរញ្ញវត្ថុ របស់ព្រះរាជាណាចក្រកម្ពុជា
- តាមដាន គ្រប់គ្រង និងធ្វើរបាយការណ៍ខាងគណនេយ្យ-ហិរញ្ញវត្ថុ
- គ្រប់គ្រងសាច់ប្រាក់ក្នុងបេឡា និងធនាគារ
- ផ្ទៀងផ្ទាត់ និងប្រមូលចំណូលឱ្យទាន់ពេលវេលា សមស្របតាមនីតិវិធីហិរញ្ញវត្ថុ
- គ្រប់គ្រងចំណូល និងចំណាយដោយអនុវត្តតាមផែនការកំណត់ជាមូលដ្ឋាន
- ណែនាំ និងត្រួតពិនិត្យបញ្ជីការបណ្តានាយកដ្ឋានរបស់ **កសស** ដែលទាក់ទងដល់មុខសញ្ញាចំណូល ចំណាយ ដើម្បីអនុវត្តឱ្យបានត្រឹមត្រូវតាមលិខិតបទដ្ឋាន និងគោលការណ៍
- ចូលរួមក្នុងការកសាងផែនការហិរញ្ញវត្ថុប្រចាំឆ្នាំ
- ចូលរួមក្នុងការងារលទ្ធកម្ម ដោយអនុវត្តតាមផែនការលទ្ធកម្មប្រចាំឆ្នាំ
- ចូលរួមក្នុងការជម្រះបញ្ជីអចលនទ្រព្យ ដោយអនុវត្តតាមច្បាប់ស្តីពីការគ្រប់គ្រងសម្បត្តិរដ្ឋ
- គ្រប់គ្រងបញ្ជីសារពើភ័ណ្ឌ
- អនុវត្តកាតព្វកិច្ចបង់ពន្ធអាករគ្រប់ប្រភេទចូលថវិការដ្ឋ
- ចូលរួមក្នុងការធ្វើសវនកម្មផ្ទៃក្នុង **កសស**
- តាមដាន និងគ្រប់គ្រងនូវរាល់បណ្តាប្រាក់ជំនួយឧបត្ថម្ភធន និងប្រាក់កម្ចី
- តាមដានបំណុល និងបំណុលរ៉ាំរ៉ៃ និងរៀបចំរបាយការណ៍ជម្រះបញ្ជីជូន **ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាប្រធានអគ្គនាយក កសស** ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលសម្រេច
- បំពេញភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន

## ខ.៧. លោក សូ សៀង នាយកផែនការ-លទ្ធកម្ម និងស្ថិតិ ៖

លោក **សូ សៀង** នាយកផែនការ-លទ្ធកម្ម និងស្ថិតិ មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- រៀបចំផែនការអាជីវកម្ម (សេវាកម្ម) ហិរញ្ញវត្ថុ និងផែនការជួសជុលសាងសង់សំណង់មូលដ្ឋាន ការប្រើប្រាស់មធ្យោបាយ គ្រឿងចក្រ ប្រេងឥន្ធនៈ ធនធានមនុស្សប្រចាំឆ្នាំជូន **កសស**
- រៀបចំផែនការអភិវឌ្ឍន៍រយៈពេលខ្លី មធ្យម វែង និងវិនិយោគសាធារណៈ
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារ អាជីវកម្ម សេវាកម្ម ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ
- កសាងកិច្ចសន្យាអាជីវកម្ម (សេវាកម្ម) កិច្ចសន្យាអភិវឌ្ឍន៍ និងវិនិយោគសាធារណៈ រយៈពេលមធ្យម និងវែង (លើសពី ០១ឆ្នាំ)
- រៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ និងផែនការលទ្ធកម្មកែតម្រូវក្នុងករណីចាំបាច់
- គ្រប់គ្រង និងសម្របសម្រួល ក្នុងការអនុវត្តនីតិវិធីលទ្ធកម្មរបស់ **កសស**

- កសាងតារាងតម្លៃអាជីវកម្ម (សេវាកម្ម) និងគម្រោងផែនការ តម្លៃសេវាកម្មអនាគត
- រៀបចំកិច្ចប្រជុំជារៀងរាល់ខែ ត្រីមាស ឆមាស និងឆ្នាំ
- បំពេញភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន

## ខ.៨. លោក ទី សាគុណ នាយកបច្ចេកទេស សម្ភារៈ-សំណង់៖

លោក **ទី សាគុណ** នាយកបច្ចេកទេស សម្ភារៈ-សំណង់ មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- ពិនិត្យ ណែនាំបង្ហាញតាមដានអំពីការអនុវត្តបទដ្ឋានបច្ចេកទេសក្នុងការប្រើប្រាស់ថែទាំជួសជុលគ្រប់បណ្តាមធ្យោបាយគ្រឿងចក្រ សម្ភារៈ ប្រេងឥន្ធនៈ បរិក្ខាអគ្គិសនី និងសំណង់របស់ **កសស**
- សិក្សាពីលក្ខណៈបច្ចេកទេសគ្រឿងចក្រ ឧបករណ៍ប្រើប្រាស់បរិក្ខាអគ្គិសនី ប្រេងឥន្ធនៈ និងលក្ខណៈបច្ចេកទេសសំណង់
- លើកគម្រោងជួសជុលធំ ជួសជុលអចិន្ត្រៃយ៍រាល់មធ្យោបាយគ្រឿងចក្រ
- ទទួលខុសត្រូវក្នុងការងារគ្រប់គ្រងថែរក្សា និងផ្គត់ផ្គង់សម្ភារៈ បន្លាស់សម្ភារៈសំណង់ បរិក្ខាអគ្គិសនី ប្រេងឥន្ធនៈ អ៊ូនាវា-ពោងសញ្ញា យានដ្ឋាន និងសំណង់ផ្សេងៗទៅតាមបទដ្ឋានបច្ចេកទេស
- សិក្សារៀបចំគម្រោង និងអនុវត្តការងារសាងសង់ជួសជុលសង់សំណង់មូលដ្ឋាន
- ចូលរួមស្រាវជ្រាវកសាងនូវរបកគំហើញថ្មីក្នុងគោលដៅអភិវឌ្ឍន៍ **កសស**
- បំពេញភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន

## ខ.៩. លោកស្រី ជ័យ សុគន្ធា នាយិកាទីផ្សារ៖

លោកស្រី **ជ័យ សុគន្ធា** នាយិកាទីផ្សារមានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- ផ្តើមគំនិតក្នុងការលើកស្ទួយគុណភាពទីផ្សារ សេវាកម្មរបស់ **កសស** អោយមានកម្រិតសមស្របទៅនឹងដំណើរនៃសកលភាវូបនីយកម្មក្នុងតំបន់ ក៏ដូចតម្រូវការរបស់អតិថិជន
- សិក្សា និងតាមដានអំពីស្ថានភាព តម្លៃ និងគុណភាពសេវាកម្មរបស់គូប្រកួតប្រជែងដើម្បីផ្តល់យោបល់ជូនថ្នាក់ដឹកនាំ
- សិក្សាស្វែងយល់ទីផ្សារអំពីតម្រូវការ ទំនោរនិន្នាការ និងព័ត៌មានត្រលប់របស់អតិថិជន
- ប្រមូលទិន្នន័យព័ត៌មានដើម្បីចងក្រង និងរៀបចំដាក់ចេញនូវយុទ្ធសាស្រ្តទីផ្សារ
- ផ្តើមគំនិតផលិតឯកសារផ្សព្វផ្សាយព័ត៌មានដូចជាព្រឹត្តប័ត្រប្រចាំឆ្នាំ ប្រតិទិន និងប្រភេទនៃសម្ភារៈផ្សព្វផ្សាយផ្សេងៗ
- រួមចំណែកលើកកម្ពស់គុណភាពសេវាកម្មរបស់ **កសស** នៅក្នុងទីផ្សារជាតិ និងអន្តរជាតិ ដើម្បី ឆ្លើយតបនឹងសំណូមពរអតិថិជន
- ធ្វើបច្ចុប្បន្នភាពគេហទំព័រ និងបណ្តាញសង្គមរបស់ **កសស**
- បំពេញភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន

## ខ.១០. លោក ជីវ ច័ន្ទសុផល នាយកតំបន់សេដ្ឋកិច្ចពិសេស៖

លោក **ជីវ ច័ន្ទសុផល** នាយកតំបន់សេដ្ឋកិច្ចពិសេស មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- ទំនាក់ទំនង និងពិភាក្សាជាមួយអតិថិជនដើម្បីរៀបចំកិច្ចព្រមព្រៀង
- ផ្តល់សេវាកម្ម និងព័ត៌មានអំពីការវិនិយោគទាក់ទងនឹង **តសព** ជូនអតិថិជនប្រកបដោយគុណភាព និងប្រសិទ្ធិភាព
- សហការ និងសម្របសម្រួល ជាមួយអាជ្ញាធរមានសមត្ថកិច្ចប្រចាំនៅរដ្ឋបាល **តសព** និងវិនិយោគិនក្នុងតំបន់ ដើម្បីធ្វើអោយប្រតិបត្តិការមានភាពរលូន
- បង្កើតគំនិតផ្នែប្រឌិតទីផ្សារថ្មីៗ ដើម្បីអោយ **តសព** មានឧត្តមភាពប្រកួតប្រជែងក្នុងតំបន់ និងសាកល
- ចូលរួមលើកគម្រោងផែនការសម្រាប់រយៈពេលវែង ខ្លី ដែលពាក់ព័ន្ធនឹង **តសព**
- ស្វែងយល់អំពីស្ថានភាព និងកម្រិត **តសព** ក្នុងប្រទេសជិតខាងក្នុងតំបន់
- សហការជាមួយនាយកដ្ឋានពាក់ព័ន្ធដើម្បីបម្រើ ឬផ្តល់សេវាជូនអតិថិជនក្នុង **តសព** ឬសេវាដទៃទៀតដែលពាក់ព័ន្ធដើម្បីជាប្រយោជន៍ដល់ **កសស**
- ទទួលខុសត្រូវលើកិច្ចការចេញវិក្កយបត្រ គិតថ្លៃឈ្នួល និងសេវាគ្រប់ប្រភេទជូនដល់អតិថិជន
- គ្រប់គ្រងសុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់ល្អក្នុង **តសព**
- ធ្វើរបាយការណ៍អំពីស្ថានភាពវិនិយោគនៅ **តសព** និងលទ្ធផលនៃប្រតិបត្តិការ
- បំពេញភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន

## ខ.១១. លោក ពិត ប្រាកដ នាយកអាជីវកម្ម៖

លោក **ពិត ប្រាកដ** នាយកអាជីវកម្ម មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- ទទួលខុសត្រូវអនុវត្តតម្លៃឈ្នួលគ្រប់ប្រភេទលើការងារសេវាកម្ម អាជីវកម្ម ដោយអនុវត្តទៅតាមបទដ្ឋាន សេចក្តីសម្រេច សេចក្តីកំណត់របស់ **កសស**
- ពិនិត្យ និងតាមដានការងារអាជីវកម្ម ការប្រើប្រាស់សេវាកម្មផ្សេងៗរបស់ **កសស**
- ចូលរួមលើកគម្រោងជាមួយបណ្តានាយកដ្ឋាននានា ក្នុងការរៀបចំកសាងកិច្ចសន្យាអាជីវកម្ម (សេវាកម្ម) កិច្ចសន្យាអភិវឌ្ឍន៍ និងវិនិយោគ និងកសាងតម្លៃឈ្នួលផ្សេងៗ សម្រាប់បម្រើ អោយការងារអាជីវកម្មរបស់ **កសស**
- បូកសរុបបញ្ជីការប្រចាំ សប្តាហ៍ ខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ជូននាយកដ្ឋានពាក់ព័ន្ធដើម្បីផ្ទៀងផ្ទាត់ជាមួយនាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ
- រៀបចំ និងកសាងកិច្ចសន្យាស្តីពីការប្រើប្រាស់សេវាកម្ម (លើកដាក់ ដឹកជញ្ជូន) របស់ **កសស** និងការជួលផ្សេងៗរយៈពេលខ្លីក្រោម ០១ឆ្នាំ
- សិក្សាអំពីតម្លៃឈ្នួលនៅតាមបណ្តាកំពង់ផែនានា នៅក្នុងតំបន់ និងក្នុងស្រុកព្រមទាំងបណ្តាច្រកព្រំដែន ដើម្បីមានមូលដ្ឋានក្នុងការកសាង និងកែលម្អតម្លៃផ្សេងៗរបស់ **កសស**
- សហការណ៍ជាមួយនាយកដ្ឋានពាក់ព័ន្ធ ក្នុងការក្រើនរំលឹកដល់អតិថិជនទាំងឡាយដែលជាប់បំណុលដើម្បីទូទាត់ឱ្យទាន់ពេលវេលា

- ទទួលខុសត្រូវគ្រប់គ្រង ប្រើប្រាស់ និងថែរក្សាប្រព័ន្ធ CTMS និង SWSS អោយដំណើរការបានរលូនល្អ និងមានប្រសិទ្ធិភាព
- ចូលរួមសហការណ៍ជាមួយសមត្ថកិច្ចពាក់ព័ន្ធនានា ដើម្បីអនុវត្តការងារច្រក ចេញ-ចូល តែមួយឱ្យមានប្រសិទ្ធិភាព និងទទួលបាននូវជោគជ័យ
- បំពេញភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន

## ខ.១២. លោក ស្រី ណារិទ្ធ នាយកប្រតិបត្តិការទីលានកុងតឺន័រ៖

លោក **ស្រី ណារិទ្ធ** នាយកប្រតិបត្តិការទីលានកុងតឺន័រ មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- ចូលរួមអនុវត្តកិច្ចព្រមព្រៀងរវាង **កសស** និងក្រុមហ៊ុននាវា
- ចូលរួមសហការណ៍ជាមួយនាយកដ្ឋានពាក់ព័ន្ធលើការងារនាំនាវា ចូល-ចេញ និងការងារផ្ទេរ-ផ្ទុក កុងតឺន័រជាមួយនាវា
- ទទួលព័ត៌មាននាវា ស្តីពីពេលវេលានៃការចូលចត និងបរិមាណកុងតឺន័រដែលត្រូវ ផ្ទេរ-ផ្ទុក និងបញ្ចូលទៅក្នុងប្រព័ន្ធ CTMS
- ធ្វើផែនការនាវា ផែនការទីលាន ផែនការមធ្យោបាយផ្ទេរ-ផ្ទុកលើកដាក់ និងកម្លាំងប្រតិបត្តិការ
- ទទួលកុងតឺន័រនាំចូលពីនាវា និងពីគ្រប់មធ្យោបាយដឹកជញ្ជូនមកទីលាន
- ប្រគល់កុងតឺន័រនាំចូល ពីនាវាទៅម្ចាស់ទំនិញ និងកុងតឺន័រនាំចេញទៅនាវា
- ផ្ទៀងផ្ទាត់វិក្កយប័ត្រ នៃការលើកដាក់នៅទីលានជាមួយម្ចាស់ទំនិញ
- ធ្វើរបាយការណ៍ ស្តីពីប្រតិបត្តិការកុងតឺន័រ ជូននាយកដ្ឋានពាក់ព័ន្ធ
- រៀបចំសណ្តាប់ធ្នាប់ ប្រព័ន្ធចរាចរណ៍ក្នុងតំបន់ប្រតិបត្តិការ និងទីលាន
- គ្រប់គ្រង ទុកដាក់ ថែរក្សា កុងតឺន័រនៅទីលានអោយមានសុវត្ថិភាព
- គ្រប់គ្រងជញ្ជីងថ្លឹងកុងតឺន័រ
- កត់ត្រាចំនួនកុងតឺន័រដែល ផ្ទេរ-ផ្ទុក ជាមួយនាវា
- គ្រប់គ្រងការប្រើប្រាស់មធ្យោបាយលើកដាក់ និងអ្នកបើកបរ ទៅតាមមុខសញ្ញាការងារអោយមានប្រសិទ្ធិភាព
- គ្រប់គ្រងការប្រើប្រាស់ប្រព័ន្ធ CTMS ទាំងអស់ដែលពាក់ព័ន្ធជាមួយប្រតិបត្តិការកុងតឺន័រ
- បំពេញភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន

## ខ.១៣. លោក លូ លីខេង នាយកប្រតិបត្តិការទំនិញទូទៅ៖

លោក **លូ លីខេង** នាយកប្រតិបត្តិការទំនិញទូទៅ មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- ទទួលព័ត៌មាននាវា ដែលផ្ទុកទំនិញរាយ
- ធ្វើផែនការ ផ្ទេរ-ផ្ទុក ទំនិញ ទៅតាមប្រភេទប្រតិបត្តិការ
- ទទួលព័ត៌មាន និងដោះស្រាយរាល់បាតុភាពផ្សេងៗតាមការដ្ឋាន
- ទទួល ប្រគល់ និងថែរក្សាទំនិញឱ្យបានត្រឹមត្រូវតាមបទដ្ឋាន
- ស្រាវជ្រាវបទដ្ឋាន និងនីតិវិធីថ្មីៗ ដើម្បីហ្វឹកហ្វឺនដល់ប្រតិបត្តិករ

- ក្រើនរំលឹកដល់ប្រតិបត្តិករ អំពីការប្រើប្រាស់ ការថែទាំគ្រឿងចក្រទៅតាមបទដ្ឋាន និងយកចិត្ត ទុកដាក់លើសុខភាព សុវត្ថិភាព ពលកម្ម ក្នុងពេលប្រតិបត្តិការគ្រប់ការដ្ឋាន
- លើកគម្រោងស្នើសុំសម្ភារៈប្រើប្រាស់ផ្សេងៗ ឧបករណ៍ និងមធ្យោបាយលើកដាក់ដឹកជញ្ជូន
- ធ្វើរបាយការណ៍អំពីលទ្ធផលការងារប្រចាំវេន ថ្ងៃ ខែ និងឆ្នាំ ដើម្បីផ្តល់ជូនភាគី និងនាយក ដ្ឋានពាក់ព័ន្ធ
- បំពេញភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន

## ខ.១៤. លោក ថោង វីរ៉ូ នាយកនាវាចរ-កណ្តធារ៖

លោក **ថោង វីរ៉ូ** នាយកនាវាចរ-កណ្តធារ មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- កណ្តធារកិច្ច
- រៀបចំផែនការស្តីពីកណ្តធារកិច្ច
- ដឹកនាំគណៈកម្មការ ដើម្បីបំពេញបែបបទនាំនាវាចូល-ចេញពីកំពង់ផែ
- គ្រប់គ្រង និងទំនាក់ទំនងប្រព័ន្ធប្រតិបត្តិការចលនានាវា
- គ្រប់គ្រង ប្រើប្រាស់ និងថែទាំ មធ្យោបាយជើងទឹក (នាវាសណ្តោង)
- គ្រប់គ្រងឯកសារ និងធ្វើរបាយការណ៍រាល់សកម្មភាពនាវា ចេញ-ចូល **កសស**
- ទទួលគ្រប់គ្រងចំណតផែ ពោង ភ្លើងសញ្ញា ជម្រៅទឹក ដើម្បីសុវត្ថិភាពនាវា
- ទំនាក់ទំនងក្នុងការប្រមូលកាកសំណល់ រឹង-រាវ ពីនាវា និងផ្គត់ផ្គង់ទឹកស្អាត
- រុករក និងសង្គ្រោះ រាល់ហេតុការណ៍ដែលអាចកើតមានឡើងក្នុងតំបន់ទឹក **កសស**
- លើកគម្រោងអភិវឌ្ឍន៍ចំណតផែ និងជម្រៅទឹក នៅថ្ងៃអនាគតសម្រាប់ **កសស**
- សិក្សា និងស្រាវជ្រាវឯកសារច្បាប់ជាតិ និងអន្តរជាតិ ដែលពាក់ព័ន្ធនឹងនាវាចរ
- គ្រប់គ្រងសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ និងទំនាក់ទំនងការងារសន្តិសុខថ្នាក់ជាតិ និងអន្តរជាតិ ព្រមទាំង ISPS Code
- បំពេញភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន

## ខ.១៥. លោក នាក់ សុហ្វីយ៉ាន នាយកគ្រឿងចក្រ៖

លោក **នាក់ សុហ្វីយ៉ាន** នាយកគ្រឿងចក្រ មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- ចូលរួមពិនិត្យការគ្រប់គ្រងថែទាំនូវបណ្តាគ្រឿងចក្រគ្រប់ប្រភេទ
- ស្រាវជ្រាវបទដ្ឋានបច្ចេកទេស ដើម្បីជាមូលដ្ឋានក្នុងការ ថែទាំ-ជួសជុល នូវមធ្យោបាយ លើក ដាក់ និងដឹកជញ្ជូន ក្នុងការធានាគុណភាពប្រកបដោយប្រសិទ្ធិភាពខ្ពស់
- ត្រួតពិនិត្យជាប្រចាំ ដើម្បីក្តាប់ឱ្យបាននូវស្ថានភាពមធ្យោបាយគ្រឿងចក្រ និងឧបករណ៍
- រៀបចំហ្វឹកហ្វឺន លើជំនាញបើកបរ និងថែទាំគ្រឿងចក្រ
- សហការណ៍ត្រួតពិនិត្យ ការជួសជុលមធ្យោបាយនានា ដើម្បីស្វែងយល់អំពីលទ្ធផលនៃការ ជួសជុល និងការប្រើប្រាស់មធ្យោបាយទាំងនោះ

- ចូលរួមកសាងគម្រោងមធ្យោបាយលើកដាក់ ដឹកជញ្ជូនទំនិញទៅតាមសភាពការណ៍អភិវឌ្ឍន៍របស់ **កសស**
- បំពេញភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន

## ខ.១៦. លោក ម៉ែន ចាន់ នាយកសវនកម្មផ្ទៃក្នុង៖

លោក **ម៉ែន ចាន់** នាយកសវនកម្មផ្ទៃក្នុង មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- ធ្វើសវនកម្មលើការអនុវត្តច្បាប់ បទបញ្ញានានា វិន័យ ថវិកា និងអភិបាលកិច្ចល្អនៅក្នុងប្រតិបត្តិការហិរញ្ញវត្ថុ ពិសេសការគៀងគរ និងគ្រប់គ្រងចំណូល ចំណាយ ថវិកា ហិរញ្ញប្បទាន បំណុល និងទ្រព្យសម្បត្តិរដ្ឋ
- ធ្វើសវនកម្មលើពាក្យបណ្តឹងបរិហារទាំងឡាយ
- ធ្វើសវនកម្មលើនីតិវិធី និងការអនុវត្តគោលការណ៍ ដើម្បីធានាថាវិធានការដែលបានដាក់ពិតជាត្រឹមត្រូវ
- ទទួលអនុវត្តការងារសវនកម្មផ្សេងៗទៀត ស្របតាមវិជ្ជាជីវៈសវនកម្ម និងសេចក្តីប្រកាសណែនាំទាក់ទងនឹងការងារសវនកម្មផ្ទៃក្នុង
- ធ្វើសវនកម្មលើគម្រោងអភិវឌ្ឍន៍នានា
- បំពេញភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន

## ខ.១៧. លោក សោម ករណី នាយកព័ត៌មានវិទ្យា៖

លោក **សោម ករណី** នាយកព័ត៌មានវិទ្យា មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- គ្រប់គ្រង និងថែទាំប្រព័ន្ធ CTMS, SWSS, EMAIL Server, Microsoft NAV។ល។
- រៀបចំ និងគ្រប់គ្រងទិន្នន័យ ពង្រឹងសុវត្ថិភាពទិន្នន័យ និងរក្សាទុកទន្និន័យនៅក្នុងប្រព័ន្ធ។
- តាមដាន ត្រួតពិនិត្យ និងថែទាំហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធ CTMS, SWSS, Email Server, Microsoft Dynamic NAV។ល។
- រៀបចំគោលនយោបាយ យុទ្ធសាស្រ្ត និងផែនការអភិវឌ្ឍប្រព័ន្ធព័ត៌មានវិទ្យា និងគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធព័ត៌មានវិទ្យា គេហទំព័រ និងសារអេឡិចត្រូនិច ។
- សិក្សាស្រាវជ្រាវបច្ចេកវិទ្យាថ្មីៗ ព្រមទាំងនិន្នាការបច្ចេកវិទ្យា និងលំហូរការងារ ដើម្បីលើកសំណើកែលម្អខ្សែសង្វាក់ការងាររបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ។
- សិក្សាស្រាវជ្រាវ និងកំណត់ហានិភ័យហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធព័ត៌មានវិទ្យា ដែលអាចកើតមានឡើងដើម្បីការពារ និងមានវិធានការទប់ស្កាត់។
- សិក្សាតម្រូវការធ្វើទំនើបកម្ម និងស្វ័យប្រវត្តិកម្មលើវិស័យព័ត៌មានវិទ្យា និងធ្វើការ បណ្តុះបណ្តាលព័ត៌មានវិទ្យាដល់មន្ត្រី និយោជិត កំពង់ផែស្វយ័តក្រុងព្រះសីហនុ ។
- បំពេញភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

## ខ.១៨. លោក មាន គឹង នាយកសំណង់-វិស្វកម្មះ

លោក **មាន គឹង** នាយកសំណង់-វិស្វកម្ម មានតួនាទី និងភារៈកិច្ចដូចខាងក្រោមៈ

- ទទួលខុសត្រូវរៀបចំ ប្លង់គោល និងប្លង់លំអិតរបស់ **កសស**
- ទទួលខុសត្រូវរៀបចំផែនការសាងសង់ និងជួសជុលហេដ្ឋារចនាសម្ពន្ធ័របស់កំពង់ផែជាប្រចាំ
- ទទួលខុសត្រូវសិក្សាគម្រោងប្លង់ អោយសមស្របទៅតាមលក្ខណៈបច្ចេកទេស ទាំងគុណភាព និងសោភ័ណភាព ។
- ទទួលខុសត្រូវ គ្រប់គ្រង និងចាត់ចែងគ្រឿងចក្រសំណង់
- ទទួលខុសត្រូវអនុវត្តន៏គម្រោងសាងសង់ ជួសជុល និងថែទាំហេដ្ឋារចនាសម្ពន្ធ័របស់ **កសស** ដូចជាៈ ផ្លូវថ្នល់, ទីលាន, ប្រពន្ធ័លូ, អគ្គិសនី, អគារ, ឃ្លាំង....... ។ ល។
- ទទួលខុសត្រូវ ជួសជុល និងថែទាំសំណង់មូលដ្ឋានរួមមានៈ ឃ្លាំងទំនប់រលក ចំណតផែ និងហេដ្ឋារចនាសម្ពន្ធ័របស់ **កសស** ។
- ទទួលខុសត្រូវ គ្រប់គ្រង និងចាត់ចែងអ៊ូនាវា, ពោងសញ្ញា, Light House និងប្រេងឥន្ទនៈបម្រើអោយការងារជួសជុលសាងសង់សំណង់របស់ **កសស** ។
- ទទួលខុសត្រូវការងារវាស់ស្ទង់
- ចូលរួមអនុវត្តន៏ និងតាមដាននូវរាល់គម្រោងអភិវឌ្ឍន៏របស់ **កសស** (PMU)
- រៀបចំប្លង់មេបណ្តាញអគ្គិសនី បណ្តាញលូ រ៉េហ្គាក្នុង **កសស**
- បំពេញភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

## គ-លទ្ធផលការងាររបស់បុគ្គលិកជាន់ខ្ពស់

គិតត្រឹមឆ្នាំ២០១៩ នេះ បុគ្គលិកជាន់ខ្ពស់បានប្រជុំបូកសរុបការងារ និងពិនិត្យលទ្ធផលដែលបានអនុវត្តកន្លងមក និងដាក់ផែនការទិសដៅដែលត្រូវអនុវត្តបន្ត។

## ឃ-ការបណ្តុះបណ្តាលបន្តសម្រាប់បុគ្គលិកជាន់ខ្ពស់

គិតត្រឹមឆ្នាំ២០១៩ នេះបុគ្គលិកជាន់ខ្ពស់របស់ **កសស** បានចូលរួមវគ្គបណ្តុះបណ្តាលស្តី អំពីការបង្ហាញព័ត៌មានសាជីវកម្ម និងការអនុវត្តអភិបាលកិច្ចសាជីវកម្មក្រោយពេលបោះផ្សាយលក់មូលបត្រជាសាធារណៈ ដែលរៀបចំឡើងនៅ **កសស** ក្រោមការបណ្តុះបណ្តាលពីមន្ត្រីរបស់ **គ.ម.ក** ។

# ផ្នែកទី ៤

# ព័ត៌មានអំពីការជួញដូរមូលបត្រ និងភាគហ៊ុនិក របស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ

## ក- ព័ត៌មានអំពីមូលបត្រ

ឈ្មោះមូលបត្រកម្មសិទ្ធិ: **មូលបត្រកម្មសិទ្ធិមានសិទ្ធិបោះឆ្នោតប្រភេទ “គ”**

អក្សរកូដមូលបត្រកម្មសិទ្ធិ: **KH1000060009**

ចំណាត់ថ្នាក់នៃមូលបត្រកម្មសិទ្ធិ: **មូលបត្រកម្មសិទ្ធិមានសិទ្ធិបោះឆ្នោតប្រភេទ “គ”**

តម្លៃចារឹកក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ: **១.០០០ រៀល**

ថ្លៃលក់ក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ: **៥.០៤០ រៀល (១,២៥៩ ដុល្លារអាមេរិក)**

បរិមាណមូលបត្រកម្មសិទ្ធិសរុបទាំងអស់ដែលកំពុងធ្វើចរាចរលើទីផ្សារ: **២១.៤៤២.៩៩២ មូលបត្រ**

មូលធនូបនីយកម្មទីផ្សារ: **១០៨.០៧២.៦៧៩.៦៨០ រៀល (២៦.៩៩១.១៧៩ ដុល្លារអាមេរិក)**

ឈ្មោះទីផ្សារមូលបត្រប្រតិស្រុត: **ផ្សារមូលបត្រកម្ពុជា**

កាលបរិច្ឆេទនៃការចុះបញ្ជីលក់មូលបត្រ: **ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៧**

## ខ- ថ្លៃ និងបរិមាណជួញដូរមូលបត្រ

| មូលបត្រកម្មសិទ្ធិ | | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ថ្លៃជួញដូរ (រៀល) | អតិបរមា | ១៤.០៨០ | ១៤.១០០ | ១២.៩៨០ | ១២.៦៨០ | ១៣.៥០០ | ១៣.៨៦០ | ១៤.២០០ | ១៥.០០០ | ២៣.៦៥០ | ២៣,៥០០ | ២១.០០០ | ២០.១០០ |
| | អប្បបរមា | ១០.៤៦០ | ១០.០០០ | ១២.៣០០ | ១២.០០០ | ១២.១០០ | ១៣.៥០០ | ១៣.០០០ | ១៣.៨០០ | ១៥.៤០០ | ១៩,៥៨០ | ១៩.៩៨០ | ១៩.៤០០ |
| | មធ្យម | ១២.៤២៨ | ១២.៥៩១ | ១២.៥៣៤ | ១២.២៧៨ | ១២.៤៧៥ | ១៣.៦១៣ | ១៣.៦៨៣ | ១៤.៥៣៤ | ១៨.៨៥៥ | ២១.៨០៧ | ២០.៣២៩ | ១៩.៦៧០ |
| បរិមាណជួញដូរ (ភាគហ៊ុន) | អតិបរមា | ១០.៧៧៣ | ៦.៤៦២ | ២.២៦០ | ៤.៣៩១ | ៩.៤៣៦.២៦៧ | ៥.៦៨៤ | ២០៣.២៨១ | ៤.៤១៩ | ១១.១២៤ | ១៥.០៦៤ | ៤.៩៣៦ | ៤.៤៨៣ |
| | អប្បបរមា | ៧៩៤ | ៥០ | ១០០ | ០ | ១៣០ | ១ | ១ | ១៨ | ១១០ | ៤៦៩ | ១៦៥ | ២ |
| | មធ្យម | ៤.៤៥០ | ២.០៦១ | ៩១០ | ១.៥៥៨ | ៥៥៦.៤៦៣ | ៨១៦ | ១០.២៥៧ | ១.០១២ | ២.១៥៩ | ៤.១៥៣ | ១.៨២០ | ១.០៥៨ |

## គ-ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុន មានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ (ចាប់ពី ៣០%ឡើងទៅ)

| ល.រ | ឈ្មោះ | សញ្ជាតិ | ចំនួនមូលបត្រ | ភាគរយ |
| --- | --- | --- | --- | --- |
| ១ | រដ្ឋតំណាងដោយក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ខ្មែរ | ៦៤.៣២៨.៩៧៥ | ៧៥,00% |
| **សរុប** | | | **៦៤.៣២៨.៩៧៥** | **៧៥,00%** |

## ឃ-ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធបោះឆ្នោតចំនួនច្រើន (ចាប់ពី ៥% ដល់តិចជាង ៣០%)

| ល.រ | ឈ្មោះ | សញ្ជាតិ | ចំនួនមូលបត្រ | ភាគរយ |
| --- | --- | --- | --- | --- |
| ១ | KAMIGUMI CO., LTD | ជប៉ុន | ១១.១៥០.៣២៤ | ១៣,00% |
| **សរុប** | | | **១១.១៥០.៣២៤** | **១៣,00%** |

## ខ- ព័ត៌មានអំពីការបែងចែកភាគលាភក្នុងរយៈពេល ៣ (បី)ឆ្នាំចុងក្រោយ

| ពិពណ៌នាលម្អិតអំពីការបែងចែកភាគ | ២០១៨ | ២០១៧ |
| --- | --- | --- |
| ចំណេញសុទ្ធ | ៤៥.៥៦៨.៧៧២.000 រៀល | ២៥.១៣៩.៣១៦.000 រៀល |
| ភាគលាភជាសាច់ប្រាក់សរុប | ១៥.១៩១.៥២៥.៧៧៦ រៀល | ៨.៦៤១.៥២៥.៧៧៦ រៀល |
| ភាគលាភជាមូលបត្រកម្មសិទ្ធិសរុប | មិនមាន | មិនមាន |
| ភាគលាភផ្សេងទៀត | មិនមាន | មិនមាន |
| អនុបាតនៃការបែងចែកភាគលាភ (%) | ៣៣,៣៣% | ៣៤,៣៧% |
| ទិន្នផលភាគលាភ (%) | ៨,00% | ៨,00% |
| ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ | ៤0៣ រៀល | ៤0៣ រៀល |

# ផ្នែកទី ៥
# របាយការណ៍សវនកម្មរបស់សវនករផ្ទៃក្នុងលើការត្រួតពិនិត្យផ្ទៃក្នុង

# ផ្នែក ក: ខ្លឹមសារសង្ខេប

## ១. សាវតារ

នាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ បានធ្វើសវនកម្មលើការគ្រប់គ្រងសកម្មភាពប្រតិបត្តិការ និងអនុលោមភាព ព្រមទាំងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងរបស់ **នាយកដ្ឋានប្រតិបត្តិការទីលានកុងតឺន័រ នាយកដ្ឋានប្រតិបត្តិការទំនិញទូទៅ នាយកដ្ឋាននាវាចរ-កណ្ដាល នាយកដ្ឋានបច្ចេកទេស-សម្ភារៈ នាយកដ្ឋានគ្រឿងចក្រ នាយកដ្ឋានតំបន់សេដ្ឋកិច្ចពិសេស នាយកដ្ឋានទីផ្សារ** និង **នាយកដ្ឋានផែនការ-លទ្ធកម្មនិងស្ថិតិ** សម្រាប់ការិយបរិច្ឆេទឆ្នាំ២០១៩ ដែលជាផ្នែកមួយនៃផែនការសកម្មភាពសវនកម្មឆ្នាំ២០១៩ នៃកម្មវិធីសវនកម្មផ្ទៃក្នុងបីឆ្នាំ ២០១៩-២០២១ របស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង ។

ការធ្វើសវនកម្មប្រចាំឆ្នាំ២០១៩ នេះ រួមមានលទ្ធផលការងារសវនកម្មស្ដីពីការអនុវត្ត ការត្រួតពិនិត្យផ្ទៃក្នុងនៃត្រីមាសទី២ ត្រីមាសទី៣ និងត្រីមាសទី៤ ឆ្នាំ២០១៩ និងអនុសាសន៍ក៏ដូចជាវិធានការ និងការឯកភាពរបស់ថ្នាក់គ្រប់គ្រងសវនដ្ឋាន ។

## ២. ហានិភ័យគន្លឹះ

**ជាទូទៅហានិភ័យអាចរាប់បញ្ចូលនូវ៖**

- ហានិភ័យប្រតិបត្តិការ : ជាហានិភ័យលើការបាត់បង់ ដែលជាលទ្ធផលបរាជ័យនៃដំណើរការមនុស្ស និងប្រព័ន្ធ ឬពីហេតុការណ៍ខាងក្រៅ ។
- ហានិភ័យហិរញ្ញវត្ថុ : ជាលទ្ធភាពដែលព័ត៌មានផ្នែកហិរញ្ញវត្ថុ ត្រូវបានរៀបចំឡើងមិនត្រឹមត្រូវធ្វើឱ្យការសម្រេចចិត្តរបស់ថ្នាក់ដឹកនាំពុំសមស្រប ។
- ហានិភ័យអនុលោមភាព: ជាលទ្ធភាពដែលសកម្មភាពអនុវត្ត មិនអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិនានាជាធរមាន ។

ដោយឡែក ក្នុងកិច្ចដំណើរការសវនកម្មនៅតាមសវនដ្ឋានខាងលើ សវនករបានកំណត់ហានិភ័យគន្លឹះមួយចំនួនដូចខាងក្រោម៖

### ២.១ ការកំណត់ហានិភ័យគន្លឹះ

- លទ្ធភាពប៉ះពាល់លើគុណភាពសេវាកម្មសាធារណៈ
- លទ្ធភាពបាត់បង់ និងប្រើប្រាស់ខុសគោលដៅរបស់អង្គភាព
- លទ្ធភាពប៉ះពាល់ដល់វិន័យ និងប្រសិទ្ធភាពប្រតិបត្តិការ ។

## ៣. វិសាលភាពសវនកម្ម

សវនកម្មនេះ គ្របដណ្តប់លើការគ្រប់គ្រងសកម្មភាពប្រតិបត្តិការ និងអនុលោមភាពព្រមទាំងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង ដែលបានដំណើរការដោយ នាយកដ្ឋានប្រតិបត្តិការទីលានកុងតឺន័រ នាយកដ្ឋានប្រតិបត្តិការទំនិញទូទៅ នាយកដ្ឋាននាវាចរ-កណ្ណធារ នាយកដ្ឋានបច្ចេកទេស-សម្ភារៈ នាយកដ្ឋានគ្រឿងចក្រ នាយកដ្ឋានតំបន់សេដ្ឋកិច្ចពិសេស នាយកដ្ឋានទីផ្សារ និង នាយកដ្ឋានផែនការ-លទ្ធកម្មនិងស្ថិតិ សម្រាប់ការិយបរិច្ឆេទឆ្នាំ២០១៩។ ការប្រមូលព័ត៌មានត្រូវបានប្រព្រឹត្តទៅនៅនាយកដ្ឋានសវនកម្មផ្ទៃក្នុង កសស ។ ក្រុមការងារសវនកម្មនឹងរាយការណ៍តែអំពីចំណុចខ្វះខាត និងចំណុចដែលត្រូវផ្តល់អនុសាសន៍កែលំអប៉ុណ្ណោះ ។

## ៤. គោលបំណងសវនកម្ម

គោលបំណងក្នុងការធ្វើសវនកម្មនៅ នាយកដ្ឋានប្រតិបត្តិការទីលានកុងតឺន័រ នាយកដ្ឋានប្រតិបត្តិការទំនិញទូទៅ នាយកដ្ឋាននាវាចរ-កណ្ណធារ នាយកដ្ឋានបច្ចេកទេស-សម្ភារៈ នាយកដ្ឋានគ្រឿងចក្រ នាយកដ្ឋានតំបន់សេដ្ឋកិច្ចពិសេស នាយកដ្ឋានទីផ្សារ និង នាយកដ្ឋានផែនការ-លទ្ធកម្ម និងស្ថិតិ គឺដើម្បីពង្រឹងប្រសិទ្ធភាព និងប្រសិទ្ធផលការងារ ពង្រឹងការអនុវត្តតួនាទី-ភារកិច្ចតាមរយៈប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងដោយផ្អែកលើការវិភាគ ការវាយតម្លៃ និងអនុសាសន៍ ដែលជាលទ្ធផលនៃការធ្វើសវនកម្ម ។

ជាទូទៅ ការងារសវនកម្មផ្តោតសំខាន់លើ ប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងដើម្បីផ្តល់ការធានាសមស្របមួយ សំដៅសម្រេចឱ្យបាននូវគោលបំណងដូចខាងក្រោម៖

- **គោលបំណងប្រតិបត្តិការៈ** ការសម្រេចបានប្រកបដោយប្រសិទ្ធភាពនូវគោលបំណងប្រតិបត្តិការការងារជាក់ស្តែង ។
- **គោលបំណងព័ត៌មានហិរញ្ញវត្ថុៈ** ភាពជឿទុកចិត្ត និងភាពពេញលេញនៃព័ត៌មានផ្នែកហិរញ្ញវត្ថុដែលប្រើប្រាស់ដោយថ្នាក់គ្រប់គ្រងសវនដ្ឋាន ។
- គោលបំណងអនុលោមភាពៈ ការអនុលោមតាមច្បាប់ បទប្បញ្ញត្តិ គោលការណ៍ និងនីតិវិធីនានាជាធរមាន ។

ក្នុងកិច្ចដំណើរការសវនកម្មនេះ សវនករបានកំណត់គោលបំណងសវនកម្ម សំខាន់ៗមួយចំនួនដូចខាងក្រោម៖

- ប្រសិទ្ធភាពនៃការអនុវត្ត និងការផ្តល់សេវាសាធារណៈ
- ការពង្រឹងការគ្រប់គ្រងមន្ត្រីរាជការ វិន័យ និងប្រសិទ្ធភាពការងារ

- ការពង្រឹងការអនុលោមភាពតាមច្បាប់ បទប្បញ្ញត្តិ និងនីតិវិធីជាធរមាន
- ការពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុ និងចំណូលអាជីវកម្ម ។

## ៥. អភិក្រមសវនកម្ម

អភិក្រមសវនកម្ម រួមមានដូចខាងក្រោម៖

- ការកត់ត្រាប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង (Internal Control) តាមរយៈការត្រួតពិនិត្យឯកសារ និងការសម្ភាសន៍មន្ត្រីពាក់ព័ន្ធ
- ការកំណត់ប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងគន្លឹះ និងប្រៀបធៀបជាមួយប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងដែលបានរំពឹងទុក
- ការធ្វើតេស្តសវនកម្ម អំពីប្រសិទ្ធភាពប្រតិបត្តិការនៃប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង ។

តាមរយៈនេះ ក្រុមការងារសវនកម្មផ្ទៃក្នុង បានសហការជាមួយថ្នាក់គ្រប់គ្រង សវនដ្ឋានដើម្បីកំណត់ការរំពឹងទុក ។

## ៦. សង្ខេបលទ្ធផលគន្លឹះ

សវនករ បានកត់សម្គាល់ឃើញថា សវនដ្ឋាននៅមានចំណុចខ្វះខាតមួយចំនួនពាក់ព័ន្ធនឹងប្រសិទ្ធភាពនៃការអនុវត្ត និងការផ្តល់សេវាសាធារណៈ ការពង្រឹងការអភិវឌ្ឍន៍ធនធានមនុស្ស និងការគ្រប់គ្រងមន្ត្រី/បុគ្គលិក វិន័យ និងប្រសិទ្ធភាពការងារ ការពង្រឹងការអនុលោមភាពតាមច្បាប់ ការរៀបចំ និងអនុវត្តសំណុំបែបបទឯកសារ ដើម្បីធានាអនុលោមភាពប្រតិបត្តិការតាមលក្ខន្តិកៈបុគ្គលិក **កសស** និងបទប្បញ្ញត្តិនានាជាធរមាន ។

## ៧. សេចក្តីសន្និដ្ឋាន

ផ្អែកតាមលទ្ធផលសវនកម្មនៅ **នាយកដ្ឋានប្រតិបត្តិការទីលានកុងតឺន័រ នាយកដ្ឋានប្រតិបត្តិការទំនិញទូទៅ នាយកដ្ឋាននាវាចរ-កណ្តាល នាយកដ្ឋានបច្ចេកទេស-សម្ភារៈ នាយកដ្ឋានគ្រឿងចក្រ នាយកដ្ឋានតំបន់សេដ្ឋកិច្ចពិសេស នាយកដ្ឋានទីផ្សារ** និង **នាយកដ្ឋានផែនការ-លទ្ធកម្មនិងស្ថិតិ** សម្រាប់ការិយបរិច្ឆេទឆ្នាំ ២០១៩ ក្រុមការងារសវនកម្មបានសង្កេតឃើញថា ប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងមួយចំនួនត្រូវបានរៀបចំល្អ និងមានប្រសិទ្ធភាពដោយមានកិច្ចសហការរវាងមន្ត្រីគ្រប់ជាន់ថ្នាក់ក្នុងការអនុវត្តការងារ ស្របតាមសេចក្តីកំណត់ស្តីពីរចនាសម្ព័ន្ធ និងភារកិច្ចរបស់នាយកដ្ឋាននីមួយៗ។ ទោះជាយ៉ាងនេះក្តី សវនដ្ឋាននៅមានចំណុចដែលត្រូវកែលម្អលើការគ្រប់គ្រងវិន័យ និងបំពេញបន្ថែមលើកង្វះខាតថ្នាក់ដឹកនាំក្នុងក្របខ័ណ្ឌនាយកដ្ឋាន និងការិយាល័យដោយចំណុចទាំងនេះនៅមិនទាន់មានលក្ខណៈល្អប្រសើរគ្រប់ជ្រុងជ្រោយនៅឡើយ និងតម្រូវអោយមានការបំពេញបន្ថែមជាចាំបាច់ ។

## ៨. វិធានការកែលម្អ

អនុសាសន៍ ដែលបានផ្តល់ជូនក្នុងគោលបំណង ដើម្បីធ្វើអោយល្អប្រសើរឡើងនូវការអនុវត្ត ដំណើរការធុរកិច្ច និងការគ្រប់គ្រងរបស់សវនដ្ឋានត្រូវបានបញ្ចូលក្នុងលទ្ធផលលម្អិត (ផ្នែក ខ)។ អនុសាសន៍អំពីការខ្វះខាតមួយចំនួនត្រូវបានឯកភាពជាមួយថ្នាក់គ្រប់គ្រងសវនដ្ឋាន ជាលាយលក្ខណ៍អក្សរ។ លទ្ធផលលម្អិត (ផ្នែក ខ) ក៏បានរំលេចអំពីការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រងសវនដ្ឋាន ចំពោះអនុសាសន៍របស់សវនករ និងចំណុចខ្វះខាតផងដែរ ។

វិធានការរបស់ថ្នាក់គ្រប់គ្រងសវនដ្ឋាន ត្រូវបានរំលេចនៅក្នុងផែនការកែលម្អ ដូចមានចែងនៅក្នុង ឧបសម្ព័ន្ធ ២ ដែលបានភ្ជាប់ជូនមកជាមួយនេះ ។

## ៩. ការថ្លែងអំណរគុណ

កិច្ចដំណើរការសវនកម្មនេះ ត្រូវបានដឹកនាំដោយលោក **ម៉ែន ចាន់** នាយកនាយកដ្ឋានសវនកម្មផ្ទៃក្នុង ព្រមទាំងសមាជិកក្រុមការងារ ក្នុងការធ្វើសវនកម្មនេះ ។

ក្រុមការងារសវនកម្មផ្ទៃក្នុង សូមថ្លែងអំណរគុណចំពោះលោកនាយក **នាយកដ្ឋានប្រតិបត្តិការទីលានកុងតឺន័រ** **នាយកដ្ឋានប្រតិបត្តិការទំនិញទូទៅ** **នាយកដ្ឋាននាវាចរ-កណ្ណធារ** **នាយកដ្ឋានបច្ចេកទេស-សម្ភារៈ** **នាយកដ្ឋានគ្រឿងចក្រ** **នាយកដ្ឋានតំបន់សេដ្ឋកិច្ចពិសេស** លោកស្រីនាយិកា **នាយកដ្ឋានទីផ្សារ** និងលោកនាយក **នាយកដ្ឋានផែនការលទ្ធកម្ម និងស្ថិតិ** ព្រមទាំងសហការីដែលបានសហការផ្តល់ព័ត៌មាន និងមតិយោបល់ដ៏មានតម្លៃ ដើម្បីអោយកិច្ចដំណើរការសវនកម្មនេះអាចប្រព្រឹត្តទៅបានតាមការគ្រោងទុក ។

# ផ្នែក ខ: លទ្ធផលសវនកម្មលម្អិត

## ១. សមាសភាពក្រុមការងារសវនកម្មផ្ទៃក្នុង និងគោលសំខាន់ៗ

### ១.១ ក្រុមការងារសវនកម្ម រួមមានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| - លោក ម៉ែន ចាន់ | នាយកសវនកម្មផ្ទៃក្នុង |
| - លោក ជីវ ច័ន្ទសុភាព | សមាជិក |
| - លោក ហោ សុធី | សមាជិក |
| - លោកស្រី ទូច វណ្ណា | សមាជិក |
| - លោក ជីវ ច័ន្ទសុធា | សមាជិក |
| - លោកស្រី ឈុន ហឿនរីណា | សមាជិក |
| - លោក ភាព ម៉េងស្រៀន | សមាជិក |
| - លោកស្រី ខន សុខុម | សមាជិក |

- លោកស្រី រ័ត្ន និមល                                        សមាជិក

១.២ ខណៈគោលសំខាន់ៗ

**ខាងក្រោមនេះគឺជាខណៈគោលសំខាន់ៗ នៅក្នុងដំណើរការសវនកម្ម៖**

- ការធ្វើសវនកម្មបានបញ្ចប់ ថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០
- សេចក្តីព្រាងលើកទី១ បានបញ្ចប់ ថ្ងៃទី២៤ ខែមករា ឆ្នាំ២០២០
- ការឆ្លើយតបចុងក្រោយពីថ្នាក់ដឹកនាំសវនដ្ឋាន ថ្ងៃទី៣០ ខែមករា ឆ្នាំ២០២០
- របាយការណ៍ស្ថាពរ ថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០

## ២. ទិដ្ឋភាពរួមសវនកម្មផ្ទៃក្នុង

គោលបំណងរួមនៃសវនកម្មផ្ទៃក្នុង គឺដើម្បីជួយថ្នាក់ដឹកនាំសវនដ្ឋាន ធ្វើអោយកាន់តែល្អប្រសើរឡើងនូវដំណើរការគ្រប់គ្រង ការត្រួតពិនិត្យផ្ទៃក្នុង និងអភិបាលកិច្ចល្អ។ ការគ្រប់គ្រងផ្ទៃក្នុងត្រូវបានអនុវត្តដោយថ្នាក់ដឹកនាំសវនដ្ឋាន និងមន្ត្រីមួយចំនួនទៀត ដើម្បីធានាអោយសម្រេចបាននូវគោលបំណងដូចខាងក្រោម៖

- ប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល
- របាយការណ៍ហិរញ្ញវត្ថុគួរអោយទុកចិត្តបាន
- អនុលោមភាពតាមលក្ខន្តិកៈបុគ្គលិក បទបញ្ជាផ្ទៃក្នុងរបស់ **កសស** និងបទដ្ឋាននានាជាធរមាន ។

ការធ្វើសវនកម្មនេះក៏ពិនិត្យលើការរៀបចំ និងប្រតិបត្តិការនៃប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងផងដែរ ។

## ៣. ការពិនិត្យលើការគ្រប់គ្រងផ្ទៃក្នុង

សវនករ បានវាយតម្លៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដោយផ្អែកលើការពិនិត្យសមត្ថភាពនៃដំណើរការគ្រប់គ្រង ដើម្បីសម្រេចបាននូវគោលបំណងគ្រប់គ្រងស្របតាមសេចក្តីកំណត់ស្តីពីរចនាសម្ព័ន្ធ និងភារកិច្ចរបស់ **នាយកដ្ឋានប្រតិបត្តិការទីលានកុងតឺន័រ នាយកដ្ឋានប្រតិបត្តិការទំនិញទូទៅ នាយកដ្ឋាននាវាចរ-កណ្តាធារ នាយកដ្ឋានបច្ចេកទេស-សម្ភារៈ នាយកដ្ឋានគ្រឿងចក្រ នាយកដ្ឋានតំបន់សេដ្ឋកិច្ចពិសេស នាយកដ្ឋានទីផ្សារ** និង **នាយកដ្ឋានផែនការ លទ្ធកម្ម និងស្ថិតិ** ។

## ៤. ព័ត៌មានអំពីសវនដ្ឋានរួម

**នាយកដ្ឋានប្រតិបត្តិការទីលានកុងតឺន័រ នាយកដ្ឋានប្រតិបត្តិការទំនិញទូទៅ នាយកដ្ឋាននាវាចរ-កណ្តាធារ នាយកដ្ឋានបច្ចេកទេស-សម្ភារៈ នាយកដ្ឋានគ្រឿងចក្រ នាយកដ្ឋានតំបន់សេដ្ឋកិច្ចពិសេស នាយកដ្ឋានទីផ្សារ** និង **នាយកដ្ឋានផែនការ លទ្ធកម្ម និងស្ថិតិ** ស្ថិតក្រោមការគ្រប់គ្រងរបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ ដោយអនុលោមតាមអនុក្រឹត្យលេខ ៥០ អនក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨ ស្តីពីការបង្កើត

កំពង់ផែស្វយ័តក្រុងព្រះសីហនុ (**កសស**) និងដំណើរការតាមសេចក្ដីកំណត់ស្ដីពីរចនាសម្ព័ន្ធនិងតួនាទី-ភារកិច្ចសម្រាប់នាយកដ្ឋាននីមួយៗរបស់ **កសស** ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៦ ។

## ៤.១ ការទទួលខុសត្រូវ

### ៤.១.១ ការទទួលខុសត្រូវរបស់សវនដ្ឋាន

**នាយកដ្ឋានប្រតិបត្តិការទីលានកុងតឺន័រ នាយកដ្ឋានប្រតិបត្តិការទំនិញទូទៅ នាយកដ្ឋាននាវាចរ-កណ្ដធារ នាយកដ្ឋានបច្ចេកទេស-សម្ភារៈ នាយកដ្ឋានគ្រឿងចក្រ នាយកដ្ឋានតំបន់សេដ្ឋកិច្ចពិសេស នាយកដ្ឋានទីផ្សារ** និង **នាយកដ្ឋានផែនការលទ្ធកម្ម និងស្ថិតិ** ទទួលខុសត្រូវចំពោះការគ្រប់គ្រងប្រព័ន្ធផ្ទៃក្នុងរបស់ខ្លួន ព្រមទាំងប្រសិទ្ធភាពប្រតិបត្តិការ និងអនុលោមភាពនៅក្នុងនាយកដ្ឋានក៏ដូចជាក្នុងក្របខ័ណ្ឌរួមរបស់ **កសស** ។

### ៤.១.២ ការទទួលខុសត្រូវរបស់ក្រុមការងារសវនកម្មផ្ទៃក្នុង

ក្រុមការងារសវនកម្មផ្ទៃក្នុង ទទួលខុសត្រូវតែលើរបាយការណ៍សវនកម្មនេះប៉ុណ្ណោះ ។

# ៥. លទ្ធផលសវនកម្ម

## ៥.១ ផ្នែកប្រសិទ្ធភាពប្រតិបត្តិការ

គោលបំណងនៃការត្រួតពិនិត្យនេះ គឺដើម្បីលើកកំពស់គុណភាព ប្រតិបត្តិការអាជីវកម្ម សេវាកម្មរបស់ **កសស** ប្រកបដោយប្រសិទ្ធភាព និងទទួលបានសេចក្ដីទុកចិត្តពីអតិថិជន អ្នកប្រើប្រាស់ផែ ភាពទន់ភ្លន់នៃតម្លៃ និងដើម្បីផ្ដល់សេវាកម្មជូនអតិថិជន បានឆាប់រហ័សតាមតម្រូវការទីផ្សារ និងជួយជម្រុញអោយសវនដ្ឋានអនុវត្តតួនាទី-ភារកិច្ចរបស់ខ្លួន ស្របតាមសេចក្ដីកំណត់ និងតម្រូវការរបស់អង្គភាព ក៏ដូចជានីតិវិធីរដ្ឋបាលសាធារណៈ និងលក្ខន្តិកៈបុគ្គលិក **កសស** ព្រមទាំងច្បាប់ និងបទប្បញ្ញត្តិនានាជាធរមាន ។

## ៥.២ លទ្ធផលនៃការអង្កេតវិជ្ជមាន

សវនករបានពិនិត្យឃើញថ្នាក់ដឹកនាំ មន្ត្រី និយោជិតក្នុងក្របខ័ណ្ឌ**នាយកដ្ឋានប្រតិបត្តិការទីលានកុងតឺន័រ នាយកដ្ឋានប្រតិបត្តិការទំនិញទូទៅ នាយកដ្ឋាននាវាចរ-កណ្ដធារ នាយកដ្ឋានបច្ចេកទេស-សម្ភារៈ នាយកដ្ឋានគ្រឿងចក្រ នាយកដ្ឋានតំបន់សេដ្ឋកិច្ចពិសេស នាយកដ្ឋានទីផ្សារ** និង **នាយកដ្ឋានផែនការលទ្ធកម្ម និងស្ថិតិ** ព្រមទាំងការិយាល័យ និងផ្នែកពាក់ព័ន្ធបាននឹងកំពុងអនុវត្តការងាររបស់ខ្លួនស្របតាមតួនាទី-ភារកិច្ចដែល **កសស** បានកំណត់ និងបានយកចិត្តទុកដាក់អនុវត្តការងារតាមមុខជំនាញរៀងៗខ្លួនក្នុងស្មារតីទទួលខុសត្រូវខ្ពស់ និងបានសហការផ្ដល់ឯកសារដល់សវនករ ដើម្បីជួយជម្រុញអោយការងារសវនកម្មផ្ទៃក្នុងរបស់ **កសស** អាចប្រព្រឹត្តទៅបាន ស្របតាមកិច្ចដំណើរការសវនកម្ម និងប្រកបដោយភាពរលូន ។

## ៥.៣ លទ្ធផលនៃការអង្កេតអវិជ្ជមាន

### ក. នាយកដ្ឋានប្រតិបត្តិការទីលានកុងតឺន័រ

១.	សវនករបានសង្កេតឃើញថា **នាយកដ្ឋានប្រតិបត្តិការទីលានកុងតឺន័រ** ក៏ដូចជាការិយាល័យ និងផ្នែកពាក់ព័ន្ធមួយចំនួននៅមានចំណុចខ្វះខាត ដែលត្រូវធ្វើការកែលម្អនិងបំពេញបន្ថែមដូចខាងក្រោម៖

### ១.១	ផ្នែករថយន្តស្ទូចចល័តលើទីលាន (RTG "RUBBER TYRED GANTRY CRANE")

**កសស** មានរថយន្តស្ទូចចល័តលើទីលានសរុបចំនួន ១៦ គ្រឿង កំពុងប្រើប្រាស់ដើម្បីបម្រើប្រតិបត្តិការអាជីវកម្ម ០៣ វេន/ថ្ងៃ ដោយប្រើប្រាស់ប្រតិបត្តិករ ១៥ នាក់/០១ វេន និងតម្រូវអោយប្រតិបត្តិករ ០១ នាក់បើកបររថយន្តស្ទូច ០១ គ្រឿង។ សវនករបានពិនិត្យឃើញថា ដោយមានកង្វះខាតប្រតិបត្តិករផ្នែក RTG បានស្នើសុំប្រតិបត្តិករបន្ថែម ០១ នាក់ទៀត ដើម្បីមានលទ្ធភាពប្រើប្រាស់រថយន្តស្ទូចចល័តលើទីលានបានទាំង ១៦ គ្រឿង តាមវេនការងារដែល **កសស** បានកំណត់ ០៣ វេន/ថ្ងៃ និងស្នើសុំពេលឈប់សម្រាកហូបបាយពី ២០ ទៅ ៣០ នាទី ពីព្រោះកន្លងមកប្រតិបត្តិករ បានឈប់សម្រាកហូបបាយតែ ១៥ នាទីប៉ុណ្ណោះ ។

**មតិឆ្លើយតបរបស់សវនដ្ឋាន៖**

ដើម្បីប្រើប្រាស់រថយន្តស្ទូចចល័តលើទីលាន សមស្របតាមលក្ខណៈបច្ចេកទេស និងមានលទ្ធភាពបង្កើនផលិតភាពរបស់ខ្លួនបន្ថែមទៀត ប្រធានផ្នែក RTG បានស្នើសុំកម្លាំងបន្ថែម ០១ នាក់ទៀត និងស្នើសុំពេលឈប់សម្រាកហូបបាយពី ២០-៣០ នាទី ។

### ១.២	ផ្នែករថយន្តលើករៀបកុងតឺន័រ (REACH STACKER)

សវនករបានពិនិត្យឃើញ រថយន្តលើករៀបកុងតឺន័ររបស់ **កសស** មានចំនួនសរុប ០៩ គ្រឿង ក្នុងនេះផ្នែក Reach Stacker បានបែងចែកប្រតិបត្តិករ ០២-០៣ នាក់អោយគ្រប់គ្រងនិងបើកបររថយន្តលើករៀបកុងតឺន័រ ០១ គ្រឿង x ០៣ វេន/០១ ថ្ងៃ។ ដើម្បីអនុវត្តតាមគោលការណ៍ដែល **កសស** បានកំណត់ ០៣ វេន/០១ ថ្ងៃ បានដោយប្រសិទ្ធភាព ផ្នែក Reach Stacker បានស្នើសុំបន្ថែមប្រតិបត្តិករ ០១ នាក់ទៀតសម្រាប់រថយន្តលើករៀបកុងតឺន័រ ដែលមានប្រតិបត្តិករតែ ០២ នាក់ ដើម្បីផ្លាស់ប្តូរវេនគ្នាបើកបរ និងចៀសវាងភាពយឺតយ៉ាវ ក៏ដូចជាគ្រោះថ្នាក់ ឬការខាតបង់ផលប្រយោជន៍រួមរបស់ **កសស** ក្នុងករណីមានប្រតិបត្តិករណាម្នាក់ឈឺ ឬមានហេតុការណ៍អ្វីមួយកើតឡើងជាយថាហេតុ ។

**មតិឆ្លើយតបរបស់សវនដ្ឋាន៖**

ដើម្បីប្រើប្រាស់រថយន្តលើករៀបកុងតឺន័រ សមស្របតាមលក្ខណៈបច្ចេកទេស និងមានលទ្ធភាពបង្កើនផលិតភាពរបស់ខ្លួនបន្ថែមទៀត ប្រធានផ្នែក Reach Stacker បានស្នើសុំកម្លាំងបន្ថែម ០១ នាក់ទៀត ។

### ១.៣	ផ្នែករថយន្តដឹកទំនិញ (PLATFORM)

ក្នុងចំណោមរថយន្តដឹកទំនិញទាំង ០៩ គ្រឿងរបស់ **កសស** សវនករបានពិនិត្យឃើញមានការបែងចែងប្រតិបត្តិករ ០២-០៣ នាក់ អោយគ្រប់គ្រង និងបើកបររថយន្តដឹកទំនិញ ០១ គ្រឿង x ០៣ វេន/០១ ថ្ងៃ។ ក្នុងនេះ ផ្នែករថយន្តដឹកបានស្នើសុំបន្ថែមប្រតិបត្តិករ ០១ នាក់ទៀត សម្រាប់រថយន្តដឹកដែលមានប្រតិបត្តិករតែ ០២នាក់ ដើម្បីផ្លាស់ប្តូរវេនគ្នាបើកបរ និងចៀសវាងភាពយឺតយ៉ាវ ក៏ដូចជាគ្រោះថ្នាក់ ឬការខាតបង់ផល

ប្រយោជន៍ រួមរបស់ **កសស** ក្នុងករណីមានប្រតិបត្តិករណាម្នាក់ឈឺ ឬមានហេតុការណ៍អ្វីមួយកើតឡើងជាយថា ហេតុ ។

**មតិឆ្លើយតបរបស់សវនដ្ឋាន៖**

ដើម្បីបំពេញតាមម៉ោងប្រតិបត្តិការអាជីវកម្មរបស់ **កសស** និងអាចបម្រើការងារប្រកបដោយប្រសិទ្ធភាព ប្រធានផ្នែករថយន្តដឹកទំនិញ បានស្នើសុំកម្លាំងបន្ថែម ០១ នាក់ទៀត សម្រាប់រថយន្តដែលមានអ្នកបើកបរតែ ០២ នាក់ ។

## ១.៤ ផ្នែកបន្ទប់ត្រួតពិនិត្យទីលានកុងតឺន័រ (CONTROL ROOM)

សវនករបានពិនិត្យឃើញ ផ្នែកត្រួតពិនិត្យទីលានកុងតឺន័រមានបុគ្គលិកសរុបចំនួន ១២ នាក់ ដោយបែងចែកជា ០៤ ក្រុម តាមវេនការងារដែល **កសស** បានកំណត់ដូចខាងក្រោម៖

- វេន ១ : ពីម៉ោង ០៨: ០០ - ម៉ោង ១៦:០០ (សម្រាកពីម៉ោង ១២:០០ ដល់ម៉ោង ១៣:០០)
- វេន ២ : ពីម៉ោង ១៦:០០ - ម៉ោង ២៤:០០ (សម្រាកពីម៉ោង ២០:០០ ដល់ម៉ោង ២១:០០)
- វេន ៣ : ពីម៉ោង ២៤:០០ - ម៉ោង ០៨: ០០ (សម្រាកពីម៉ោង ០៤:០០ ដល់ម៉ោង ០៥:០០) ។

### ១.៤.១ អំពីតួនាទីនិងភារកិច្ច

សវនករបានពិនិត្យឃើញ នាយកដ្ឋានប្រតិបត្តិការទីលានកុងតឺន័រ បង្កើតក្រុមការងារមួយរួមមានផ្នែកគ្រប់គ្រងគ្រឿងចក្រ ផ្នែកឯកសារ ផ្នែកត្រួតពិនិត្យកុងតឺន័រ/ផ្នែករៀបចំផែនការទីលាន និងផ្នែកប្រតិបត្តិការនាវា/ផ្នែករៀបចំផែនការនាវា ដើម្បីបង្កើនប្រសិទ្ធភាពការងារ នៅក្នុងទីលានកុងតឺន័ររបស់ កសស ។ ក្នុងនេះ សវនករបានពិនិត្យឃើញ ផ្នែកត្រួតពិនិត្យកុងតឺន័រ/ផ្នែករៀបចំផែនការទីលានកុងតឺន័រ មានមន្ត្រីជំនាញ ០៤ នាក់ ប៉ុន្តែក្នុងចំណោមមន្ត្រីទាំង ០៤ នាក់នេះ មានតែម្នាក់ប៉ុណ្ណោះដែលមានសិទ្ធិរៀបចំផែនការស្តុកកុងតឺន័រនៅក្នុងទីលាន ។

**មតិឆ្លើយតបរបស់សវនដ្ឋាន៖**

ការរៀបចំផែនការស្តុកកុងតឺន័រនៅក្នុងទីលាន ត្រូវមានបទពិសោធន៍ច្បាស់លាស់ និងធ្វើឡើងតាមលក្ខណៈបច្ចេកទេស និងសមត្ថភាពទីលាន ដូច្នេះតម្រូវអោយពួកគាត់ធ្វើការបណ្តើររៀនបណ្តើរ រហូតដល់មានភាពស្ទាត់ជំនាញ ទើបអនុញ្ញាតអោយបំពេញការងារដោយឯករាជ ។

## ២. នាយកដ្ឋានប្រតិបត្តិការទំនិញទូទៅ

១.	សវនករបានសង្កេតឃើញថា នាយកដ្ឋានប្រតិបត្តិការទំនិញទូទៅ ក៏ដូចជាការិយាល័យនិងផ្នែកពាក់ព័ន្ធមួយចំនួននៅមានចំណុចខ្វះខាត ដែលត្រូវធ្វើការកែលម្អ និងបំពេញបន្ថែមដូចខាងក្រោម៖

## ១.១ ផ្នែករថយន្តស្ទូច

**កសស** មានរថយន្តស្ទូចចល័តសរុបចំនួន ២០ គ្រឿង ក្នុងនេះមាន ០៣ គ្រឿងត្រូវបានជម្រះបញ្ជីក្នុងអំឡុងឆ្នាំ២០១៧។ ក្នុងចំណោមអ្នកបើកបររថយន្តស្ទូចចល័តខាងលើមាន ០២ នាក់ បានបាត់បង់សមត្ថភាពការងារអស់រយៈពេលជាយូរមកហើយ ប៉ុន្តែថ្នាក់ដឹកនាំសវនដ្ឋានមិនមានឯកសារបញ្ជាក់ច្បាស់លាស់ ។

**មតិឆ្លើយតបរបស់សវនដ្ឋាន៖**

អ្នកបើកបររថយន្តស្ទូចចល័តទាំង ០២ នាក់នោះ ត្រូវបានសម្រួលការងារជូន និងបញ្ឈប់ពីការបើកបរហើយ។

## ១.២ ផ្នែករថយន្តដឹកទំនិញ

**កសស** មានរថយន្តដឹកទំនិញសរុបចំនួន ២៨ គ្រឿង ក្នុងនេះមាន ១១ គ្រឿងត្រូវបានជម្រះបញ្ជីក្នុងអំឡុងឆ្នាំ២០១៧ ។

ពាក់ព័ន្ធនឹងម៉ោងការងារអាជីវកម្ម សវនករបានសង្កេតឃើញថា ដោយបរិមាណទំនិញ-កុងតឺន័រឆ្លងកាត់កំពុងកើនឡើងយ៉ាងគំហុក កម្មករបើកបរថយន្តដឹកទំនិញបានធ្វើការលើសម៉ោងដែល **កសស** បានកំណត់ ហើយដោយមានអ្នកបើកបរមិនគ្រប់គ្រាន់តាមតម្រូវការ ពេលខ្លះពួកគាត់ធ្វើការលើសពី ០៨ ម៉ោងរហូតដល់ ១២ ម៉ោងក្នុងមួយថ្ងៃ ។

**មតិឆ្លើយតបរបស់សវនដ្ឋាន៖**

សវនដ្ឋាននឹងសម្រួលការងារ និងស្នើសុំគោលការណ៍ថ្នាក់ដឹកនាំ **កសស** បន្ថែមកម្លាំងបើកបរជូនដើម្បីអោយពួកគាត់ធ្វើការងារត្រឹមតែពេលម៉ោងប្រតិបត្តិការដែល **កសស** បានកំណត់ ។

## ១.៣ ផ្នែករថយន្តចូក

ដោយត្រូវបានបន្ថែម ០២ គ្រឿងទៀត រថយន្តចូកមានចំនួនសរុប ១០ គ្រឿង ប៉ុន្តែក្នុងចំណោមរថយន្តចូកទាំង ១០ គ្រឿងនេះ មាន ០៤ គ្រឿងត្រូវបានជម្រះបញ្ជីក្នុងអំឡុងឆ្នាំ២០១៧ ។

តាមការសាកសួរអ្នកគ្រប់គ្រងគ្រឿងចក្របានអោយដឹងថា ផ្នែករថយន្តចូកមានកម្មករបើកបរ ០១ នាក់បានឈឺបាត់បង់សតិ/ស្មារតីចងចាំ ប៉ុន្តែរហូតមកដល់ពេលនេះ អ្នកគ្រប់គ្រងគ្រឿងចក្រមិនមានឯកសារពេទ្យបញ្ជាក់ច្បាស់លាស់ទេ។ តាមការសង្កេតឃើញថា ពេលខ្លះគាត់ចតគ្រឿងចក្រ/ទុកចោលក្នុងការដ្ឋានការងារ ហើយពេលខ្លះទៀតគាត់បើកគ្រឿងចក្រមកទុកនៅកន្លែងធ្វើការតែម្តង ។

**មតិឆ្លើយតបរបស់សវនដ្ឋាន៖**

អ្នកបើកបររថយន្តចូក ០១ នាក់ ដែលឈឺបាត់បង់ការស្មារតី ឬការចងចាំនោះ ត្រូវបានសម្រួលការងារជូន និងបញ្ឈប់ពីការបើកបរហើយ ។

## ១.៤ ការធ្វើផែនការផ្ទេរ-ផ្ទុក ទំនិញទៅតាមប្រភេទប្រតិបត្តិការ

សវនករបានពិនិត្យឃើញ សវនដ្ឋានបែងចែកការងារតាមប្រភេទ ប្រតិបត្តិការអាជីវកម្មរបស់ **កសស** រួមមានផែនការប្រចាំថ្ងៃ ផែនការអាជីវកម្ម និងសរុបតោនលើករៀប ប៉ុន្តែមិនបានបញ្ជាក់អំពីតម្រូវការកម្លាំងកម្មករ មធ្យោបាយគ្រឿងចក្រ និងសម្ភារប្រើប្រាស់។ ល។ ដើម្បីអនុវត្តផែនការច្បាស់លាស់ទេ ។

**មតិឆ្លើយតបរបស់សវនដ្ឋានៈ**

ការរៀបចំផែនការប្រចាំថ្ងៃ ផែនការអាជីវកម្ម និងសរុបតោនលើករៀប ត្រូវធ្វើឡើងតាមតម្រូវការជាក់ស្តែង បានន័យថាយើងចល័តកម្លាំងលៃបំរុងសម្ភារ និងមធ្យោបាយប្រើប្រាស់តាមបរិមាណទំនិញ ។

## គ. នាយកដ្ឋាននាវាចរ-កណ្តាធារ

១. សវនករបានសង្កេតឃើញថា **នាយកដ្ឋាននាវាចរ-កណ្ណធារ** ក៏ដូចជាការិយាល័យ និងផ្នែកពាក់ព័ន្ធមួយចំនួននៅមានចំណុចខ្វះខាតដែលត្រូវធ្វើការកែលម្អ និងបំពេញបន្ថែមដូចខាងក្រោមៈ

### ១.១ រចនាសម្ព័ន្ធនិងភារកិច្ច

យោងតាមរចនាសម្ព័ន្ធ និងភារកិច្ចរបស់ **នាយកដ្ឋាននាវាចរ-កណ្ណធារ** សវនករបានពិនិត្យឃើញមានការិយាល័យ ០២ នៅមិនទាន់បានបង្កើតឡើងនៅឡើយ។ ដោយឡែក ការិយាល័យសន្តិសុខដែលត្រូវបានបង្កើតឡើងរួចហើយនោះ នៅមិនទាន់បានបញ្ចូលក្នុងរចនាសម្ព័ន្ធគ្រប់គ្រងរួមរបស់ **នាយកដ្ឋាននាវាចរ-កណ្ណធារ** នៅឡើយ ។

ប្រការខាងលើ ធ្វើឱ្យរចនាសម្ព័នគ្រប់គ្រងរបស់សវនដ្ឋាន មានភាពមិនច្បាស់លាស់ ធ្វើឱ្យប៉ះពាល់ប្រសិទ្ធភាពប្រតិបត្តិការប្រចាំថ្ងៃ ធ្វើឱ្យថ្នាក់ដឹកនាំសវនដ្ឋាន និងមន្ត្រីសំខាន់ៗមួយចំនួនអនុវត្តការងារត្រួតគ្នា ឬអាចមានភាពទំនេរពីក្រៅពីការងារច្រើន និងមិនអនុលោមតាមសេចក្តីកំណត់ស្តីពីរចនាសម្ព័ន្ធនិងភារកិច្ចរបស់ **នាយកដ្ឋាននាវាចរ-កណ្ណធារ** នៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៦ ។

ដើម្បីរួមចំណែកលើកកំពស់ប្រសិទ្ធភាព និងប្រសិទ្ធផលប្រតិបត្តិការអាជីវកម្ម សេវាកម្មរបស់ **កសស** ដឹកនាំសវនដ្ឋានគួររៀបចំរចនាសម្ព័ន្ធគ្រប់គ្រងជាថ្មី ដោយយោងតម្រូវការដែលបានស្នើសុំនៅក្នុងផែនការពលកម្មឆ្នាំ២០១៩ ដាក់ជូននាយកដ្ឋានរដ្ឋបាល-ធនធានមនុស្ស ពិនិត្យ និងរៀបចំបែបបទស្នើសុំថ្នាក់ដឹកនាំ **កសស** បង្កើតការិយាល័យ ០២ ទៀត និងស្នើសុំតែងតាំងប្រធានការិយាល័យជាផ្លូវការ ដើម្បីរួមគ្នាបំពេញការងារដោយភាពរលូន តម្លាភាព និងស្របតាមរចនាសម្ព័ន្ធ និងភារកិច្ចដែល **កសស** បានកំណត់ ។

**មតិឆ្លើយតបរបស់សវនដ្ឋានៈ**

សវនដ្ឋានមិនបានឆ្លើយតប ។

### ១.២ សម្រង់បញ្ជីវត្តមានប្រចាំថ្ងៃ

យោងតាមសម្រង់បញ្ជីវត្តមានការងារប្រចាំថ្ងៃ ដែលទទួលបានពីសវនដ្ឋាន និងផ្នែកពាក់ព័ន្ធ សវនករបានពិនិត្យឃើញបុគ្គលិក ០៣ (បី) រូប អវត្តមាន/មិនបានចុះហត្ថលេខា ក្នុងសម្រង់បញ្ជីវត្តមានខែកក្កដា និងខែសីហានៃការិយបរិច្ឆេទឆ្នាំ២០១៩ អស់រយៈពេល ០២ ខែជាប់គ្នា ដោយមិនបានបញ្ជាក់មូលហេតុច្បាស់លាស់។

ប្រការខាងលើ មិនអនុលោមតាមគោលការណ៍ ដែលមានចែងនៅក្នុងប្រការ ៤៣ នៃលក្ខន្តិកៈបុគ្គលិកកំពង់ផែស្វយ័តក្រុងព្រះសីហនុ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០០៣ និងចំណុចទី៣ នៃបទបញ្ជាផ្ទៃក្នុងរបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ លេខ ០០១.បបផក/កសស/រប.ប ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៧ ។

ដើម្បីលើកកម្ពស់វិន័យការងារ និងភាពថ្លៃថ្នូរបស់អង្គភាព សវនករយល់ឃើញថាថ្នាក់ដឹកនាំ **នាយកដ្ឋាននាវាចរ-កណ្ណធារ** គួរពិនិត្យឡើងវិញ និងចាត់វិធានការបុគ្គលិកដែលអវត្តមានដោយមិនបានបញ្ជាក់មូលហេតុច្បាស់លាស់ ដោយអនុវត្តតាមបទប្បញ្ញត្តិទូទៅ នៃលក្ខន្តិកៈបុគ្គលិក **កសស** ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០០៣ និងចំណុចទី៣ នៃបទបញ្ជាផ្ទៃក្នុងរបស់ **កសស** ។

**មតិឆ្លើយតបរបស់សវនដ្ឋានៈ**

ថ្នាក់ដឹកនាំសវនដ្ឋាន នឹងពិនិត្យ-សួរនាំដើម្បីកែលម្អបុគ្គលិកទាំង ០៣ នាក់ ។

## ១.៣ ប្រព័ន្ធគ្រប់គ្រង CCTV Camera

តាមការចុះពិនិត្យផ្ទាល់ និងការជួបជាមួយប្រធានផ្នែកគ្រប់គ្រងសុវត្ថិភាព សវនករបានពិនិត្យឃើញ Camera សុវត្ថិភាពចំនួន ១៥ គ្រឿង ខូចមិនអាចប្រើប្រាស់បាន ។

ប្រការខាងលើនេះ បានកើតមានឡើងដោយសារការខូច/ដាច់ខ្សែភ្លើង ក្រោមដីមួយចំនួននិងបាតុភូតធម្មជាតិដូចជារន្ទះបាញ់ ជាហេតុបណ្តាលអោយផ្នែកបច្ចេកទេស មិនអាចបញ្ជូនភ្លើងទៅប្រើប្រាស់បានគ្រប់គ្រាន់។ កត្តានេះ អាចបណ្តាលអោយមានភាពមិនល្អប្រសើរ និងប៉ះពាល់ដល់ការធានាប្រតិបត្តិការអាជីវកម្មសេវាកម្ម ជាពិសេសការគ្រប់គ្រងសន្តិសុខ សុវត្ថិភាព និងសណ្តាប់នៅធ្នាប់ក្នុងបរិវេណ **កសស** ។

សវនករយល់ឃើញថា ថ្នាក់ដឹកនាំសវនដ្ឋាននិងនាយកដ្ឋានពាក់ព័ន្ធ គួរចាំបាច់សហការត្រួតពិពិត្យស្ថានភាពជាក់ស្តែង និងស្នើសុំថ្នាក់ដឹកនាំ **កសស** ជួសជុលអោយបានឆាប់ ដើម្បីធានាសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់ ជូនអតិថិជន អ្នកប្រើប្រាស់ផែ និងចៀសវាងការបាត់បង់ទ្រព្យសម្បត្តិរបស់អង្គភាព ។

**មតិឆ្លើយតបរបស់សវនដ្ឋានៈ**

សវនដ្ឋានបានឯកភាពស្នើសុំជួសជុលអោយបានឆាប់ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រងសន្តិសុខ សុវត្ថិភាព ។

## ១.៤ អាងនាវាសណ្តោង

តាមការចុះពិនិត្យទីតាំងអាងនាវាសណ្តោង និងការជួបជាមួយប្រធានផ្នែកគ្រប់គ្រងមធ្យោបាយជើងទឹកផ្ទាល់សវនករសង្កេតឃើញថា ក្នុងបរិវេណផ្ទៃទឹកនៃអាងនាវាសណ្តោងមានលក្ខណៈចង្អៀតខ្លាំង ហើយជម្រៅទឹកក្នុងអាងនាវាមានសភាពរាក់ជាងមុន ។

ករណីនេះ បានកើតមានឡើងដោយសារក្រុមហ៊ុនឯកជនមួយចំនួន បានយកអូប័រទំនើបៗទាំងខ្នាតតូច និងខ្នាតធំចូលចត ព្រមទាំងមានទូកនេសាទឈើរបស់ប្រជានេសាទ ចូលចតរួមគ្នាក្នុងអាងតែមួយ និងមានល្បាប់ភក់ហូរចូលអាងនាវា ។

ប្រការខាងលើនេះ អាចធ្វើអោយខូចខាតទាំងផ្នែកបាត និងផ្នែកខាងលើរបស់នាវាដែលជាហេតុបណ្តាលអោយមានការរាំងស្ទះ និងប៉ះពាល់ដល់ប្រតិបត្តិការអាជីវកម្មប្រចាំថ្ងៃ ក៏ដូចជាការផ្តល់សេវាកម្មជូនអតិថិជនរបស់ **កសស** ។

ដើម្បីចៀសវាងការរាំងស្ទះ ដល់ប្រតិបត្តិការនាវាសណ្តោង ថ្នាក់ដឹកនាំសវនដ្ឋានគួរលើកគម្រោងស្នើសុំថ្នាក់ដឹកនាំ **កសស** ពិនិត្យលទ្ធភាពស្តារបាតអាងនាវាសណ្តោង អោយមានជម្រៅសមស្របតាមលក្ខណៈបច្ចេកទេស និងគួររៀបចំបែងចែកចំណតអោយបានត្រឹមត្រូវ ឬផ្លាស់ប្តូរទីតាំងចំណតនាវាសណ្តោងរបស់ **កសស** អោយនៅដាច់ដោយឡែកដើម្បីធានា សុវត្ថិភាព ការពារការខូចខាត ឬផលប៉ះពាល់ ក៏ដូចជាគ្រោះថ្នាក់ផ្សេងៗដែលអាចកើតមានឡើងជាយថាហេតុ ។

**មតិឆ្លើយតបរបស់សវនដ្ឋាន៖**

សវនដ្ឋានតែងតែលើកឡើងនៅក្នុងអង្គប្រជុំ ស្នើសុំដល់ថ្នាក់ដឹកនាំ **កសស** ។

## ឃ. នាយកដ្ឋានបច្ចេកទេស-សម្ភារៈ

**១.** សវនករបានសង្កេតឃើញថា **នាយកដ្ឋានបច្ចេកទេស-សម្ភារៈ** ក៏ដូចជាការិយាល័យ និងផ្នែកពាក់ព័ន្ធមួយចំនួននៅមានចំណុចខ្វះខាត ដែលត្រូវធ្វើការកែលម្អ និងបំពេញបន្ថែមដូចខាងក្រោម៖

### ១.១ ក្លោងទ្វារ កសស នៅច្រកទ្វារប៉ុស្តិ៍លេខ ២

តាមការចុះពិនិត្យជាក់ស្តែង សវនករបានសង្កេតឃើញក្លោងទ្វារ **កសស** នៅច្រកទ្វារប៉ុស្តិ៍លេខ២ នៅសល់តែគ្រោងដែកច្រេះស៊ី មានខ្សែភ្លើងឥតសណ្តាប់ធ្នាប់ កាត់ទទឹងផ្លូវចូល-ចេញនៃច្រកទ្វារនេះ។ ក្នុងនេះដែរ សវនករបានសង្កេតឃើញ មិនមានស្លាកឈ្មោះជាអក្សរសម្គាល់ថាជា៖ **កំពង់ផែស្វយ័តក្រុងព្រះសីហនុ** ឬជា៖ Sihanoukville Autonomous Port នោះទេ ។

ប្រការខាងលើ មិនមានអនុលោមភាពតាមបទបញ្ជាផ្ទៃក្នុងរបស់ កំពង់ផែស្វយ័តក្រុងព្រះសីហនុ **(កសស)** លេខ ០០១ បបផក/កសស/រប.ប ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៧ ត្រង់ចំណុចទី V. ស្តីពីការរក្សាសុវត្ថិភាពពលកម្ម សណ្តាប់ធ្នាប់ការងារ និងការថែរក្សាឧបករណ៍ សម្ភារការងារ និងចំណុចទី III. ស្តីពីការប្រើប្រាស់និងថែរក្សាទ្រព្យសម្បត្តិ សម្ភារមធ្យោបាយ ឬឧបករណ៍របស់ **កសស** ដោយសន្សំសំចៃប្រុងប្រយ័ត្នសម្អាត ថែរក្សា និងទុកដាក់ឱ្យបានគង់វង្ស ។

កត្តានេះ បានកើតមានឡើងដោយសារអ្នកគ្រប់គ្រងក្នុងក្របខ័ណ្ឌសវនដ្ឋាន និង/ឬ នាយកដ្ឋានពាក់ព័ន្ធមិនបានយកចិត្តទុកដាក់ និងសហការត្រួតពិនិត្យការងាររបស់ខ្លួន ឬបណ្តាលមកពីការមិនបានបែងចែកការងារជូនមន្ត្រី បុគ្គលិក ស្របតាមសេចក្តីកំណត់ ស្តីពីតួនាទីនិងភារកិច្ចរបស់ **កសស** ។

កត្តានេះ អាចបណ្តាលអោយបាត់បង់សោភ័ណភាព សណ្តាប់ធ្នាប់ និងប៉ះពាល់ដល់កេរ្តិ៍ឈ្មោះរបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ ដែលជាកំពង់ផែសមុទ្រអន្តរជាតិទឹកជ្រៅតែមួយគត់នៃព្រះរាជាណាចក្រកម្ពុជា។

សវនករយល់ឃើញថា ថ្នាក់ដឹកនាំសវនដ្ឋាន និងនាយកដ្ឋានពាក់ព័ន្ធ គួរសហការត្រួតពិនិត្យ និងស្នើសុំថ្នាក់ដឹកនាំ **កសស** ជួសជុលអោយបានឆាប់ ដើម្បីរក្សាសោភ័ណភាព ធានាសណ្តាប់ធ្នាប់ និងលើកកំពស់កេរ្តិ៍ឈ្មោះរបស់ **កសស** ទាំងក្នុងឆាកជាតិ និងអន្តរជាតិ ។

**មតិឆ្លើយតបរបស់សវនដ្ឋានៈ**

បញ្ហាក្លោងទ្វារប៉ុស្តិ៍លេខ២ សវនដ្ឋានក៏បានពិនិត្យឃើញដែរ ហើយនឹងធ្វើយ៉ាងណាអោយមានសុវត្ថិភាព ដើម្បីចៀសវាងគ្រោះថ្នាក់ជាយថាហេតុ ហើយការជួសជុលយើងនឹងធ្វើតាមក្រោយដោយសារថវិការបស់ **កសស** យើងគឺប្រមូលផ្តុំទៅលើការងារចាំបាច់និងបន្ទាន់ៗ ដូចជាការរៀបចំទីលានស្តុកសំបកកុងតឺន័រ និងការរៀបចំចាក់បេតុងនៅក្រោយឃ្លាំងលេខ៥ ដែលបច្ចុប្បន្ននេះមានលក្ខណៈចាំបាច់សម្រាប់ការងារអាជីវកម្មរបស់ **កសស** យើង ដែលបញ្ហាកន្លងមក គឺយើងបានយកចិត្តទុកដាក់ និងប្រមូលផ្តុំថវិកាទៅធ្វើការងារបម្រើអោយអាជីវកម្មស្នូលរបស់ **កសស** ជាមុន ។

## ១.២ អគារជម្រកកម្មករផែចាស់

តាមការចុះពិនិត្យស្ថានភាពជាក់ស្តែង សវនករបានសង្កេតឃើញ អគារជម្រកកម្មករនៅផែចាស់មានលក្ខណៈចាស់ទ្រុឌទ្រោម និងអាចបាក់ស្រុតជាយថាហេតុ។ ក្រុមការងារសវនកម្មបានពិនិត្យឃើញថាអគារនេះមិនអាចប្រើប្រាស់ជាជម្រកកម្មករបានទៀតទេ ពីព្រោះគ្រឿងដង្កំដែកផ្នែកខាងលើ និងដំបូលស្ថិតក្នុងស្ថានភាពងាយបាក់បែក ។

ប្រការខាងលើ មិនមានអនុលោមភាពតាមបទបញ្ជាផ្ទៃក្នុងរបស់ **កំពង់ផែស្វយ័តក្រុងព្រះសីហនុ (កសស)** លេខ ០០១ បបផក/កសស/បប ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៧ ត្រង់ចំណុចទី V. ស្តីពីការរក្សាសុវត្ថិភាពពលកម្ម សណ្តាប់ធ្នាប់ការងារ និងការថែរក្សាឧបករណ៍ សម្ភារការងារ និងចំណុចទី III. ស្តីពីការប្រើប្រាស់និងថែរក្សា ទ្រព្យសម្បត្តិ សម្ភារមធ្យោបាយ ឬឧបករណ៍របស់ **កសស** ដោយសន្សំសំចៃ ប្រុងប្រយ័ត្ន សម្អាតថែរក្សា និងទុកដាក់ឱ្យបានគង់វង្ស ។

ស្ថានភាពនេះ បានកើតមានឡើងដោយសារអ្នកគ្រប់គ្រង ក្នុងក្របខ័ណ្ឌសវនដ្ឋាន និង/ឬ នាយកដ្ឋានពាក់ព័ន្ធមិនបានយកចិត្តទុកដាក់ និងសហការត្រួតពិនិត្យការងាររបស់ខ្លួន ឬបណ្តាលមកពីការមិនបានបែងចែកការងារជូន មន្ត្រី បុគ្គលិក ស្របតាមសេចក្តីកំណត់របស់ **កសស** ។

កត្តានេះ អាចបណ្តាលអោយមានគ្រោះថ្នាក់ដល់អាយុជីវិត កម្មករ និយោជិត **កសស** ក៏ដូចជាកម្មករនាវា ភ្ញៀវជាតិ និងអន្តរជាតិ ដែលចូលជ្រកបណ្តោះអាសន្ន នៅក្នុងអំឡុងពេលនៃការបំពេញការងារ ឬការឆ្លងកាត់។ ល។ និងបង្ហាញអោយឃើញថា **កសស** មិនយកចិត្តទុកដាក់ដល់ សុវត្ថិភាព សុខភាព របស់បុគ្គលិកកម្មករ និងប្រព័ន្ធគ្រប់គ្រងបរិស្ថាន ជាពិសេសអាចប៉ះពាល់ដល់កេរ្តិ៍ឈ្មោះរបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ ដែលជាកំពង់ផែសមុទ្រអន្តរជាតិទឹកជ្រៅតែមួយគត់ នៃព្រះរាជាណាចក្រកម្ពុជា ។

ថ្នាក់ដឹកនាំសវនដ្ឋាននិងនាយកដ្ឋានពាក់ព័ន្ធ គួរបង្កើតក្រុមការងារ សិក្សាអំពីលក្ខណៈបច្ចេកទេស និងលើកគម្រោងស្នើសុំថ្នាក់ដឹកនាំ **កសស** ពិនិត្យលទ្ធភាពជួសជុលអគារជម្រកកម្មរនេះអោយបានឆាប់ដើម្បីបង្ការគ្រោះថ្នាក់ដល់អាយុជីវិតកម្មករ និយោជិត និងធានាសុវត្ថិភាពការងារ ស្របតាមប្រព័ន្ធគ្រប់គ្រងសុវត្ថិភាព សុខភាព និងបរិស្ថានរបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ ។

**មតិឆ្លើយតបរបស់សវនដ្ឋានៈ**

បញ្ហាអគារជម្រកកម្មករផែចាស់ ក៏ដូចគ្នានឹងបញ្ហាក្លោងទ្វារប៉ុស្តិ៍លេខ២ ដែរ គឺសវនដ្ឋានបានពិនិត្យរួចហើយៗនឹងធ្វើយ៉ាងណាអោយមានសុវត្ថិភាព ដើម្បីចៀសវាងគ្រោះថ្នាក់ដល់កម្មករ បុគ្គលិកជាយថាហេតុ ហើយការជួសជុលយើងនឹងធ្វើតាមក្រោយ ដោយសារថវិការបស់ **កសស** យើងគឺប្រមូលផ្តុំទៅលើការងារចាំបាច់និងបន្ទាន់ៗដូចជា ការរៀបចំទីលានស្តុកសំបកកុងតឺន័រ និងការរៀបចំចាក់បេតុងនៅក្រោយឃ្លាំងលេខ៥ ដែលបច្ចុប្បន្ននេះមានលក្ខណៈចាំបាច់ សម្រាប់ការងារអាជីវកម្មរបស់ **កសស** យើង ហើយចំពោះបញ្ហាកន្លងមក គឺយើងបានយកចិត្តទុកដាក់ និងប្រមូលផ្តុំថវិកាទៅធ្វើការងារបម្រើអោយអាជីវកម្មស្នូលរបស់ **កសស** ជាមុន ។

## ១.៣ វង្វង់មូលដើមផ្លូវចូលទៅកាន់តំបន់សេដ្ឋកិច្ចពិសេស កសស ផ្លូវទៅតំបន់ទំនប់រលក និងភូមិថ្មី

ក្រុមការងារសវនកម្មផ្ទៃក្នុង បានចុះពិនិត្យរង្វង់មូលដើមផ្លូវ ចូលទៅកាន់តំបន់សេដ្ឋកិច្ចពិសេស **កសស** ផ្លូវទៅតំបន់ទំនប់រលកនិងភូមិថ្មីដែល **កសស** បានកសាងឡើងដើម្បីជួយសម្រួលចរាចរណ៍ពីកំពង់ផែទៅកាន់តំបន់សេដ្ឋកិច្ចពិសេស កាត់តាមផ្លូវទៅតំបន់ទំនប់រលកនិងភូមិថ្មី។ ក្រុមការងារបានកត់សម្គាល់ឃើញថារង្វង់មូលនេះ មានលក្ខណៈចាស់ទ្រុឌទ្រោមគ្មានការថែទាំ និងមានស្ថានភាពពិបាកមើលសញ្ញាចរាចរណ៍ខ្លាំងនៅពេលយប់ ។

កត្តាខាងលើ មិនអនុលោមតាមបទបញ្ជាផ្ទៃក្នុងរបស់ **កំពង់ផែស្វយ័តក្រុងព្រះសីហនុ (កសស)** លេខ ០០១ បបផក/កសស/រប.ប ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៧ ត្រង់ចំណុចទី V. ស្តីពីការរក្សាសុវត្ថិភាពពលកម្ម សណ្តាប់ធ្នាប់ការងារ និងការថែរក្សាឧបករណ៍ សម្ភារការងារ និងចំណុចទី III. ស្តីពីការប្រើប្រាស់ និងថែរក្សាទ្រព្យសម្បត្តិ សម្ភារមធ្យោបាយ ឬឧបករណ៍របស់ **កសស** ដោយសន្សំសំចៃ ប្រុងប្រយ័ត្ន សម្អាតថែរក្សា និងទុកដាក់ឱ្យបានគង់វង្ស ។

ប្រការនេះ កើតមានឡើងដោយសារអ្នកគ្រប់គ្រងក្នុងក្របខ័ណ្ឌសវនដ្ឋាន និង/ឬ នាយកដ្ឋានពាក់ព័ន្ធ មិនបានយកចិត្តទុកដាក់ ត្រួតពិនិត្យការងាររបស់ខ្លួន និង/ឬ បណ្តាលមកពីភាពមមាញឹកក្នុងការបម្រើកិច្ចប្រតិបត្តិការអាជីវកម្មរបស់ **កសស** ការបំពេញការងារសំខាន់ៗ ដើម្បីឆ្លើយតបនឹងតម្រូវការរបស់អតិថិជន អ្នកប្រើប្រាស់ផែ ក៏ដូចជាបរិមាណទំនិញដែលកំពុងកើនឡើងយ៉ាងគំហុក ។

ករណីនេះ បណ្តាលអោយមានការលំបាកធ្វើដំណើរឆ្លងកាត់នៅពេលយប់ និងអាចបង្កអោយមានគ្រោះថ្នាក់កើតឡើងជាយថាហេតុ ពីព្រោះផ្នែកខ្លះនៃផ្លូវរង្វង់មូលនេះ ចាប់ផ្តើមបាក់បែកជាបណ្តើរៗ ហើយថ្នាំពណ៌ និងស្លាកសញ្ញាចរាចរណ៍ត្រូវបានរលុបទាំងស្រុង ។

ថ្នាក់ដឹកនាំសវនដ្ឋាន និងនាយកដ្ឋានពាក់ព័ន្ធ គួរសហការត្រួតពិនិត្យ និងលើកគម្រោងស្នើសុំថ្នាក់ដឹកនាំ **កសស** ពិនិត្យលទ្ធភាពជួសជុលអោយបានឆាប់ ដើម្បីបង្ការគ្រោះថ្នាក់ដែលអាចកើតមានឡើងជាយថាហេតុ ជាពិសេសពាក់ព័ន្ធនឹងកេរ្តិ៍ឈ្មោះរបស់ **កសស** ដែលជាអ្នកកសាងរង្វង់មូលនេះឡើង។ បន្ថែមលើនេះ នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃក្រសួងបរិស្ថាន ក៏បានលើកឡើងអំពីបញ្ហាខាងលើនិងធ្លាប់បានស្នើសុំអោយ **កសស** កែលម្អរង្វង់មូលនេះឡើងវិញ ក្នុងអង្គប្រជុំវាយតម្លៃហេតុប៉ះពាល់បរិស្ថាន នៃគម្រោងសាងសង់ចំណតផែពហុបំណងរបស់ **កសស** ដែលបានបញ្ចប់ក្នុងរយៈពេលកន្លងទៅនេះ ។

**មតិឆ្លើយតបរបស់សវនដ្ឋាន៖**

ចំពោះបញ្ហារង្វង់មូល ទៅតំបន់សេដ្ឋកិច្ចពិសេស ភូមិថ្មីនិងតំបន់ទំនប់រលក យើងពិតជាបានពិនិត្យឃើញប៉ុន្តែនៅមិនទាន់បានចាត់ចែង អោយបានទាន់ពេលវេលានៅឡើយ ពីព្រោះយើងបានប្រមូលផ្តុំធនធានទៅលើការងារអាជីវកម្មរបស់ **កសស** និងធ្វើទីលានកុងតឺន័រដែលកំពុងមានភាពកកស្ទះជាមុនសិន ហើយយើងខ្ញុំក៏សូមទទួលយកការណែនាំនេះផងដែរ ចំពោះកាងារជួសជុលសវនដ្ឋាន និងចាត់ចែងឡើងវិញនៅពេលមានភាពធូរស្បើយពីបញ្ហាកកស្ទះកុងតឺន័ររបស់ **កសស** ។

## ខ. នាយកដ្ឋានគ្រឿងចក្រ

**១.** សវនករបានសង្កេតឃើញថា **នាយកដ្ឋានគ្រឿងចក្រ** ក៏ដូចជាការិយាល័យនិងផ្នែកពាក់ព័ន្ធនៅមានចំណុចខ្វះខាត ដែលត្រូវធ្វើការកែលម្អនិងបំពេញបន្ថែមដូចខាងក្រោម៖

### ១.២ កង្វះខាតកុំព្យូទ័រ សម្រាប់បម្រើការងាររដ្ឋបាល

តាមការចុះធ្វើសវនកម្មជាក់ស្តែង សវនករបានពិនិត្យឃើញថា នាយកដ្ឋានគ្រឿងចក្រនៅមិនទាន់មានកុំព្យូទ័រប្រើប្រាស់គ្រប់គ្រាន់នៅឡើយ ។

ប្រការខាងលើ អាចបណ្តាលឱ្យរាំងស្ទះការងារប្រចាំថ្ងៃ ការងាររដ្ឋបាលរបស់សវនដ្ឋាន និងការធ្វើរបាយការណ៍បច្ចេកទេសជូនថ្នាក់ដឹកនាំ **កសស** និង/ឬ នាយកដ្ឋានពាក់ព័ន្ធអោយបានជ្រាបអំពីការប្រើប្រាស់និងជួសជុល-ថែទាំគ្រឿងចក្រ ដើម្បីបម្រើប្រតិបត្តិការអាជីវកម្មរបស់ **កសស** និងមានវិធានការកែលំអអោយកាន់តែល្អប្រសើរឡើងមួយកម្រិតទៀត ។

ដើម្បីចៀសវាងការរាំងស្ទះដល់ការងារប្រចាំថ្ងៃ ការងាររដ្ឋបាល និងការធ្វើកំណត់ហេតុ/របាយការណ៍សំខាន់ៗផ្សេងៗទៀត សវនករយល់ឃើញថា ថ្នាក់ដឹកនាំនាយកដ្ឋានគ្រឿងចក្រគួរធ្វើសំណើសុំកុំព្យូទ័រ និង/ឬ សម្ភារការិយាល័យ និងគ្រឿងបរិធានចាំបាច់សផ្សេងៗទៀតយកមកបម្រើការងារក្នុងក្របខ័ណ្ឌសវនដ្ឋាន ។

**មតិឆ្លើយតបរបស់សវនដ្ឋាន៖**

កង្វះខាតបរិក្ខារការិយាល័យ សម្រាប់បំពើឯកសាររដ្ឋបាលរបស់នាយកដ្ឋានគ្រឿងចក្រ នាយកដ្ឋានយើងខ្ញុំបានធ្វើសំណើរសុំគ្រឿងកង្វះខាតបរិក្ខារដូចជាកុំព្យូទ័រជាដើម។ ប៉ុន្តែរហូតមកដល់ពេលនេះនាយកដ្ឋានគ្រឿងចក្រមិនទាន់ទទួលនូវការឆ្លើយតបនៅឡើយ ។

## ១.២ ភាពយឺតយ៉ាវក្នុងការជួសជុលគ្រឿងចក្រ

តាមការចុះធ្វើសវនកម្មជាក់ស្តែង សវនករបានពិនិត្យឃើញថា គ្រឿងចក្រសំខាន់ៗមួយចំនួនដូចបានរៀបរាប់ខាងក្រោម នៅតែទទួលបានការជួសជុល និងផ្លាស់ប្តូរគ្រឿងបន្លាស់យឺតយ៉ាវ៖

- Reach Stacker No. 108 ខូចប្រអប់លេខនៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៨
- Reach Stacker No. 106 ខូចប្រព័ន្ធភ្លើងនៅខែ០៨ ឆ្នាំ២០១៩

ប្រការខាងលើនេះ អាចធ្វើអោយរាំងស្ទះដល់ការផ្តល់សេវាកម្មជូនអតិថិជន ប៉ះពាល់កិច្ចដំណើរការអាជីវកម្ម នាំអោយប្រតិបត្តិការលើកដាក់-ផ្ទេរផ្ទុក ទំនិញ/កុងតេន័រ និងផលិតភាពរបស់ **កសស** មានការថយចុះ។

សវនករយល់ឃើញថា ថ្នាក់ដឹកនាំនាយកដ្ឋានគ្រឿងចក្រ គួរបន្តសហការជាមួយនាយកដ្ឋាន **បច្ចេកទេស-សម្ភារៈ** ដើម្បីជំរុញអោយផ្នែករោងជាងធ្វើការជួសជុល និង/ឬ ផ្លាស់ប្តូរគ្រឿងបន្លាស់អោយបានឆាប់រហ័ស ដើម្បីចៀសវាងការរាំងស្ទះដល់កិច្ចដំណើរការអាជីវកម្មរបស់ **កសស** ។

**មតិឆ្លើយតបរបស់សវនដ្ឋាន៖**

ភាពយឺតយ៉ាវការងារជួសជុលគ្រឿងចក្រ (Stacker 108 & 106)

ចំពោះករណីនេះ នាយកដ្ឋានយើងខ្ញុំបានជំរុញដល់នាយកដ្ឋានបច្ចេកទេស ដែលជាអ្នកបញ្ជាក្នុងការងារជួសជុលគ្រឿងចក្រទាំងអស់ ។

# ច. នាយកដ្ឋានតំបន់សេដ្ឋកិច្ចពិសេស

**១.** សវនករបានសង្កេតឃើញថា **នាយកដ្ឋានតំបន់សេដ្ឋកិច្ចពិសេស** ក៏ដូចជាការិយាល័យ និងផ្នែកពាក់ព័ន្ធមួយចំនួននៅមានចំណុចខ្វះខាត ដែលត្រូវធ្វើការកែលម្អ និងបំពេញបន្ថែមដូចខាងក្រោម៖

## ១.១ អាងចម្រោះទឹកកខ្វក់

តាមការចុះពិនិត្យជាក់ស្តែង សវនករបានសង្កេតឃើញមន្ត្រី ការិយាល័យជួសជុល និងថែទាំធ្វើការពិនិត្យអាងចម្រោះទឹកកខ្វក់ជាប្រចាំ ប៉ុន្តែពួកគាត់មិនបានរក្សាទុកកំណត់ហេតុ និង/ឬ របាយការណ៍ត្រួតពិនិត្យការងារប្រចាំថ្ងៃជាលាយលក្ខណ៍អក្សរ ។

ករណីខាងលើ អាចប៉ះពាល់ដល់ប្រសិទ្ធភាព ការងារជួសជុល និងថែទាំប្រព័ន្ធអាងចម្រោះទឹកកខ្វក់នៅក្នុងដែនសមត្ថកិច្ចរបស់នាយកដ្ឋានតំបន់សេដ្ឋកិច្ចពិសេស ។

មូលហេតុខាងលើ បានកើតមានឡើងដោយសារមន្ត្រី/បុគ្គលិក ទទួលបន្ទុកផ្នែកជួសជុល និងថែទាំមិនបានយកចិត្តទុកដាក់លើតួនាទី-ភារកិច្ចរបស់ខ្លួន ជាពិសេសក្នុងការកសាង និងរក្សាទុកឯកសារត្រួតពិនិត្យការងារជួសជុល និងថែទាំប្រព័ន្ធអាងចម្រោះទឹកកខ្វក់ ។

កត្តានេះ អាចធ្វើឱ្យមានភាពមិនច្បាស់លាស់ និងមិនអនុលោមតាមលក្ខណៈបច្ចេកទេសក្នុងការជួសជុលនិងថែទាំអាងចម្រោះទឹកកខ្វក់ ពីព្រោះសវនករបានសង្កេតឃើញ មិនមានឯកសារជាលាយលក្ខណ៍អក្សរ និងរបាយការណ៍ត្រួតពិនិត្យការងារប្រចាំថ្ងៃ ជូនថ្នាក់ដឹកនាំសវនដ្ឋានដើម្បីចាត់វិធានការបន្តមុននឹងស្នើសុំថ្នាក់ដឹកនាំ **កសស** ដើម្បីធ្វើការជួសជុល ។

ថ្នាក់ដឹកនាំសវនដ្ឋាន គួរណែនាំការិយាល័យជួសជុលនិងថែទាំ និងផ្នែកពាក់ព័ន្ធអោយកសាង និងរក្សាទុកសំណុំឯកសារ ក៏ដូចជាកំណត់ហេតុ ឬរបាយការណ៍ត្រួតពិនិត្យរាល់ការងារ ដែលបានអនុវត្តអោយបានច្បាស់លាស់ដើម្បីងាយស្រួលតាមដានការជួសជុល និងថែទាំប្រព័ន្ធអាងចម្រោះទឹកកខ្វក់ខាងលើអោយបានសមស្របតាមលក្ខណៈបច្ចេកទេស និងចូលរួមចំណែកការពារបរិស្ថាន **កសស** ។

**មតិឆ្លើយតបរបស់សវនដ្ឋាន៖** ការិយាល័យថែទាំ-ជួសជុលនឹងព្យាយាមកែលម្អ-បំពេញចំណុចខ្វះខាតទាំងនេះដោយស្មារតីទទួលខុសត្រូវ ។

## ១.២ ប៉ុស្តិ៍យាម និងច្រកទ្វារអគារសយនដ្ឋាន ក្នុងតំបន់សេដ្ឋកិច្ចពិសេសភាគខាងត្បូងជាប់ផ្លូវភូមិថ្មី

តាមការចុះពិនិត្យប៉ុស្តិ៍យាមនៅតាមច្រកទ្វារ នៃអគារសយនដ្ឋានក្នុង **តសព** ភាគខាងត្បូងជាប់ផ្លូវភូមិថ្មី សវនករបានសង្កេតឃើញករណីដូចខាងក្រោម៖

- ប៉ុស្តិ៍យាមច្រកទ្វារទី១ ៖ របងថ្មមានស្នាមប្រេះ និងទ្រេតចង់ដួល ហើយចម្រឹងដែកការពារដែលរុំព័ទ្ធដោយលួសបន្លា នៅផ្នែកខាងលើរបងថ្មត្រូវបានកាត់ផ្តាច់ជាច្រើនកន្លែង ។
- ប៉ុស្តិ៍យាមច្រកទ្វារទី២ ៖ ទ្វាររបងមានស្ថានភាពពិបាកទាញបើក/បិទខ្លាំង ។
- ប៉ុស្តិ៍យាមច្រកទ្វារទី៣ ៖ មានស្មៅដុះព័ទ្ធជុំវិញរបងថ្មមានស្នាមប្រេះ ហើយចម្រឹងដែកការពារដែលរុំព័ទ្ធដោយលួសបន្លានៅផ្នែកខាងលើរបងថ្មត្រូវបានកាត់ផ្តាច់ ។

កត្តាខាងលើ មិនអនុលោមតាមបទបញ្ជាផ្ទៃក្នុងរបស់ កំពង់ផែស្វយ័តក្រុងព្រះសីហនុ (**កសស**) លេខ ០០១ បបផក/កសស/រប.ប ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៧ ត្រង់ចំណុចទី III. ស្តីពីការប្រើប្រាស់ និងថែរក្សា

ទ្រព្យសម្បត្តិ សម្ភារមធ្យោបាយ ឬឧបករណ៍របស់ **កសស** ដោយសន្សំសំចៃ ប្រុងប្រយ័ត្ន សម្អាតថែរក្សា និងទុកដាក់ឱ្យបានគង់វង្ស និងចំណុចទី V. ស្តីពីការរក្សាសុវត្ថិភាពពលកម្ម សណ្តាប់ធ្នាប់ការងារ និងការថែរក្សាឧបករណ៍សម្ភារការងារ ។

មូលហេតុនេះ កើតមានឡើងដោយសារមន្ត្រី/បុគ្គលិកទទួលបន្ទុកការងារផ្ទាល់ និង/ឬ នាយកដ្ឋានពាក់ព័ន្ធមិនបានយកចិត្តទុកដាក់ និងសហការត្រួតពិនិត្យការងាររបស់ខ្លួន ស្របតាមសេចក្តីកំណត់ស្តីពីតួនាទី- ភារកិច្ចរបស់មន្ត្រី/បុគ្គលិក **កសស** ។

កត្តានេះ អាចបណ្តាលអោយស្ថានភាពមិនប្រក្រតីកើតមានឡើង និងនាំអោយជនអនាមិក ឬជនមិនស្គាល់អត្តសញ្ញាណចូល-ចេញ ក្នុងគោលបំណងមិនល្អ បណ្តាលអោយបាត់បង់ទ្រព្យសម្បត្តិរដ្ឋដែលត្រូវបានបំពាក់នៅក្នុងអគារ Terrace Houses ជាច្រើនខ្នង ។

ថ្នាក់ដឹកនាំសវនដ្ឋាន គួរចាត់មន្ត្រី/បុគ្គលិកដែលទទួលបន្ទុកការងារនេះផ្ទាល់ ចុះពិនិត្យស្ថានភាព និងទីតាំងជាក់ស្តែង ដើម្បីសហការចាត់វិធានការការពារ ធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំ **កសស** ពិនិត្យនិងស្នើសុំជួសជុល ដើម្បីចៀសវាងគ្រោះថ្នាក់ជាយថាហេតុ និងធានាសន្តិសុខ សុវត្ថិភាព ជូនអតិថិជនស្របតាមប្រព័ន្ធគ្រប់គ្រងសុវត្ថិភាព សុខភាព និងបរិស្ថាន របស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ ។

**មតិឆ្លើយតបរបស់សវនដ្ឋាន៖** សូមឯកភាពតាមមតិរបស់សវនករដែលបានលើកឡើង ។

## ១.៣ អគារសយនដ្ឋានមួយខ្នងនៅជិតអាងស្តុកទឹកក្នុងតំបន់សេដ្ឋកិច្ចពិសេស

តាមការចុះពិនិត្យអគារសយនដ្ឋានមួយខ្នង នៅជិតអាងស្តុកទឹកស្អាតក្នុងតំបន់សេដ្ឋកិច្ចពិសេស សវនករបានសង្កេតឃើញមានបន្ទប់ចំនួន ៨ (ប្រាំបី) និងមានស្ថានភាពដូចខាងក្រោម ៖

- បរិវេណខាងក្រៅអគារ ៖ មានការចោលសម្រាមគ្មានសណ្តាប់ធ្នាប់ជាច្រើនកន្លែង
- បរិវេណខាងក្នុងអាគារ៖ ក្នុងបន្ទប់នីមួយៗគ្មានការសម្អាតថែទាំ និងត្រូវបានរក្សាទុកសម្ភារជាច្រើនប្រភេទដោយគ្មានសណ្តាប់ធ្នាប់
- ទ្វារនិងបង្អួចភាគច្រើនបានខូចជាបណ្តើរៗ ។

ប្រការខាងលើ មិនអនុលោមតាមបទបញ្ជាផ្ទៃក្នុងរបស់ កំពង់ផែស្វយ័តក្រុងព្រះសីហនុ (**កសស**) លេខ ០០១ បបផក/កសស/រប.ប ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៧ ត្រង់ចំណុចទី III. ស្តីពីការប្រើប្រាស់ និងថែរក្សាទ្រព្យសម្បត្តិ សម្ភារមធ្យោបាយ ឬឧបករណ៍របស់ **កសស** ដោយសន្សំសំចៃ ប្រុងប្រយ័ត្ន សម្អាតថែរក្សា និងទុកដាក់ឱ្យបានគង់វង្ស និងចំណុចទី V. ស្តីពីការរក្សាសុវត្ថិភាពពលកម្ម សណ្តាប់ធ្នាប់ការងារ និងការថែរក្សាឧបករណ៍សម្ភារការងារ ។

មូលហេតុនេះ បានកើតមានឡើងដោយសារ មន្ត្រី/បុគ្គលិកទទួលបន្ទុកការងារផ្ទាល់ និង/ឬ ផ្នែកពាក់ព័ន្ធមិនបានយកចិត្តទុកដាក់ និងសហការត្រួតពិនិត្យការងារ ស្របតាមតួនាទីនិងភារកិច្ចដែល **កសស** បានកំណត់ ។

ករណីនេះ អាចបណ្តាលអោយសវនដ្ឋានខ្វះការយកចិត្តទុកដាក់ និងការទទួលខុសត្រូវក្នុងការថែទាំទ្រព្យសម្បត្តិ ឧបករណ៍ប្រើប្រាស់ និងរក្សាសុវត្ថិភាពពលកម្ម សណ្តាប់ធ្នាប់ការងារនិងបរិស្ថាន នាំអោយផ្ទុយពីបទបញ្ជាផ្ទៃក្នុង និងប្រាសចាកពីប្រព័ន្ធគ្រប់គ្រង សុវត្ថិភាព សុខភាព និងបរិស្ថានរបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ។

ថ្នាក់ដឹកនាំសវនដ្ឋាន គួរចាត់មន្ត្រី/បុគ្គលិកចុះពិនិត្យស្ថានភាពជាក់ស្តែង ដើម្បីរាយការណ៍ជូនថ្នាក់ដឹកនាំ **កសស** និងស្នើសុំជួសជុលសម្ភារប្រើប្រាស់/ឧបករណ៍ដែលខូច រៀបចំសំអាត ប្រមូលសម្រាម រក្សាសណ្តាប់ធ្នាប់ និងបរិស្ថានអោយបានសមស្របតាមប្រព័ន្ធគ្រប់គ្រង សុវត្ថិភាព សុខភាព និងបរិស្ថានរបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ ។

**មតិឆ្លើយតបរបស់សវនដ្ឋាន៖** យើងខ្ញុំនឹងពិនិត្យមើលឡើងវិញ និងបំពេញចន្លោះប្រហោងដោយស្មារតីទទួលខុសត្រូវ ។

## ១.៤ ប្រព័ន្ធលូបង្ហូរទឹកភ្លៀង (លូអក្សរ V) ក្នុងបរិវេណ តសព ភាគខាងជើងរោងចក្រ Ojitex Harta Packaging (Sihanoukville) Co.,Ltd ជាប់របង និងផ្ទះប្រជាជននៅតំបន់ទំនប់រលក

តាមការចុះពិនិត្យស្ថានភាពប្រព័ន្ធលូបង្ហូរទឹកភ្លៀង (លូអក្សរ V) នៅទីតាំងខាងលើ សវនករបានកត់សម្គាល់ឃើញករណីដូចខាងក្រោម៖

- ផ្នែកខាងលើនៃប្រព័ន្ធលូមានស្នាមប្រេះ និងបាក់បែកជាច្រើនកន្លែង
- ប្រព័ន្ធលូខាងលើស្ថិតក្នុងសានភាពកកស្ទះ
- ផ្ទៃប្រឡាយ (លូបង្ហូរទឹកភ្លៀង) មានល្បាប់ភក់ និងពោរពេញដោយសំរាម ស្បោងផ្លាស្ទីក សំបកកំប៉ុង និងដបផ្លាស្ទិកជាច្រើនប្រភេទ
- ក្នុងបរិវេណប្រព័ន្ធលូមានស្មៅដុះច្រើនឥតសណ្តាប់ធ្នាប់
- សំណាញ់លួសផ្នែកខាងលើនៃរបង **តពស** ដែលស្ថិតនៅជាប់ផ្ទះប្រជាជនតំបន់ទំនប់រលកបានដាច់ជាច្រើនកន្លែង ។

កត្តាខាងលើ មិនអនុលោមតាមបទបញ្ជាផ្ទៃក្នុងរបស់ កំពង់ផែស្វយ័តក្រុងព្រះសីហនុ (**កសស**) លេខ ០០១ បបផក/កសស/រប.ប ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៧ ត្រង់ចំណុចទី III. ស្តីពីការប្រើប្រាស់ និងថែរក្សាទ្រព្យសម្បត្តិ សម្ភារមធ្យោបាយ ឬឧបករណ៍របស់ **កសស** ដោយសន្សំសំចៃ ប្រុងប្រយ័ត្ន សម្អាតថែរក្សា និងទុកដាក់ឱ្យបានគង់វង្ស និងចំណុចទី V. ស្តីពីការរក្សាសុវត្ថិភាពពលកម្ម សណ្តាប់ធ្នាប់ការងារ និងការថែរក្សាឧបករណ៍ សម្ភារការងារ ។

ករណីនេះ បានកើតមានឡើងដោយសារមន្ត្រី/បុគ្គលិកទទួលបន្ទុកការងារផ្ទាល់ធ្វេសប្រហែស មិនយកចិត្តទុកដាក់ចុះពិនិត្យតាមដានការងារដែលស្ថិតក្រោមការគ្រប់គ្រង និងទទួលខុសត្រូវរបស់ខ្លួន។

កត្តានេះ អាចបណ្តាលអោយទឹកភ្លៀងកកស្ទះខ្លាំងនៅរដូវវស្សា ជាពិសេសនៅភាគខាងជើងរោងចក្រ Ojitex Harta Packaging (Sihanoukville) Co.,Ltd ជាប់របង **តសព** និងផ្ទះប្រជាជននៅតំបន់ទំនប់រលក ដោយសារទីតាំងនេះមានល្បាប់ភក់ សម្រាម ស្បោងផ្លាស្ទិក និងសំបកដបបហូរចូលច្រើន ។

ថ្នាក់ដឹកនាំសវនដ្ឋាន គួរចាត់មន្ត្រី/បុគ្គលិកទទួលបន្ទុកការងារផ្ទាល់ចុះពិនិត្យទីតាំង និងស្ថានភាពជាក់ស្តែងដើម្បីចាត់វិធានការ ការពារ/ស្តារឡើងវិញក្នុងក្របខ័ណ្ឌសវនដ្ឋាន និង/ឬ រាយការណ៍ជូនថ្នាក់ដឹកនាំ **កសស** ដើម្បីស្នើសុំកិច្ចសហការជួសជុលប្រព័ន្ធលូ និងការខូចខាតខាងលើអោយបានឆាប់ដើម្បីចៀសវាងការដក់ទឹករយៈពេលយូរ នាំអោយខូចបរិស្ថានក្នុង **តសព** ផ្ទុយពីអនុលោមភាពនៃបទបញ្ជាផ្ទៃក្នុង និងប្រាសចាកពីប្រព័ន្ធគ្រប់គ្រង សុវត្ថិភាព សុខភាព និងបរិស្ថានរបស់ **កសស** ។

**មតិឆ្លើយតបរបស់សវនដ្ឋាន៖** នាយកដ្ឋានយើងខ្ញុំកំពុងកសាងឯកសារដើម្បីស្នើសុំ-រាយការណ៍ជូនថ្នាក់ដឹកនាំ មានវិធានការជួសជុល-ស្តារប្រឡាយឡើងវិញ ។

## ឆ. នាយកដ្ឋានទីផ្សារ

១. សវនករបានសង្កេតឃើញថា នាយកដ្ឋានទីផ្សារក៏ដូចជាការិយាល័យ និងផ្នែកពាក់ព័ន្ធមួយចំនួននៅមានចំណុចខ្វះខាត ដែលត្រូវធ្វើការកែលម្អ និងបំពេញបន្ថែមដូចខាងក្រោម៖

### ១.១ រចនាសម្ព័ន្ធនិងភារកិច្ច

យោងតាមរចនាសម្ព័ន្ធគ្រប់គ្រង នាយកដ្ឋានទីផ្សារមានការិយាល័យសរុបចំនួន០៣ រួមមាន៖ ១) ការិយាល័យស្រាវជ្រាវទីផ្សារ និងអភិវឌ្ឍន៍យុទ្ធសាស្ត្រ ២) ការិយាល័យទំនាក់ទំនងអតិថិជននិងផ្សព្វផ្សាយ និង ៣) ការិយាល័យកិច្ចការផែអាស៊ាន ។

ក្នុងចំណោមការិយាល័យទាំង ០៣ (បី) ដូចបានរៀបរាប់ខាងលើ សវនករបានសង្កេតឃើញមានការិយាល័យ ០២ (ពីរ) នៅមិនទាន់បានបំពេញការងាររបស់ខ្លួន ស្របតាមសេចក្តីកំណត់លេខ ០០៨ សកណ/កសស/រប.ធម ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៦ ស្តីពីរចនាសម្ព័ន្ធ និងភារកិច្ចរបស់នាយកដ្ឋានទីផ្សារនៃកំពង់ផែស្វយ័តក្រុងព្រះសីហនុនៅឡើយ ។

កត្តាខាងលើបានកើតមានឡើង ដោយសារថ្នាក់ដឹកនាំសវនដ្ឋាន មិនទាន់បានបែងចែកការងារជូនការិយាល័យនីមួយៗ ដែលស្ថិតក្រោមការគ្រប់គ្រង និងទទួលខុសត្រូវរបស់ខ្លួនស្របតាមតួនាទី និងភារកិច្ចដែល **កសស** បានកំណត់។ ប្រការនេះ អាចប៉ះពាល់ប្រសិទ្ធភាពការងារប្រចាំថ្ងៃរបស់សវនដ្ឋាន និងការអនុវត្តទិសដៅអភិវឌ្ឍន៍របស់ **កសស** ក៏ដូចជាការរួមចំណែកបំពេញកិច្ចការសង្គមផ្សេងៗដែលតម្រូវឡើងដោយថ្នាក់ដឹកនាំ **កសស** ។

ដើម្បីរួមចំណែកលើកកំពស់ប្រសិទ្ធភាព និងប្រសិទ្ធផលប្រតិបត្តិការអាជីវកម្ម សេវាកម្មរបស់ **កសស** ថ្នាក់ដឹកនាំសវនដ្ឋានគួររៀបចំចាត់ចែង និងអនុវត្តរចនាសម្ព័ន្ធគ្រប់គ្រងសម្រាប់ការិយាល័យនីមួយៗដែលស្ថិត

ក្រោមការគ្រប់គ្រង និងទទួលខុសត្រូវរបស់ខ្លួនឱ្យមានអនុលោមភាពស្របតាមសេចក្តីកំណត់ស្តីពីរចនាសម្ព័ន្ធ និងភារកិច្ចរបស់នាយកដ្ឋានទីផ្សារ នៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ ។

**មតិឆ្លើយតបរបស់សវនដ្ឋាន៖** នាយកដ្ឋានទីផ្សារសូមឯកភាពនឹងការកត់សម្គាល់របស់សវនករអំពីកង្វះខាតកន្លងមកក្នុងការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រង និងការបែងចែកតួនាទីភារកិច្ចរបស់ខ្លួន ហើយបានសិក្សារៀបចំរចនាសម្ព័ន្ធថ្មីរួចហើយរង់ចាំការសម្រេចអនុម័តពីថ្នាក់ដឹកនាំ ដើម្បីដាក់ប្រើប្រាស់ជាផ្លូវការ ។

## ១.២ សៀវភៅផ្សព្វផ្សាយ (BOOKLET) របស់ កសស

ក្រុមការងារសវនកម្មផ្ទៃក្នុង បានសង្កេតឃើញថាសៀវភៅផ្សព្វផ្សាយ (BOOKLET) របស់ **កសស** សម្រាប់ការិយបរិច្ឆេទនីមួយៗ ដែលនាយកដ្ឋានទីផ្សារជាអ្នកទទួលបន្ទុកបោះផ្សាយ មានសារៈសំខាន់ណាស់ក្នុងការឆ្លុះបញ្ចាំងអំពីសកម្មភាព ប្រតិបត្តិការអាជីវកម្ម សេវាកម្ម និងការអភិវឌ្ឍន៍របស់ **កសស**។ ករណីនេះ សវនករយល់ឃើញថា ក្រៅពីការផ្តល់ជូនអតិថិជន អ្នកប្រើប្រាស់ផែ ភ្ញៀវជាតិ និងអន្តរជាតិដោយផ្ទាល់ សវនដ្ឋានគួរលៃបំរុងទុកមួយចំនួន ដើម្បីចែករំលែកជូននាយកដ្ឋានពាក់ព័ន្ធ សម្រាប់ធ្វើការសិក្សាស្វែងយល់បន្ថែម និងជួយផ្សព្វផ្សាយបន្តអំពី **កសស**។ ប៉ុន្តែរហូតមកដល់ពេលនេះ សវនករបានពិនិត្យឃើញថា សវនដ្ឋានមិនទាន់បានចែករំលែកសៀវភៅផ្សព្វផ្សាយខាងលើ ជូននាយកដ្ឋានពាក់ព័ន្ធក្នុងក្របខ័ណ្ឌ **កសស** នៅឡើយ ។

ប្រការខាងលើ កើតមានឡើងដោយសារមន្ត្រីទទួលបន្ទុកការងារផ្ទាល់ ឬថ្នាក់ដឹកនាំសវនដ្ឋានមានការមមាញឹកខ្លាំង ឬមិនបានគិតគូរគ្រប់ជ្រុងជ្រោយអំពីសារៈសំខាន់ នៃការសិក្សាស្វែងយល់បន្ថែមអំពីចំណុចខ្វះខាត និងការផ្សព្វផ្សាយបន្តជូនអតិថិជន អ្នកប្រើប្រាស់ផែ និងក្រុមហ៊ុនពាក់ព័ន្ធនានាអំពីវឌ្ឍនភាព និងសក្តានុពលអភិវឌ្ឍន៍របស់ **កសស**។ កត្តានេះ អាចបណ្តាលឱ្យនាយកដ្ឋានមួយចំនួន មិនបានយល់ដឹងច្បាស់លាស់អំពីវឌ្ឍនភាពការផ្លាស់ប្តូរ និងអភិវឌ្ឍន៍របស់ **កសស** ពីមួយថ្ងៃទៅមួយថ្ងៃ និងមិនអាចជួយផ្សព្វផ្សាយបន្តអំពី **កសស** បាន ។

សវនករយល់ឃើញថាសៀវភៅផ្សព្វផ្សាយរបស់ **កសស** នេះ ប្រមូលផ្តុំដោយព័ត៌មានសំខាន់ៗ ពាក់ព័ន្ធនឹងកិច្ចប្រតិបត្តិការអាជីវកម្ម សេវាកម្ម និងដំណើរការអភិវឌ្ឍន៍ដែលថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិក កម្មករ ត្រូវយល់ដឹងនិងរួមចំណែកកែលំអ ដើម្បីលើកកំពស់ប្រសិទ្ធភាព និងប្រសិទ្ធផលប្រតិបត្តិការរបស់ **កសស**។ ហេតុដូច្នេះ ថ្នាក់ដឹកនាំសវនដ្ឋានគួរលៃបំរុងទុក សៀវភៅផ្សព្វផ្សាយនេះមួយចំនួនដើម្បីចែករំលែកជូននាយកដ្ឋានពាក់ព័ន្ធរបស់ **កសស** សម្រាប់ធ្វើការសិក្សាស្វែងយល់ផ្សព្វផ្សាយបន្ត និងអូសទាញអតិថិជនសក្តានុពលបន្ថែមទៀត ។

**មតិឆ្លើយតបរបស់សវនដ្ឋាន៖** នាយកដ្ឋានទីផ្សារទទួលស្គាល់ថា ពិតជាមានការខ្វះខាតក្នុងការចែកជូននូវសៀវភៅផ្សព្វផ្សាយរបស់ **កសស** ដល់នាយកដ្ឋានពាក់ព័ន្ធ ប៉ុន្តែនេះមិនមែនជាបញ្ហាធំទេដោយហេតុថានាយកដ្ឋានផ្សេងៗអាចធ្វើសំណើ ឬមកសុំពីនាយកដ្ឋានទីផ្សារដោយផ្ទាល់នៅគ្រប់ពេលម៉ោងការងារ ហើយ

យើងខ្ញុំតែងឆ្លើយតបដោយសកម្មជាដរាប។ យើងខ្ញុំតែងគិតគូរអំពីការផ្សព្វផ្សាយជូនដល់អតិថិជន និងអំពីមតិត្រឡប់របស់អតិថិជនមិនដែលធ្វេសប្រហែសឡើយ ។

## ១.៣ ការស្រាវជ្រាវទីផ្សារ និងបង្កើតផែនការយុទ្ធសាស្ត្រ

យោងតាមការជួបពិភាក្សាការងារ និងសួរនាំលោកស្រីនាយិកាសវនដ្ឋាន បានឱ្យដឹងថារហូតមកដល់ពេលនេះនាយកដ្ឋានទីផ្សារ នៅមិនទាន់បានធ្វើការសិក្សាស្រាវជ្រាវអំពីចំណែកទីផ្សារ និងបង្កើតផែនការយុទ្ធសាស្ត្រពាក់ព័ន្ធនឹងការកំណត់ទិសដៅគោលបំណង និងការវិភាគអំពីកត្តាខាងក្នុង និងកត្តាខាងក្រៅព្រមទាំងចំណុចខ្លាំង និងចំណុចខ្សោយរបស់ **កសស** នៅឡើយទេ ។

ករណីខាងលើ មិនមានអនុលោមភាពស្របតាមសេចក្តីកំណត់ ស្តីពីរចនាសម្ព័ន្ធនិងភារកិច្ចរបស់នាយកដ្ឋានទីផ្សារលេខ ០០៨ សកណ/កសស/រប.ធម ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៦ នោះទេ។ ប្រការនេះកើតមានឡើងដោយសារមន្ត្រីទទួលបន្ទុកការងារក្នុងក្របខ័ណ្ឌការិយាល័យស្រាវជ្រាវទីផ្សារ និងអភិវឌ្ឍន៍យុទ្ធសាស្ត្រ មិនបានយកចិត្តទុកដាក់សិក្សាស្រាវជ្រាវ ឬថ្នាក់ដឹកនាំសវនដ្ឋានមានការមមាញឹកខ្លាំងមិនបានផ្តល់ការណែនាំ ឬបែងចែកការងារជូនមន្ត្រី/បុគ្គលិក ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួន ជាពិសេសការិយាល័យស្រាវជ្រាវទីផ្សារ និងអភិវឌ្ឍន៍យុទ្ធសាស្ត្រ ស្របតាមរចនាសម្ព័ន្ធនិងភារកិច្ចដែល **កសស** បានកំណត់ ។

សវនករយល់ឃើញថា ការខកខានមិនបានធ្វើការសិក្សាស្រាវជ្រាវអំពីចំណែកទីផ្សារនានាទាំងក្នុងស្រុក និងក្នុងតំបន់រួមទាំងការបង្កើតផែនការយុទ្ធសាស្ត្រគ្រប់គ្រងដំណើរការអភិវឌ្ឍន៍ និងប្រតិបត្តិការនាំអោយអង្គភាពមិនអាចកំណត់ទិសដៅ និងគោលបំណងច្បាស់លាស់ ដើម្បីឆ្លើយតបនឹងតម្រូវការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធកំពង់ផែ ក៏ដូចជាបរិមាណទំនិញ-កុងតឺន័រដែលកំពុងកើនឡើង ព្រមទាំងការកំណត់យុទ្ធសាស្ត្រទប់ទល់នឹងការប្រកួតប្រជែង និងគម្រាមកំហែងពីប្រភពខាងក្រៅ ដែលអាចប៉ះពាល់ដល់ប្រតិបត្តិការ និងចំណូលអាជីវកម្មរបស់ **កសស** ។

ដើម្បីលើកកំពស់គុណភាព ប្រសិទ្ធភាព និងប្រសិទ្ធផលប្រតិបត្តិការអាជីវកម្ម សេវាកម្មរបស់ **កសស** អោយកាន់តែល្អប្រសើរឡើងដូចកំពង់ផែនានាក្នុងតំបន់ សវនករយល់ឃើញថាសវនដ្ឋានគួរធ្វើការសិក្សាស្រាវ ជ្រាវអំពីចំណែកទីផ្សារនានា ទាំងក្នុងស្រុក និងក្នុងតំបន់ ដោយផ្តោតសំខាន់លើការប្រឈម ការប្រកួតប្រជែង រួមទាំងចំណុចខ្លាំង និងចំណុចខ្សោយរបស់ **កសស** ដើម្បីបង្កើតផែនការយុទ្ធសាស្ត្រសមស្របមួយក្នុងគោលបំណងបង្កើនគុណភាព និងផលិតភាពប្រតិបត្តិការ ឆ្លើយតបនឹងការគម្រាមកំហែងពីកត្តាខាងក្នុង និងកត្តាខាងក្រៅ តម្រូវការរបស់អតិថិជន និងដោះស្រាយបរិមាណទំនិញនិងកុងតឺន័រដែលកំពុងកើនឡើងប្រកបដោយប្រសិទ្ធភាព ។

**មតិឆ្លើយតបរបស់សវនដ្ឋាន៖** នាយកដ្ឋានទីផ្សារសូមឯកភាពចំពោះការរកឃើញរបស់សវនករអំពីកង្វះខាតនៃសកម្មភាពក្នុងការិយាល័យមួយនេះកន្លងមក។ ទោះយ៉ាងណា យើងបានរៀបចំរចនាសម្ព័ន្ធថ្មីរួមទាំងបរិយាយនូវតួនាទីភារកិច្ច សម្រាប់គ្រប់សមាជិកក្នុងនាយកដ្ឋានទីផ្សារ ពីថ្នាក់នាយករហូតដល់បុគ្គលិក។

យើងខ្ញុំបាននឹងកំពុងយកចិត្តទុកដាក់ជាសំខាន់ ទៅលើការងារតាមដែនសមត្ថកិច្ចរបស់ខ្លួន ប៉ុន្តែយើងក៏មានបញ្ហាប្រឈមមួយចំនួនដែរ ហើយបញ្ហាសំខាន់ជាងគេ គឺកង្វះខាតធនធានមនុស្សដែលមានគុណភាព។

## ង. នាយកដ្ឋានផែនការ លទ្ធកម្ម និងស្ថិតិ

១. សវនករបានសង្កេតឃើញថា នាយកដ្ឋានផែនការ លទ្ធកម្ម និងស្ថិតិ ក៏ដូចជាការិយាល័យនិងផ្នែកពាក់ព័ន្ធមួយចំនួននៅមានចំណុចខ្វះខាត ដែលត្រូវធ្វើការកែលម្អ និងបំពេញបន្ថែមដូចខាងក្រោម៖

### ១.១ រចនាសម្ព័ន្ធនិងភារកិច្ច

យោងតាមសេចក្តីកំណត់ ស្តីពីរចនាសម្ព័ន្ធ និងភារកិច្ចរបស់នាយកដ្ឋានផែនការ លទ្ធកម្ម និងស្ថិតិ លេខ ០០៤ សកណ/កសស/រប.ធម ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៦ សវនករបានពិនិត្យឃើញមានការិយាល័យជំនាញ ០៤ រួមមាន៖ ១) ការិយាល័យស្ថិតិ ២) ការិយាល័យគ្រប់គ្រងគម្រោង ៣) ការិយាល័យផែនការ-វិនិយោគ និង ៤) ការិយាល័យលទ្ធកម្មសាធារណៈ ។

ក្នុងចំណោមការិយាល័យជំនាញទាំង ០៤ (បួន) នេះ សវនករបានពិនិត្យឃើញការិយាល័យគ្រប់គ្រងគម្រោងជាការិយាល័យថ្មីមួយ ដែលទើបតែត្រូវបានបង្កើតឡើង និងដាក់អោយស្ថិតក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានផែនការ លទ្ធកម្ម និងស្ថិតិ។ ជាមួយគ្នានេះដែរ សវនករបានពិនិត្យឃើញមិនទាន់មានសេចក្តីសម្រេចតែងតាំងថ្នាក់ប្រធាន អនុប្រធានការិយាល័យ និងតម្រូវការបុគ្គលិកព្រមទាំងសម្ភារ និងគ្រឿងបរិធានផ្សេងៗ ដើម្បីបម្រើការងារក្នុងក្របខ័ណ្ឌ ការិយាល័យគ្រប់គ្រងគម្រោងនៅឡើយ ។

ករណីខាងលើ បណ្តាលមកពីថ្នាក់ដឹកនាំ **កសស** មានបំណងផ្ទេរអង្គភាពគ្រប់គ្រងគម្រោង (PMU "Project Management Unit") របស់ **កសស** ដែលកំពុងបំពេញតួនាទីជាអ្នកគ្រប់គ្រងកិច្ចដំណើរការអនុវត្តគម្រោងអភិវឌ្ឍន៍កំពង់ផែរបស់ **កសស** ដែលទទួលបន្ទុកសាងសង់ដោយក្រុមហ៊ុនម៉ៅការសំណង់និងក្រុមហ៊ុនទីប្រឹក្សាបរទេស តាមរយៈការដេញថ្លៃប្រកួតប្រជែងជាលក្ខណៈអន្តរជាតិ និងស្ថិតក្រោមការគ្រប់គ្រងរបស់ថ្នាក់ដឹកនាំ **កសស** អោយទៅជាការិយាល័យផ្លូវការមួយ និងដាក់អោយស្ថិតក្រោមការគ្រប់គ្រងបន្ត និងទទួលខុសត្រូវដោយនាយកដ្ឋានផែនការ លទ្ធកម្ម និងស្ថិតិ ។

ចំពោះថ្នាក់ដឹកនាំរបស់សវនដ្ឋាន សវនករបានពិនិត្យឃើញមាន នាយក ០១ រូប នាយករង ០២ រូប និងប្រធានការិយាល័យ ០៤ រូប ប៉ុន្តែជាក់ស្តែងសវនដ្ឋាន មានសេចក្តីសម្រេចតែងតាំងជាផ្លូវការតែនាយក ០១ រូប នាយករង ០១ រូប និងប្រធានការិយាល័យ ០២ រូបប៉ុណ្ណោះ គឺប្រធានការិយាល័យស្ថិតិ និងប្រធានការិយាល័យលទ្ធកម្មសាធារណៈ។ ដោយឡែក នាយករង ០១ រូប ប្រធានការិយាល័យផែនការ-វិនិយោគ និងប្រធានការិយាល័យគ្រប់គ្រងគម្រោង នៅមិនទាន់មានសេចក្តីសម្រេចតែងតាំងជាផ្លូវការនៅឡើយ ។

ប្រការខាងលើ ធ្វើឱ្យប៉ះពាល់ប្រសិទ្ធភាពនៃការគ្រប់គ្រង ការងារប្រចាំថ្ងៃរបស់សវនដ្ឋាន នាំអោយមានការអូសបន្លាយពេលវេលា បណ្តាលឱ្យរចនាសម្ព័ន្ធគ្រប់គ្រងរបស់សវនដ្ឋានមានភាពមិនច្បាស់លាស់ ធ្វើឱ្យ

ថ្នាក់ដឹកនាំសវនដ្ឋាន រួមទាំងមន្ត្រីសំខាន់ៗមួយចំនួនទៀតទទួលខុសត្រូវ និងអនុវត្តការងារត្រួតគ្នាច្រើនផ្នែក និងមិនអនុលោមតាមរចនាសម្ព័ន្ធ និងភារកិច្ចដែល **កសស** បានកំណត់ ។

ដើម្បីរួមចំណែកលើកកំពស់ប្រសិទ្ធភាព និងប្រសិទ្ធផលប្រតិបត្តិការអាជីវកម្ម សេវាកម្ម ក៏ដូចជាការងារគ្រប់គ្រងគម្រោងរបស់ **កសស** សវនករយល់ឃើញថា ថ្នាក់ដឹកនាំសវនដ្ឋានគួររៀបចំរចនាសម្ព័ន្ធគ្រប់គ្រងជាថ្មី ដោយយោងតម្រូវការដែលបានស្នើសុំនៅក្នុងផែនការពលកម្មឆ្នាំ២០១៩ និងដាក់ជូននាយកដ្ឋានរដ្ឋបាល-ធនធានមនុស្ស ពិនិត្យ រៀបចំបែបបទស្នើសុំថ្នាក់ដឹកនាំ **កសស** បង្កើតការិយាល័យគ្រប់គ្រងគម្រោង និងតែងតាំងប្រធានការិយាល័យជាផ្លូវការ រួមទាំងប្រធានការិយាល័យផែនការ-វិនិយោគ តាមសំណើសុំរបស់សវនដ្ឋាន ដើម្បីរួមគ្នាបំពេញការងារដោយភាពរលូន តម្លាភាព និងស្របតាមរចនាសម្ព័ន្ធ និងភារកិច្ចដែល **កសស** បានកំណត់ ។

**មតិឆ្លើយតបរបស់សវនដ្ឋាន៖** សវនដ្ឋានសូមទទួលយក និងស្នើសុំថ្នាក់ដឹកនាំពិនិត្យ ឯកភាពដើម្បីធ្វើការតែងតាំងមន្ត្រីស្របតាមរចនាសម្ព័ន្ធ ។

## ១.២ ការតែងតាំងមន្ត្រីរបស់សវនដ្ឋាន

យោងតាមរចនាសម្ព័ន្ធគ្រប់គ្រង និងភារកិច្ចរបស់សវនដ្ឋាន សវនករបានពិនិត្យឃើញមាន៖ នាយក ០១ រូប នាយករង ០២ រូប ប្រធានការិយាល័យ ០៤ រូប និងបុគ្គលិកសរុបចំនួន ១៣ នាក់ ស្រី ០៤ នាក់និងប្រុស ០៩ នាក់ ប៉ុន្តែតាមការពិនិត្យជាក់ស្តែង សវនករបានសង្កេតឃើញមានសេចក្តីសម្រេចតែងតាំងតែលោកនាយក ០១ រូប នាយករង ០១ រូប និងប្រធានការិយាល័យ ០២ រូបប៉ុណ្ណោះ ។ ដោយឡែក បេក្ខភាពនាយករង ០១ រូប និងប្រធានការិយាល័យ ០២ រូបទៀត នៅមិនទាន់មានសេចក្តីសម្រេចតែងតាំងជាផ្លូវការនៅឡើយ ។

ប្រការខាងលើនេះ ធ្វើឱ្យរចនាសម្ព័ន្ធគ្រប់គ្រងរបស់សវនដ្ឋាន និងការបំពេញតួនាទី-ភារកិច្ចតាមការិយាល័យ ឬផ្នែកមួយចំនួនមានលក្ខណៈមិនច្បាស់លាស់ ប៉ះពាល់ប្រសិទ្ធភាពការងារ និងមិនមានអនុលោមភាពសមស្រប ពីព្រោះបេក្ខភាពនាយករង ០១ រូប និងប្រធានការិយាល័យ ០២ រូបទៀតនៅមិនទាន់មានសេចក្តីសម្រេចតែងតាំងដោយថ្នាក់ដឹកនាំ **កសស** នៅឡើយ ។

ករណីនេះ សវនករយល់ឃើញថាថ្នាក់ដឹកនាំសវនដ្ឋាន គួររៀបចំរចនាសម្ព័ន្ធគ្រប់គ្រងជាថ្មីដោយឈរលើតម្រូវការធនធានមនុស្ស សមត្ថភាព បទពិសោធន៍ ការតាំងចិត្តបម្រើការងារ និងប្រកាន់ខ្ជាប់នូវក្រមសីលធម៌វិជ្ជាជីវៈរបស់អង្គភាព ស្របតាមគោលការណ៍ដែលមានចែង នៅក្នុងបទបញ្ជាផ្ទៃក្នុងរបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ (**កសស**) លេខ ០០១ បបផក/កសស/រប.ប ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៧ ក្នុងចំណុចទី VII. ស្តីពីរបៀបរបបធ្វើការងារមុននឹងដាក់ឆ្លងថ្នាក់ដឹកនាំ **កសស** ដើម្បីស្នើសុំការឯកភាព និងសម្រេចតែងតាំងថ្នាក់នាយករង និងប្រធានការិយាល័យស្របតាមតម្រូវការរបស់សវនដ្ឋាន ។

**មតិឆ្លើយតបរបស់សវនដ្ឋានៈ** សវនដ្ឋាននឹងពិនិត្យលទ្ធភាព រៀបចំរចនាសម្ព័ន្ធគ្រប់គ្រងស្របតាមសំណើសុំក្នុងផែនការពលកម្មឆ្នាំ២០១៩ និងដាក់ស្នើសុំថ្នាក់ដឹកនាំតាមឋានានុក្រម ពិនិត្យ វាយតម្លៃ និងសម្រេចផ្តល់ជូនតាមគោលការណ៍ច្បាប់ ។

## ១.៣ ផែនការពលកម្មឆ្នាំ ២០១៩ របស់ កសស

យោងតាមផែនការពលកម្មឆ្នាំ២០១៩ សវនករបានពិនិត្យឃើញថា នាយកដ្ឋានជំនាញមួយចំនួនដែលស្ថិតក្រោមការគ្រប់គ្រងរបស់ **កសស** នៅមិនទាន់បានទទួលតម្រូវការធនធានមនុស្ស ថ្នាក់នាយករងប្រធានការិយាល័យនិងបុគ្គលិក តាមចំនួនដែលបានស្នើសុំក្នុងផែនការឆ្នាំរបស់ខ្លួន ដើម្បីចាត់អោយបំពេញការងារតាមតម្រូវការក្នុងក្របខ័ណ្ឌនាយកដ្ឋាន និងរួមចំណែកទទួលខុសត្រូវ ការងារប្រចាំថ្ងៃស្របតាមតួនាទី-ភារកិច្ចដែលថ្នាក់ដឹកនាំ **កសស** បានកំណត់នៅឡើយ ។

ប្រការខាងលើ បានកើតមានឡើងដោយសារមន្ត្រី/បុគ្គលិក ទទួលបន្ទុកការងារផ្នែករដ្ឋបាល ឬថ្នាក់ដឹកនាំនាយកដ្ឋានមិនបានពិនិត្យទំហំការងារ ធនធានមនុស្សដែលមានស្រាប់ ភាពចាំបាច់នៃតម្រូវការបន្ថែម និងស្ថានភាពនៃការអនុវត្តការងារប្រចាំថ្ងៃ ដើម្បីរាយការណ៍ជូននិងស្នើសុំថ្នាក់ដឹកនាំ **កសស** ធ្វើការពិនិត្យវាយតម្លៃ និងសម្រេចផ្តល់ជូនតាមការស្នើសុំ នៅក្នុងផែនការពលកម្មឆ្នាំ២០១៩ ។

ករណីនេះ អាចបណ្តាលអោយប៉ះពាល់ប្រសិទ្ធភាព និងប្រសិទ្ធផលប្រតិបត្តិការអាជីវកម្ម សេវាកម្មរបស់ **កសស** នាំអោយមានការអូសបន្លាយពេលវេលា និងអនុវត្តការងារមិនសមស្របតាមតម្រូវការរបស់អតិថិជន អ្នកប្រើប្រាស់ផែ ជាពិសេស ប្រតិបត្តិការអាជីវកម្ម សេវាកម្ម និងទិសដៅអភិវឌ្ឍន៍របស់ **កសស** ។

សវនករយល់ឃើញថា ដើម្បីរួមចំណែកលើកកំពស់គុណភាព និងប្រសិទ្ធភាពប្រតិបត្តិការអាជីវកម្ម សេវាកម្មរបស់ **កសស** អោយកាន់តែល្អប្រសើរឡើងដូចកំពង់ផែនានាក្នុងតំបន់ ថ្នាក់ដឹកនាំនាយកដ្ឋានជំនាញនីមួយៗគួរពិនិត្យបន្ទុកការងារ និងតម្រូវការធនធានមនុស្សអោយបានច្បាស់លាស់ មុននឹងលើកសំណើសុំថ្នាក់ដឹកនាំ **កសស** ពិនិត្យ វាយតម្លៃ និងសម្រេចផ្តល់ជូនតាមនីតិវិធីច្បាប់។ ទោះជាយ៉ាងនេះក្តី ដើម្បីធ្វើអោយផែនការពលកម្មឆ្នាំ២០១៩ មានប្រសិទ្ធភាពអនុវត្តពេញលក្ខណៈ ថ្នាក់ដឹកនាំនាយកដ្ឋានជំនាញគួរពិនិត្យស្ថានភាពជាក់ស្តែង ទំហំការងារ ធនធានដែលមានស្រាប់ និងតម្រូវការបន្ថែមអោយបានសមស្រប ដើម្បីចៀសវាងការប្រើប្រាស់ធនធានលើសតម្រូវការ និងក្នុងលក្ខណៈខ្វះខ្វាយ នាំអោយអង្គភាពខាតបង់ថវិកា ធនធានមនុស្ស និងបាត់បង់ឧត្តមភាពប្រកួតប្រជែង ។

**មតិឆ្លើយតបរបស់សវនដ្ឋានៈ** សវនដ្ឋានសូមទទួលយក និងសហការជាមួយនាយកដ្ឋានពាក់ព័ន្ធដើម្បីពិនិត្យស្ថានភាពជាក់ស្តែង ទំហំការងារ និងធនធានដែលមានស្រាប់ នៅក្នុងនាយកដ្ឋាននីមួយៗដើម្បីផ្ទៀងផ្ទាត់ជាមួយតម្រូវការដែលបានស្នើសុំ ។

## ៥.៤ អនុសាសន៍

ដើម្បីលើកកំពស់គុណភាព និងកែលម្អប្រសិទ្ធភាពប្រតិបត្តិការអាជីវកម្ម សេវាកម្មរបស់ **កសស** ឱ្យកាន់តែល្អប្រសើរឡើងជាលំដាប់ និងទទួលបានសេចក្តីទុកចិត្តពីអតិថិជន អ្នកប្រើប្រាស់ផែបន្ថែមទៀត **នាយកដ្ឋានប្រតិបត្តិការទីលានកុងតឺន័រ នាយកដ្ឋានប្រតិបត្តិការទំនិញទូទៅ នាយកដ្ឋាននាវាចរ-កណ្តាធារ នាយកដ្ឋានបច្ចេកទេស-សម្ភារៈ នាយកដ្ឋានគ្រឿងចក្រ នាយកដ្ឋានតំបន់សេដ្ឋកិច្ចពិសេស នាយកដ្ឋានទីផ្សារ** និង **នាយកដ្ឋានផែនការលទ្ធកម្ម និងស្ថិតិ** គួររួមគ្នាទទួលខុសត្រូវ និងបន្តអភិវឌ្ឍន៍ធនធានមនុស្ស បង្កើនចំណេះដឹង សមត្ថភាព បទពិសោធន៍ មុខជំនាញ ការតាំងចិត្តបម្រើការងារដោយប្រកាន់ខ្ជាប់នូវក្រមសីលធម៌វិជ្ជាជីវៈរបស់អង្គភាព ស្របតាមគោលការណ៍ ដែលមានចែងនៅក្នុងបទបញ្ជាផ្ទៃក្នុង របស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ (**កសស**) លេខ ០០១ បបផក/កសស/រប.ប ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៧ ក្នុងចំណុចទី VII. ស្តីពីរបៀបរបបធ្វើការងារ។

ដោយឡែក ពាក់ព័ន្ធនឹងតម្រូវការធនធានមនុស្ស គ្រប់នាយកដ្ឋាន ជាពិសេស **នាយកដ្ឋានផែនការ-លទ្ធកម្ម និងស្ថិតិ** គួរសហការជាមួយនាយកដ្ឋានពាក់ព័ន្ធដើម្បីសម្របសម្រួល ពិនិត្យស្ថានភាព និងធនធានជាក់ស្តែងរបស់នាយកដ្ឋានជំនាញនីមួយៗ និងរាយការណ៍ជូនថ្នាក់ដឹកនាំ **កសស** ដើម្បីស្នើសុំតែងតាំងថ្នាក់នាយករង ប្រធានការិយាល័យ ព្រមទាំងបុគ្គលិកដែលបានស្នើសុំនៅក្នុងផែនការពលកម្មឆ្នាំ២០១៩ ដើម្បីបំពេញការងារអោយបានសមស្រប តាមសេចក្តីកំណត់ស្តីពីរចនាសម្ព័ន្ធ និងភារកិច្ចរបស់នាយកដ្ឋាននីមួយៗ។

## ៥.៥ មតិឆ្លើយតបរបស់សវនដ្ឋាន

ចំពោះលទ្ធផលឆ្លុះបញ្ចាំងរាល់ចំណុចអវិជ្ជមាន និងអនុសាសន៍កែលម្អខាងលើ និងតាមរយៈការផ្តល់មតិឆ្លើយតបក្នុងពេលប្រជុំសរុបឆ្លងរបាយការណ៍លទ្ធផលសវនកម្មនេះ សវនដ្ឋានបានឯកភាពតាមអនុសាសន៍សវនករ និងសន្យាខិតខំកែលម្អ ឱ្យមានប្រសិទ្ធភាពខ្ពស់នៅពេលខាងមុខ ។

## ៥.៦ មតិសវនករផ្ទៃក្នុងចំពោះមតិឆ្លើយតប

ការបំភ្លឺរបស់សវនដ្ឋានលើចំណុចខ្វះចន្លោះខាងលើ មានលក្ខណៈច្បាស់លាស់ និងសមស្របតាមស្ថានភាពជាក់ស្តែង។ នាយកដ្ឋានសវនកម្មផ្ទៃក្នុង នឹងបន្តតាមដានការអនុវត្តអនុសាសន៍នេះនៅត្រីមាស ឆមាស និងឆ្នាំខាងមុខជាបន្តបន្ទាប់ទៀត ។

# ៦. សេចក្តីសន្និដ្ឋានរួម

នៅក្នុងអំឡុងពេលនៃការធ្វើសវនកម្មនេះ ផ្នែកខ្លះនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង នៅក្នុងនាយកដ្ឋាននីមួយៗត្រូវបានកត់សម្គាល់ឃើញថា មានការខិតខំប្រឹងប្រែង រៀបចំដំណើរការអនុវត្តប្រកបដោយប្រសិទ្ធភាពប្រតិបត្តិការនិងទទួលខុសត្រូវខ្ពស់។ ជាមួយគ្នានេះ ក្រុមការងារសវនកម្មផ្ទៃក្នុងបានសង្កេតឃើញថាថ្នាក់ដឹកនាំ មន្ត្រីនិងបុគ្គលិក គ្រប់នាយកដ្ឋានមានឆន្ទៈរួមសហការ និងយក

ចិត្តទុកដាក់ក្នុងការបំពេញតួនាទី-ភារកិច្ចរបស់ខ្លួន ដោយអនុលោមតាមលក្ខន្តិកៈបុគ្គលិក កសស គោលការណ៍ច្បាប់ និងបទប្បញ្ញត្តិនានាជាធរមាន ។

## ៧. ផែនការសកម្មភាពកែលម្អ

ដើម្បីជានាប្រសិទ្ធភាពអនុវត្ត និងកែលម្អតាមអនុសាសន៍ដែលសវនករបានផ្តល់ជូន ថ្នាក់ដឹកនាំ **នាយកដ្ឋានប្រតិបត្តិការទីលានកុងតឺន័រ នាយកដ្ឋានប្រតិបត្តិការទំនិញទូទៅ នាយកដ្ឋាននាវាចរ-កណ្តាធារ នាយកដ្ឋានបច្ចេកទេស-សម្ភារៈ នាយកដ្ឋានគ្រឿងចក្រ នាយកដ្ឋានតំបន់សេដ្ឋកិច្ចពិសេស នាយកដ្ឋានទីផ្សារ** និង **នាយកដ្ឋានផែនការលទ្ធកម្ម និងស្ថិតិ** បានឯកភាពតាមផែនការសកម្មភាព ដូចបានកំណត់នៅក្នុងតារាងនៃឧបសម្ព័ន្ធ ២ ។

ថ្ងៃសុក្រ ៧កើត ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
ខេត្តព្រះសីហនុ, ថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០

**នាយកសវនកម្មផ្ទៃក្នុង**

**ម៉ែន ចាន់**

**បានឃើញ និងឯកភាព**
ខេត្តសៀមរាប, ថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២០
**ប្រធានគណៈកម្មាធិការសវនកម្ម**

**ហ៊ុន មុន្នីវណ្ណា**

<u>កន្លែងទទួលៈ</u>

- នាយកដ្ឋានសវនកម្មផ្ទៃក្នុង
- ឯកសារ-កាលប្បវត្តិ

# ផ្នែកទី ៦

# របាយការណ៍ហិរញ្ញវត្ថុដែលធ្វើសវនកម្ម ដោយសវនករឯករាជ្យ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

កំពង់ផែស្វយ័តក្រុងព្រះសីហនុ

## របាយការណ៍ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលរបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ (ហៅកាត់ថា "ក.ស.ស") មានសេចក្តីសោមនស្ស សូមបង្ហាញរបាយការណ៍របស់ខ្លួន និងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចហើយ សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩។

## សកម្មភាពអាជីវកម្មចម្បង

សកម្មភាពអាជីវកម្មចម្បងរបស់ ក.ស.ស គឺពាក់ព័ន្ធនឹងការផ្តល់សេវាកំពង់ផែសមុទ្រ និងសេវាផ្សេងៗទៀតដែលពាក់ព័ន្ធនឹងកំពង់ផែ ព្រមទាំងអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសសម្រាប់ជួល។

## លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុសម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗ។

## ទ្រព្យសកម្ម

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានកត់សម្គាល់ហេតុការណ៍ណាមួយដែលនឹងបណ្តាលឱ្យមានការភាន់ច្រឡំដល់ការកំណត់តម្លៃទ្រព្យសកម្ម នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ ក.ស.ស នោះទេ។

## បំណុលយថាភាព និងបំណុលផ្សេងៗទៀត

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ មិនមាន :

ក) បន្ទុកណាមួយលើទ្រព្យសកម្មរបស់ ក.ស.ស ដែលបានកើតឡើងដោយសារការដាក់បញ្ចាំ សម្រាប់ធានាបំណុលរបស់បុគ្គលណាម្នាក់ឡើយ ចាប់តាំងពីដំណាច់ឆ្នាំមក ឬ

ខ) បំណុលយថាភាពណាមួយ កើតឡើងចំពោះ ក.ស.ស ចាប់តាំងពីដំណាច់ឆ្នាំមក។

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល ក.ស.ស ពុំមានបំណុលយថាភាព ឬបំណុលផ្សេងៗទៀត ដែលត្រូវបានទាមទារឱ្យសង ឬអាចត្រូវបានទាមទារឱ្យសង ក្នុងអំឡុងពេល១២ខែបន្ទាប់ពីដំណាច់ឆ្នាំ ដែលនឹងអាចមានផលប៉ះពាល់ធ្ងន់ធ្ងរដល់លទ្ធភាពរបស់ ក.ស.ស ក្នុងការបំពេញកាតព្វកិច្ចសងបំណុលរបស់ខ្លួន នៅថ្ងៃកំណត់សងនោះទេ។

## ការផ្លាស់ប្តូរហេតុការណ៍

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលបានកើតឡើងពាក់ព័ន្ធនឹងរបាយការណ៍នេះ ឬរបាយការណ៍ហិរញ្ញវត្ថុរបស់ ក.ស.ស ដែលធ្វើឱ្យចំនួនទឹកប្រាក់ ដែលបានរាយការណ៍នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុមានកំហុសឆ្គងធ្ងន់ធ្ងរនោះទេ។

## ប្រតិបត្តិការមិនធម្មតា

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល លទ្ធផលហិរញ្ញវត្ថុរបស់ ក.ស.ស សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ មិនបានទទួលរងនូវឥទ្ធិពលធ្ងន់ធ្ងរ ដែលកើតចេញពីគណនី ប្រតិបត្តិការ ឬព្រឹត្តិការណ៍ទាំងឡាយ ដែលមានលក្ខណៈជាសារវន្ត និងមិនធម្មតានោះទេ។

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវក្នុងការធានាថា របាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើងត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់នៃស្ថានភាពហិរញ្ញវត្ថុរបស់ ក.ស.ស គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ និងលទ្ធផលហិរញ្ញវត្ថុ ព្រមទាំងលំហូរសាច់ប្រាក់សម្រាប់ដំណាច់ឆ្នាំ។ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ក្រុមប្រឹក្សាភិបាលត្រូវ៖

១) អនុវត្តគោលការណ៍គណនេយ្យដែលសមស្រប ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (ហៅកាត់ថា "CIFRS") ដែលគាំទ្រដោយការវិនិច្ឆ័យ និងការប៉ាន់ប្រមាណសមហេតុផល ហើយបន្ទាប់មកត្រូវអនុវត្តវាជាប្រចាំ

២) គោរពតាមតម្រូវការរបស់ CIFRS ក្នុងការលាតត្រដាងព័ត៌មាន ហើយប្រសិនបើមានការប្រាសចាកណាមួយពីស្តង់ដារទាំងនេះ ក្នុងការបង្ហាញឱ្យមានត្រឹមត្រូវ ការប្រាសចាកទាំងនោះត្រូវបានលាតត្រដាង ពន្យល់ និងកំណត់ចំនួនទឹកប្រាក់សមស្របនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ

៣) ថែរក្សាបញ្ជីគណនេយ្យឱ្យបានគ្រប់គ្រាន់ ដើម្បីឱ្យ ក.ស.ស អាចរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដែលអនុលោមទៅតាម CIFRS និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងដែលមានប្រសិទ្ធភាព

៤) រៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយផ្អែកលើមូលដ្ឋាននិរន្តរភាព លើកលែងតែមានការសន្មតថា ក.ស.ស មិនមានលក្ខណៈសមស្របក្នុងការបន្តប្រតិបត្តិការនៅពេលអនាគតដែលអាចប៉ាន់ស្មានបាន និង

៥) គ្រប់គ្រង និងដឹកនាំ ក.ស.ស ឱ្យមានប្រសិទ្ធភាព ហើយប្រាកដថាការសម្រេចចិត្តលើបញ្ហាសំខាន់ៗទាំងអស់ ដែលអាចប៉ះពាល់ដល់ប្រតិបត្តិការ ហើយការចូលរួមរាល់ការសម្រេចចិត្តទាំងនោះ ត្រូវបានឆ្លុះបញ្ចាំងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលធានាអះអាងថា ក.ស.ស បានអនុវត្តតាមរាល់តម្រូវការខាងលើ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ សមាជិកក្រុមប្រឹក្សាភិបាលរបស់ ក.ស.ស មានសមាសភាគដូចខាងក្រោម៖

| ឈ្មោះ | តំណាង | តួនាទី |
|---|---|---|
| ឯកឧត្តម លូ គឹមឈន់ | ប្រធានអគ្គនាយកកំពង់ផែស្វយ័តក្រុងព្រះសីហនុ | ប្រធានក្រុមប្រឹក្សាភិបាល |
| ឯកឧត្តម ផាន់ ផល្លា | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិកក្រុមប្រឹក្សាភិបាល |
| ឯកឧត្តម ស៊ុយ សាន | ក្រសួងសាធារណៈការ និងដឹកជញ្ជូន | សមាជិកក្រុមប្រឹក្សាភិបាល |
| ឯកឧត្តម សុខ សុភ័ក្រ្ត | ក្រសួងពាណិជ្ជកម្ម | សមាជិកក្រុមប្រឹក្សាភិបាល |
| លោក លូ លីខេង | បុគ្គលិកកំពង់ផែស្វយ័តក្រុងព្រះសីហនុ | សមាជិកក្រុមប្រឹក្សាភិបាល |
| លោក ហ៊ុន មុន្នីវណ្ណ | នាយកប្រតិបត្តិឯករាជ្យ | សមាជិកក្រុមប្រឹក្សាភិបាល |
| លោក Hidetoshi Kume | នាយកមិនប្រតិបត្តិ | សមាជិកក្រុមប្រឹក្សាភិបាល |

## ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ

យើងខ្ញុំជាក្រុមប្រឹក្សាភិបាល អនុម័តលើរបាយការណ៍ហិរញ្ញវត្ថុដែលភ្ជាប់មកជាមួយ ព្រមទាំងកំណត់សម្គាល់ផ្សេងៗ ដែលបានបង្ហាញត្រឹមត្រូវ នូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់នៃស្ថានភាពហិរញ្ញវត្ថុរបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ គិតត្រឹម ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់សម្រាប់ដំណាច់ឆ្នាំ ដោយស្របតាមស្តង់ដាររបាយ-ការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា។

**តាងនាមក្រុមប្រឹក្សាភិបាល**

**ឯកឧត្តម លូ គឹមឈន់**
ប្រធានក្រុមប្រឹក្សាភិបាល និងជា អគ្គនាយក

**លោក ប៉ាត សិត**
នាយក គណនេយ្យ និងហិរញ្ញវត្ថុ

ខេត្តព្រះសីហនុ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០

## របាយការណ៍សវនករឯករាជ
## ជូនភាគហ៊ុនិក កំពង់ផែស្វយ័តក្រុងព្រះសីហនុ

### មតិយោបល់របស់យើងខ្ញុំ

តាមមតិយោបល់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុរបស់ កំពង់ផែស្វយ័តក្រុងព្រះសីហនុ (ហៅកាត់ថា"ក.ស.ស") បង្ហាញត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់អំពីស្ថានភាពហិរញ្ញវត្ថុរបស់ ក.ស.ស គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ និងលទ្ធផលហិរញ្ញវត្ថុ ព្រមទាំងលំហូរសាច់ប្រាក់សម្រាប់ដំណាច់ឆ្នាំ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (ហៅកាត់ថា "CIFRS")។

### របាយការណ៍ដែលយើងខ្ញុំបានធ្វើសវនកម្ម

របាយការណ៍ហិរញ្ញវត្ថុរបស់ ក.ស.ស រួមមាន៖

- តារាងតុល្យការគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩
- របាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗសម្រាប់ដំណាច់ឆ្នាំ
- របាយការណ៍បម្រែបម្រួលមូលធនសម្រាប់ដំណាច់ឆ្នាំ
- របាយការណ៍លំហូរសាច់ប្រាក់សម្រាប់ដំណាច់ឆ្នាំ និង
- កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ រាប់ទាំងសេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ។

### មូលដ្ឋាននៃមតិយោបល់របស់យើងខ្ញុំ

យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារអន្តរជាតិ ស្តីពីសវនកម្ម នៃ កម្ពុជា (ហៅកាត់ថា "ស្តង់ដារសវនកម្ម")។ ការទទួលខុសត្រូវរបស់យើងខ្ញុំដែលអនុលោមទៅតាមស្តង់ដារទាំងនោះ ត្រូវបានពណ៌នាបន្ថែមទៀតនៅក្នុងកថាខណ្ឌ *"ការទទួលខុសត្រូវរបស់សវនករក្នុងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ"* នៅក្នុងរបាយការណ៍សវនកម្មរបស់យើងខ្ញុំ។

យើងខ្ញុំជឿជាក់ថាភស្តុតាងសវនកម្មដែលយើងខ្ញុំបានទទួល មានភាពគ្រប់គ្រាន់ និងសមហេតុផល ដើម្បីធ្វើជាមូលដ្ឋានសម្រាប់ការបញ្ចេញមតិយោបល់របស់យើងខ្ញុំ។

### ឯករាជ្យ

យើងខ្ញុំមានឯករាជ្យពី ក.ស.ស ដែលអនុលោមទៅតាមក្រមសីលធម៌សម្រាប់គណនេយ្យករវិជ្ជាជីវៈ ដែលចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដារក្រមសីលធម៌អន្តរជាតិ (ហៅកាត់ថា "ក្រមសីលធម៌អន្តរជាតិ") និងអនុលោមទៅតាមក្រមសីលធម៌របស់ វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (ហៅកាត់ថា "ក្រមសីលធម៌ វគសក")។ យើងខ្ញុំបានបំពេញកាតព្វកិច្ចក្នុងការទទួលខុសត្រូវផ្នែកក្រមសីលធម៌ផ្សេងៗទៀត ដែលកំណត់ដោយក្រមសីលធម៌អន្តរជាតិ និង ក្រមសីលធម៌ វគសក។

pwc

## បញ្ហាសវនកម្មសំខាន់ៗ

តាមការវិនិច្ឆ័យប្រកបដោយវិជ្ជាជីវៈរបស់យើងខ្ញុំ បញ្ហាសវនកម្មសំខាន់ៗគឺជាបញ្ហាទាំងឡាយណា ដែលមានសារៈសំខាន់បំផុតនៅក្នុងការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុក្នុងការិយបរិច្ឆេទក្នុងគ្រា។ យើងបានកំណត់បញ្ហាសវនកម្មសំខាន់មួយៈ កាតព្វកិច្ចអត្ថប្រយោជន៍សោធននិវត្តន៍។ បញ្ហាទាំងនេះត្រូវបានលើកឡើងនៅក្នុងបរិបទនៃការធ្វើសវនកម្មរបស់យើងខ្ញុំទៅលើរបាយការណ៍ហិរញ្ញវត្ថុទាំងមូល ដូចនេះក្នុងការបញ្ចេញមតិយោបល់ យើងខ្ញុំពុំបញ្ចេញយោបល់ដោយឡែកទៅលើបញ្ហាទាំងនេះទេ។

| បញ្ហាសវនកម្មសំខាន់ៗ | នីតិវិធីដែលយើងខ្ញុំដោះស្រាយបញ្ហាសវនកម្មសំខាន់ៗ |
|---|---|
| **កាតព្វកិច្ចអត្ថប្រយោជន៍សោធននិវត្តន៍** | |
| យោងទៅកំណត់សម្គាល់ ២.១៦.១ (i) – សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ ស្តីពីកាតព្វកិច្ចអត្ថ-ប្រយោជន៍សោធនិវត្តន៍ និងកំណត់សម្គាល់ ៤.ក – ការសន្មត និង ការវិនិច្ឆ័យលើកាតព្វកិច្ចអត្ថប្រយោជន៍សោធននិវត្តន៍។<br><br>គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ក.ស.ស មានសមតុល្យដែលនៅមិនទាន់ទូទាត់ ចំពោះគម្រោងអត្ថប្រយោជន៍សោធននិវត្តន៍ចំនួន ៨៣.០៧៤ លានរៀល។<br><br>គណៈគ្រប់គ្រង បានវាយតម្លៃបំណុលកាតព្វកិច្ច អាស្រ័យទៅតាមទិន្នន័យប្រជាសាស្ត្រក្នុងគ្រាកន្លងមក ស្ថានភាពអាជីវកម្មក្នុងពេលបច្ចុប្បន្ន និងគោលការណ៍គណនេយ្យ។ គណៈគ្រប់គ្រងក៏បានជួលក្រុមអ្នកជំនាញខាងក្រៅ ដើម្បីធ្វើការគណនាលម្អិតអំពីភាពស្មុគស្មាញនេះផងដែរ។<br><br>ការវាយតម្លៃ កាតព្វកិច្ចអត្ថប្រយោជន៍សោធននិវត្តន៍ តម្រូវឱ្យមាន ការវិនិច្ឆ័យជាក់លាក់របស់គណៈគ្រប់គ្រង និងអ្នកជំនាញបច្ចេកទេសក្នុងការអនុវត្តការសន្មតដែលសមស្រប។ បម្រែបម្រួលការសន្មតសំខាន់ៗ រួមមាន កំណើនប្រាក់បៀវត្សរ៍ អតិផរណា អត្រាអប្បហារ និងអត្រាមរណភាព ដែលអាចនាំឱ្យមានផលប៉ះពាល់ជាសារវន្តលើការគណនាបំណុល។<br><br>យើងខ្ញុំផ្តោតលើផ្នែកទាំងនេះ ដោយសារវាពាក់ព័ន្ធយ៉ាងសំខាន់ទៅលើការវិនិច្ឆ័យ និងការប៉ាន់ស្មានរបស់គណៈគ្រប់គ្រង ដើម្បីធ្វើការវាយតម្លៃយ៉ាងសមស្រប និងត្រឹមត្រូវ។ | នីតិវិធីសវនកម្មរបស់យើងខ្ញុំ ទាក់ទិនទៅនឹងការប៉ាន់ស្មានរបស់គណៈគ្រប់គ្រង លើចំនួនទឹកប្រាក់បំណុលនេះ រួមមាន៖<br>• វាយតម្លៃអំពីសមត្ថភាព ឯករាជ្យ និងភាពម៉ឺងម៉ាត់ ព្រមទាំងពិនិត្យលក្ខណៈសម្បត្តិនៃអ្នកជំនាញរបស់គណៈគ្រប់គ្រង (ក្រុមអ្នកជំនាញខាងក្រៅ) និងពិនិត្យលើវិសាលភាពការងាររបស់ពួកគាត់ផងដែរ។<br>• វាយតម្លៃលើការសន្មតហានិភ័យ និង ភាពសមហេតុសមផលនៃកាតព្វកិច្ចអត្ថប្រយោជន៍។<br>• ប្រៀបធៀបកំណើនប្រាក់បៀវត្សរ៍ ជាមួយនឹងកំណើនប្រាក់បៀវត្សរ៍ក្នុងគ្រាកន្លងមក និងគម្រោងនាពេលអនាគត ព្រមទាំងអត្រាអតិផរណាដែលទិន្នន័យនេះត្រូវបានផ្សព្វផ្សាយដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អត្រាអប្បហាររបស់ប្រាក់បញ្ញើដែលមានប្រភេទរូបិយវត្ថុ/កាលកំណត់ដូចគ្នា ព្រមទាំងអត្រាមរណៈ ដែលមានទិន្នន័យចុងក្រោយបំផុត ត្រូវបានផ្សព្វផ្សាយក្នុងតារាងអត្រាមរណៈ រំពឹងទុករបស់ប្រទេសថៃសម្រាប់ឆ្នាំ២០១៧។<br>• ផ្ទៀងផ្ទាត់បម្រែបម្រួលកាតព្វកិច្ចអត្ថប្រយោជន៍ ជាមួយនឹងព័ត៌មានគាំទ្រមូលដ្ឋាន ដូចជា ចំណាយថ្លៃសេវានាពេលបច្ចុប្បន្ន ចំណាយការប្រាក់អត្ថប្រយោជន៍បានបង់ ការខាតបង់ពីការវាស់វែងឡើងវិញ និងការផ្ទៀងផ្ទាត់ សមតុល្យដើមគ្រា និងសមតុល្យចុងគ្រា និង<br>• ផ្ទៀងផ្ទាត់ និងគណនាចំនួនទឹកប្រាក់ ក្នុងរបាយការណ៍វាយតម្លៃអត្ថប្រយោជន៍ ជាមួយនឹងការកត់ត្រាគណនេយ្យ និង ប្រភពទិន្នន័យពីនាយកដ្ឋានធនធាន មនុស្ស។<br><br>ជាលទ្ធផលនៃនីតិវិធីទាំងនេះ យើងខ្ញុំកំណត់ថាការសន្មតសំខាន់ៗសម្រាប់ការប៉ាន់ស្មាននេះគឺមានមូលដ្ឋានសមហេតុផល។ យើងខ្ញុំមិនបានរកឃើញនូវកំហុសខុសឆ្គងជាសារវន្តណាមួយទេ។ |

pwc

## ព័ត៌មានផ្សេងៗ

គណៈគ្រប់គ្រងទទួលខុសត្រូវចំពោះព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗរួមមានរបាយការណ៍របស់ក្រុមប្រឹក្សាភិបាល (ប៉ុន្តែមិនរួមបញ្ចូលនូវរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សវនកររបស់យើងខ្ញុំទេ) ដែលយើងខ្ញុំទទួលបានមុនកាលបរិច្ឆេទនៃរបាយការណ៍សវនករ និងព័ត៌មានដែលរួមបញ្ចូលនៅក្នុងរបាយការណ៍ប្រចាំឆ្នាំ ត្រូវបានរំពឹងថានឹងផ្តល់ឱ្យយើងខ្ញុំ បន្ទាប់ពីកាលបរិច្ឆេទនៃរបាយការណ៍សវនករនេះ។

មតិយោបល់របស់យើងខ្ញុំចំពោះរបាយការណ៍ហិរញ្ញវត្ថុ ពុំបានគ្របដណ្តប់ទៅលើព័ត៌មានផ្សេងៗនោះទេ ហើយយើងខ្ញុំមិនធ្វើការធានាអះអាងចំពោះព័ត៌មានទាំងនោះទេ។

ទាក់ទងនឹងការធ្វើសវនកម្មរបស់យើងខ្ញុំទៅលើរបាយការណ៍ហិរញ្ញវត្ថុ យើងខ្ញុំទទួលខុសត្រូវក្នុងការអានព័ត៌មានផ្សេងៗដែលបានរៀបរាប់ខាងលើ ដើម្បីពិចារណាថាតើព័ត៌មានផ្សេងៗទាំងនោះមានភាពផ្ទុយគ្នាជាសារវន្តពីរបាយការណ៍ហិរញ្ញវត្ថុ ឬផ្ទុយពីការយល់ដឹងរបស់យើងខ្ញុំ ផ្អែកលើលទ្ធផលនៃការធ្វើសវនកម្ម ឬមានការរាយការណ៍ពីកំហុសឆ្គងជាសារវន្តដែលបានកើតឡើងឬទេ។

ផ្អែកទៅលើការងារដែលយើងខ្ញុំបានបំពេញ ទៅលើព័ត៌មានផ្សេងៗដែលយើងខ្ញុំបានទទួលមុនកាលបរិច្ឆេទនៃរបាយការណ៍សវនករនេះ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថាមានកំហុសឆ្គងជាសារវន្តដែលកើតចេញពីព័ត៌មានផ្សេងៗទាំងនេះ យើងខ្ញុំត្រូវរាយការណ៍ពីអង្គហេតុនៃកំហុសឆ្គងទាំងនោះ។ យើងខ្ញុំមិនមានអ្វីត្រូវរាយការណ៍ចំពោះបញ្ហានេះទេ។

នៅពេលដែលយើងខ្ញុំអានរបាយការណ៍ប្រចាំឆ្នាំ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថាមានកំហុសឆ្គងជាសារវន្តនៅក្នុងរបាយការណ៍នោះ យើងខ្ញុំត្រូវរាយការណ៍ជូនអ្នកដែលទទួលបន្ទុកអភិបាលកិច្ចនេះ។

## ការទទួលខុសត្រូវរបស់គណៈគ្រប់គ្រង និងអ្នកដែលទទួលបន្ទុកអភិបាលកិច្ចរបាយការណ៍ហិរញ្ញវត្ថុ

គណៈគ្រប់គ្រងទទួលខុសត្រូវក្នុងការរៀបចំ និងបង្ហាញរបាយការណ៍ហិរញ្ញវត្ថុឱ្យបានត្រឹមត្រូវ ដោយអនុលោមទៅតាម CIFRS និងទទួលខុសត្រូវលើការត្រួតពិនិត្យផ្ទៃក្នុង ដែលគណៈគ្រប់គ្រងកំណត់ថាមានភាពចាំបាច់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ឱ្យចៀសផុតពីការរាយការណ៍ខុសជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ។

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ គណៈគ្រប់គ្រងទទួលខុសត្រូវក្នុងការវាយតម្លៃអំពីលទ្ធភាពរបស់ ក.ស.ស ក្នុងការបន្តនិរន្តរភាពអាជីវកម្ម ការលាតត្រដាងព័ត៌មានដែលពាក់ព័ន្ធ ក៏ដូចជាបញ្ហាផ្សេងៗដែលទាក់ទិនទៅនឹងនិរន្តរភាពអាជីវកម្ម ដោយប្រើមូលដ្ឋានគណនេយ្យសម្រាប់និរន្តរភាពអាជីវកម្ម លើកលែងតែគណៈគ្រប់គ្រងគ្រោងនឹងបិទអាជីវកម្មរបស់ ក.ស.ស ឬបញ្ឈប់ប្រតិបត្តិការ ដោយមិនមានជម្រើសណាផ្សេងប្រកបដោយភាពប្រាកដប្រជាណាមួយ។

អ្នកដែលទទួលបន្ទុកលើអភិបាលកិច្ច ត្រូវមានការទទួលខុសត្រូវក្នុងការត្រួតពិនិត្យដំណើរការនៃការរាយការណ៍ហិរញ្ញវត្ថុរបស់ ក.ស.ស ។

## ការទទួលខុសត្រូវរបស់សវនករ ក្នុងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ

គោលបំណងរបស់យើងខ្ញុំគឺស្វែងរកអំណះអំណាងដែលសមហេតុផល ថារបាយការណ៍ហិរញ្ញវត្ថុទាំងមូលពុំមានការរាយការណ៍ខុសជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ និងចេញរបាយការណ៍សវនកម្មដែលមានមតិយោបល់របស់យើងខ្ញុំ។ ការអះអាងដែលសមហេតុផលគឺជាការអះអាងក្នុងកម្រិតខ្ពស់ ប៉ុន្តែវាមិនមែនជាការធានាថា សវនកម្មដែលបានធ្វើឡើងដោយអនុលោមទៅតាមស្តង់ដារសវនកម្ម តែងតែរកឃើញជានិច្ចនូវការរាយការណ៍ខុសជាសារវន្តដែលបានកើតឡើងនោះទេ។ ការរាយការណ៍ខុសអាចកើតឡើងពីការក្លែងបន្លំ ឬកំហុសឆ្គង ហើយវាត្រូវបានចាត់ទុកថាមាន លក្ខណៈជាសារវន្ត ប្រសិនបើការរាយការណ៍ខុសនីមួយៗ ឬការរាយការណ៍ខុសសរុប អាចត្រូវបានរំពឹងថាវាជះឥទ្ធិពលលើមូលដ្ឋាននៃការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

ផ្នែកមួយនៃការធ្វើសវនកម្មដែលអនុលោមទៅតាមស្តង់ដារសវនកម្ម តម្រូវឱ្យយើងខ្ញុំប្រើប្រាស់ការវិនិច្ឆ័យ និងរក្សាភាពងឿងឆ្ងល់ប្រកបដោយវិជ្ជាជីវៈក្នុងពេលបំពេញការងារសវនកម្មរបស់យើងខ្ញុំ ហើយយើងខ្ញុំ៖

- កំណត់ និងវាយតម្លៃហានិភ័យនៃភាពខុសជាសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុ ដែលអាចបណ្តាលមកពីការក្លែងបន្លំឬកំហុសឆ្គងផ្សេងៗ ដោយតាក់តែងនីតិវិធីសវនកម្ម និងធ្វើសវនកម្មដើម្បីឆ្លើយតបទៅនឹងហានិភ័យទាំងនោះ និងស្វែងរកភស្តុតាងសវនកម្មគ្រប់គ្រាន់និងសមស្រប ដើម្បីធ្វើជាមូលដ្ឋានសម្រាប់ការបញ្ចេញមតិយោបល់របស់យើងខ្ញុំ។ ហានិភ័យដែលបណ្តាលមកពីការរកមិនឃើញកំហុសជាសារវន្តពីការក្លែងបន្លំ វាមានទំហំធំជាង ហានិភ័យដែលបណ្តាលមកពីកំហុសឆ្គងអចេតនា។ ការក្លែងបន្លំរួមមាន ការសមគំនិត ការក្លែងបន្លំឯកសារ ការលុបបំបាត់ដោយចេតនា ការបង្ហាញខុស ឬការរំលងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។
- ស្វែងយល់អំពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលពាក់ព័ន្ធទៅនឹងសវនកម្ម ដើម្បីតាក់តែងនីតិវិធីសវនកម្មដែលសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនបញ្ចេញមតិយោបល់របស់យើងខ្ញុំទៅលើប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ ក.ស.ស ទេ។
- វាយតម្លៃអំពីភាពសមស្របនៃគោលការណ៍គណនេយ្យដែលបានប្រើប្រាស់ ភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យ និងការលាតត្រដាងពាក់ព័ន្ធ ដែលគណៈគ្រប់គ្រងបានធ្វើឡើង។
- សន្និដ្ឋានលើភាពសមស្របនៃការប្រើប្រាស់មូលដ្ឋានគណនេយ្យនិរន្តរភាពអាជីវកម្ម របស់គណៈគ្រប់គ្រង អាស្រ័យទៅលើភស្តុតាងសវនកម្មដែលយើងខ្ញុំទទួលបាន ថាតើវាមានភាពមិនច្បាស់លាស់ជាសារវន្តដែលបានកើតឡើងកម្រិតណាពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌនានា អាចបណ្តាលឱ្យមានការសង្ស័យជាដុំកំភួនទៅលើលទ្ធភាពរបស់ ក.ស.ស ក្នុងការបន្តនិរន្តរភាពអាជីវកម្មរបស់ខ្លួនដែរឬទេ។ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថា វាមានភាពមិនច្បាស់លាស់ជាសារវន្តបានកើតឡើង នោះយើងខ្ញុំត្រូវធ្វើការបង្ហាញនៅក្នុងរបាយការណ៍សវនកម្ម ដើម្បីទាញចំណាប់អារម្មណ៍អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុ ចំពោះការលាតត្រដាងព័ត៌មាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើការលាតត្រដាងនោះនៅមិនទាន់គ្រប់គ្រាន់ទៀត យើងខ្ញុំត្រូវធ្វើការកែប្រែមតិយោបល់របស់យើងខ្ញុំ។ សេចក្តីសន្និដ្ឋានសរុបរបស់យើងខ្ញុំ អាស្រ័យទៅលើភស្តុតាងសវនកម្មដែលយើងខ្ញុំទទួលបាន រហូតដល់ថ្ងៃចុះហត្ថលេខាលើរបាយការណ៍សវនកម្មនេះ។ ទោះជាយ៉ាងណាក៏ដោយ ព្រឹត្តិការណ៍ ឬលក្ខខណ្ឌនានាក្នុងពេលអនាគត អាចបណ្តាលឱ្យ ក.ស.ស ឈប់បន្តនិរន្តរភាពអាជីវកម្ម។

- វាយតម្លៃការបង្ហាញទូទៅ រចនាសម្ព័ន្ធ និងខ្លឹមសារក្នុងរបាយការណ៍ហិរញ្ញវត្ថុ រួមទាំងការលាតត្រដាងព័ត៌មាន ផ្សេងៗ និងកំណត់ថារបាយការណ៍ហិរញ្ញវត្ថុបង្ហាញពីប្រតិបត្តិការ និងព្រឹត្តិការណ៍ជាក់ស្តែង ដែលអាចធ្វើឱ្យមានការបង្ហាញត្រឹមត្រូវ។

យើងខ្ញុំបានរាយការណ៍ជូនអ្នកដែលទទួលបន្ទុកអភិបាលកិច្ចនូវបញ្ហាផ្សេងៗដូចជា ទំហំការងារ និងពេលវេលាសវនកម្ម ព្រមទាំងបញ្ហាសវនកម្មសំខាន់ៗ រួមទាំងរាយការណ៍ពីភាពខ្វះខាតជាសារវន្តនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលយើងខ្ញុំបានរកឃើញក្នុងការធ្វើសវនកម្មរបស់យើងខ្ញុំ។

យើងខ្ញុំក៏ធ្វើការអះអាងចំពោះអ្នកទទួលបន្ទុកអភិបាលកិច្ច ថាយើងខ្ញុំបានអនុវត្តតាមក្របខណ្ឌវិជ្ជាជីវៈពាក់ព័ន្ធទាក់ទិននឹងឯករាជ្យ ព្រមទាំងសម្រាប់ជូនពួកគេអំពីទំនាក់ទំនងនានាទាំងអស់ និងបញ្ហាផ្សេងៗទៀត ដែលអាចចាត់ទុកថាមានផលប៉ះពាល់ចំពោះឯករាជ្យរបស់យើងខ្ញុំ និងវិធានការប្រព័ន្ធការពាររបស់យើងខ្ញុំ។

ស្តែងចេញពីបញ្ហានានាដែលយើងខ្ញុំបានជម្រាបជូនអ្នកទទួលបន្ទុកអភិបាលកិច្ច យើងខ្ញុំកំណត់ពីបញ្ហានានាដែលមានភាពជាសារវន្តក្នុងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុក្នុងការិយបរិច្ឆេទបច្ចុប្បន្ន ដូចនេះបញ្ហានេះជាបញ្ហាសវនកម្មសំខាន់។ យើងខ្ញុំពណ៌នាបញ្ហាទាំងនេះនៅក្នុងរបាយការណ៍សវនកររបស់យើងខ្ញុំ លើកលែងតែក្នុងករណីដែលច្បាប់ ឬបទប្បញ្ញត្តិ ហាមប្រាមការបង្ហាញបញ្ហាទាំងនេះជាសាធារណៈ ឬលើកលែងតែក្នុងករណីដ៏កម្របំផុតដែលយើងខ្ញុំកំណត់ថាបញ្ហានេះមិនគួរបញ្ចូលទៅក្នុងរបាយការណ៍របស់យើងខ្ញុំ ដោយមូលហេតុថាវានឹងមានផលអវិជ្ជមាននានា ដែលនាំឱ្យមានផលប៉ះពាល់ដល់ផលប្រយោជន៍សាធារណៈ ចំពោះការរាយការណ៍បែបនេះ។

**ជ. ក្រុមហ៊ុន** PricewaterhouseCoopers (Cambodia) Ltd.

**ឡាង ហ៊ី**

Partner

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ
## នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

| | កំណត់សម្គាល់ | ២០១៩<br>ពាន់រៀល | ២០១៨<br>ពាន់រៀល<br>(បានរាយការណ៍ឡើងវិញ) | ០១ មករា ២០១៨<br>ពាន់រៀល<br>(បានរាយការណ៍ឡើងវិញ) |
|---|---|---|---|---|
| **ទ្រព្យសកម្ម** | | | | |
| **ទ្រព្យសកម្មរយៈពេលវែង** | | | | |
| ទ្រព្យសម្បត្តិ និងបរិក្ខារ | ៦ | ៨៥៧.១៧៨.៣៣១ | ៨៤៥.៦៦១.៩៧១ | ៨០៨.៨៧០.៣៣៨ |
| ទ្រព្យសម្បត្តិវិនិយោគ | ៧ | ២៧៥.៨៨០.៧៤៥ | ២៧៩.៤៨២.១៨០ | ២៨៣.៦៧២.០៦៩ |
| ទ្រព្យសកម្មអរូបី | ៨ | ៦.៤៣១.៩៦០ | ៧.៤៩៤.៨៣១ | ៨.៥៥៧.៧០២ |
| ឥណទានផ្តល់ឱ្យបុគ្គលិក | ៩ | ១.២២៨.០១៩ | ៣.៤២១.១៣២ | ៥.៣០៥.១១៣ |
| | | ១.១៤០.៧១៩.០៥៥ | ១.១៣៦.០៦០.១១៤ | ១.១០៦.៤០៥.២២២ |
| **ទ្រព្យសកម្មរយៈពេលខ្លី** | | | | |
| ឥណទានផ្តល់ឱ្យបុគ្គលិក | ៩ | ២.១៩៣.១១២ | ១.៨៨៣.៩៨១ | ១.៦១៨.៤២៥ |
| សន្និធិ | ១០ | ១៨.៥១៩.២៥៥ | ១១.៣២២.៦១៨ | ៨.៤៤៣.៥៦៦ |
| គណនីអតិថិជនពាណិជ្ជកម្ម និងគណនីអតិថិជនផ្សេងៗ | ១១ | ៥៣.៤២៩.៥៨៤ | ៤១.៨៥៩.០១១ | ៣៩.៧៦៧.៣៩៥ |
| ប្រាក់បញ្ញើរយៈពេលខ្លីនៅធនាគារ | ១២ | ១២៩.៦១៥.៦១៨ | ៧៤.៨៧៣.២៣៩ | ៧៣.១៩៤.២០១ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | ១៣ | ២៧.៧៨៩.៥៩៧ | ៦២.១៩១.៥២៥ | ៥១.០៨១.២២៩ |
| | | ២៣១.៥៤៧.១៦៦ | ១៩២.១៣០.៣៧៤ | ១៧៤.១០៤.៨១៦ |
| **ទ្រព្យសកម្មសរុប** | | ១.៣៧២.២៦៦.២២១ | ១.៣២៨.១៩០.៤៨៨ | ១.២៨០.៥១០.០៣៨ |
| **មូលធន និងបំណុល** | | | | |
| **មូលធន** | | | | |
| ដើមទុន និងបុព្វលាភភាគហ៊ុន | ១៤ | ៥១៨.០១៨.០៦៣ | ៥១៨.០១៨.០៦៣ | ៥១៨.០១៨.០៦៣ |
| ទុនបម្រុងផ្សេងៗ | ១៥ | ២៤.៧១២.៧២២ | ២០.១៥៥.៨៤៦ | ១៧.៦៤១.៩១៤ |
| ចំណេញរក្សាទុក | | ១៣៩.៧៩៤.០៥៥ | ១១១.៣៣៦.៣២៥ | ១០៥.០៧៩.៣៧៧ |
| **មូលធនសរុប** | | ៦៨២.៥២៤.៨៤០ | ៦៤៩.៥១០.២៣៤ | ៦៤០.៧៣៩.៣៥៤ |
| **បំណុល** | | | | |
| **បំណុលរយៈពេលវែង** | | | | |
| ភាគលាភធានាត្រូវបង់ | ១៤ | - | ៥.២៥៦.៣៣៩ | ៩.៣៥៦.២៦០ |
| ប្រាក់កម្ចី | ១៦ | ៥០៧.២៧៣.៧២២ | ៥២៨.៤២៣.៩១៨ | ៥០៣.៥៣៧.៣០៦ |
| កាតព្វកិច្ចអត្ថប្រយោជន៍សោធននិវត្តន៍ | ១៧ | ៧៥.១២៥.០៦១ | ៧៦.៤៨០.៩៧៦ | ៤៥.៣៥១.៤៧៥ |
| កាតព្វកិច្ចការទូទាត់ប្រាក់បំណាច់អតីតភាពការងារ | ១៨ | ១.០៩៦.៧០១ | ១.៤៧១.៧៦៨ | - |
| ចំណូលពន្យារ | ១៩ | ៥.៥៨០.៧១៣ | ៥.៦៣៥.២៤៥ | ៥.៧៩៥.១១៤ |
| បំណុលពន្ធពន្យារ | ២៨ | ១៥.៧៨៤.៦៧៦ | ២.៦៨៧.០៨៤ | ៦.១៤៩.៤០០ |
| | | ៦០៤.៨៦០.៨៧៣ | ៦១៩.៩៥៥.៣៣០ | ៥៧០.១៨៩.៥៥៥ |
| **បំណុលរយៈពេលខ្លី** | | | | |
| ភាគលាភធានាត្រូវបង់ | ១៤ | ៥.២៥៦.៣៤០ | ៤.៩១២.៤៦៦ | ៥.៤០៣.៦៣៤ |
| ប្រាក់កម្ចី | ១៦ | ៣៦.៤៣០.៥០២ | ២២.១៩៧.៣១១ | ២១.៦៩៧.៥៧៦ |
| កាតព្វកិច្ចអត្ថប្រយោជន៍សោធននិវត្តន៍ | ១៧ | ៧.៩៤៩.០០០ | ៣.០៥៧.០០០ | ២.៩៩៥.៧៨០ |
| កាតព្វកិច្ចការទូទាត់ប្រាក់បំណាច់អតីតភាពការងារ | ១៨ | ១.៥៨៩.៥០៥ | ៣៦៧.៩៥៣ | - |
| ចំណូលពន្យារ | ១៩ | ១៣៤.៤៧៥ | ២៥១.៥២៧ | ១៣៣.២២១ |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីអ្នកផ្គត់ផ្គង់ផ្សេងៗ | ២០ | ២៤.៩០១.២៣២ | ២០.៩៤១.៩០៤ | ៣៥.៨៨៨.៥០០ |
| បំណុលពន្ធលើប្រាក់ចំណូល | | ៨.៦១៩.៤៥៤ | ៦.៩៩៦.៧៦៣ | ៣.៤៦២.៤១៨ |
| | | ៨៤.៨៨០.៥០៨ | ៥៨.៧២៤.៩២៤ | ៦៩.៥៨១.១២៩ |
| **បំណុលសរុប** | | ៦៨៩.៧៤១.៣៨១ | ៦៧៨.៦៨០.២៥៤ | ៦៣៩.៧៧០.៦៨៤ |
| **មូលធន និងបំណុលសរុប** | | ១.៣៧២.២៦៦.២២១ | ១.៣២៨.១៩០.៤៨៨ | ១.២៨០.៥១០.០៣៨ |

កំណត់សម្គាល់ដែលបានភ្ជាប់មកជាមួយពីទំព័រទី ១៣ ដល់ ទំព័រទី ៦៨ ជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

## កំពង់ផែស្វយ័តក្រុងព្រះសីហនុ

## របាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗ
## សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

| **ប្រតិបត្តិការអាជីវកម្មកំពុងបន្ត** | **កំណត់សម្គាល់** | **២០១៩ ពាន់រៀល** | **២០១៨ ពាន់រៀល** |
|---|---|---|---|
| | | | (បានរាយការណ៍ឡើងវិញ) |
| **ចំណូល** | ២១ | ៣៣៣.៩១៣.៣៧៧ | ២៧៥.៩៧៥.៦៤៥ |
| **ចំណាយ** | | | |
| ចំណាយសម្ភារប្រើប្រាស់ | ២២ | (៩៥.២៣១.៧៤១) | (៧៦.១៩២.៨៤៣) |
| ចំណាយប្រាក់បៀវត្សរ៍ ប្រាក់ឈ្នួល និងចំណាយពាក់ព័ន្ធ | ២៣ | (៨៨.១២៨.០០១) | (៧៥.៥៦៣.៣១៨) |
| ចំណាយរំលស់ទ្រព្យសម្បត្តិ និងបរិក្ខារ និងរំលស់ទ្រព្យសកម្មអរូបី | ២៤ | (៣០.៩១០.២៧៤) | (២៨.២៧៥.៧៣១) |
| ចំណាយជួសជុល និងថែទាំ | | (៨.១០១.២៩២) | (៦.០៤២.៣៩៧) |
| ចំណាយផ្សេងៗ | ២៥ | (២៦.១១៤.២៤២) | (២៤.៩៦៤.៩៣២) |
| ខាតផ្សេងៗ – សុទ្ធ | ២៦ | (៤.០៥៧.៦៩៣) | (៤២៧.៨១១) |
| | | (២៥២.៥៤៣.២៤៣) | (២១១.៤៦៧.០៣២) |
| ចំណេញប្រតិបត្តិការ | | ៨១.៣៧០.១៣៤ | ៦៤.១០៨.៦១៣ |
| ចំណូលហិរញ្ញវត្ថុ | | ៤.១៧៥.៥៨៦ | ៣.៧១១.៦៦៦ |
| ចំណាយហិរញ្ញវត្ថុ | | (២០.៣៦០.២៩២) | (១៩.១១៧.៤៩២) |
| ចំណាយហិរញ្ញវត្ថុ - សុទ្ធ | ២៧ | (១៦.១៨៤.៧០៦) | (១៥.៤០៥.៨២៦) |
| **ចំណេញមុនបង់ពន្ធលើប្រាក់ចំណូល** | | ៦៥.១៨៥.៤២៨ | ៤៨.៧០២.៧៨៧ |
| ចំណាយពន្ធលើប្រាក់ចំណូល | ២៨ | (២១.៧២១.៩២៨) | (៣.៥៣៧.០១៥) |
| **ចំណេញក្នុងឆ្នាំ** | | ៤៣.៤៦៣.៥០០ | ៤៥.១៦៥.៧៧២ |
| **ចំណូលលម្អិតផ្សេងៗ** | | | |
| ខ្ទង់ដែលមិនត្រូវបានចាត់ថ្នាក់ឡើងវិញក្នុងចំណេញ – ខាត៖ | | | |
| ការវាស់វែងកាតព្វកិច្ចអត្ថប្រយោជន៍សោធននិវត្តន៍ឡើងវិញ | | (៦៦១.០០០) | (២៩.១៥៧.០០០) |
| **លទ្ធផលលម្អិតសរុបក្នុងឆ្នាំ** | | (៦៦១.០០០) | (២៩.១៥៧.០០០) |
| **ចំណេញរបស់ភាគហ៊ុនិក** | | ៤៣.៤៦៣.៥០០ | ៤៥.១៦៥.៧៧២ |
| **លទ្ធផលលម្អិតសរុបរបស់ភាគហ៊ុនិក** | | ៤២.៨០២.៥០០ | ១៦.០០៨.៧៧២ |

ចំណេញក្នុងមួយភាគហ៊ុនរបស់ភាគហ៊ុនិករបស់ ក.ស.ស សម្រាប់ដំណាច់ឆ្នាំនេះមានដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ចំណេញក្នុងមួយភាគហ៊ុនមូលដ្ឋាន (ជារៀល) | ២៩ | ៥០៦,៧៣ | ៥២៦,៥៨ |
| ចំណេញក្នុងមួយភាគហ៊ុនថយចុះ (ជារៀល) | ២៩ | ៥០៦,៧៣ | ៥២៦,៥៨ |

កំណត់សម្គាល់ដែលបានភ្ជាប់មកជាមួយពីទំព័រទី ១៣ ដល់ ទំព័រទី ៦៨ ជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

# កំពង់ផែស្វយ័តក្រុងព្រះសីហនុ

## របាយការណ៍បម្រែបម្រួលមូលធន
## សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

| | ដែលជារបស់ភាគហ៊ុនិក | | | |
|---|---|---|---|---|
| | **ដើមទុន និង បុព្វលាភភាគហ៊ុន ពាន់រៀល** | **ទុនបម្រុងផ្សេងៗ ពាន់រៀល** | **ចំណេញរក្សាទុក ពាន់រៀល** | **សរុប ពាន់រៀល** |
| **សមតុល្យនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨** | ៥១៨.០១៨.០៦៣ | ១៧.៦៤១.៩១៤ | ១១០.៩៥០.៥៧៧ | ៦៤៦.៦១០.៥៥៤ |
| ការកែតម្រូវឆ្នាំមុន (កំណត់សម្គាល់ ៣៣) | - | - | (៥.៨៧១.២០០) | (៥.៨៧១.២០០) |
| **មូលធនសរុបបានរាយការណ៍ឡើងវិញនាដើមឆ្នាំហិរញ្ញវត្ថុ** | ៥១៨.០១៨.០៦៣ | ១៧.៦៤១.៩១៤ | ១០៥.០៧៩.៣៧៧ | ៦៤០.៧៣៩.៣៥៤ |
| ចំណេញក្នុងឆ្នាំ | - | - | ៤៥.១៦៥.៧៧២ | ៤៥.១៦៥.៧៧២ |
| លទ្ធផលលម្អិតផ្សេងៗ-កាត់ពន្ធរួច | - | - | (២៩.១៥៧.០០០) | (២៩.១៥៧.០០០) |
| លទ្ធផលលម្អិតសរុបក្នុងឆ្នាំ | - | - | ១៦.០០៨.៧៧២ | ១៦.០០៨.៧៧២ |
| ផ្ទេរទៅទុនបម្រុង (កំណត់សម្គាល់ ១៥) | - | ២.៥១៣.៩៣២ | (២.៥១៣.៩៣២) | - |
| ភាគលាភបានបង់ (កំណត់សម្គាល់ ៣.២.១) | - | - | (៧.២៣៧.៨៩២) | (៧.២៣៧.៨៩២) |
| **សមតុល្យនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨** (បានរាយការណ៍ឡើងវិញ) | ៥១៨.០១៨.០៦៣ | ២០.១៥៥.៨៤៦ | ១១១.៣៣៦.៣២៥ | ៦៤៩.៥១០.២៣៤ |
| **សមតុល្យនៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៨ ជាការបង្ហាញដំបូង** | ៥១៨.០១៨.០៦៣ | ២០.១៥៥.៨៤៦ | ១១៩.០១៥.៥២៥ | ៦៥៧.១៨៩.៤៣៤ |
| ការកែតម្រូវឆ្នាំមុន (កំណត់សម្គាល់ ៣៣) | - | - | (៧.៦៧៩.២០០) | (៧.៦៧៩.២០០) |
| **មូលធនសរុបបានរាយការណ៍ឡើងវិញនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩** | ៥១៨.០១៨.០៦៣ | ២០.១៥៥.៨៤៦ | ១១១.៣៣៦.៣២៥ | ៦៤៩.៥១០.២៣៤ |
| ចំណេញក្នុងឆ្នាំ | - | - | ៤៣.៤៦៣.៥០០ | ៤៣.៤៦៣.៥០០ |
| លទ្ធផលលម្អិតផ្សេងៗ-កាត់ពន្ធរួច | - | - | (៦៦១.០០០) | (៦៦១.០០០) |
| លទ្ធផលលម្អិតសរុបក្នុងឆ្នាំ | - | - | ៤២.៨០២.៥០០ | ៤២.៨០២.៥០០ |
| ផ្ទេរទៅទុនបម្រុង (កំណត់សម្គាល់ ១៥) | - | ៤.៥៥៦.៨៧៦ | (៤.៥៥៦.៨៧៦) | - |
| ភាគលាភបានបង់ (កំណត់សម្គាល់ ៣.២.១) | - | - | (៩.៧៨៧.៨៩៤) | (៩.៧៨៧.៨៩៤) |
| **សមតុល្យនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩** | ៥១៨.០១៨.០៦៣ | ២៤.៧១២.៧២២ | ១៣៩.៧៩៤.០៥៥ | ៦៨២.៥២៤.៨៤០ |

កំណត់សម្គាល់ដែលបានភ្ជាប់មកជាមួយពីទំព័រទី ១៣ ដល់ ទំព័រទី ៦៨ ជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

**កំពង់ផែស្វយ័តក្រុងព្រះសីហនុ**

## របាយការណ៍លំហូរសាច់ប្រាក់
## សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

| | កំណត់សម្គាល់ | ២០១៩ ពាន់រៀល | ២០១៨ ពាន់រៀល (បានរាយការណ៍ឡើងវិញ) |
|---|---|---|---|
| **លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | |
| សាច់ប្រាក់បានពីប្រតិបត្តិការ | ៣០ | ១០០.២៦១.៤៦២ | ៧៦.២៣២.៤៦២ |
| ពន្ធលើប្រាក់ចំណូលបានបង់ | | (៧.០០១.៦៤៥) | (៣.៤៦៤.៩៨៦) |
| លំហូរសាច់ប្រាក់ចូលសុទ្ធពីសកម្មភាពប្រតិបត្តិការ | | ៩៣.២៥៩.៨១៧ | ៧២.៧៦៧.៤៧៦ |
| **លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | |
| ការទិញទ្រព្យសម្បត្តិ និងបរិក្ខារ | ៦ | (៣៣.៩១៩.៩៩២) | (៥៨.៩៨១.៨២៦) |
| ការទិញទ្រព្យសម្បត្តិវិនិយោគ | ៧ | (២.៥៩៤.៥៧៩) | (៧៩៩.៣៤១) |
| ការដាក់ប្រាក់បញ្ញើរយៈពេលខ្លីនៅធនាគារ | | (៥៤.៧៤២.៣៧៩) | (១.៦៧៩.០៣៨) |
| សាច់ប្រាក់បានពីការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ | | ៧៧.៨៦៤ | - |
| ប្រាក់ដើមបានទទួលពីឥណទានបុគ្គលិក | | ២.៥៦៦.៧២៦ | ២.៥៦៦.៧២៦ |
| ការប្រាក់បានទទួល | | ២.៩២៩.២០៥ | ២.៧៩៦.៤២៥ |
| សាច់ប្រាក់(លំហូរចេញ)ពីសកម្មភាពវិនិយោគសុទ្ធ | | (៨៥.៦៨៣.១៥៥) | (៥៦.០៩៧.០៥៤) |
| **លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | |
| ភាគលាភបានបង់ | ៣.២.១ | (១៥.១៩១.៥២៧) | (១២.៦៤១.៥២៥) |
| សាច់ប្រាក់បានមកពីប្រាក់កម្ចី | | ៤.៤៨០.៣៨៩ | ៣៨.២៧៦.៨៧១ |
| ការបង់សងប្រាក់កម្ចី | | (២១.៨៧៣.៧៥៤) | (២០.១៦០.១៥១) |
| ការប្រាក់បានបង់ | | (៩.៣៩៣.៦៩៨) | (១១.០៣៥.៣២១) |
| សាច់ប្រាក់(លំហូរចេញ)ពីសកម្មភាពហិរញ្ញប្បទានសុទ្ធ | | (៤១.៩៧៨.៥៩០) | (៥.៥៦០.១២៦) |
| **(ថយ)/កំណើនសាច់ប្រាក់ និងសាច់ប្រាក់សមមូលសុទ្ធ** | | (៣៤.៤០១.៩២៨) | ១១.១១០.២៩៦ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូលដើមឆ្នាំ | | ៦២.១៩១.៥២៥ | ៥១.០៨១.២២៩ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលចុងឆ្នាំ** | ១៣ | ២៧.៧៨៩.៥៩៧ | ៦២.១៩១.៥២៥ |

កំណត់សម្គាល់ដែលបានភ្ជាប់មកជាមួយពីទំព័រទី ១៣ ដល់ ទំព័រទី ៦៨ ជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

## កំពង់ផែស្វយ័តក្រុងព្រះសីហនុ

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

### ១. ព័ត៌មានទូទៅ

កំពង់ផែស្វយ័តក្រុងព្រះសីហនុ (ហៅកាត់ថា "ក.ស.ស") គឺជាគ្រឹះស្ថានស្វយ័តសាធារណៈ ដែលស្ថិតក្រោមការគ្រប់គ្រងផ្នែកបច្ចេកទេសរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន និងស្ថិតក្រោមការគ្រប់គ្រងផ្នែកហិរញ្ញវត្ថុ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយមានការិយាល័យកណ្តាលនៅក្រុងព្រះសីហនុ ព្រះរាជាណាចក្រកម្ពុជា។

ក.ស.ស គឺជានីតិអង្គភាពដែលមានលក្ខណៈស្វយ័តទាំងផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ និងត្រូវបានបង្កើតឡើងដោយអនុលោមទៅតាមអនុក្រឹតលេខ ៥០ អនក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨ ដែលបានផ្តល់ស្ថានភាពឱ្យក្រុមហ៊ុនជាស្ថាប័នស្វយ័តសាធារណៈ។

ក.ស.ស បានចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្ម និងទទួលបានវិញ្ញាបនបត្រចុះបញ្ជីលេខ Co.៤៧៨៤ET/២០១៧ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៧។ ភាគហ៊ុនប្រភេទ "គ" របស់ ក.ស.ស ត្រូវបានចុះបញ្ជីនៅផ្សារមូលបត្រកម្ពុជា (ហៅកាត់ថា "ផ.ម.ក") នៅថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៧។

បច្ចុប្បន្ននេះ ក.ស.ស គឺជាកំពង់ផែសមុទ្រអន្តរជាតិ និង ជាកំពង់ផែពាណិជ្ជកម្មតែមួយគត់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ អនុលោមទៅតាមអនុក្រឹតស្តីពី ការបង្កើតកំពង់ផែស្វយ័តក្រុងព្រះសីហនុ បេសកកម្មរបស់ ក.ស.ស គឺផ្តល់សេវាកំពង់ផែសមុទ្រ និងសកម្មភាពផ្សេងៗដែលពាក់ព័ន្ធនឹងសេវាកំពង់ផែសមុទ្រ ដូចខាងក្រោម៖

- កណ្តាលធារកិច្ចនាំនាវាចេញ-ចូល និងផ្តល់ភស្តុភាដល់នាវា
- លើកដាក់ ផ្ទេរផ្ទុក និងដឹកជញ្ជូនទំនិញ
- ការងារថែរក្សា ស្តុកទំនិញ ឃ្លាំង-ទីលាន
- ការងារអភិវឌ្ឍន៍ ស្តារ និងពង្រីកហេដ្ឋារចនាសម្ព័ន្ធ ក.ស.ស ដែលមានស្រាប់
- ទទួលខុសត្រូវ និងចាត់ចែងលើការងារការពារសុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់ក្នុងតំបន់គ្រប់គ្រង និង
- គ្រប់គ្រងដឹកនាំ និងចាត់ចែងសកម្មភាពឱ្យមានប្រសិទ្ធភាព និងមានការរីកចម្រើន

ក.ស.ស ក៏ធ្វើប្រតិបត្តិការជួលតំបន់សេដ្ឋកិច្ចពិសេសរបស់ខ្លួនផងដែរ ជាម្ចាស់ទ្រព្យជួល។

ក្នុងឋានៈជាស្ថាប័នស្វយ័តសាធារណៈ ក.ស.ស ទទួលបានពីរាជរដ្ឋាភិបាលកម្ពុជា នូវសិទ្ធិអំណាច និងកាតព្វកិច្ចសំខាន់នានា ដើម្បីបំពេញសកម្មភាពស្របតាមកម្មវត្ថុរបស់ខ្លួន ។

ការិយាល័យចុះបញ្ជីរបស់ ក.ស.ស មានទីតាំងស្ថិតនៅវិថី សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ព្រះរាជាណាចក្រកម្ពុជា។

របាយការណ៍ហិរញ្ញវត្ថុសម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ត្រូវបានក្រុមប្រឹក្សាភិបាលអនុម័តឱ្យចេញផ្សាយនៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០។

## ២. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ

## ២.១ មូលដ្ឋានក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

គោលការណ៍គណនេយ្យសំខាន់ៗដែលបានអនុវត្តក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុត្រូវបានបង្ហាញដូចខាងក្រោម។ គោលការណ៍ទាំងនេះត្រូវបានអនុវត្តស៊ីសង្វាក់គ្នាគ្រប់ឆ្នាំទាំងអស់ដែលបានបង្ហាញ លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ។

របាយការណ៍ហិរញ្ញវត្ថុរបស់ ក.ស.ស ត្រូវបានបង្ហាញជាប្រាក់រៀល ។

របាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើងតាមវិធីសាស្ត្រថ្លៃដើម។

ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុដែលស្របទៅតាម CIFRS តម្រូវឱ្យប្រើប្រាស់ការប៉ាន់ស្មានគណនេយ្យជាក់លាក់សំខាន់ៗមួយចំនួន ហើយក៏តម្រូវឱ្យគណៈគ្រប់គ្រងធ្វើការវិនិច្ឆ័យនៅក្នុងអនុវត្តគោលការណ៍គណនេយ្យនេះដែរ។ ផ្នែកដែលទាក់ទងទៅនឹងការវិនិច្ឆ័យ ឬភាពស្មុគស្មាញក្នុងកម្រិតខ្ពស់ ឬផ្នែកដែលការសន្មត និងការប៉ាន់ស្មានមានលក្ខណៈជាសារវន្តចំពោះរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានលាតត្រដាងនៅក្នុងកំណត់សម្គាល់ ៤។

### (i) ស្តង់ដារគណនេយ្យថ្មី ស្តង់ដារគណនេយ្យដែលបានធ្វើវិសោធនកម្ម និងបំណកស្រាយផ្សេងៗ

ស្តង់ដារគណនេយ្យថ្មី ស្តង់ដារគណនេយ្យដែលបានកែលម្អ ឬស្តង់ដារគណនេយ្យដែលបានធ្វើវិសោធនកម្ម និងបំណកស្រាយមួយចំនួន បានចូលជាធរមានសម្រាប់ ការិយបរិច្ឆេទរាយការណ៍នេះ

| | |
|---|---|
| • ស្តង់ដារគណនេយ្យថ្មី (*) | CIFRS 16 ៖ ភតិសន្យា |
| • ការកែលម្អប្រចាំឆ្នាំ | CIAS 12 ៖ ចំណូលពន្ធ |
| • ការកែលម្អប្រចាំឆ្នាំ | CIAS 23 ៖ ចំណាយប្រាក់កម្ចី |
| • ស្តង់ដារគណនេយ្យដែលបានធ្វើវិសោធនកម្ម | CIAS 19 ៖ អត្ថប្រយោជន៍និយោជិត |
| • បំណកស្រាយថ្មី | បំណកស្រាយ ២៣៖ ភាពមិនប្រាកដប្រជាទៅលើការកត់ត្រាពន្ធលើប្រាក់ចំណូល |

(*) CIFRS 16 ស្តីពី "ភតិសន្យា" ជាលទ្ធផលស្ទើរតែភតិសន្យាទាំងអស់នឹងត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ដោយសារភាពខុសគ្នារវាងភតិសន្យាប្រតិបត្តិ និងភតិសន្យាហិរញ្ញវត្ថុត្រូវបានលុបចោល។ ស្តង់ដារថ្មី តម្រូវឱ្យទទួលស្គាល់ទ្រព្យសកម្ម (សិទ្ធិប្រើប្រាស់ទ្រព្យជួល) និងបំណុលហិរញ្ញវត្ថុ ដែលត្រូវបង់ថ្លៃជួល។ មានករណីលើកលែងតែចំពោះភតិសន្យាដែលមានរយៈពេលខ្លី ឬមានតម្លៃឈ្នួលទាបតែប៉ុណ្ណោះ។ ក.ស.ស មានភតិសន្យាប្រតិបត្តិមិនច្រើន ហើយថែមទាំងមានតម្លៃទាប។

ការកត់ត្រាគណនេយ្យចំពោះភាគីម្ចាស់ទ្រព្យជួលមិនមានការផ្លាស់ប្តូរជាសារវន្តទេ ហើយ ក.ស.ស គឺជាម្ចាស់ទ្រព្យជួល។

មិនមានផលប៉ះពាល់ជាសារវន្តដល់ការអនុវត្តស្តង់ដារខាងលើទេ។

### (ii) ស្តង់ដារគណនេយ្យថ្មី និងបំណកស្រាយផ្សេងៗដែលមិនទាន់បានអនុវត្ត

ស្តង់ដារគណនេយ្យថ្មី និងបំណកស្រាយមួយចំនួន ដែលមិនទាន់បានផ្សព្វផ្សាយ គឺមិនចាំបាច់រាយការណ៍ក្នុងការិយបរិច្ឆេទសម្រាប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ហើយ ក.ស.ស ក៏មិនទាន់បានអនុវត្តនៅឡើយផងដែរ។ ស្តង់ដារទាំងនេះ មិនត្រូវបានគេរំពឹងថា នឹងមានផលប៉ះពាល់ជាសារវន្តដល់អង្គភាពនៅក្នុងការិយបរិច្ឆេទរាយការណ៍ពេលបច្ចុប្បន្ន ឬអនាគតទេ ហើយនិងប្រតិបត្តិការនាពេលអនាគតដែលអាចមើលឃើញជាមុន។

## ២. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (ត)

## ២.២ ការប្តូររូបិយប័ណ្ណ

(i) រូបិយប័ណ្ណគោល និងរូបិយប័ណ្ណសម្រាប់បង្ហាញ

គណនីទាំងអស់ដែលមាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុត្រូវបានវាស់វែងដោយប្រើប្រាស់រូបិយប័ណ្ណនៃបរិយាកាសសេដ្ឋកិច្ចចម្បងដែល ក.ស.ស ធ្វើប្រតិបត្តិការ (ហៅកាត់ថា "រូបិយប័ណ្ណគោល")។ ក.ស.ស រក្សាកំណត់ត្រាបញ្ជីគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនជាប្រាក់រៀល ដែលជារូបិយប័ណ្ណគោល និងជារូបិយប័ណ្ណសម្រាប់បង្ហាញ។

(ii) ប្រតិបត្តិការ និងសមតុល្យ

ប្រតិបត្តិការជារូបិយប័ណ្ណផ្សេងៗក្រៅពីប្រាក់រៀល ត្រូវបានប្តូរទៅជារូបិយប័ណ្ណគោល តាមអត្រាប្តូរប្រាក់នាកាលបរិច្ឆេទនៃប្រតិបត្តិការនោះ។ ចំណេញ និងខាតដែលបណ្តាលមកពីការទូទាត់ប្រតិបត្តិការបែបនេះ និងពីការប្តូរទ្រព្យសកម្ម និងបំណុលរូបិយវត្ថុនានាដែលជារូបិយប័ណ្ណផ្សេងៗក្រៅពីប្រាក់រៀល តាមអត្រានាដំណាច់ឆ្នាំ ត្រូវបានកត់ត្រាក្នុងចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗ។ ចំណេញនិងខាតពីការប្តូររូបិយប័ណ្ណដែលពាក់ព័ន្ធនឹងប្រាក់កម្ចី ត្រូវបានបង្ហាញនៅក្នុងចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗ ក្រោមខ្ទង់ "ចំណូលហិរញ្ញវត្ថុ និងចំណាយហិរញ្ញវត្ថុ"។

## ២.៣ ទ្រព្យសម្បត្តិ និងបរិក្ខារ

ទ្រព្យសម្បត្តិ និងបរិក្ខារ ត្រូវបានរាយការណ៍តាមថ្លៃដើម ដករំលស់បង្គរ។ ថ្លៃដើមរួមមានចំណាយផ្ទាល់ផ្សេងៗក្នុងការទិញទ្រព្យសម្បត្តិទាំងអស់នោះ។

ចំណាយបន្តបន្ទាប់មកទៀតត្រូវបានកត់ត្រាបញ្ចូលទៅក្នុងតម្លៃយោងនៃទ្រព្យសកម្ម ឬត្រូវបានទទួលស្គាល់ជាទ្រព្យសកម្មដាច់ដោយឡែកតាមការសមស្រប តែនៅពេលដែលមានភាពប្រាកដថាផលប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតដែលពាក់ព័ន្ធនឹងទ្រព្យសកម្មនោះ នឹងហូរចូលមកក្នុង ក.ស.ស ហើយចំណាយទាំងនោះអាចត្រូវបានវាស់វែងគួរឱ្យជឿជាក់ប៉ុណ្ណោះ។ តម្លៃយោងនៃផ្នែកដែលត្រូវបានជំនួសឡើងវិញ ត្រូវបានឈប់កត់ត្រា។ ចំណាយទៅលើរាល់ការជួសជុល និងថែទាំផ្សេងៗ ត្រូវបានកត់ត្រានៅក្នុងចំណេញ-ខាត ក្នុងឆ្នាំដែលប្រតិបត្តិការនោះបានកើតឡើង។

ដីធ្លីមិនត្រូវបានគេធ្វើរំលស់ទេ។ រំលស់លើទ្រព្យសកម្មផ្សេងៗ ត្រូវបានគណនាតាមវិធីសាស្ត្ររំលស់ថេរ ដើម្បីជម្រុះចោលថ្លៃដើមនៃទ្រព្យសកម្ម ឱ្យនៅត្រឹមតម្លៃសំណល់របស់វា លើអាយុកាលប្រើប្រាស់ប៉ាន់ស្មាន ដូចខាងក្រោម៖

| | ចំនួនឆ្នាំ |
|---|---|
| ការកែលម្អដីធ្លី | ៧,៣០,៥០ |
| អគារ | ៧,២០,២៥,៣០,៣៥,៥០ |
| បរិក្ខារបច្ចេកទេស | ៥-៣០ |
| សង្ហារិម និងបរិក្ខារបំពាក់ | ៣-១០ |
| កុំព្យូទ័រ និងបរិក្ខារការិយាល័យ | ៣-៥ |
| បរិក្ខារដឹកជញ្ជូន | |
| - យានយន្ត | ៥ |
| - ផ្សេងៗ (គ្រឿងម៉ាស៊ីន រថយន្តដឹកកុងតឺន័រ ឆេឡេវ៉ាទ័រ) | ១០-១៥ |
| បរិក្ខារកំពង់ផែសមុទ្រ | ២០-៣០ |
| ប៉ាឡែត (Palettes) | ១០ |

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩**

## ២. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ២.៣ ទ្រព្យសម្បត្តិ និងបរិក្ខារ (ត)

តម្លៃសំណល់ និងអាយុកាលប្រើប្រាស់របស់ទ្រព្យសកម្ម ត្រូវបានត្រួតពិនិត្យនិងកែតម្រូវតាមការសមស្រប នៅរៀងរាល់កាលបរិច្ឆេទរាយការណ៍នីមួយៗ។

ចំណេញនិងខាតពីការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ ត្រូវបានកំណត់ដោយធ្វើការប្រៀបធៀបសាច់ប្រាក់លក់បានជាមួយនឹងតម្លៃយោង ហើយត្រូវបានកត់ត្រានៅក្នុងចំណេញ-ខាត។

### ២.៤ ទ្រព្យសកម្មអរូបី

ទ្រព្យសកម្មអរូបីរួមមានកម្មវិធីគណនេយ្យ និងប្រព័ន្ធប្រតិបត្តិការកំពង់ផែ ត្រូវបានកត់ត្រាតាមថ្លៃដើម ដករំលស់បង្គរ និងការថយចុះតម្លៃ ប្រសិនបើមាន។ ទ្រព្យសកម្មអរូបីទាំងនេះត្រូវបានធ្វើមូលធនកម្មតាមមូលដ្ឋានថ្លៃដើមដែលបានកើតឡើងក្នុងការទិញ និងយកកម្មវិធីនោះមកប្រើប្រាស់។ ក.ស.ស បានធ្វើរំលស់ទ្រព្យសកម្មអរូបីដែលនៅមានអាយុកាលប្រើប្រាស់ ដោយប្រើវិធីសាស្ត្ររំលស់ថេរ អាស្រ័យទៅតាមរយៈពេលដូចខាងក្រោម៖

| | ចំនួនឆ្នាំ |
|---|---|
| កម្មវិធីគណនេយ្យ | ១០ |
| ប្រព័ន្ធប្រតិបត្តិការកំពង់ផែ | ១០ |

### ២.៥ ទ្រព្យសម្បត្តិវិនិយោគ

ទ្រព្យសម្បត្តិដែលត្រូវបានកាន់កាប់សម្រាប់ការជួលរយៈពេលវែង ឬសម្រាប់រំលស់ដើមទុន ឬសម្រាប់ទាំងពីរយ៉ាង ហើយដែលមិនត្រូវបានកាន់កាប់ដោយ ក.ស.ស ត្រូវបានចាត់ថ្នាក់ជាទ្រព្យសម្បត្តិវិនិយោគ។ ទ្រព្យសម្បត្តិវិនិយោគ ក៏រួមបញ្ចូលនូវទ្រព្យសម្បត្តិដែលកំពុងសាងសង់សម្រាប់អភិវឌ្ឍឱ្យក្លាយជាទ្រព្យសម្បត្តិវិនិយោគនាពេលអនាគត។ ទ្រព្យសម្បត្តិវិនិយោគត្រូវបានកត់ត្រាជាបឋមតាមថ្លៃដើម ដករំលស់បង្គរនិងការថយចុះតម្លៃ។ ក.ស.ស ប្រើប្រាស់គំរូថ្លៃដើម និងគណនីសម្រាប់ទ្រព្យសម្បត្តិវិនិយោគ ដោយអនុលោមទៅតាម CIAS 16 (ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ)។

ទ្រព្យសម្បត្តិវិនិយោគត្រូវបានផ្ទេរទៅជាសន្និធិ តែនៅពេលដែលមានការផ្លាស់ប្តូរក្នុងការប្រើប្រាស់ ដោយមានភស្តុតាងបង្ហាញពីការចាប់ផ្តើមការអភិវឌ្ឍ ក្នុងទស្សនវិស័យសម្រាប់ការលក់។ នៅពេលដែល ក.ស.ស សម្រេចលក់ទ្រព្យសម្បត្តិវិនិយោគណាមួយចេញ ដោយមិនមានការអភិវឌ្ឍ ក្រុមហ៊ុនបន្តចាត់ទុកទ្រព្យសម្បត្តិនោះ ជាទ្រព្យសម្បត្តិវិនិយោគរហូតដល់ពេលឈប់កត់ត្រា និងលុបវាចេញពីរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ហើយមិនចាត់ទុកវាជាសន្និធិទេ។ ប្រសិនបើទ្រព្យសម្បត្តិវិនិយោគត្រូវបានគេអភិវឌ្ឍឡើងវិញដើម្បីប្រើប្រាស់បន្តទៅទៀតជាទ្រព្យសម្បត្តិវិនិយោគ នោះទ្រព្យសម្បត្តិនោះនៅរក្សាទុកជាទ្រព្យសម្បត្តិវិនិយោគដដែល ហើយមិនត្រូវបានចាត់ថ្នាក់ឡើងវិញជាទ្រព្យសម្បត្តិដែលកាន់កាន់ដោយម្ចាស់ក្នុងអំឡុងពេលការអភិវឌ្ឍឡើងវិញទេ។

នៅពេលលក់ទ្រព្យសម្បត្តិវិនិយោគណាមួយ ឬនៅពេលដែលទ្រព្យសម្បត្តិវិនិយោគណាមួយត្រូវបានដកចេញពីការប្រើប្រាស់ជាអចិន្ត្រៃយ៍ និងមិនមានការរំពឹងថានឹងមានអត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតពីការលក់ចេញទៀត នោះវានឹងត្រូវបានគេឈប់កត់ត្រា (លុបចេញពីតារាងតុល្យការ)។ ចំនួនលម្អៀងរវាងសាច់ប្រាក់សុទ្ធដែលបានពីការលក់ និងតម្លៃយោង ត្រូវបានកត់ត្រាក្នុងចំណេញខាត ក្នុងការិយបរិច្ឆេទឈប់ប្រើ ឬការិយបរិច្ឆេទលក់ចេញ។

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩**

## ២. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ២.៥ ទ្រព្យសម្បត្តិវិនិយោគ (ត)

ដីមិនត្រូវបានធ្វើរំលស់ទេ ចំណែកអគារត្រូវបានត្រូវបានធ្វើរំលស់ ដោយប្រើវិធីសាស្ត្ររំលស់ថេរលើអាយុកាលប្រើប្រាស់ប៉ាន់ស្មានរបស់វាក្នុងរយៈពេល៥០ឆ្នាំ។

### ២.៦ អ៊ីមផៃរមិននៃទ្រព្យសកម្ម

ទ្រព្យសកម្មដែលត្រូវធ្វើរំលស់ ត្រូវបានត្រួតពិនិត្យលើអ៊ីមផៃរមិន នៅពេលដែលមានព្រឹត្តិការណ៍ ឬការផ្លាស់ប្តូរកាលៈទេសៈនានា ចង្អុលបង្ហាញថាតម្លៃយោងនឹងមិនអាចស្រង់មកវិញបាន។ ការខាតដែលបណ្តាលមកពីអ៊ីមផៃរមិន ត្រូវបានកត់ត្រាតាមតម្លៃយោងរបស់ទ្រព្យសកម្ម ដែលលើសពីតម្លៃដែលអាចស្រង់មកវិញបាន។ តម្លៃដែលអាចស្រង់មកវិញបាន គឺជាតម្លៃដែលខ្ពស់ជាងគេរវាងតម្លៃសមស្របនៃទ្រព្យសកម្ម ដកចំណាយលើការលក់ និងតម្លៃនៅអាចប្រើប្រាស់បានរបស់វា។ ក្នុងការប៉ាន់ស្មានរកអ៊ីមផៃរមិន ទ្រព្យសកម្មត្រូវបានបែងចែកជាក្រុមតូចៗបំផុត សម្រាប់ទ្រព្យសកម្មដែលមានលក្ខណៈជាលំហូរសាច់ប្រាក់ដាច់ដោយឡែកធំៗ (ឯកតាបង្កើតសាច់ប្រាក់)។

### ២.៧ ទ្រព្យសកម្មហិរញ្ញវត្ថុ

២.៧.១ ការធ្វើចំណាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុ

ក.ស.ស បានធ្វើចំណាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុរបស់ខ្លួន ដោយបានវាស់វែងតាមថ្លៃដើមដករំលស់។ ការធ្វើចំណាត់ថ្នាក់គឺអាស្រ័យទៅតាមគំរូអាជីវកម្មក្នុងការគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ និងរយៈពេលកិច្ចសន្យានៃលំហូរសាច់ប្រាក់។

ក.ស.ស បានធ្វើចំណាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុឡើងវិញ នៅពេលដែលគំរូអាជីវកម្មក្នុងការគ្រប់គ្រងទ្រព្យសកម្មរបស់ខ្លួនផ្លាស់ប្តូរតែមួយប៉ុណ្ណោះ។

ឥណទានផ្តល់ឱ្យបុគ្គលិក គណនីអតិថិជនពាណិជ្ជកម្ម និងគណនីអតិថិជនផ្សេងៗ ប្រាក់បញ្ញើរយៈពេលខ្លីនៅធនាគារ និងសាច់ប្រាក់ និងសាច់ប្រាក់សមមូល បានបំពេញតាមលក្ខណៈវិនិច្ឆ័យក្នុងការសងប្រាក់ដើម និងការប្រាក់ (SPPI) ទាំងស្រុង ដោយសារលក្ខខណ្ឌក្នុងកិច្ចសន្យារបស់វា បានធ្វើឱ្យលំហូរសាច់ប្រាក់កើនឡើង ដែលចាត់ទុកបានជា SPPI ព្រមទាំងមានភាពស៊ីសង្វាក់គ្នាជាមួយនឹងកិច្ចព្រមព្រៀងផ្តល់ប្រាក់កម្ចីមូលដ្ឋាន។ វាក៏ត្រូវបានរៀបចំឡើងនៅក្នុងគំរូអាជីវកម្ម held-to-collect ដូចនេះវាត្រូវបានចាត់ថ្នាក់ និងត្រូវបានវាស់វែងតាមថ្លៃដើមដករំលស់។

២.៧.២ ការទទួលស្គាល់ និងការវាស់វែង

នៅពេលទទួលស្គាល់ដំបូង ក.ស.ស វាស់វែងទ្រព្យសកម្មហិរញ្ញវត្ថុតាមតម្លៃសមស្រប បូកជាមួយនឹងចំណាយប្រតិបត្តិការដែលបានចំណាយផ្ទាល់ក្នុងការទិញទ្រព្យសកម្មហិរញ្ញវត្ថុ ក្នុងករណីដែលទ្រព្យសកម្មហិរញ្ញវត្ថុមិនវាស់វែងតាមតម្លៃសមស្រប ក្នុងចំណេញ-ខាត (FVPL)។ ចំណាយប្រតិបត្តិការនៃទ្រព្យសកម្មហិរញ្ញវត្ថុ ដែលបានកត់ត្រាតាម FVPL ត្រូវបានកត់ត្រាជាចំណាយនៅក្នុងចំណេញ-ខាត។

បម្រែបម្រួលតម្លៃសមស្របរបស់ទ្រព្យសកម្មហិរញ្ញវត្ថុតាម FVPL ត្រូវបានទទួលស្គាល់ក្នុងចំណេញ-ខាតផ្សេងៗ នៅក្នុងរបាយការណ៍ចំណេញ-ខាត តាមការជាក់ស្តែង។

## ២. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ២.៧ ទ្រព្យសកម្មហិរញ្ញវត្ថុ (ត)

២.៧.៣ អ៊ីមភែរមិននៃទ្រព្យសកម្មហិរញ្ញវត្ថុ

ក.ស.ស បានកំណត់ដោយផ្អែកលើការមើលឃើញពីការខាត់បង់ឥណទានរំពឹងទុក ដែលទាក់ទងនឹងទ្រព្យសកម្មហិរញ្ញវត្ថុរបស់ខ្លួន គិតត្រឹមថ្លៃដើមដករំលស់។ វិធីសាស្ត្រថយចុះតម្លៃដែលបានអនុវត្ត អាស្រ័យទៅលើថាតើមានកំណើននៃហានិភ័យឥណទានជាសារវន្តដែរឬទេ។

សម្រាប់គណនីអតិថិជនពាណិជ្ជកម្ម ក.ស.ស បានអនុវត្តវិធីសាស្ត្រសាមញ្ញ ដែលបានអនុម័តដោយ CIFRS 9 ដែលតម្រូវឱ្យការខាតបង់អាយុកាលដែលបានរំពឹងទុក ត្រូវបានកត់ត្រាពីការទទួលស្គាល់ដំបូងនៃគណនីអតិថិជន។

### ២.៨ ការកាត់កងឧបករណ៍ហិរញ្ញវត្ថុ

ទ្រព្យសកម្មនិងបំណុលហិរញ្ញវត្ថុត្រូវបានកាត់កងជាមួយគ្នា ហើយចំនួនសុទ្ធបន្ទាប់ពីកាត់កងត្រូវបានរាយការណ៍ក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នៅពេលដែលក្រុមហ៊ុនមានសិទ្ធិស្របច្បាប់ក្នុងការកាត់កងចំនួនដែលបានកត់ត្រា និងនៅពេលដែលក្រុមហ៊ុនមានបំណងទូទាត់វាតាមមូលដ្ឋានសុទ្ធបន្ទាប់ពីកាត់កង ឬមានបំណងកត់ត្រាទ្រព្យសកម្ម និងទូទាត់បំណុលក្នុងពេលដំណាលគ្នា។

### ២.៩ សន្និធិ

សន្និធិត្រូវបានកត់ត្រាតាមតម្លៃមួយណាដែលទាបជាងគេ (ថ្លៃដើមក្នុងការទិញ និងថ្លៃដើមផ្សេងៗទៀតក្នុងការនាំយកសន្និធិនោះមកកាន់ទីតាំង និងលក្ខខណ្ឌបច្ចុប្បន្នរបស់វា) ធៀបនឹងតម្លៃសុទ្ធដែលអាចលក់បាន។ តម្លៃសុទ្ធដែលអាចលក់បាន គឺជាតម្លៃលក់ប៉ាន់ស្មាននៅក្នុងដំណើរការអាជីវកម្មធម្មតា ដកចំណាយក្នុងការលក់ផ្សេងៗ។

សន្និធិរួមមាន វត្ថុប្រើប្រាស់ គ្រឿងបន្លាស់ និងសន្និធិផ្សេងៗដែលពាក់ព័ន្ធនឹងការផ្គត់ផ្គង់ ត្រូវបានវាយតម្លៃតាមថ្លៃដើមជាក់ស្តែង ក្នុងការយកសន្និធិនោះមកប្រើប្រាស់ទៅតាមគោលបំណងដែលបានគ្រោងទុក ដកសំវិធានធនសម្រាប់សន្និធិខូចខាត សន្និធិប្រើប្រាស់លែងបាន និងសន្និធិដែលមានចលនាយឺតយ៉ាវ ដោយប្រើមូលដ្ឋានចូលមុន-ចេញមុន។

### ២.១០ គណនីអតិថិជនពាណិជ្ជកម្ម និងគណនីអតិថិជនផ្សេងៗ

គណនីអតិថិជនពាណិជ្ជកម្ម និងគណនីអតិថិជនផ្សេងៗ ជាទឹកប្រាក់ដែលទទួលបានពីការផ្តល់សេវាកម្មផ្សេងៗដល់អតិថិជនក្នុងដំណើរការអាជីវកម្មធម្មតា។ គណនីអតិថិជនពាណិជ្ជកម្មត្រូវបានចាត់ថ្នាក់ជាបំណុលរយៈពេលខ្លី ប្រសិនបើការប្រមូលប្រាក់កំណត់ក្នុងរយៈពេល១ឆ្នាំ ឬតិចជាង (ឬនៅក្នុងអំឡុងពេលប្រតិបត្តិការអាជីវកម្មធម្មតា)។ ប្រសិនបើលើសពី១ឆ្នាំ វាត្រូវបានចាត់ទុកជាបំណុលរយៈពេលវែង។

គណនីអតិថិជនពាណិជ្ជកម្ម និងគណនីអតិថិជនផ្សេងៗ ត្រូវបានកត់ត្រាជាបឋមតាមតម្លៃសមស្រប ហើយបន្ទាប់មកទៀតវាត្រូវបានវាស់វែងតាមថ្លៃដើមដករំលស់ ដោយប្រើវិធីសាស្ត្រអត្រាការប្រាក់ដែលមានប្រសិទ្ធភាព ដកសំវិធានធនសម្រាប់ការថយចុះតម្លៃ និងការខាតបង់រំពឹងទុក (កំណត់សម្គាល់ ៣.១ (ខ.៣))។

### ២.១១ សាច់ប្រាក់ និងសាច់ប្រាក់សមមូល

សាច់ប្រាក់ និងសាច់ប្រាក់សមមូល រួមមាន សាច់ប្រាក់ក្នុងដៃ សមតុល្យនៅធនាគារ និងការវិនិយោគរយៈពេលខ្លីដែលអាចបម្លែងទៅជាសាច់ប្រាក់បានភ្លាមៗ និងមានអាយុកាលបីខែ ឬក៏តិចជាងបីខែ។

## ២. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ២.១២ ដើមទុន និងបុព្វលាភភាគហ៊ុន

ដើមទុន និងបុព្វលាភភាគហ៊ុន ត្រូវបានចាត់ថ្នាក់ជាមូលធន។ ចំណាយផ្ទាល់បន្ថែមក្នុងដំណើរការបោះភាគហ៊ុនថ្មី ត្រូវបង្ហាញក្នុងមូលធន ដោយដកចេញពីមូលធនបន្ទាប់ពីកាត់ពន្ធរួច។

### ២.១៣ ប្រាក់កម្ចី

ប្រាក់កម្ចីត្រូវបានកត់ត្រាជាបឋមតាមតម្លៃសមស្រប ដកចំណាយប្រតិបត្តិការដែលបានកើតឡើង ហើយបន្ទាប់មក វាត្រូវបានរាយការណ៍តាមថ្លៃដើមដករំលស់។ ភាពលម្អៀងរវាងសាច់ប្រាក់ (ដកចំណាយប្រតិបត្តិការ) និងទឹកប្រាក់ដែល បង្វិលសងវិញ ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍ចំណេញ-ខាត លើរយៈពេលនៃប្រាក់កម្ចី ដោយប្រើវិធីសាស្ត្រការប្រាក់ មានប្រសិទ្ធិភាព។

កម្រៃបានបង់លើដំណើរការឥណទាន ត្រូវបានកត់ត្រាជាចំណាយប្រតិបត្តិការប្រាក់កម្ចី ទៅតាមចំនួនឥណទាន មួយចំនួន ឬឥណទានទាំងអស់ដែលត្រូវដក។ ក្នុងករណីនេះ កម្រៃបានបង់លើដំណើរការឥណទានត្រូវបានពន្យារ រហូតដល់ ពេលដកសាច់ប្រាក់ជាក់ស្តែង។ នៅពេលមិនមានភស្តុតាងបញ្ជាក់ថា មានការដកឥណទានមួយចំនួន ឬឥណទានទាំងអស់ នោះកម្រៃបានបង់លើដំណើរការឥណទានត្រូវបានចាត់ថ្នាក់ជាចំណាយបង់មុនសម្រាប់សេវាសាច់ប្រាក់ និងត្រូវបានធ្វើរំលស់ លើរយៈពេលឥណទានដែលពាក់ព័ន្ធ។

### ២.១៤ បន្ទុកប្រាក់កម្ចី

បន្ទុកប្រាក់កម្ចីជាក់លាក់និងទូទៅដែលបានចំណាយផ្ទាល់ក្នុងការទិញ ការសាងសង់ ហើយជាទ្រព្យសកម្មដែល ត្រូវចំណាយពេលវេលាចាំបាច់សម្រាប់បញ្ចប់ ដើម្បីអាចប្រើប្រាស់តាមការគ្រោងទុករបស់គេ ឬសម្រាប់លក់ ត្រូវបានកត់ត្រា បន្ថែមទៅក្នុងថ្លៃដើមនៃទ្រព្យសកម្មទាំងនោះ រហូតដល់ពេលទ្រព្យសកម្មនោះមានភាពរួចរាល់សម្រាប់ការប្រើប្រាស់ ឬសម្រាប់ លក់បាន។

ចំណូលលើការវិនិយោគដែលរកបានពីការវិនិយោគបណ្តោះអាសន្ននៃប្រាក់កម្ចីជាក់លាក់ ដែលមិនទាន់ជាចំណាយ របស់ទ្រព្យសម្បត្តិដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ត្រូវបានដកចេញពីបន្ទុកប្រាក់កម្ចីត្រូវបានធ្វើមូលធនកម្ម។

បន្ទុកប្រាក់កម្ចីផ្សេងៗទៀតទាំងអស់ ត្រូវបានកត់ត្រាក្នុងរបាយការណ៍ចំណេញ-ខាត និងចំណូលលម្អិតផ្សេងៗ ក្នុងការិយបរិច្ឆេទដែលវាកើតឡើង។

### ២.១៥ ពន្ធលើប្រាក់ចំណូល

ចំណាយពន្ធលើប្រាក់ចំណូលក្នុងការិយបរិច្ឆេទ គឺជាពន្ធត្រូវបង់លើប្រាក់ចំណូលជាប់ពន្ធក្នុងការិយបរិច្ឆេទ ដោយ ផ្អែកទៅលើអត្រាពន្ធលើប្រាក់ចំណូលដែលត្រូវអនុវត្តក្នុងយុត្តាធិការប្រទេសកម្ពុជា និងធ្វើនិយ័តកម្ម ចំពោះបម្រែបម្រួលពន្ធ ពន្យារ និងបំណុលពន្ធ ដែលបណ្តាលមកពីលម្អៀងបណ្តោះអាសន្ន និងការខាតពន្ធដែលមិនបានប្រើប្រាស់។

ចំណាយពន្ធលើប្រាក់ចំណេញក្នុងគ្រា ត្រូវបានគណនាតាមមូលដ្ឋានច្បាប់សារពើពន្ធដែលបានអនុម័តជាស្ថាពរ ឬ អនុម័តរួចមួយផ្នែកធំ គិតត្រឹមដំណាច់កាលបរិច្ឆេទរាយការណ៍នៅក្នុងប្រទេសកម្ពុជា ជាកន្លែងដែល ក.ស.ស បង្កើតប្រាក់ ចំណេញជាប់ពន្ធ។ គណៈគ្រប់គ្រងវាយតម្លៃពីមួយគ្រាទៅមួយគ្រាអំពីស្ថានភាព ដែលបានកត់ត្រានៅក្នុងលិខិតប្រកាសពន្ធ ទាក់ទិនទៅនឹងសភាពការណ៍ផ្សេងៗដែលបទប្បញ្ញត្តិពន្ធត្រូវធ្វើបំណកស្រាយ។ ក.ស.ស កត់ត្រាសំវិធានធនតាមការសម ស្រប តាមមូលដ្ឋាននៃចំនួនដែលរំពឹងថានឹងត្រូវបង់ជូនអាជ្ញាធរពន្ធដារ។

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩**

## ២. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ២.១៥ ពន្ធលើប្រាក់ចំណូល (ត)

ពន្ធពន្យារលើប្រាក់ចំណេញត្រូវបានកត់ត្រាពេញលេញ ដោយប្រើវិធីសាស្ត្របំណុល លើបណ្តោះអាសន្នដែលកើតឡើងរវាងមូលដ្ឋានពន្ធនៃទ្រព្យសកម្ម និងបំណុល និងតម្លៃយោងរបស់វានៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ ពន្ធពន្យារលើប្រាក់ចំណេញត្រូវកំណត់ដោយប្រើអត្រាពន្ធដែលបានអនុម័តជាស្ថាពរ ឬបានអនុម័តរួចមួយផ្នែកធំ គិតត្រឹមកាលបរិច្ឆេទតារាងតុល្យការ និងត្រូវបានរំពឹងថានឹងត្រូវអនុវត្ត នៅពេលដែលពន្ធពន្យារលើប្រាក់ចំណេញពាក់ព័ន្ធត្រូវទទួលបាន ឬនៅពេលដែលបំណុលពន្ធពន្យារលើប្រាក់ចំណូលត្រូវទូទាត់។

ពន្ធពន្យារទ្រព្យសកម្មត្រូវបានកត់ត្រា តែក្នុងករណីដែលមានភាពប្រាកដថានឹងមានចំនួនទឹកប្រាក់ជាប់ពន្ធនាពេលអនាគត អាចប្រើប្រាស់សម្រាប់ទូទាត់ជាមួយនឹងលម្អៀងបណ្តោះអាសន្ន និងការខាតបង់បានប៉ុណ្ណោះ។

ពន្ធពន្យារទ្រព្យសកម្មត្រូវបានកាត់កងជាមួយនឹងបំណុលពន្ធពន្យារ ប្រសិនបើក្រុមហ៊ុនមានសិទ្ធិស្របច្បាប់ ដើម្បីកាត់កង ហើយប្រសិនបើសមតុល្យពន្ធពន្យារនេះ ពាក់ព័ន្ធជាមួយនឹងអាជ្ញាធរពន្ធដារតែមួយ។ ពន្ធក្នុងគ្រា និងបំណុលពន្ធត្រូវបានកាត់កង នៅពេលដែលអង្គភាពមួយ មានសិទ្ធិតាមផ្លូវច្បាប់ដើម្បីកាត់កងវា ហើយមានគោលបំណងទូទាត់សមតុល្យលើមូលដ្ឋានសុទ្ធ ឬមានបំណងទទួលស្គាល់ទ្រព្យសកម្ម និងទូទាត់បំណុលក្នុងពេលដំណាលគ្នា។

ពន្ធក្នុងគ្រា និងពន្ធពន្យារត្រូវបានទទួលស្គាល់ក្នុងចំណេញ-ខាត លើកលែងតែចំនួនពន្ធ ដែលទាក់ទងទៅនឹងខ្ទង់ផ្សេងៗ ដែលបានកត់ត្រានៅក្នុងលទ្ធផលលម្អិតផ្សេងៗ ឬដែលបានកត់ត្រាដោយផ្ទាល់ទៅក្នុងមូលធន។ ក្នុងករណីនេះ ចំនួនពន្ធក៏ត្រូវកត់ត្រានៅក្នុងលទ្ធផលលម្អិតផ្សេងៗ ឬកត់ត្រាដោយផ្ទាល់ទៅក្នុងមូលធនផងដែរ។

### ២.១៦ អត្ថប្រយោជន៍បុគ្គលិក

#### ២.១៦.១ អត្ថប្រយោជន៍សោធននិវត្តន៍

ក.ស.ស បានផ្តល់ឱ្យគម្រោងពីរនៃអត្ថប្រយោជន៍បុគ្គលិក ទៅដល់បុគ្គលិកនៅពេលដែលដល់អាយុចូលនិវត្តន៍៖

- កាតព្វកិច្ចអត្ថប្រយោជន៍ចូលនិវត្តន៍
- ប្រាក់បំណាច់លើកទឹកចិត្ត

**ក.ស.ស ប្រតិបត្តិគម្រោងអត្ថប្រយោជន៍នេះដូចខាងក្រោម ៖**

- វិភាគទានរបស់បុគ្គលិក ១០% នៃប្រាក់បៀវត្សរ៍ប្រចាំខែរបស់ពួកគាត់។
- វិភាគទានរបស់ ក.ស.ស ១០% នៃប្រាក់បៀវត្សរ៍ប្រចាំខែរបស់បុគ្គលិក។
- ក្រុមប្រឹក្សាភិបាលសម្រេចលើចំនួនបន្ថែមដែលត្រូវបញ្ចូលទៅក្នុងគម្រោងនេះ តាមមូលដ្ឋានប្រចាំឆ្នាំ អាស្រ័យទៅតាមលទ្ធផលរបស់ ក.ស.ស ក្នុងឆ្នាំ។

<u>ដើម្បីមានសិទ្ធិទទួលបានអត្ថប្រយោជន៍សោធននិវត្តន៍នេះ បុគ្គលិកត្រូវបំពេញតាមលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖</u>

- ជាបុគ្គលិកអចិន្ត្រៃយ៍។
- បានបំពេញការងារជូន ក.ស.ស ចំនួន ២៥ ឆ្នាំ ឬ ច្រើនជាងនេះ។
- បានចូលរួមវិភាគទុនក្នុងគម្រោងនេះ តាមការកំណត់។
- មានប័ណ្ណបុគ្គលិក និង
- ប្រសិនបើចូលនិវត្តមុនពេលដល់អាយុចូលនិវត្ត ការចូលនិវត្តនោះត្រូវមានការអនុម័តដោយប្រធានក្រុមប្រឹក្សា-ភិបាល និងអគ្គនាយក។

## ២. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (ត)

## ២.១៦ អត្ថប្រយោជន៍បុគ្គលិក (ត)

### ២.១៦.១ អត្ថប្រយោជន៍សោធននិវត្តន៍ (ត)

### i) ភាតព្វកិច្ចអត្ថប្រយោជន៍សោធននិវត្តន៍

(ក) បុគ្គលិកដែលបានបម្រើការងាររយៈពេល២៥ឆ្នាំ ឬច្រើនឆ្នាំជាងនេះ មានជម្រើសពីរក្នុងការទទួលបានអត្ថប្រយោជន៍នេះ គឺបើកប្រាក់បង់ផ្តាច់តែមួយដងនៅពេលដល់អាយុចូលនិវត្ត ឬបើកប្រាក់ប្រចាំខែរហូតដល់ពេលទទួលមរណភាព។ ការបង់ប្រាក់ជូនបុគ្គលិកដែលមានសិទ្ធិទទួលបានអត្ថប្រយោជន៍នេះ គឺអាស្រ័យទៅតាមខ និងលក្ខខណ្ឌនានា ដូចខាងក្រោម៖

<u>ចំពោះការបង់ប្រាក់ផ្តាច់៖</u>

បុគ្គលិកដែលបានសម្រេចទទួលយកការបង់ប្រាក់ផ្តាច់នៅពេលដល់អាយុចូលនិវត្ត នឹងទទួលបាននូវចំនួនទឹកប្រាក់ស្មើនឹង ១២,៥ដង នៃប្រាក់បៀវត្សរ៍ខែចុងក្រោយរបស់ពួកគេ។

<u>ចំពោះការបង់ប្រាក់ប្រចាំខែរហូតដល់ពេលទទួលមរណភាព៖</u>

ការបង់ប្រាក់ប្រចាំខែដែលត្រូវបង់ជូនបុគ្គលិកដែលសម្រេចជ្រើសរើសយកអត្ថប្រយោជន៍ប្រចាំខែ រហូតដល់ពេលទទួលមរណភាព គឺអាស្រ័យទៅតាមចំនួនឆ្នាំនៃអតីតភាពការងាររបស់ពួកគេ ដូចបានកំណត់ខាងក្រោម៖

| <u>អតីតភាពការងារ</u> | <u>អត្ថប្រយោជន៍</u> |
|---|---|
| ២៥ ឆ្នាំ | ទទួលបានការបង់ប្រាក់ប្រចាំខែចំនួន ៧៥% នៃប្រាក់បៀវត្សរ៍ខែចុងក្រោយសុទ្ធរបស់ពួកគេ។ |
| ២៦-៤០ ឆ្នាំ | ទទួលបានការបង់ប្រាក់ប្រចាំខែចំនួន ៧៥% នៃប្រាក់បៀវត្សរ៍ខែចុងក្រោយសុទ្ធរបស់ពួកគេ បូកនឹង ១% បន្ថែម លើឆ្នាំនីមួយៗទៅលើរយៈពេល២៥ឆ្នាំខាងលើ។ |
| ៤០ឆ្នាំឡើងទៅ | ទទួលបានការបង់ប្រាក់ប្រចាំខែចំនួន ៩០% នៃប្រាក់បៀវត្សរ៍ខែចុងក្រោយសុទ្ធរបស់ពួកគេ។ |

(ខ) បុគ្គលិកដែលបានបម្រើការងាររយៈពេលតិចជាង ២៥ ឆ្នាំ នៅពេលចូលនិវត្ត បញ្ឈប់ពីការងារ ឬទទួលមរណភាព គឺមិនមានសិទ្ធិទទួលបានអត្ថប្រយោជន៍សោធននិវត្តន៍នេះទេ ប៉ុន្តែពួកគេមានសិទ្ធិទទួលបានការបង់ប្រាក់មួយចំនួនដូចខាងក្រោម៖

| <u>អតីតភាពការងារ</u> | <u>អត្ថប្រយោជន៍</u> |
|---|---|
| តិចជាង ១០ ឆ្នាំ | មិនទទួលបានអត្ថប្រយោជន៍ និងមិនទទួលបានវិភាគទានសរុបមកវិញទេ។ វិភាគទានសរុបនឹងក្លាយទៅជាចំណូលអត្ថប្រយោជន៍។ |
| ១០-២៤ ឆ្នាំ | ទទួលបាន ២០០% នៃវិភាគទានសរុបពី ក.ស.ស និងបុគ្គលិក។ |

ប្រសិនបើគម្រោងនេះត្រូវបានលុបចោលដោយមូលហេតុណាមួយ បុគ្គលិកអាចទាមទារនូវចំណែកបដិភាគរបស់គាត់ពីគម្រោងនេះវិញបាន អាស្រ័យទៅតាមលក្ខខណ្ឌជាក់ស្តែងរបស់គម្រោង ព្រមទាំងនីតិវិធីដែលបានចែងក្នុងគោលការណ៍។

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩**

## ២. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (ត)

## ២.១៦ អត្ថប្រយោជន៍បុគ្គលិក (ត)

### ២.១៦.១ អត្ថប្រយោជន៍សោធននិវត្តន៍ (ត)

**i) ភាតព្វកិច្ចអត្ថប្រយោជន៍សោធននិវត្តន៍ (ត)**

(គ) អត្ថប្រយោជន៍ចូលនិវត្តមុនកំណត់

បុគ្គលិកដែលបានចូលនិវត្ត ឬត្រូវបណ្តេញចេញមុនពេលដល់អាយុចូលនិវត្ត នឹងទទួលបានអត្ថប្រយោជន៍ ដូចខាងក្រោម៖

| អតីតភាពការងារ | អត្ថប្រយោជន៍ |
|---|---|
| តិចជាង ១០ ឆ្នាំ | មិនទទួលបានវិភាគទានសរុបរបស់បុគ្គលិកមកវិញទេ។ |
| ពី ១០-២០ ឆ្នាំ | ១២០% នៃវិភាគទានសរុបរបស់បុគ្គលិក និង ១% បន្ថែម លើឆ្នាំនីមួយៗក្នុងរយៈពេល១០ឆ្នាំ។ |
| ពី ២១-៣០ ឆ្នាំ | ១៣៥% នៃវិភាគទានសរុបរបស់បុគ្គលិក និង ១% បន្ថែម លើឆ្នាំនីមួយៗក្នុងរយៈពេល២១ឆ្នាំ។ |
| ពី ៣១-៤០ ឆ្នាំ | ១៥៥% នៃវិភាគទានសរុបរបស់បុគ្គលិក និង ១% បន្ថែម លើឆ្នាំនីមួយៗក្នុងរយៈពេល៣១ឆ្នាំ។ |
| ពី៤០ឆ្នាំឡើងទៅ | ១៦៤% នៃវិភាគទានសរុបរបស់បុគ្គលិក។ |

(ឃ) អត្ថប្រយោជន៍មរណភាព

បុគ្គលិកដែលទទួលមរណភាព នឹងទទួលបានការបង់ប្រាក់ផ្តាច់តែមួយដង។ អត្ថប្រយោជន៍ដូចខាងក្រោមនេះ គឺអាស្រ័យទៅលើការចូលរួមវិភាគទានសរុបរបស់បុគ្គលិក និងអាស្រ័យទៅលើចំនួនឆ្នាំអតីតភាពការងាររបស់បុគ្គលិកនោះ ៖

| អតីតភាពការងារ | មរណភាពទាក់ទងនឹងការងារ | មរណភាពមិនទាក់ទងនឹងការងារ |
|---|---|---|
| តិចជាង ១១ឆ្នាំ | ១២៥% | ១១៥% |
| ពី ១១-២០ ឆ្នាំ | ១៤៥% | ១៣៥% |
| ពី ២១-៣០ ឆ្នាំ | ១៥៥% | ១៤៥% |
| ពី៣០ឆ្នាំឡើងទៅ | ១៦៥% | ១៥៥% |

(ង) អត្ថប្រយោជន៍ពិការភាព៖

បុគ្គលិកដែលបានបម្រើការងារតិចជាង២៥ឆ្នាំ ហើយបានធ្លាក់ខ្លួនពិការ នឹងទទួលបានការបង់ប្រាក់ផ្តាច់តែមួយដង អាស្រ័យទៅតាមការចូលរួមវិភាគទានរបស់ ក.ស.ស និងរបស់បុគ្គលិក ដូចខាងក្រោម៖

| អតីតភាពការងារ | ពិការភាពបណ្តាលមកពីការងារ | ពិការភាពមិនបណ្តាលមកពីការងារ |
|---|---|---|
| តិចជាង ១១ឆ្នាំ | ១២៥% | ១១៥% |
| ពី ១១-២៥ឆ្នាំ | ១២៥% បូក ៣% លើឆ្នាំនីមួយៗក្នុងរយៈពេល១០ឆ្នាំ។ | ១១៥% បូក ៣% លើឆ្នាំនីមួយៗក្នុងរយៈពេល១០ឆ្នាំ។ |
| ចាប់ពី២៥ឆ្នាំឡើងទៅ | | |
| ជម្រើសទី១ | ១៧០% | ១៦០% |
| ជម្រើសទី២ | អត្ថប្រយោជន៍សោធននិវត្តន៍ប្រចាំខែ | អត្ថប្រយោជន៍សោធននិវត្តន៍ប្រចាំខែ |

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩**

**២. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (ត)**

**២.១៦ អត្ថប្រយោជន៍បុគ្គលិក (ត)**

**២.១៦.១ អត្ថប្រយោជន៍សោធននិវត្តន៍ (ត)**

ii) **ប្រាក់បំណាច់លើកទឹកចិត្ត**

ក.ស.ស ក៏បានផ្តល់ឱ្យនូវគម្រោងអត្ថប្រយោជន៍បុគ្គលិកផ្សេងៗទៀត ដែលជាប្រាក់បំណាច់លើកទឹកចិត្តដល់បុគ្គលិកដែលបម្រើការងារឱ្យ ក.ស.ស រហូតដល់អាយុចូលនិវត្តន៍។

នៅពេលចូលនិវត្តន៍ បុគ្គលិកនឹងទទួលបានប្រាក់បំណាច់លើកទឹកចិត្ត (គិតជាចំនួនទឹកប្រាក់) ដែលបានចែងក្នុងរូបមន្ត = (ក) * (ខ)

(ក) ចំនួនឆ្នាំដែលបានបម្រើការងាររបស់ពួកគេ ចាប់ពីកាលបរិច្ឆេទចូល រហូតដល់អាយុចូលនិវត្តន៍

(ខ) អត្រាអត្ថប្រយោជន៍អាស្រ័យលើឆ្នាំដែលបានបម្រើការងាររបស់ពួកគេ ដែលបានចែងដូចខាងក្រោម៖

| <u>អតីតភាពការងារ</u> | <u>អត្រាអត្ថប្រយោជន៍</u> |
|---|---|
| ២៥ឆ្នាំឡើងទៅ | ៧៥% នៃប្រាក់បៀវត្សរ៍ខែចុងក្រោយគោល របស់ពួកគេនៅអាយុចូលនិវត្តន៍ |
| ២៦ - ៤០ឆ្នាំ | ៧៥% បូមបន្ថែម១% សម្រាប់បន្ថែមឆ្នាំនីមួយៗដែលបានបម្រើការងាលើសពី ២៥ឆ្នាំ នៃប្រាក់បៀវត្សរ៍ខែចុងក្រោយគោលរបស់ពួកគេ នៅអាយុចូលនិវត្តន៍ |
| លើសពី ៤០ឆ្នាំ | គិតត្រឹម ៩០% នៃប្រាក់បៀវត្សរ៍ខែចុងក្រោយគោលរបស់ពួកគេ នៅអាយុចូលនិវត្តន៍ |

បំណុលដែលបានកត់ត្រានៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ទាក់ទងនឹងគម្រោងអត្ថប្រយោជន៍ពេលចូលនិវត្តដែលបានកំណត់ គឺជាតម្លៃបច្ចុប្បន្ននៃកាតព្វកិច្ចបានកំណត់ គិតត្រឹមដំណាច់ការិយបរិច្ឆេទរាយការណ៍ ដកតម្លៃសមស្របនៃទ្រព្យតម្កល់ (ប្រសិនបើមាន)។ កាតព្វកិច្ចសោធននិវត្តន៍ត្រូវបានគណនាដោយប្រើវិធីសាស្រ្តប៉ាន់ស្មានឯកតាឥណទាន (projected unit credit)។ តម្លៃបច្ចុប្បន្ននៃកាតព្វកិច្ចសោធននិវត្តន៍ ត្រូវបានកំណត់ដោយធ្វើអប្បហារលើលំហូរសាច់ប្រាក់ប៉ាន់ស្មាននាពេលអនាគត ដោយប្រើអត្រាការប្រាក់បញ្ញើមធ្យមនៃមូលនិធិដែលបានផ្ញើនៅធនាគារ ដែលបម្រុងទុកសម្រាប់បង់អត្ថប្រយោជន៍សោធននិវត្តន៍ នាកាលបរិច្ឆេទវាយតម្លៃ ដោយសារទីផ្សារ សញ្ញាប័ណ្ណសាជីវកម្មមិនមានគុណភាពខ្ពស់ និងមិនមានសញ្ញាប័ណ្ណរដ្ឋាភិបាលនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ចំណេញ និងខាតពីការវាស់វែងឡើងវិញដែលកើតពីការធ្វើនិយ័តកម្ម និងបម្រែបម្រួលក្នុងការសន្មត ត្រូវបានកត់ត្រាជាបន្ទុក ឬកត់ត្រាខាងខ្ទង់ឥណទានក្នុងចំណូលលម្អិតផ្សេងៗ ក្នុងការិយបរិច្ឆេទដែលវាកើតឡើង។

ក៏ប៉ុន្តែ នៅក្នុងខែធ្នូ ឆ្នាំ២០១៩ ក្រុមប្រឹក្សាភិបាលបានធ្វើវិសោធនកម្មលើគោលការណ៍ ស្តីពីចំនួនឆ្នាំដែលបានបម្រើការងារ ដោយរាប់គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨តែប៉ុណ្ណោះ ហើយក៏មិនអោយលើសរយៈពេលអតិបរមា ៤០ឆ្នាំដែរ។ ការប៉ាន់ស្មានរបស់គណៈគ្រប់គ្រងអំពីផលប៉ះពាល់នៃការផ្លាស់ប្តូរ ដែលបានកើតឡើង នឹងត្រូវបានកត់ត្រាភ្លាមៗក្នុង ចំណេញ-ខាត។

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩**

## ២. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ២.១៦ អត្ថប្រយោជន៍បុគ្គលិក (ត)

### ២.១៦.២ កាតព្វកិច្ចការទូទាត់ប្រាក់បំណាច់អតីតភាពការងារ

នៅខែមិថុនា ឆ្នាំ២០១៨ រាជរដ្ឋាភិបាលកម្ពុជាបានធ្វើវិសោធនកម្មស្តីពីច្បាប់ការងារ ដែលណែនាំអំពីគម្រោងការទូទាត់ប្រាក់បំណាច់អតីតភាពការងារ។ បន្ទាប់មកនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ ប្រកាសលេខ ៤៤៣ K.B/Br.K.Kh.L ត្រូវបានចេញផ្សាយដោយផ្តល់នូវគោលការណ៍ណែនាំស្តីពីការអនុវត្តច្បាប់។ អនុលោមទៅតាមច្បាប់/ប្រកាស អង្គភាពនីមួយៗតម្រូវឱ្យបង់ប្រាក់ឱ្យនិយោជិត ជាមួយកិច្ចសន្យាការងារដែលមានរយៈពេលមិនកំណត់ច្បាស់លាស់ដូចខាងក្រោម៖

i) សេវាកម្មប្រចាំឆ្នាំ - មានសុពលភាពចាប់ពីខែមករា ឆ្នាំ២០១៩ ដែលគិតជាមធ្យម ១៥ថ្ងៃនៃប្រាក់បៀវត្សរ៍ និងអត្ថប្រយោជន៍ឆ្នាំនីមួយៗ ដែលត្រូវទូទាត់ជារៀងរាល់ ៦ខែម្តង គិតនៅថ្ងៃទី៣០ ខែមិថុនា និងថ្ងៃទី៣១ ខែធ្នូ (៧.៥ ថ្ងៃក្នុងការទូទាត់ម្តងៗ)

ii) ប្រាក់ដំណាច់អតីតភាពការងាររំលឹក - និយោជិតមានសិទ្ធិទទួលបាន១៥ថ្ងៃនៃប្រាក់បៀវត្សរ៍របស់ពួកគេ ប្រចាំឆ្នាំនៃការបម្រើសេវាកម្មចាប់តាំងពីថ្ងៃចូលបម្រើការងាររហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ និងនៅតែបន្តធ្វើការងារជាមួយក្រុមហ៊ុន។ ការទូទាត់ប្រាក់ដំណាច់អតីតភាពការងាររំលឹក គឺអាស្រ័យលើអតីតការងាររបស់បុគ្គលិក ហើយមិនត្រូវលើសពី ៦ខែមធ្យមភាគនៃប្រាក់បៀវត្សរ៍គោលរបស់បុគ្គលិកនីមួយៗឡើយ។ នៅថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៩ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចេញផ្សាយសេចក្តីណែនាំ លេខ០៤២/១៩ K.B/S.N.N.Kh.L ដើម្បីពន្យាពេលការទូទាត់ប្រាក់បំណាច់អតីតភាពការងាររំលឹក ដែលនឹងត្រូវសងឱ្យចំនួនបីថ្ងៃក្នុងខែមិថុនា និងក្នុងខែធ្នូ ហើយចាប់ផ្តើមនៅខែធ្នូ ឆ្នាំ២០២១។

ប្រាក់ឈ្នួលប្រចាំឆ្នាំ ត្រូវបានចាត់ទុកថាជាអត្ថប្រយោជន៍បុគ្គលិករយៈពេលខ្លី។ ប្រាក់ទាំងនេះ ត្រូវបានបង្ករនៅក្នុងឆ្នាំដែលសេវាកម្មពាក់ព័ន្ធត្រូវបានផ្តល់ដោយបុគ្គលិករបស់ ក.ស.ស។

បំណុលប្រាក់បំណាច់អតីតភាពការងាររំលឹក ត្រូវបានកត់ត្រាតាមតម្លៃបច្ចុប្បន្ននៃកាតព្វកិច្ចដែលបានកំណត់នាការិយបរិច្ឆេទរាយការណ៍ ដោយប្រើវិធីសាស្ត្រ ប៉ាន់ស្មានឯកតាឥណទាន ដើម្បីធ្វើការប៉ាន់ស្មានឱ្យបានកាន់តែល្អនូវតម្លៃចុងក្រោយដែល ក.ស.ស ត្រូវបង់ឱ្យបុគ្គលិក ជាថ្នូរនឹងការបម្រើការងារជូន ក.ស.ស ក្នុងពេលបច្ចុប្បន្ន និងក្នុងពេលកន្លងមក។ កាតព្វកិច្ចនេះកើតឡើង នៅពេលដែលបុគ្គលិកបានបម្រើការងារជូន ក.ស.ស ហើយត្រូវបានរំពឹងថា ក.ស.ស នឹងទូទាត់ប្រាក់បំណាច់នេះក្នុងការិយបរិច្ឆេទរាយការណ៍នាពេលអនាគត។ តម្លៃបច្ចុប្បន្ននៃការទូទាត់ប្រាក់បំណាច់អតីតភាពការងាររំលឹក ត្រូវបានកំណត់ដោយធ្វើអប្បហារចំណាយប៉ាន់ស្មាននាពេលអនាគត។

## ២. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ២.១៧ សំវិធានធន និងបំណុលយថាភាព

សំវិធានធនត្រូវបានកត់ត្រានៅពេលដែល ក.ស.ស មានកាតព្វកិច្ចតាមផ្លូវច្បាប់នាពេលបច្ចុប្បន្ន ឬកាតព្វកិច្ចប្រយោលដែលជាលទ្ធផលនៃព្រឹត្តិការណ៍ពីអតីតកាល ហើយវាទំនងជាតម្រូវឱ្យមានការចំណាយធនធានដើម្បីទូទាត់កាតព្វកិច្ចទាំងនោះ ហើយចំនួនទឹកប្រាក់អាចប៉ាន់ស្មានគួរឱ្យជឿជាក់បាន។ សំវិធានធនមិនត្រូវបានកត់ត្រាសម្រាប់ការខាតបង់ពីប្រតិបត្តិការនាពេលអនាគតទេ។

សំវិធានធនត្រូវបានវាស់វែងតាមចំណាយរំពឹងទុកដើម្បីទូទាត់កាតព្វកិច្ច។ ប្រសិនបើតម្លៃពេលវេលានៃទឹកប្រាក់មានចំនួនជាសារវន្ត នោះសំវិធានធនត្រូវវាស់វែងតាមតម្លៃបច្ចុប្បន្នរបស់វា ដោយប្រើអត្រាមុនបង់ពន្ធ ដែលឆ្លុះបញ្ចាំងអំពីការវាយតម្លៃទីផ្សារបច្ចុប្បន្ននូវតម្លៃពេលវេលានៃទឹកប្រាក់ និងហានិភ័យជាក់លាក់ចំពោះកាតព្វកិច្ចទាំងនោះ។ កំណើនសំវិធានធនដោយសារពេលវេលាកន្លងផុត ត្រូវបានកត់ត្រាជាចំណាយការប្រាក់។

បំណុលយថាភាពគឺជាកាតព្វកិច្ចមួយដែលអាចកើតឡើងពីព្រឹត្តិការណ៍អតីតកាល ហើយបំណុលនោះនឹងត្រូវបញ្ជាក់ដោយភាពកើតមាន ឬមិនកើតមាននៃហេតុការណ៍មិនពិតប្រាកដនាពេលអនាគតមួយ ឬច្រើន ដែលមិនស្ថិតនៅក្រោមការគ្រប់គ្រងទាំងស្រុងរបស់ ក.ស.ស។ បំណុលយថាភាពក៏អាចជាកាតព្វកិច្ចនាពេលបច្ចុប្បន្ន ដែលកើតមកពីព្រឹត្តិ-ការណ៍អតីតកាលដែលមិនទាន់បានកត់ត្រា ដោយសារមិនមានភាពប្រាកដថានឹងមានលំហូរធនធានសេដ្ឋកិច្ចចេញ ឬចំនួននៃកាតព្វកិច្ចនោះមិនអាចវាស់វែងគួរឱ្យជឿជាក់បាន។ បំណុលយថាភាពមិនត្រូវបានកត់ត្រាទេ ប៉ុន្តែវាត្រូវបានលាតត្រដាងនៅក្នុងកំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ។ នៅពេលមានបម្រែបម្រួលនៃលំហូរចេញអាចកើតមានឡើង ហើយលំហូរចេញនោះមានភាពប្រាកដប្រជា បំណុលយថាភាពនឹងត្រូវបានកត់ត្រាជាសំវិធានធន។

### ២.១៨ ការកត់ត្រាប្រាក់ចំណូល

យោងតាម CIFRS 15 ក.ស.ស ទទួលស្គាល់ប្រាក់ចំណូល នៅពេលដែល ក.ស.ស មានភាពប្រាកដចំពោះកាតព្វកិច្ចដំណើរការ តាមរយៈការផ្ទេរទំនិញ ឬ សេវាដែលបានសន្យា ទៅឱ្យអតិថិជន (នៅពេលដែលអតិថិជនទទួលបានការគ្រប់គ្រងលើទំនិញ ឬសេវានោះ)។ កាតព្វកិច្ចដំណើរការគឺជាការសន្យាផ្ទេរទំនិញ ឬសេវាណាមួយឱ្យអតិថិជន។ ចំនួនទឹកប្រាក់ចំណូលដែលបានទទួលស្គាល់ គឺជាចំនួនទឹកប្រាក់ដែលបានបែងចែកទៅតាមកាតព្វកិច្ចដំណើរការដែលមានភាពប្រាកដ។

<u>ចំណូលបានពីកំពង់ផែ</u>

ប្រាក់ចំណូលជាចម្បងរួមមាន កម្រៃដែលទទួលបានពីការដឹកជញ្ជូនទំនិញ (ការលើកដាក់ទំនិញពីនាវា/ចូលនាវា) ការលើកដាក់ទំនិញ (ការលើកដាក់ទំនិញពីយានយន្ត/ចូលយានយន្ត) សេវាកម្មច្រកចេញចូលកំពង់ផែ (ការបញ្ជានាវាចូលចំណត) ការរក្សាទុកកុងតឺន័រ និងសេវាផ្សេងៗទៀត។ ប្រាក់ចំណូលពីការផ្តល់សេវាទាំងនេះ ត្រូវបានកត់ត្រានៅពេលដែលបានបំពេញសេវាជូនអតិថិជន។

<u>ចំណូលពីការជួល - ក.ស.ស គឺជាភាគីម្ចាស់ទ្រព្យជួល</u>

ភតិសន្យាដែលជាចំណែកនៃហានិភ័យដែលមានលក្ខណៈជាសារវន្ត និងភាពជាម្ចាស់ ត្រូវបានរក្សាទុកដោយភាគីម្ចាស់ទ្រព្យជួល ត្រូវបានចាត់ថ្នាក់ជាភតិសន្យាប្រតិបត្តិ។ ចំណូលពីការជួលរបស់ភតិសន្យាប្រតិបត្តិ ត្រូវបានកត់ត្រាក្នុងរយៈពេលនៃភតិសន្យា តាមមូលដ្ឋានរំលស់ថេរ។

**២. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (ត)**

**២.១៨ ការកត់ត្រាប្រាក់ចំណូល (ត)**

<u>ចំណូលផ្សេងៗ</u>

ចំណូលផ្សេងៗរួមមានកម្រៃពីការចូលឡានធំៗ និងកម្រៃផ្សេងៗទៀត។ ចំណូលផ្សេងៗត្រូវបានកត់ត្រានៅពេលបានបំពេញសេវាណាមួយ។

**២.១៩ ចំណូលការប្រាក់**

ចំណូលការប្រាក់ត្រូវបានកត់ត្រាដោយប្រើវិធីសាស្ត្រការប្រាក់មានប្រសិទ្ធភាព និងរួមបញ្ចូលក្នុងចំណូលហិរញ្ញវត្ថុនៅក្នុងចំណេញ-ខាត។

**២.២០ ភតិសន្យា-ក.ស.ស ជាភាគីម្ចាស់ទ្រព្យជួល**

ទ្រព្យសម្បត្តិជួលដែលស្ថិតក្រោមភតិសន្យាប្រតិបត្តិ ត្រូវបានរួមបញ្ចូលក្នុងទ្រព្យសម្បត្តិវិនិយោគ នៅក្នុងរបាយ-ការណ៍ស្ថានភាពហិរញ្ញវត្ថុ (កំណត់សម្គាល់ ៧)។ សូមមើលកំណត់សម្គាល់ ២.១៨ សម្រាប់ការកត់ត្រាចំណូលពីការជួល។

**២.២១ ភាគលាភ**

សំវិធានធនត្រូវបានកត់ត្រាចំពោះចំនួនទឹកប្រាក់ភាគលាភណាមួយដែលត្រូវបានប្រកាស ត្រូវបានអនុញ្ញាតសមស្រប និងមិនស្ថិតនៅក្រោមឆន្ទានុសិទ្ធិរបស់ ក.ស.ស នាដំណាច់ការិយបរិច្ឆេទរាយការណ៍ ឬនៅមុនដំណាច់ការិយបរិច្ឆេទរាយការណ៍ ប៉ុន្តែមិនបានបែងចែកនាដំណាច់ការិយបរិច្ឆេទរាយការណ៍។

**២.២២ ចំណេញក្នុងមួយភាគហ៊ុន**

(ក) ចំណេញក្នុងមួយភាគហ៊ុនជាមូលដ្ឋាន (Basic Earnings Per Share)

មូលដ្ឋាននៃចំណេញក្នុងមួយភាគហ៊ុន ត្រូវបានគណនាដោយ៖

- យកចំណេញរបស់ម្ចាស់ភាគហ៊ុន ក.ស.ស មិនរាប់បញ្ចូលចំណាយក្នុងការលក់ភាគហ៊ុន ក្រៅពីភាគហ៊ុនធម្មតា
- ចែកជាមួយនឹងចំនួនភាគហ៊ុនធម្មតាមធ្យមដែលនៅសល់ ក្នុងអំឡុងឆ្នាំហិរញ្ញវត្ថុ ដោយកែតម្រូវសម្រាប់ធាតុបន្ថែមនៅក្នុងភាគហ៊ុនធម្មតា ដែលបានបោះផ្សាយក្នុងអំឡុងឆ្នាំ និងមិនរាប់បញ្ចូលភាគហ៊ុនដែលអាចទិញយកមកវិញ (treasury shares) ប្រសិនបើមាន។

(ខ) ចំណេញក្នុងមួយភាគហ៊ុនថយចុះ (Diluted Earnings Per Share)

ចំណេញក្នុងមួយភាគហ៊ុនថយចុះ៖ កែតម្រូវតួលេខដែលបានប្រើប្រាស់ក្នុងការកំណត់ចំណេញក្នុងមួយភាគហ៊ុនជាមូលដ្ឋាន ដោយគិតទៅលើ៖

- ផលប៉ះពាល់លើការប្រាក់បន្ទាប់ពីដកពន្ធលើប្រាក់ចំណេញ និងចំណាយការប្រាក់ផ្សេងៗទៀត ដែលទាក់ទិននឹងភាគហ៊ុនធម្មតាដែលមានសក្តានុពល និង
- ចំនួនមធ្យមនៃភាគហ៊ុនធម្មតាបន្ថែម ដែលអាចត្រូវបានសន្មតថាមានការផ្ទេរភាគហ៊ុនដែលមានសក្តានុពលទាំងអស់ទៅជាភាគហ៊ុនធម្មតា។

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

## ២. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ២.២៣ ការរាយការណ៍តាមផ្នែក

ការរាយការណ៍តាមផ្នែកត្រូវបានរាយការណ៍ឱ្យស៊ីសង្វាក់ជាមួយនឹងការរាយការណ៍ផ្ទៃក្នុង ដែលបានផ្តល់ជូនប្រធានអ្នកសម្រេចចិត្តផ្នែកប្រតិបត្តិការ។ ប្រធានអ្នកសម្រេចចិត្តផ្នែកប្រតិបត្តិការគឺជាក្រុមគណៈគ្រប់គ្រង (រួមទាំងអគ្គនាយក និងអគ្គនាយករងទាំងអស់) ដែលជាអ្នកធ្វើការសម្រេចចិត្តចំពោះការបែងចែកធនធាន និងជាអ្នកធ្វើការវាយតម្លៃលើលទ្ធផលនៃផ្នែកប្រតិបត្តិការ និងជាអ្នកដែលធ្វើការសម្រេចចិត្តផ្នែកយុទ្ធសាស្ត្រ។

### ២.២៤ ចំនួនតួលេខបង្គត់

ចំនួនទឹកប្រាក់ទាំងអស់ដែលបានលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ និងក្នុងកំណត់សម្គាល់ផ្សេងៗ ត្រូវបានបង្គត់ ដោយកាត់ខ្ទង់ពាន់រៀល លុះត្រាតែមានការបញ្ជាក់ផ្សេងពីនេះ។

## ៣. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ

### ៣.១ កត្តាហានិភ័យហិរញ្ញវត្ថុផ្សេងៗ

ក.ស.ស អាចប្រឈមមុខនឹងហានិភ័យផ្សេងៗដូចជា ហានិភ័យទីផ្សារ (រួមបញ្ចូលហានិភ័យអត្រាការប្រាក់ និងហានិភ័យការប្តូររូបិយប័ណ្ណ) ហានិភ័យឥណទាន និងហានិភ័យសាច់ប្រាក់ងាយស្រួល។ ក.ស.ស គ្រប់គ្រង និងសន្ទុតហានិភ័យទាំងនេះ ដោយការតាមដានអត្រាការប្រាក់លើទីផ្សារ ប្រវត្តិឥណទាននៃភាគីដៃគូរបស់ខ្លួន អត្រាប្តូររូបិយប័ណ្ណ និងលំហូរសាច់ប្រាក់។ បច្ចុប្បន្ននេះ ក.ស.ស មិនប្រើប្រាស់ឧបករណ៍ហិរញ្ញវត្ថុនិស្សន្ទ (derivative financial instruments) ដើម្បីការពារហានិភ័យអត្រាការប្រាក់ និងហានិភ័យការប្តូររូបិយប័ណ្ណរបស់ខ្លួននោះទេ។

(ក) ហានិភ័យទីផ្សារ

(ក.១) ហានិភ័យអត្រាការប្រាក់

ហានិភ័យអត្រាការប្រាក់គឺជាហានិភ័យដែលបម្រែបម្រួលការប្រាក់លើទីផ្សារនាពេលអនាគត នឹងធ្វើឱ្យប៉ះពាល់ដល់លទ្ធផលនៃប្រតិបត្តិការ និងលំហូរសាច់ប្រាក់របស់ ក.ស.ស។

ក.ស.ស បានទទួលប្រាក់កម្ចី (ក្នុងអត្រាការប្រាក់ថេរ) ពីទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិរបស់ប្រទេសជប៉ុន (JICA) និងធនាគារជប៉ុនសម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ (JIBC) តាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ក.ស.ស មិនមានការផ្លោះប្តូរអត្រាការប្រាក់ ឬឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត ដើម្បីការពារហានិភ័យអត្រាការប្រាក់ទេ។ ក្រុមហ៊ុនមានផលប៉ះពាល់ដល់ហានិភ័យតម្លៃសមស្រប ទោះជាយ៉ាងណាក៏ដោយ គណៈគ្រប់គ្រងកំពុងពិនិត្យមើលយ៉ាងដិតដល់នូវការប្រែប្រួលទីផ្សារ ហើយនឹងឈានដល់ការផ្លោះប្តូរអត្រាការប្រាក់ ប្រសិនបើចាំបាច់។ ក.ស.ស មានប្រាក់កម្ចីត្រូវបានគណនាតាមថ្លៃដើមដករំលស់។

(ក.២) ហានិភ័យការប្តូររូបិយប័ណ្ណ

ក.ស.ស ប្រឈមមុខនឹងហានិភ័យការប្តូររូបិយប័ណ្ណ ដែលសំខាន់ជាងគេគឺការប្តូរពីប្រាក់រៀល ទៅជាប្រាក់យ៉េន និងទៅជាប្រាក់ដុល្លារអាមេរិក ដោយសារប្រាក់កម្ចីពី JICA និងពី JIBC តាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គឺទទួលបានជាប្រាក់យ៉េន និងប្រាក់ដុល្លារអាមេរិក ក៏ប៉ុន្តែ ក.ស.ស កត់ត្រាគណនេយ្យរបស់ខ្លួនជាប្រាក់រៀល ដែលជារូបិយប័ណ្ណគោល។ បច្ចុប្បន្ននេះ ក.ស.ស មិនប្រើប្រាស់ការការពារ ឬប្រើកិច្ចសន្យាប្តូររូបិយប័ណ្ណនាពេលអនាគត ដើម្បីការពារហានិភ័យនេះទេ។

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

### ៣. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)
### ៣.១ កត្តាហានិភ័យហិរញ្ញវត្ថុផ្សេងៗ (ត)

(ក) ហានិភ័យទីផ្សារ (ត)

(ក.២) ហានិភ័យការប្តូររូបិយប័ណ្ណ (ត)

ភាពងាយទទួលរងនូវផលប៉ះពាល់របស់ ក.ស.ស ពីអត្រាប្តូររូបិយប័ណ្ណ ទៅលើឧបករណ៍ហិរញ្ញវត្ថុជាប្រាក់យ៉េន និងឧបករណ៍ហិរញ្ញវត្ថុជាប្រាក់ដុល្លារអាមេរិករបស់ខ្លួន ត្រូវបានវិភាគដូចខាងក្រោម។ ឧបករណ៍ហិរញ្ញវត្ថុរបស់ ក.ស.ស ត្រូវបានកត់ត្រាជាចម្បងជារូបិយប័ណ្ណបរទេសទាំងពីរនេះ។ ក.ស.ស បានវិភាគបម្រែបម្រួលនៃរូបិយប័ណ្ណទាំងនេះក្នុងរយៈពេលបីឆ្នាំចុងក្រោយ ហើយបានសន្និដ្ឋានថាអត្រាបម្រែបម្រួល ២,៦% សម្រាប់ប្រាក់យ៉េន និង ០,៦% សម្រាប់ប្រាក់ដុល្លារ-អាមេរិក គឺមានភាពសមហេតុផល។

ប្រសិនបើប្រាក់យ៉េនធ្លាក់ចុះ ឬកើនឡើង២,៦% (មធ្យមភាគនៃអត្រាប្រែប្រួលសម្រាប់រយៈពេលបីឆ្នាំចុងក្រោយ) ធៀបនឹងប្រាក់រៀល នោះប្រាក់ចំណេញប្រចាំឆ្នាំក្រោយបង់ពន្ធនឹងត្រូវកើនឡើង ឬថយចុះ ៩.៣៦៧ លានរៀល ដែលជាលទ្ធផលបណ្តាលមកពីចំណេញ/ខាតពីការប្តូរប្រាក់កម្ចី ដែលទទួលបានជាប្រាក់យ៉េន។

ប្រសិនបើប្រាក់ដុល្លារអាមេរិកធ្លាក់ចុះ ឬកើនឡើង០,៦% (មធ្យមភាគនៃអត្រាប្រែប្រួលសម្រាប់រយៈពេលបីឆ្នាំចុងក្រោយ) ធៀប នឹងប្រាក់រៀល នោះប្រាក់ចំណេញប្រចាំឆ្នាំក្រោយបង់ពន្ធនឹងត្រូវកើនឡើង ឬថយចុះ ២៣០លានរៀល ដែលជាលទ្ធផលបណ្តាលមកពីចំណេញ/ខាតពីការប្តូរប្រាក់បញ្ញើរយៈពេលខ្លីនៅធនាគារ ដែលទទួលបានជាប្រាក់ដុល្លារអាមេរិក។

តារាងខាងក្រោមនេះសង្ខេបពីហានិភ័យអត្រាការប្តូររូបិយប័ណ្ណរបស់ ក.ស.ស គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ និងថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨។ ចំនួនទឹកប្រាក់ក្នុងតារាងនេះគឺជាឧបករណ៍ហិរញ្ញវត្ថុតាមតម្លៃយោង និងតាមប្រភេទរូបិយប័ណ្ណ ដោយមានតម្លៃសមមូលនឹងពាន់រៀល។

| | សមមូលនឹងពាន់រៀល | | | |
|---|---|---|---|---|
| | **ប្រាក់យ៉េន** | **ប្រាក់ដុល្លារអាមេរិក** | **ប្រាក់រៀល** | **សរុប** |
| **ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩** | | | | |
| **ទ្រព្យសកម្មហិរញ្ញវត្ថុ** | | | | |
| គណនីអតិថិជនពាណិជ្ជកម្ម និងគណនីអតិថិជនផ្សេងៗ | - | ៣៦.៥៥២.៦៦១ | ១៤.៦៨២.១០៥ | ៥១.២៣៤.៧៦៦ |
| ឥណទានផ្តល់ឱ្យបុគ្គលិក | - | - | ៣.៤២១.១៣១ | ៣.៤២១.១៣១ |
| ប្រាក់បញ្ញើរយៈពេលខ្លីនៅធនាគារ | - | ១២៤.៥៩៤.៦៥៩ | ៥.០២០.៩៥៩ | ១២៩.៦១៥.៦១៨ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | - | ២៧.២៥៧.៥១៣ | ៥៣២.០៨៤ | ២៧.៧៨៩.៥៩៧ |
| | - | ១៨៨.៤០៤.៨៣៣ | ២៣.៦៥៦.២៧៩ | ២១២.០៦១.១១២ |
| **បំណុលហិរញ្ញវត្ថុ** | | | | |
| ប្រាក់កម្ចី | (៤០២.០៨៨.៤៥៣) | (១៤១.៦១៥.៧៧១) | - | (៥៤៣.៧០៤.២២៤) |
| ភាគលាភអប្បបរមាជានាត្រូវបង់ | - | - | (៥.២៥៦.៣៤០) | (៥.២៥៦.៣៤០) |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីអ្នកផ្គត់ផ្គង់ផ្សេងៗ | - | (៦.១៦៣.៩៧០) | (៤.៤៦៥.៨៧៦) | (១០.៦២៩.៨៤៦) |
| | (៤០២.០៨៨.៤៥៣) | (១៤៧.៧៧៩.៧៤១) | (៩.៧២២.២១៦) | (៥៥៩.៥៩០.៤១០) |
| **ស្ថានភាពសុទ្ធ** | (៤០២.០៨៨.៤៥៣) | ៤០.៦២៥.០៩២ | ១៣.៩៣៤.០៦៣ | (៣៤៧.៥២៩.២៩៨) |

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩**

## ៣. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

## ៣.១ កត្តាហានិភ័យហិរញ្ញវត្ថុផ្សេងៗ (ត)

(ក) ហានិភ័យទីផ្សារ (ត)

(ក.២) ហានិភ័យការប្តូររូបិយប័ណ្ណ (ត)

| | សមមូលនឹងពាន់រៀល | | | |
|---|---|---|---|---|
| | **ប្រាក់យ៉េន** | **ប្រាក់ដុល្លារអាមេរិក** | **ប្រាក់រៀល** | **សរុប** |
| **ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨** | | | | |
| **ទ្រព្យសកម្មហិរញ្ញវត្ថុ** | | | | |
| គណនីអតិថិជនពាណិជ្ជកម្ម និងគណនីអតិថិជនផ្សេងៗ | - | ២៨.៩៦២.៥៣២ | ១០.១០៧.១៩០ | ៣៩.០៦៩.៧២២ |
| ឥណទានផ្តល់ឱ្យបុគ្គលិក | - | - | ៥.៣០៥.១១៣ | ៥.៣០៥.១១៣ |
| ប្រាក់បញ្ញើរយៈពេលខ្លីនៅធនាគារ | - | ៧០.០៤៦.៩៣០ | ៤.៨២៦.៣០៩ | ៧៤.៨៧៣.២៣៩ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | - | ៥០.៣៥៥.៦០៦ | ១១.៨៣៥.៩១៩ | ៦២.១៩១.៥២៥ |
| | - | ១៤៩.៣៦៥.០៦៨ | ៣២.០៧៤.៥៣១ | ១៨១.៤៣៩.៥៩៩ |
| **បំណុលហិរញ្ញវត្ថុ** | | | | |
| ប្រាក់កម្ចី | (៤២០.១៩២.៩៤៣) | (១៣០.៤២៨.២៨៦) | - | (៥៥០.៦២១.២២៩) |
| ភាគលាភអប្បបរមាធានាត្រូវបង់ | - | - | (១០.១៦៨.៨០៥) | (១០.១៦៨.៨០៥) |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីអ្នកផ្គត់ផ្គង់ផ្សេងៗ | - | (៣.៥៧១.២៤០) | (៣.៧១៩.០៥០) | (៧.២៩០.២៩០) |
| | (៤២០.១៩២.៩៤៣) | (១៣៣.៩៩៩.៥២៦) | (១៣.៨៨៧.៨៥៥) | (៥៦៨.០៨០.៣២៤) |
| **ស្ថានភាពសុទ្ធ** | (៤២០.១៩២.៩៤៣) | ១៥.៣៦៥.៥៤២ | ១៨.១៨៦.៦៧៦ | (៣៨៦.៦៤០.៧២៥) |

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩**

### ៣. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### ៣.១ កត្តាហានិភ័យហិរញ្ញវត្ថុផ្សេងៗ (ត)

(ខ) ហានិភ័យឥណទាន

ក.ស.ស ប្រឈមមុខនឹងហានិភ័យឥណទាន ដែលពាក់ព័ន្ធជាចម្បងទៅនឹងគណនីអតិថិជនពាណិជ្ជកម្ម និងគណនីអតិថិជនផ្សេងៗ ឥណទានផ្តល់ឱ្យបុគ្គលិក ប្រាក់បញ្ញើរយៈពេលខ្លីនៅធនាគារ និងសាច់ប្រាក់នៅធនាគារ ដែលវាស់វែងតាមថ្លៃដើមដករំលស់។

(ខ.១) ការគ្រប់គ្រងហានិភ័យ

ដើម្បីគ្រប់គ្រងហានិភ័យលើគណនីអតិថិជនពាណិជ្ជកម្ម និងគណនីអតិថិជនផ្សេងៗ ក.ស.ស តម្រូវឱ្យក្រុមហ៊ុនដឹកជញ្ជូនតាមនាវានីមួយៗតម្កល់ប្រាក់កក់មុននឹងបំពេញសេវាណាមួយឱ្យក្រុមហ៊ុននោះ។ ចំពោះគ្រឹះស្ថានរបស់រដ្ឋាភិបាលមិនតម្រូវឱ្យមានប្រាក់កក់ទេ ដោយសារ ក.ស.ស ជឿជាក់ថាខ្លួនអាចប្រមូលប្រាក់ពីស្ថាប័នទាំងនោះតាមរយៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ដែលជាប្រភពហិរញ្ញវត្ថុនៃគ្រឹះស្ថានរដ្ឋទាំងនោះ)។ ចំពោះក្រុមហ៊ុនដឹកជញ្ជូនតាមនាវាដែលមិនប្រើប្រាស់សេវារបស់ ក.ស.ស ញឹកញាប់ដូចជាដឹកជញ្ជូនគឺមិនតម្រូវឱ្យកក់ប្រាក់ទេ ដោយសារក្រុមហ៊ុនទាំងនៅតម្រូវឱ្យបង់ប្រាក់នៅពេលបំពេញសេវាតែម្តង។ ក.ស.ស មានគោលការណ៍កាត់ប្រាក់កក់ ចំពោះអតិថិជនដែលមិនបានទូទាត់សងបំណុលរបស់ពួកគេទៅតាម ខ និងកិច្ចសន្យាឥណទាន។ ហានិភ័យឥណទានរបស់ ក.ស.ស ចំពោះគណនីអតិថិជនពាណិជ្ជកម្ម និងគណនីអតិថិជនផ្សេងៗ ត្រូវបានកំណត់ឱ្យនៅត្រឹមតម្លៃយោងនៃគណនីអតិថិជននោះ ដកសំវិធានធនសម្រាប់ការថយចុះតម្លៃនៃគណនីអតិថិជន និងការខាតបង់រំពឹងទុក ផ្អែកតាមការត្រួតពិនិត្យលើចំនួនដែលនៅមិនទាន់ទូទាត់នាដំណាច់ឆ្នាំ។ មិនមានការប្រមូលផ្តុំហានិភ័យឥណទានជាសារវន្តទេ ទាំងហានិភ័យតាមរយៈអតិថិជនទោល វិស័យអាជីវកម្មជាក់លាក់ និង/ឬ តំបន់អាជីវកម្ម។

ឥណទានផ្តល់ឱ្យបុគ្គលិក ត្រូវបានផ្តល់ឱ្យបុគ្គលិកក្នុងចំនួនកំណត់តែប៉ុណ្ណោះ អាស្រ័យទៅតាមកម្រិតតួនាទីរបស់បុគ្គលិក រយៈពេលបម្រើការងារ និងកម្រិតប្រាក់បៀវត្សរ៍។ ការសងប្រាក់ត្រូវបានកាត់ដោយផ្ទាល់ចេញពីប្រាក់បៀវត្សរ៍ប្រចាំខែរបស់បុគ្គលិក។ ហានិភ័យឥណទានមានកម្រិតទាប ដោយសារបុគ្គលិកគ្រប់រូបរបស់ ក.ស.ស មានអត្ថប្រយោជន៍បុគ្គលិកច្រើនជាងឥណទានដែលបានស្នើសុំសម្រាប់ទិញភាគហ៊ុន។ ម្យ៉ាងទៀត ភាគហ៊ុនត្រូវបង្វិលឱ្យ ក.ស.ស វិញ នៅពេលដែលបុគ្គលិកលាឈប់ពីការងារពី ក.ស.ស។

ចំពោះប្រាក់បញ្ញើរយៈពេលខ្លីនៅធនាគារ ការដាក់ប្រាក់ត្រូវបានធ្វើឡើងតែជាមួយធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុដែលមានកេរ្តិ៍ឈ្មោះល្អតែប៉ុណ្ណោះ។

(ខ.២) ទ្រព្យធានា

ចំពោះគណនីអតិថិជនពាណិជ្ជកម្មខ្លះ ក.ស.ស អាចទទួលទ្រព្យធានាក្នុងទម្រង់ជាការតម្កល់ជាសាច់ប្រាក់ ដែលអាចស្នើឱ្យបង់ប្រាក់បាន ប្រសិនបើភាគីដៃគូខកខានមិនបានបង់ប្រាក់តាមលក្ខខណ្ឌក្នុងកិច្ចព្រមព្រៀង។

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩**

## ៣. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

## ៣.១ កត្តាហានិភ័យហិរញ្ញវត្ថុផ្សេងៗ (ត)

(ខ) ហានិភ័យឥណទាន (ត)

(ខ.៣) ការថយចុះតម្លៃនៃទ្រព្យសកម្មហិរញ្ញវត្ថុ

ក.ស.ស មានតែទ្រព្យសកម្មហិរញ្ញវត្ថុ (ភាគច្រើនគឺ គណនីអតិថិជនពាណិជ្ជកម្ម) ដែលត្រូវអនុវត្តតាមគំរូការខាតបង់រំពឹងទុក។

ទន្ទឹមនឹងនោះសាច់ប្រាក់ និងសាច់ប្រាក់សមមូល ក៏ត្រូវអនុវត្តតាមតម្រូវការនៃការថយចុះតម្លៃរបស់ CIFRS 9 ដែរ ហើយការខាតបង់ពីការថយចុះតម្លៃដែលបានរកឃើញ មិនមានចំនួនជាសារវន្តទេ។

*គណនីអតិថិជនពាណិជ្ជកម្ម*

ក.ស.ស អនុវត្តវិធីសាស្ត្រដែលមានលក្ខណៈសាមញ្ញក្នុង CIFRS 9 ដើម្បីវាស់វែងការខាតរំពឹងទុក (ECL) ដែលប្រើប្រាស់អាយុកាលសំវិធានធនខាតបង់រំពឹងទុក ចំពោះគណនីអតិថិជនពាណិជ្ជកម្មទាំងអស់។

ក្នុងការវាស់វែងការខាតរំពឹងទុក គណនីអតិថិជនពាណិជ្ជកម្មត្រូវបានដាក់ជាក្រុម អាស្រ័យទៅតាមលក្ខណៈនៃហានិភ័យឥណទានជារួម និងចំនួនថ្ងៃផុតកំណត់។

ជាទូទៅ គណនីអតិថិជនពាណិជ្ជកម្មរបស់ ក.ស.ស រួមមាន ទឹកប្រាក់ត្រូវទទួលពីកូនបំណុលចន្លោះពី ៣១ ទៅ ៤១ នាក់ ចាប់ពីឆ្នាំ២០១៣ ដល់ឆ្នាំ២០១៩។ យោងទៅតាមបទពិសោធន៍នៃការខាតបង់ឥណទានរបស់ ក.ស.ស ក្នុងគ្រាកន្លងមកចំពោះគណនីអតិថិជនពាណិជ្ជកម្ម គឺអតិថិជនបានសងប្រាក់ទៀងទាត់ក្នុងរយៈពេល៧ឆ្នាំចុងក្រោយនេះ លើកលែងតែវិក្កិយបត្រមួយដែលបានចេញក្នុងខែធ្នូ ឆ្នាំ២០១៣។ រាល់វិក្កិយបត្រទាំងអស់ត្រូវបានទូទាត់មិនលើសរយៈពេលមួយឆ្នាំទេ។ ផ្អែកទៅតាមរបាយការណ៍នៃចិរវេលាកំណត់សងដែលបានផ្តល់ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ភាគច្រើនសមតុល្យដែលមានចិរវេលាកំណត់សងលើសពី១២០ថ្ងៃ ត្រូវបានទូទាត់រួចរាល់នាពេលបន្ទាប់មក ក្នុងខែមករា ឆ្នាំ២០២០។

អត្រាការខាតបង់ក្នុងគ្រាកន្លងមក ត្រូវបានធ្វើនិយ័តកម្មដើម្បីឆ្លុះបញ្ចាំងពីព័ត៌មាននាពេលបច្ចុប្បន្ន និងព័ត៌មាននាពេលអនាគត ទៅលើកត្តាម៉ាក្រូសេដ្ឋកិច្ចផ្សេងៗ ដែលមានផលប៉ះពាល់ដល់លទ្ធភាពរបស់អតិថិជនក្នុងការទូទាត់សង។ ក.ស.ស បានកំណត់អំពី ផលិតផលសរុបក្នុងស្រុក និងអត្រាកើននៅប្រទេសកម្ពុជា ដែល ក.ស.ស កំពុងផ្តល់សេវារបស់ខ្លួន ត្រូវបានចាត់ទុកថាជាកត្តាដែលមានការពាក់ព័ន្ធ ក្នុងចំណោមកត្តាផ្សេងៗទៀត ដូចនេះហើយ ក.ស.ស បានកែតម្រូវអត្រាខាតបង់ក្នុងគ្រាកន្លងមកអាស្រ័យទៅតាមបម្រែបម្រួលរំពឹងទុកនៃកត្តាទាំងអស់នេះ។

គណនីអតិថិជនពាណិជ្ជកម្មត្រូវបានជម្រះចេញពីបញ្ជី នៅពេលដែលមិនមានការរំពឹងទុកសមហេតុផលណាមួយ ថាអាចប្រមូលបានមកវិញ។ សញ្ញាណដែលបង្ហាញថាមិនមានការរំពឹងទុកសមហេតុផល ក្នុងការប្រមូលបានមកវិញ រួមមានកត្តាមួយចំនួនក្នុងចំណោមកត្តាជាច្រើន ដូចជា បរាជ័យរបស់កូនបំណុលក្នុងការសងប្រាក់តាមពេលវេលាកំណត់ និងបរាជ័យក្នុងការសងប្រាក់តាមកិច្ចសន្យាក្នុងរយៈពេលមួយ ដែលលើសពីចំនួនថ្ងៃផុតកំណត់ជាក់លាក់ ដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាល។

ការខាតបង់ដែលបណ្តាលមកពីអ៊ីមភែរមិននៃគណនីអតិថិជនពាណិជ្ជកម្ម ត្រូវបានដាក់បង្ហាញដោយការខាតបង់ដែលបណ្តាលមកពីការថយចុះតម្លៃសុទ្ធ ក្នុងចំណេញប្រតិបត្តិការ។ ការប្រមូលបានមកវិញនាពេលបន្ទាប់មក នៃចំនួនទឹកប្រាក់ដែលបានជម្រះចេញពីបញ្ជីរួចហើយ ត្រូវបានកត់ត្រាខាងខ្វង់ឥណទាន ក្នុងប្រភេទគណនីដូចគ្នា។

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩**

**៣. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)**
**៣.១ កត្តាហានិភ័យហិរញ្ញវត្ថុផ្សេងៗ (ត)**
(ខ) ហានិភ័យឥណទាន (ត)
(ខ.៣) ការថយចុះតម្លៃនៃទ្រព្យសកម្មហិរញ្ញវត្ថុ (ត)
*គណនីអតិថិជនពាណិជ្ជកម្ម (ត)*

យោងតាមមូលដ្ឋាននេះ សំវិធានធនសម្រាប់ការខាតបង់ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ និងថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១៨ ត្រូវបានកំណត់ដូចខាងក្រោម ចំពោះគណនីអតិថិជនពាណិជ្ជកម្ម៖

| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩** | **អត្រាខាតបង់រំពឹងទុក** | **តម្លៃយោងដុល** | **សំវិធានធនសម្រាប់ការខាតបង់** |
|---|---|---|---|
| | **%** | **ពាន់រៀល** | **ពាន់រៀល** |
| រយៈពេលខ្លី | 0% | ២៤.៦៤៦.៤៧២ | - |
| ហួសកាលកំណត់លើសពី ៣០ ថ្ងៃ | 0% | ៥.៦៦០.២៨៣ | - |
| ហួសកាលកំណត់លើសពី ៦០ ថ្ងៃ | 0% | ៣៦៩.៣៧៥ | - |
| ហួសកាលកំណត់លើសពី ៩០ ថ្ងៃ | 0% | ១.២៩៧.៨៧៦ | - |
| ហួសកាលកំណត់លើសពី ១២០ ថ្ងៃ | ២០,៩៧% | ៥.៧៩៣.៩០៤ | ១.២១៥.២៤៨ |
| សរុប | | ៣៧.៧៦៧.៩១០ | ១.២១៥.២៤៨ |
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨** | | | |
| រយៈពេលខ្លី | 0% | ២០.៨៧៣.២៥៤ | - |
| ហួសកាលកំណត់លើសពី ៣០ ថ្ងៃ | 0% | ៦.០៥០.១៣០ | - |
| ហួសកាលកំណត់លើសពី ៦០ ថ្ងៃ | 0% | ៣០០.៤៦៥ | - |
| ហួសកាលកំណត់លើសពី ៩០ ថ្ងៃ | 0% | ៤៦៥.០៨៨ | - |
| ហួសកាលកំណត់លើសពី ១២០ ថ្ងៃ | ២០,៩៧% | ១.៦១១.៦២៧ | ៣៣៨.០៣២ |
| ការវាយតម្លៃប្រមូលផ្តុំ | | ២៩.៣០០.៥៦៤ | ៣៣៨.០៣២ |
| ការវាយតម្លៃទោល | ១០០% | ២៨៦.២៨៣ | ២៨៦.២៨៣ |
| សរុប | | ២៩.៥៨៦.៨៤៧ | ៦២៤.៣១៥ |

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩**

### ៣. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### ៣.១ កត្តាហានិភ័យហិរញ្ញវត្ថុផ្សេងៗ (ត)

(ខ) ហានិភ័យឥណទាន (ត)

(ខ.៣) ការថយចុះតម្លៃនៃទ្រព្យសកម្មហិរញ្ញវត្ថុ (ត)

*គណនីអតិថិជនពាណិជ្ជកម្ម (ត)*

សំវិធានធនសម្រាប់ការខាតបង់គណនីអតិថិជនពាណិជ្ជកម្ម គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ផ្ទៀងផ្ទាត់ទៅនឹងសំវិធានធនដើមគ្រាសម្រាប់ការខាតបង់ មានដូចខាងក្រោម៖

| | ២០១៩<br>ពាន់រៀល | ២០១៨<br>ពាន់រៀល |
|---|---|---|
| សំវិធានធនសម្រាប់ការខាតបង់ដើមគ្រា គិតត្រឹមថ្ងៃទី០១ ខែមករា | ៦២៤.៣១៥ | ២៨៨.៥៦៣ |
| កំណើនសំវិធានធនសម្រាប់ការខាតបង់ ដែលបានទទួលស្គាល់នៅក្នុង ចំណេញ-ខាតក្នុងអំឡុងឆ្នាំ | ៨៧៧.២១៦ | ៣៣៨.០៣២ |
| វិក័យបត្រជម្រះចេញពីបញ្ជីក្នុងអំឡុងឆ្នាំ ដែលមិនអាចប្រមូលមកវិញបាន | (២៨៦.២៨៣) | - |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (២.២៨០) |
| សំវិធានធនសម្រាប់ការខាតបង់ចុងគ្រា គិតត្រឹមថ្ងៃទី៣១ ខែធ្នូ | ១.២១៥.២៤៨ | ៦២៤.៣១៥ |

(គ) ហានិភ័យសន្ទនីយ

ក.ស.ស ប្រឈមមុខនឹងហានិភ័យសន្ទនីយ ដែលកើតពីការបង្វិលសាច់ប្រាក់ទូទៅក្នុងសកម្មភាពអាជីវកម្មរបស់ខ្លួន។ ហានិភ័យសន្ទនីយរួមមានហានិភ័យដែលអាចធ្វើឱ្យ ក.ស.ស មិនមានលទ្ធភាពបង្វិលសាច់ប្រាក់ក្នុងសកម្មភាពអាជីវកម្មរបស់ខ្លួនឱ្យទាន់ពេលវេលា។

គោលការណ៍របស់ ក.ស.ស គឺត្រូវរក្សាទុកសាច់ប្រាក់ និងសាច់ប្រាក់សមមូលឱ្យបានគ្រប់គ្រាន់ សម្រាប់ ប្រតិបត្តិការរបស់ខ្លួន និងប្រើប្រាស់កញ្ចប់ឥណទាន ជាមួយនឹងមូលនិធិផ្ទាល់ ដើម្បីបង់ការចំណាយវិនិយោគ។

ក.ស.ស មានប្រាក់កម្ចីមិនទាន់ដកយកដូចខាងក្រោមនេះ នាដំណាច់ឆ្នាំ៖

| | ២០១៩<br>ពាន់រៀល | ២០១៨<br>ពាន់រៀល |
|---|---|---|
| **អត្រាការប្រាក់ថេរ** | | |
| មានកាលកំណត់លើសពី១ឆ្នាំ | ៨៨០.១៣១.៩៦៩ | ៤២.៩១៩.៥៩៩ |

តារាងខាងក្រោមនេះវិភាគអំពីបំណុលហិរញ្ញវត្ថុរបស់ ក.ស.ស តាមរយៈពេលដែលនៅសល់ រហូតដល់កាលបរិច្ឆេទផុតកំណត់ គិតត្រឹមកាលបរិច្ឆេទតារាងតុល្យការ។ ចំនួនដែលបានលាតត្រដាងនៅក្នុងតារាងនេះ គឺជាលំហូរសាច់ប្រាក់ក្នុងកិច្ចសន្យាដែលមិនធ្វើអប្បហារ។

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩**

## ៣. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

## ៣.១ កត្តាហានិភ័យហិរញ្ញវត្ថុផ្សេងៗ (ត)

(គ) ហានិភ័យសន្ទនីយ (ត)

| | ក្រោម ១ ឆ្នាំ<br>ពាន់រៀល | ពី ១-២ ឆ្នាំ<br>ពាន់រៀល | ពី ២-៥ ឆ្នាំ<br>ពាន់រៀល | លើសពី ៥ ឆ្នាំ<br>ពាន់រៀល | លំហូរសាច់ប្រាក់តាមកិច្ចសន្យាសរុប<br>ពាន់រៀល | ចំណុលតម្លៃយោងសរុប<br>ពាន់រៀល |
|---|---|---|---|---|---|---|
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩** | | | | | | |
| ប្រាក់កម្ចី | ៥១.៩៣៥.៨៧១ | ៤៦.៩២៥.៤៥៥ | ១៣៥.០២៥.០០៥ | ៤៥៤.៩៦០.០៧៦ | ៦៨៨.៨៤៦.៤០៧ | ៥៤៣.៧០៤.២២៤ |
| ភាគលាភអប្បបរមាធានាត្រូវបង់ | ៥.៤០៣.៦៣៤ | - | - | - | ៥.៤០៣.៦៣៤ | ៥.២៥៦.៣៤០ |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និង គណនីអ្នកផ្គត់ផ្គង់ផ្សេងៗ | ១០.៦២៩.៨៤៦ | - | - | - | ១០.៦២៩.៨៤៦ | ១០.៦២៩.៨៤៦ |
| | ៦៧.៩៦៩.៣៥១ | ៤៦.៩២៥.៤៥៥ | ១៣៥.០២៥.០០៥ | ៤៥៤.៩៦០.០៧៦ | ៧០៤.៨៧៩.៨៨៧ | ៥៥៩.៥៩០.៤១០ |
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨** | | | | | | |
| ប្រាក់កម្ចី | ៣៥.០១៨.១៧៥ | ៣៩.១៥៧.៣០៥ | ១២៨.៣១៧.០៣៨ | ៥១៣.៤០៤.៨០៣ | ៧១៥.៨៩៧.៣២១ | ៥៥០.៦២១.២២៩ |
| ភាគលាភអប្បបរមាធានាត្រូវបង់ | ៥.៤០៣.៦៣៤ | ៥.៤០៣.៦៣៤ | - | - | ១០.៨០៧.២៦៨ | ១០.១៦៨.៨០៥ |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និង គណនីអ្នកផ្គត់ផ្គង់ផ្សេងៗ | ៧.២៩០.២៩០ | - | - | - | ៧.២៩០.២៩០ | ៧.២៩០.២៩០ |
| | ៤៧.៧១២.០៩៩ | ៤៤.៥៦០.៩៣៩ | ១២៨.៣១៧.០៣៨ | ៥១៣.៤០៤.៨០៣ | ៧៣៣.៩៩៤.៨៧៩ | ៥៦៨.០៨០.៣២៤ |

## ៣.២ ការគ្រប់គ្រងហានិភ័យដើមទុន

ទិសដៅរបស់ ក.ស.ស ក្នុងការគ្រប់គ្រងដើមទុន គឺដើម្បីការពារលទ្ធភាពរបស់ខ្លួនក្នុងការបន្តនិរន្តរភាពអាជីវកម្ម ដើម្បីផ្តល់ផលប្រយោជន៍ជូនភាគហ៊ុនិក និងភាគីពាក់ព័ន្ធផ្សេងទៀត និងរក្សារចនាសម្ព័ន្ធមូលធនល្អបំផុត ដើម្បីកាត់បន្ថយចំណាយដើមទុន។

ក.ស.ស មិនមានគោលការណ៍ជាក់លាក់ចំពោះអនុបាតបំណុលធៀបនឹងដើមទុននោះទេ។

### ៣.២.១ ភាគលាភ

នៅថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៩ ក្រុមប្រឹក្សាភិបាលបានអនុម័តបែងចែកភាគលាភ ចំពោះប្រាក់ចំណេញសម្រាប់ដំណាច់ឆ្នាំហិរញ្ញវត្ថុថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ ដូចខាងក្រោម៖

| | **២០១៩**<br>**ពាន់រៀល** | **២០១៨**<br>**ពាន់រៀល** |
|---|---|---|
| ភាគលាភបានបង់ឱ្យភាគហ៊ុនប្រភេទ ខ | ៦.៥៥០.០០០ | ៤.០០០.០០០ |
| ភាគលាភបានបង់ឱ្យភាគហ៊ុនប្រភេទ គ ដែលទទួលបាន ៤០៣រៀលក្នុងមួយភាគហ៊ុន | ៨.៦៤១.៥២៧ | ៨.៦៤១.៥២៥ |
| ភាគលាភបានបង់សរុប (*) | ១៥.១៩១.៥២៧ | ១២.៦៤១.៥២៥ |

(*) ភាគលាភបានបង់សរុបមានចំនួន ១៥.១៩១.៥២៧ លានរៀល រួមមានភាគលាភអប្បបរមាធានាមានចំនួន ៥.៤០៣.៦៣៣ ពាន់រៀល (កំណត់សម្គាល់ ១៤) (ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨៖ ៥.៤០៣.៦៣៣ ពាន់រៀល។ ប្រាក់នៅសល់ចំនួន ៩.៧៨៧.៨៩៤ ពាន់រៀល (ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨៖ ៧.២៣៧.៨៩២ ពាន់រៀល) ត្រូវបានដកចេញពីចំណេញរក្សាទុក។

## ៣. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### ៣.៣ តម្លៃសមស្របរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុវាស់វែងតាមថ្លៃដើមដករំលស់

វិធីសាស្ត្រ និងការសន្មត ដែលបានប្រើប្រាស់ក្នុងការប៉ាន់ស្មានតម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុ មានដូចខាងក្រោម៖

(ក) *សាច់ប្រាក់ និងសាច់ប្រាក់សមមូល និងប្រាក់បញ្ញើរយៈពេលខ្លីនៅធនាគារ* - តម្លៃយោងនៃគណនីទាំងនេះ មានតម្លៃប្រហាក់ប្រហែលនឹងតម្លៃសមស្រប ដោយសារវាមានរយៈពេលខ្លី។

(ខ) *គណនីអតិថិជន និងគណនីអ្នកផ្គត់ផ្គង់ផ្សេងៗ* - តម្លៃយោងដកសំវិធានធនដែលបណ្តាលមកពីការថយចុះតម្លៃ មានតម្លៃប្រហាក់ប្រហែលនឹងតម្លៃសមស្រប ដោយសារគណនីទាំងនេះស្ថិតនៅក្រោមលក្ខខណ្ឌឥណទានធម្មតា និងមានរយៈពេលខ្លី។

(គ) *ឥណទានផ្តល់ឱ្យបុគ្គលិក* - តម្លៃយោងរយៈពេលខ្លីនៃឥណទានផ្តល់ឱ្យបុគ្គលិក ត្រូវបានចាត់ទុកថាមានតម្លៃស្មើគ្នានឹងតម្លៃសមស្របរបស់វា ដោយសារវាមានរយៈពេលខ្លី នៃឥណទានផ្តល់ឱ្យបុគ្គលិក។ ចំពោះឥណទានផ្តល់ឱ្យបុគ្គលិករយៈពេលវែង មានតម្លៃសមស្របចំនួន ១.១៣៧ លានរៀល គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ធៀបនឹងតម្លៃយោងដែលមានទឹកប្រាក់ចំនួន ១.២២៨ លានរៀល។ តម្លៃសមស្របត្រូវបានគណនាផ្អែកតាមលំហូរសាច់ប្រាក់អប្បហារ ដោយប្រើអត្រាប្រាក់កម្ចីនាពេលបច្ចុប្បន្ន។ វាត្រូវបានចាត់ទុកថាស្ថិតនៅក្នុងតម្លៃសមស្រប កម្រិតទី៣ ក្នុងឋានានុក្រមតម្លៃសមស្រប ដោយសារការរួមបញ្ចូលនូវធាតុចូលដែលមិនអាចអង្កេតបាន រួមមាន ហានិភ័យឥណទានរបស់សមភាគីជាដើម។

(ឃ) *គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីអ្នកផ្គត់ផ្គង់ផ្សេងៗ* – តម្លៃយោងនៃគណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីអ្នកផ្គត់ផ្គង់ផ្សេងៗ ត្រូវបានចាត់ទុកថាមានតម្លៃស្មើគ្នានឹងតម្លៃសមស្របរបស់វា ដោយសារវាមានរយៈពេលខ្លី។

(ង) *ភាគលាភអប្បបរមាធានាត្រូវបង់* - តម្លៃយោងរយៈពេលខ្លីនៃភាគលាភអប្បបរមាធានាត្រូវបង់ ត្រូវបានចាត់ទុកថាមានតម្លៃស្មើគ្នានឹងតម្លៃសមស្របរបស់វា ដោយសារវាមានរយៈពេលខ្លី នៃភាគលាភអប្បបរមាធានាត្រូវបង់។ តម្លៃសមស្របត្រូវបានគណនាផ្អែកតាមលំហូរសាច់ប្រាក់អប្បហារ ដោយប្រើអត្រាប្រាក់បញ្ញើនាពេលបច្ចុប្បន្ន។ វាត្រូវបានចាត់ទុកថាស្ថិតនៅក្នុងតម្លៃសមស្របកម្រិតទី៣ ក្នុងឋានានុក្រមតម្លៃសមស្រប ដោយសារការរួមបញ្ចូលនូវធាតុចូលដែលមិនអាចអង្កេតបាន រួមមានហានិភ័យ ឥណទានរបស់សមភាគីជាដើម។

(ច) *ប្រាក់កម្ចី* - តម្លៃសមស្របនៃប្រាក់កម្ចីត្រូវប៉ាន់ស្មានដោយធ្វើអប្បហារលើលំហូរសាច់ប្រាក់ចេញក្នុងកិច្ចសន្យានាពេលអនាគត ដោយប្រើអត្រាប្រាក់កម្ចីនាដំណាច់ឆ្នាំ។

ឧបករណ៍ហិរញ្ញវត្ថុដែលវាស់វែងតាមតម្លៃសមស្រប ត្រូវបានវិភាគទៅតាមឋានានុក្រមនៃការវាស់វែងតម្លៃសមស្របដូចខាងក្រោម៖

កម្រិត ១ តម្លៃលក់ក្នុងទីផ្សារសកម្ម (មិនកែតម្រូវ) ចំពោះទ្រព្យសកម្ម ឬបំណុលដែលអាចកំណត់បាន។ ក.ស.ស មិនមានកាន់កាប់មូលបត្រចុះបញ្ជីទេ។

កម្រិត ២ ធាតុចូលផ្សេងៗ ក្រៅពីតម្លៃលក់ដែលបានរួមបញ្ចូលក្នុងកម្រិត ១ ដែលអាចអង្កេតទ្រព្យសកម្ម ឬ បំណុលបានដោយផ្ទាល់ (តាមថ្លៃកំណត់) ឬ ដោយប្រយោល (តាមថ្លៃនិស្សន្ទ)។

កម្រិត ៣ ធាតុចូលចំពោះទ្រព្យសកម្ម ឬបំណុល ដែលមិនអាស្រ័យលើទិន្នន័យលើទីផ្សារដែលអាចសង្កេតបាន (ដែលជាធាតុចូលដែលមិនអាចអង្កេតបាន)។

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩**

## ៤. ការប៉ាន់ស្មានគណនេយ្យ ការសន្មត និងការវិនិច្ឆ័យសំខាន់ៗ

ការប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យ ត្រូវបានវាយតម្លៃជាបន្តបន្ទាប់ ដោយផ្អែកទៅតាមបទពិសោធន៍ក្នុងគ្រាមុន និងកត្តាផ្សេងៗទៀត រួមមានការរំពឹងទុកនៃព្រឹត្តិការណ៍នាពេលអនាគត ដែលគេជឿជាក់ថាមានភាពសមហេតុផលទៅតាមកាលៈទេសៈផ្សេងៗ។ ក.ស.ស ធ្វើការប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យដោយគិតពីអនាគតកាល។ តាមនិយមន័យលទ្ធផលនៃការប៉ាន់ស្មានគណនេយ្យ កម្រដូចគ្នានឹងលទ្ធផលពិតជាក់ស្តែងណាស់។ ការប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យដែលមានហានិភ័យធំ អាចបណ្តាលឱ្យមាននិយ័តកម្មជាសារវន្តលើតម្លៃយោងរបស់ទ្រព្យសកម្ម និងបំណុលក្នុងឆ្នាំហិរញ្ញវត្ថុបន្ទាប់ ត្រូវបានបង្ហាញដូចខាងក្រោម៖

### (ក) កាតព្វកិច្ចសោធននិវត្តន៍

តម្លៃបច្ចុប្បន្ននៃកាតព្វកិច្ចសោធននិវត្តន៍គឺអាស្រ័យទៅតាមកត្តាមួយចំនួន ដែលត្រូវបានកំណត់តាមមូលដ្ឋានដែលពាក់ព័ន្ធនឹងការគណនាហានិភ័យ ដោយប្រើប្រាស់ការសន្មតមួយចំនួន។ ការសន្មតដែលបានប្រើប្រាស់ក្នុងការកំណត់ចំណាយសុទ្ធសម្រាប់ប្រាក់សោធននិវត្តន៍ រួមមានអត្រាអប្បហារ អត្រាកំណើនប្រាក់បៀវត្សរ៍ អត្រាមរណៈ និងអត្រាបោះបង់ការងារ។ បម្រែបម្រួលណាមួយលើការសន្មតទាំងនេះ នឹងធ្វើឱ្យប៉ះពាល់ដល់តម្លៃយោងរបស់កាតព្វកិច្ចសោធននិវត្តន៍នេះ។

គិតត្រឹមចុងឆ្នាំ២០១៩ កម្ពុជាមានសញ្ញាប័ណ្ណសាជីវកម្មតែបួនប៉ុណ្ណោះ ដែលបានចុះបញ្ជីនៅក្នុងទីផ្សារមូលបត្រកម្ពុជា។ សញ្ញាប័ណ្ណបច្ចុប្បន្នដែលត្រូវបានចេញផ្សាយជាប្រាក់រៀល មានអត្រាប័ណ្ណឥណទានជាមធ្យម ៨% ក្នុងមួយឆ្នាំ មានរយៈពេលកំណត់បីឆ្នាំ និងមានចំណាត់ថ្នាក់ BBB+។ សញ្ញាប័ណ្ណសាជីវកម្មនេះ មិនត្រូវបានចាត់ទុកថាមានគុណភាពខ្ពស់ (ចំណាត់ថ្នាក់ AA ឬ ខ្ពស់ជាងនេះ) ទេ ហើយការជួញដូរសញ្ញាប័ណ្ណសាជីវកម្ម មិនទាន់មានភាពសកម្មនៅឡើយទេ ដូចនេះ ក.ស.ស ប្រើប្រាស់អត្រាការប្រាក់បញ្ញើមធ្យមប្រចាំឆ្នាំជាប្រាក់រៀលពីធនាគារ ជាអត្រាអប្បហារដែលបានកែតម្រូវ ដើម្បីកំណត់តម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់ចេញប៉ាន់ស្មាននាពេលអនាគត ដែលតម្រូវឱ្យមាន សម្រាប់ការទូទាត់កាតព្វកិច្ចសោធននិវត្តន៍។

នៅពេលដែលអត្រាអប្បហារដែលបានប្រើប្រាស់ ខុសពីការប៉ាន់ស្មានរបស់គណៈគ្រប់គ្រង ០,៥% ហើយអត្រាកំណើនប្រាក់បៀវត្សរ៍បានប្រើប្រាស់ខុសពីការប៉ាន់ស្មានរបស់គណៈគ្រប់គ្រង ២,៥% នោះតម្លៃកាតព្វកិច្ចសោធននិវត្តន៍ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ អាចនឹងត្រូវផ្លាស់ប្តូរប្រហាក់ប្រហែលនឹងចំនួនខាងក្រោម៖

| | **មូលដ្ឋាន** | **ផលប៉ះពាល់** (sensitivity impact) | | | |
|---|---|---|---|---|---|
| អត្រាអប្បហារ | ៦,០០% | ៦,៥០% | ៥,៥០% | ៦,០០% | ៦,០០% |
| អត្រាកំណើនប្រាក់បៀវត្សរ៍ | ៥,០០% | ៥,០០% | ៥,០០% | ៧,៥០% | ២,៥០% |
| កាតព្វកិច្ចសោធននិវត្តន៍បានកំណត់ (លានរៀល) | ៨៣.០៧៤ | ៧៨.៧៩៨ | ៨៧.៧៨៧ | ៩៣.៣៦២ | ៧៥.៥៥៣ |
| ផលប៉ះពាល់ (លានរៀល) | | (៤.២៧៦) | ៤.៧១៣ | ១០.២៨៨ | (៧.៥២១) |
| ផលប៉ះពាល់ (%) | | (៥%) | ៦% | ១២% | (៩%) |

## ៥. ព័ត៌មានប្រតិបត្តិការតាមផ្នែក

ក.ស.ស មានប្រតិបត្តិការតាមផ្នែកដែលត្រូវរាយការណ៍គឺ សេវាផ្នែកកំពង់ផែ។ ប្រធានអ្នកសម្រេចចិត្តផ្នែកប្រតិបត្តិការ (ក្រុមគណៈគ្រប់គ្រង) ត្រួតពិនិត្យរបាយការណ៍គ្រប់គ្រងផ្ទៃក្នុង ដែលបានរាយការណ៍អំពីលទ្ធផលនៃសេវាផ្នែកកំពង់ផែទាំងមូល ដើម្បីវាយតម្លៃអំពីលទ្ធផល និងការបែងចែកធនធាន។ ប្រធានអ្នកសម្រេចចិត្តផ្នែកប្រតិបត្តិការវាយតម្លៃអំពីលទ្ធផលនៃប្រតិបត្តិការតាមផ្នែក ដោយផ្អែកទៅលើទំហំប្រាក់ចំណូលដុល (កំណត់សម្គាល់ ២១)។ ប្រធានអ្នកសម្រេចចិត្តផ្នែកប្រតិបត្តិការ ក៏ត្រួតពិនិត្យផងដែរទៅលើចំណេញមុនបង់ពន្ធ និងចំណេញសុទ្ធធៀបនឹងការិយបរិច្ឆេទមុនៗ។ លើសពីនេះ ក.ស.ស ក៏មានតំបន់សេដ្ឋកិច្ចពិសេស ដែលកំពុងធ្វើប្រតិបត្តិការនៅដំណាក់កាលដំបូង (កំណត់សម្គាល់ ៨)។

ប្រាក់ចំណូលភាគច្រើនបានមកពីអតិថិជនខាងក្រៅ។ ក.ស.ស មានទីតាំងស្ថិតនៅក្នុងខេត្តព្រះសីហនុ ហើយប្រាក់ចំណូលភាគច្រើន មានប្រភពចេញពីខេត្តព្រះសីហនុ និងតំបន់ជុំវិញ។

ក្នុងអំឡុងឆ្នាំ មានចំណូលសរុបចំនួន ៧៧.៨០៤.000 ពាន់រៀល ដែលបានមកពីអតិថិជនធំៗ ចំនួនពីរនាក់។

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
# សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

## ៦. ទ្រព្យសម្បត្តិ និងបរិក្ខារ

| | ដីធ្លី<br>ពាន់រៀល | ការកែលម្អដីធ្លី<br>ពាន់រៀល | អគារ<br>ពាន់រៀល | បរិក្ខារ<br>បច្ចេកទេស<br>ពាន់រៀល | គ្រឿងសង្ហារិមនិង<br>បរិក្ខារបំពាក់<br>ពាន់រៀល | កុំព្យូទ័រ និង<br>បរិក្ខារិយាល័យ<br>ពាន់រៀល | យានយន្ត<br>ពាន់រៀល | បរិក្ខារ<br>កំពង់ផែសមុទ្រ<br>ពាន់រៀល | ការងារកំពុង<br>ដំណើរការ<br>ពាន់រៀល | ប៉ាន់ឡុត<br>ពាន់រៀល | សរុប<br>ពាន់រៀល |
|---|---|---|---|---|---|---|---|---|---|---|---|
| **នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨** | | | | | | | | | | | |
| តម្លៃចុះបញ្ជីសុទ្ធដើមគ្រា | ២៥២.០៤៥.៦៤០ | ២៥.១៥០.៥១៤ | ១៥៣.៣៧២.៤៥៤ | ៦.៤១៥.២៨៤ | ៣៤៦.៣១២ | ២.២៧៨.២៣៨ | ១៥.៧៣៤.៥៣៥ | ១៩៦.៣៤៣.៦២៧ | ១៥៦.៩០៣.៦២៤ | ២៨០.១១០ | ៨០៨.៨៧០.៣៣៨ |
| ទិញបន្ថែម | - | ១.៨៦៦.១៧៨ | ៦៨.៩១៩ | - | ២៣៧.២៦០ | ១.៤៥៥.៤៣៤ | ៩.៩៥០.៧៩៤ | - | ៤៥.២៥៦.៨៥២ | ១៧៩.៨២៦ | ៥៩.០១៥.២៦៣ |
| ធ្វើចំណាត់ថ្នាក់ឡើងវិញ | (១.១១៥.៧៣១) | - | - | - | - | - | - | - | - | - | (១.១១៥.៧៣១) |
| ផ្ទេរ | - | - | ១.៣៤៣.៤៩៥ | - | - | - | - | - | (១.៣៤៣.៤៩៥) | - | - |
| រំលស់ | - | (១.០៨៥.៦១២) | (៤.៨៨៩.២៩៤) | (១.៤៤៤.៥២៥) | (១៨៧.៧២០) | (១.៤២២.៣០៨) | (១.៩៦៤.៩២៧) | (៩.៨២៥.៧១៧) | - | (២៨៧.៧៩៦) | (២១.១០៧.៨៩៩) |
| តម្លៃចុះបញ្ជីសុទ្ធចុងគ្រា | ២៥០.៩២៩.៩០៩ | ២៥.៩៣១.០៨០ | ១៤៩.៨៩៥.៥៧៤ | ៤.៩៧០.៧៥៩ | ៣៩៥.៨៥២ | ២.៣១១.៣៦៤ | ២៣.៧២០.៤០២ | ១៨៦.៥១៧.៩១០ | ២០០.៨១៦.៩៨១ | ១៧២.១៤០ | ៨៤៥.៦៦១.៩៧១ |
| **នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨** | | | | | | | | | | | |
| ថ្លៃដើម | ២៥០.៩២៩.៩០៩ | ២៩.០៤៧.៤៧៥ | ១៦៤.៤៣៦.៧៨០ | ៩.២៤៧.៩១២ | ១.១៤២.៥០៩ | ៥.៧៥៥.៧៩៣ | ២៧.៥៨៥.៩២៣ | ២១០.១០០.៨៩០ | ២០០.៨១៦.៩៨១ | ៩៣២.៩៧៦ | ៨៩៩.៩៩៧.១៤៨ |
| រំលស់បង្គរ | - | (៣.១១៦.៣៩៥) | (១៤.៥៤១.២០៦) | (៤.២៧៧.១៥៣) | (៧៤៦.៦៥៧) | (៣.៤៤៤.៤២៩) | (៣.៨៦៥.៥២១) | (២៣.៥៨២.៩៨០) | - | (៧៦០.៨៣៦) | (៥៤.៣៣៥.១៧៧) |
| តម្លៃចុះបញ្ជីសុទ្ធ | ២៥០.៩២៩.៩០៩ | ២៥.៩៣១.០៨០ | ១៤៩.៨៩៥.៥៧៤ | ៤.៩៧០.៧៥៩ | ៣៩៥.៨៥២ | ២.៣១១.៣៦៤ | ២៣.៧២០.៤០២ | ១៨៦.៥១៧.៩១០ | ២០០.៨១៦.៩៨១ | ១៧២.១៤០ | ៨៤៥.៦៦១.៩៧១ |
| **នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩** | | | | | | | | | | | |
| តម្លៃចុះបញ្ជីសុទ្ធដើមគ្រា | ២៥០.៩២៩.៩០៩ | ២៥.៩៣១.០៨០ | ១៤៩.៨៩៥.៥៧៤ | ៤.៩៧០.៧៥៩ | ៣៩៥.៨៥២ | ២.៣១១.៣៦៤ | ២៣.៧២០.៤០២ | ១៨៦.៥១៧.៩១០ | ២០០.៨១៦.៩៨១ | ១៧២.១៤០ | ៨៤៥.៦៦១.៩៧១ |
| ទិញបន្ថែម (*) | - | ៨៦.៣៥៧ | ៣៥៧.៦៣៩ | ២.៦៥៩.៦០០ | ៣២៨.៨៧៦ | ១.១៧១.០២៥ | ៦.៣១៩.២០៩ | ១១.៧១២.៧៧៨ | ១២.៥៤០.៨៤៥ | - | ៣៥.១៧៦.៣២៩ |
| លក់ - សុទ្ធ | - | - | - | - | - | - | (៨.៥៨០) | - | - | - | (៨.៥៨០) |
| ផ្ទេរ | - | ៥.៧៨៨.៥៥៩ | ១៨០.១២២.៩០៣ | ២២.៤១១.៤៦៧ | - | - | - | - | (២០៨.៣២២.៩២៩) | - | - |
| រំលស់ | - | (១.១៩១.៥៥៩) | (៦.១៩៥.៤៤៤) | (១.៨២០.២១៣) | (២២៤.៦០០) | (១.៤៧៣.០៧៩) | (២.៥៥៤.៦៥៥) | (១០.១១៧.៧៦៧) | - | (១២៤.០៧២) | (២៣.៦៥១.៣៨៩) |
| តម្លៃចុះបញ្ជីសុទ្ធចុងគ្រា | ២៥០.៩២៩.៩០៩ | ៣០.៦១៤.៤៣៧ | ៣២៤.២៣០.៦៧២ | ២៨.២២១.៦១៣ | ៥០០.១២៨ | ២.០០៩.៣១០ | ២៧.៤៧៦.៣៧៦ | ១៨៨.១១២.៩២១ | ៥.០៣៤.៨៩៧ | ៤៨.០៦៨ | ៨៥៧.១៧៨.៣៣១ |
| **នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩** | | | | | | | | | | | |
| ថ្លៃដើម | ២៥០.៩២៩.៩០៩ | ៣៤.៩២២.៣៩១ | ៣៤៤.៩១៧.៣២២ | ៣៤.៣១៨.៩៧៩ | ១.៤៧១.៣៨៥ | ៦.៩២៦.៨១៨ | ៣៣.៨៩៦.៥៥២ | ២២១.៨១៣.៦៦៨ | ៥.០៣៤.៨៩៧ | ៩៣២.៩៧៦ | ៩៣៥.១៦៤.៨៩៧ |
| រំលស់បង្គរ | - | (៤.៣០៧.៩៥៤) | (២០.៦៨៦.៦៥០) | (៦.០៩៧.៣៦៦) | (៩៧១.២៥៧) | (៤.៩១៧.៥០៨) | (៦.៤២០.១៧៦) | (៣៣.៧០០.៧៤៧) | - | (៨៨៤.៩០៨) | (៧៧.៩៨៦.៥៦៦) |
| តម្លៃចុះបញ្ជីសុទ្ធ | ២៥០.៩២៩.៩០៩ | ៣០.៦១៤.៤៣៧ | ៣២៤.២៣០.៦៧២ | ២៨.២២១.៦១៣ | ៥០០.១២៨ | ២.០០៩.៣១០ | ២៧.៤៧៦.៣៧៦ | ១៨៨.១១២.៩២១ | ៥.០៣៤.៨៩៧ | ៤៨.០៦៨ | ៨៥៧.១៧៨.៣៣១ |

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩**

## ៦. ទ្រព្យសម្បត្តិ និងបរិក្ខារ (ត)

(*) សូមយោងទៅលើការផ្ទៀងផ្ទាត់ការទិញបន្ថែមជាសាច់ប្រាក់ និងមិនមែនសាច់ប្រាក់ខាងក្រោម (ការទិញទ្រព្យសម្បត្តិ និង បរិក្ខារ)សម្រាប់ដំណាច់ឆ្នាំ។

| | ២០១៩<br>ពាន់រៀល | ២០១៨<br>ពាន់រៀល |
|---|---|---|
| ការទិញ (សាច់ប្រាក់ និងមិនមែនសាច់ប្រាក់) ក្នុងឆ្នាំ | ៣៥.១៧៦.៣២៩ | ៥៩.០១៥.២៦៣ |
| ការសងអ្នកផ្គត់ផ្គង់ (មិនមែនសាច់ប្រាក់) | (១.២៥៦.៣៣៧) | (៣៣.៤៣៧) |
| **សាច់ប្រាក់បានបង់ក្នុងឆ្នាំ** | ៣៣.៩១៩.៩៩២ | ៥៨.៩៨១.៨២៦ |

ចំណាយការប្រាក់ ដែលត្រូវបានធ្វើមូលធនកម្មលើទ្រព្យសកម្មដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ មានចំនួន ១០.៨០៣ លានរៀល ដែលមាន(អត្រាការប្រាក់ ១,៦៥% ប្រចាំឆ្នាំលើកម្ចីពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ–(JICA)–ឥណទានលេខ CP-P10 និង ១,២៦% លើកម្ចីពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ–(JICA) – ឥណទានលេខ CP-P21 (កំណត់សម្គាល់ ១៦)) ។

តារាងខាងក្រោមសង្ខេបពីស្ថានភាពស្របច្បាប់នៃដីធ្លី និងតម្លៃយោងរបស់វា។

| | ២០១៩<br>ពាន់រៀល | ២០១៨<br>ពាន់រៀល |
|---|---|---|
| ដីធ្លីដែលមានប័ណ្ណកម្មសិទ្ធិស្របច្បាប់ | ៧៣៥.០០០ | ៧៣៥.០០០ |
| ដីធ្លីដែលមិនមានប័ណ្ណកម្មសិទ្ធិ | ២៥០.១៩៤.៩០៩ | ២៥០.១៩៤.៩០៩ |
| | ២៥០.៩២៩.៩០៩ | ២៥០.៩២៩.៩០៩ |

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

### ៧. ទ្រព្យសម្បត្តិវិនិយោគ

| | ដីធ្លី<br>ពាន់រៀល | អគារ<br>ពាន់រៀល | សំណង់កំពុងសាងសង់<br>ពាន់រៀល | សរុប<br>ពាន់រៀល |
|---|---:|---:|---:|---:|
| **ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨** | | | | |
| តម្លៃចុះបញ្ជីសុទ្ធដើមគ្រា | ១៣១.៩៧៧.៥០៥ | ១៥០.៩៩១.៥០៤ | ៧០៣.០៦០ | ២៨៣.៦៧២.០៦៩ |
| ទិញបន្ថែម | - | ២៦៩.៧៥៤ | ៥២៩.៥៨៧ | ៧៩៩.៣៤១ |
| ការធ្វើចំណាត់ថ្នាក់ឡើងវិញ | ១.១១៥.៧៣១ | - | - | ១.១១៥.៧៣១ |
| ផ្ទេរ | ១.២៣២.៦៤៧ | - | (១.២៣២.៦៤៧) | - |
| វិលស់ | - | (៦.១០៤.៩៦១) | - | (៦.១០៤.៩៦១) |
| តម្លៃចុះបញ្ជីសុទ្ធចុងគ្រា | ១៣៤.៣២៥.៨៨៣ | ១៤៥.១៥៦.២៩៧ | - | ២៧៩.៤៨២.១៨០ |
| **នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨** | | | | |
| ថ្លៃដើម | ១៣៤.៣២៥.៨៨៣ | ១៦៣.៣៩៣.០១៤ | - | ២៩៧.៧១៨.៨៩៧ |
| រំលស់បង្គរ | - | (១៨.២៣៦.៧១៧) | - | (១៨.២៣៦.៧១៧) |
| តម្លៃចុះបញ្ជីសុទ្ធ | ១៣៤.៣២៥.៨៨៣ | ១៤៥.១៥៦.២៩៧ | - | ២៧៩.៤៨២.១៨០ |
| **ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩** | | | | |
| តម្លៃចុះបញ្ជីសុទ្ធដើមគ្រា | ១៣៤.៣២៥.៨៨៣ | ១៤៥.១៥៦.២៩៧ | - | ២៧៩.៤៨២.១៨០ |
| ទិញបន្ថែម | - | ២.៥៩៤.៥៧៩ | - | ២.៥៩៤.៥៧៩ |
| រំលស់ | - | (៦.១៩៦.០១៤) | - | (៦.១៩៦.០១៤) |
| តម្លៃចុះបញ្ជីសុទ្ធចុងគ្រា | ១៣៤.៣២៥.៨៨៣ | ១៤១.៥៥៤.៨៦២ | - | ២៧៥.៨៨០.៧៤៥ |
| **នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩** | | | | |
| ថ្លៃដើម | ១៣៤.៣២៥.៨៨៣ | ១៦៥.៩៨៧.៥៩៣ | - | ៣០០.៣១៣.៤៧៦ |
| រំលស់បង្គរ | - | (២៤.៤៣២.៧៣១) | - | (២៤.៤៣២.៧៣១) |
| តម្លៃចុះបញ្ជីសុទ្ធ | ១៣៤.៣២៥.៨៨៣ | ១៤១.៥៥៤.៨៦២ | - | ២៧៥.៨៨០.៧៤៥ |

*ដំណើរការវាយតម្លៃ (បច្ចេកទេស/ធាតុចូល) ប្រើក្នុងការកំណត់តម្លៃសមស្រប*

ទ្រព្យសម្បត្តិវិនិយោគត្រូវបានវាយតម្លៃ ដោយក្រុមហ៊ុនវាយតម្លៃដែលមានការទទួលស្គាល់ដោយ គណៈកម្មការមូលបត្រកម្ពុជា។ ក.ស.ស បានទទួលការវាយតម្លៃឯករាជចំពោះទ្រព្យសម្បត្តិវិនិយោគរបស់ខ្លួន គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ ហើយគណៈគ្រប់គ្រងជឿជាក់ថា វាមិនមានការផ្លាស់ប្តូរសំខាន់ៗលើការវាយតម្លៃហូតដល់កាលបរិច្ឆេទរាយការណ៍ទេ។

តម្លៃសមស្របកម្រិតបីរបស់ទ្រព្យសម្បត្តិវិនិយោគ ត្រូវបានទាញយកដោយប្រើប្រាស់វិធីសាស្រ្តប្រៀបធៀបការលក់ជាមួយនឹងវិធីសាស្រ្តវាយតម្លៃដីធ្លី និងវិធីសាស្រ្តថ្លៃដើមសម្រាប់អគារ។ ដីធ្លីត្រូវបានវាយតម្លៃដោយប្រើប្រាស់វិធីសាស្រ្តប្រៀបធៀបការលក់ ចាត់ចូលទៅក្នុងធាតុគណនីប្រៀបធៀប។ តម្លៃទាំងនេះ ត្រូវបានកែតម្រូវសម្រាប់ភាពខុសគ្នាក្នុងការសន្មតសំខាន់ៗ ដូចជា ទំហំ និងទីតាំង ស្ថានភាព និងកត្តាពាក់ព័ន្ធផ្សេងទៀត។

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩**

## ៧. **ទ្រព្យសម្បត្តិវិនិយោគ** (ត)

គណៈគ្រប់គ្រងជឿជាក់ថាតម្លៃសមស្របរបស់ទ្រព្យសម្បត្តិវិនិយោគ អាចត្រូវបានវាស់វែងគួរឱ្យជឿជាក់បាន។

| | **២០១៩** **ពាន់រៀល** | **២០១៨** **ពាន់រៀល** |
|---|---|---|
| ដីធ្លីតាមតម្លៃសមស្រប | ៣.១៣៦.៤០៨.៥០៨ | ៣.០៩២.៥៣៧.២៧៣ |
| អគារតាមតម្លៃសមស្រប | ១៣៧.៧០២.៤០០ | ១៣៥.៧៧៦.២៥៦ |
| | ៣.២៧៤.១១០.៩០៨ | ៣.២២៨.៣១៣.៥២៩ |

តារាងខាងក្រោមនេះ សង្ខេបពីស្ថានភាពស្របច្បាប់នៃដីធ្លី និងតម្លៃយោងរបស់វា។

| | **២០១៩** **ពាន់រៀល** | **២០១៨** **ពាន់រៀល** |
|---|---|---|
| ដីធ្លីដែលមានប័ណ្ណកម្មសិទ្ធិស្របច្បាប់ - តំបន់សេដ្ឋកិច្ចពិសេស(*) | ៨៥.២១២.៣៧០ | ៨៥.២១២.៣៧០ |
| ដីធ្លីដែលមានប័ណ្ណកម្មសិទ្ធិស្របច្បាប់ - តំបន់ផ្សេងៗ | ៣.២៨៦.៧២៤ | ៣.២៨៦.៧២៤ |
| ដីធ្លីដែលមិនមានប័ណ្ណកម្មសិទ្ធិ | ៤៤.៧១១.០៥៨ | ៤៤.៧១១.០៥៨ |
| ដីធ្លីដែលមានប័ណ្ណកម្មសិទ្ធិស្របច្បាប់ ប៉ុន្តែប្រជាពលរដ្ឋកំពុងរស់នៅ (ត្រូវបានចាត់ថ្នាក់ឡើងវិញពី ទ្រព្យសម្បត្តិ និងបរិក្ខារ) | ១.១១៥.៧៣១ | ១.១១៥.៧៣១ |
| | ១៣៤.៣២៥.៨៨៣ | ១៣៤.៣២៥.៨៨៣ |

(*) នេះគឺជាតម្លៃដីចំនួន៤១ហិកតា ដែលត្រូវបានផ្ទេរជាផ្លូវការមកឱ្យ ក.ស.ស តាមរយៈគណៈកម្មាធិការអន្តរក្រសួង ក្នុងឆ្នាំ២០០២។

ក.ស.ស បានទូទាត់ និងបានដោះស្រាយតំបន់ដែលនៅជុំវិញលើទំហំដី៤១ហិកតានេះ ហើយទទួលបានដីចំនួន២៧ ហិកតាបន្ថែមទៀតក្នុងឆ្នាំ២០១២ ដោយតម្លៃនៃដីធ្លីនោះនឹងត្រូវកំណត់ដោយគណៈកម្មាធិការអន្តរក្រសួង។ តម្លៃដី ២៧ ហិកតានេះ មិនទាន់ត្រូវបានកត់ត្រានៅក្នុងបញ្ជីនៅឡើយទេ ប៉ុន្តែ ក.ស.ស បានទទួលប័ណ្ណកម្មសិទ្ធិតាមផ្លូវច្បាប់រួចរាល់ហើយ។

ចំនួនទឹកប្រាក់ខាងក្រោមដែលត្រូវបានកត់ត្រាក្នុងចំណេញ-ខាត ត្រូវបានទាញយកមកពីការធ្វើអាជីវកម្មលើទ្រព្យសម្បត្តិវិនិយោគ ៖

| | **២០១៩** **ពាន់រៀល** | **២០១៨** **ពាន់រៀល** |
|---|---|---|
| ចំណូលពីការជួល | ២.៧៥១.៤៩៤ | ៣.០១៦.៣៦៥ |
| ចំណាយរំលស់ | (៦.១៩៦.០១៤) | (៦.១០៤.៩៦១) |
| ចំណាយប្រតិបត្តិការផ្ទាល់ដែលកើតចេញពីការវិនិយោគទ្រព្យសម្បត្តិ ដែលបង្កើតឱ្យមានចំណូលពីការជួល | (២.៧៧៧.៨៤៧) | (៣.៤១៣.៣២៩) |

## ៧. ទ្រព្យសម្បត្តិវិនិយោគ (ត)

តំបន់សេដ្ឋកិច្ចពិសេសកំពុងតែស្ថិតក្នុងដំណាក់កាល នៃការធ្វើប្រតិបត្តិការអាជីវកម្មរបស់ខ្លួន ក្នុងដំណាក់កាលដំបូងនៅឡើយ។

ការទូទាត់ភតិសន្យាអប្បបរមាទទួលបាន ចំពោះភតិសន្យានៃទ្រព្យសម្បត្តិវិនិយោគ មានដូចខាងក្រោម៖

| | ២០១៩<br>ពាន់រៀល | ២០១៨<br>ពាន់រៀល |
|---|---:|---:|
| ១ឆ្នាំ | ៦៩.២៧៥ | ៦៨.៣០៦ |
| ចន្លោះពី១ឆ្នាំ ទៅ ២ឆ្នាំ | ៦៩.២៧៥ | ៦៨.៣០៦ |
| ចន្លោះពី២ឆ្នាំ ទៅ ៣ឆ្នាំ | ៧៣.៣៥០ | ៦៨.៣០៦ |
| ចន្លោះពី៣ឆ្នាំ ទៅ ៤ឆ្នាំ | ៧៣.៣៥០ | ៧២.៣២៤ |
| ចន្លោះពី៤ឆ្នាំ ទៅ ៥ឆ្នាំ | ៧៣.៣៥០ | ៧២.៣២៤ |
| លើសពី៥ឆ្នាំ | ៧៥៧.៩៥០ | ៨១៩.៦៧២ |
| | ១.១១៦.៥៥០ | ១.១៦៩.២៣៨ |

## ៨. ទ្រព្យសកម្មអរូបី

| | កម្មវិធី<br>ពាន់រៀល |
|---|---:|
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨** | |
| តម្លៃចុះបញ្ជីសុទ្ធដើមគ្រា | ៨.៥៥៧.៧០២ |
| រំលស់ | (១.០៦២.៨៧១) |
| តម្លៃចុះបញ្ជីសុទ្ធចុងគ្រា | ៧.៤៩៤.៨៣១ |
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨** | |
| ថ្លៃដើម | ១០.៦០៨.៣៥២ |
| រំលស់បង្គរ | (៣.១១៣.៥២១) |
| តម្លៃចុះបញ្ជីសុទ្ធ | ៧.៤៩៤.៨៣១ |
| | |
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩** | |
| តម្លៃចុះបញ្ជីសុទ្ធដើមគ្រា | ៧.៤៩៤.៨៣១ |
| រំលស់ | (១.០៦២.៨៧១) |
| តម្លៃចុះបញ្ជីសុទ្ធចុងគ្រា | ៦.៤៣១.៩៦០ |
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩** | |
| ថ្លៃដើម | ១០.៦០៨.៣៥២ |
| រំលស់បង្គរ | (៤.១៧៦.៣៩២) |
| តម្លៃចុះបញ្ជីសុទ្ធ | ៦.៤៣១.៩៦០ |

## ៩. **ឥណទានផ្តល់ឱ្យបុគ្គលិក**

| | **២០១៩ ពាន់រៀល** | **២០១៨ ពាន់រៀល** |
|---|---|---|
| រយៈពេលខ្លី | ២.១៩៣.១១២ | ១.៨៨៣.៩៨១ |
| រយៈពេលវែង | ១.២២៨.០១៩ | ៣.៤២១.១៣២ |
| | ៣.៤២១.១៣១ | ៥.៣០៥.១១៣ |

នៅថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ក.ស.ស បានអនុម័តផ្តល់ឥណទានគ្មានការប្រាក់ ចំនួន ១០.២៦៦.៩០៤ ពាន់រៀល ដែលមានរយៈពេលបួនឆ្នាំឱ្យបុគ្គលិករបស់ខ្លួន រួមទាំងបុគ្គលិកដែលបានចូលនិវត្ត ដើម្បីទិញភាគហ៊ុន ប្រភេទ "គ" នៅពេលដែល ក.ស.ស ចុះបញ្ជីលក់មូលបត្រជាសាធារណៈលើកដំបូង។

និយ័តកម្មតម្លៃសមស្របលើសមតុល្យឥណទាន ២.៦២១.៨២៤ ពាន់រៀល ត្រូវបានកត់ត្រាដំបូងជាទ្រព្យសកម្មផ្សេងៗ នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ និងដករំលស់ក្នុងចំណេញ-ខាត ក្នុងខ្ទង់ប្រាក់បៀវត្សរ៍ ប្រាក់ឈ្នួល និងចំណាយពាក់ព័ន្ធ ក្នុងរយៈពេលបួនឆ្នាំ ដោយសារតម្លៃសមស្របរបស់ឥណទាននេះ ត្រូវបានកាត់បន្ថយដោយអត្រាអនុគ្រោះ (គ្មានការប្រាក់) ហើយអត្ថប្រយោជន៍ត្រូវបានផ្តល់ឱ្យបុគ្គលិក។

តម្លៃសមស្របដំបូងនៃឥណទានផ្តល់ឱ្យបុគ្គលិក គឺអាស្រ័យទៅតាមលំហូរសាច់ប្រាក់អប្បហារ ដោយប្រើអត្រាការប្រាក់មធ្យម ១៥,២៧% ក្នុងមួយឆ្នាំ និងបន្ទាប់មកទៀត ត្រូវបានទទួលស្គាល់តាមថ្លៃដើមដករំលស់។ គណៈគ្រប់គ្រងបានវាយតម្លៃថាអត្រាការប្រាក់ ១៥,២៧% គឺជាអត្រាសមស្រប ដែលប្រហាក់ប្រហែលនឹងអត្រាដែលបុគ្គលិកអាចខ្ចីប្រាក់ដោយមិនមានការធានា ពីធនាគារពាណិជ្ជនានាជាប្រាក់រៀល ក្នុងរយៈពេល៤ឆ្នាំ។

បម្រែបម្រួលឥណទានផ្តល់ឱ្យបុគ្គលិក មានដូចខាងក្រោម៖

| | **២០១៩ ពាន់រៀល** | **២០១៨ ពាន់រៀល** |
|---|---|---|
| សមតុល្យដើមគ្រា | ៥.៣០៥.១១៣ | ៦.៩២៣.៥៣៨ |
| បន្ថែម៖ ចំណាយការប្រាក់ពីអត្រាអប្បហារដែលកត់ត្រាត្រលប់មកវិញ | ៦៨២.៧៤៤ | ៩៤៨.៣០១ |
| ដក៖ ការសងឥណទាន | (២.៥៦៦.៧២៦) | (២.៥៦៦.៧២៦) |
| សមតុល្យចុងគ្រា | ៣.៤២១.១៣១ | ៥.៣០៥.១១៣ |

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩**

## ១០. សន្និធិ

| ទ្រព្យសកម្មរយៈពេលខ្លី | **២០១៩ ពាន់រៀល** | **២០១៨ ពាន់រៀល** |
|---|---:|---:|
| សម្ភារប្រើប្រាស់ | ១៧.២៤៧.៥៣៩ | ១០.៥៤៤.២៤៨ |
| ប្រេងឥន្ធនៈ និងប្រេងម៉ាស៊ីន | ១.២៧២.៨៤០ | ១.១០៤.១១០ |
| សម្ភារងាយឆេះ | ៧៤១.៨៧០ | ៤១៧.២៥៤ |
| សំវិធានធនសម្រាប់គ្រឿងបន្លាស់ (*) | (៧៤២.៩៩៤) | (៧៤២.៩៩៤) |
| | ១៨.៥១៩.២៥៥ | ១១.៣២២.៦១៨ |

(*) គណៈគ្រប់គ្រងធ្វើការវាយតម្លៃលើសន្និធិដែលដំណើរការយឺតតាមពេលវេលាកំណត់ និងពិចារណាទៅលើតម្លៃសំវិធាន-ធន ដែលនៅសល់មានភាពគ្រប់គ្រាន់ និងត្រឹមត្រូវនៅដំណាច់ការិយបរិច្ឆេទ។

សន្និធិដែលបានកត់ត្រាជាចំណាយក្នុងអំឡុងដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ មានទឹកប្រាក់ចំនួន ៩០.៦៤១ លានរៀល (៣១ ធ្នូ ២០១៨ ៖ ៧៣.០៨៥ លានរៀល)។

## ១១. គណនីអតិថិជនពាណិជ្ជកម្ម និងគណនីអតិថិជនផ្សេងៗ

| | **២០១៩ ពាន់រៀល** | **២០១៨ ពាន់រៀល** |
|---|---:|---:|
| គណនីអតិថិជនពាណិជ្ជកម្ម | ៣៧.៧៦៧.៩១០ | ២៩.៥៨៦.៨៤៧ |
| សំវិធានធនសម្រាប់ការខាតបង់ [កំណត់សម្គាល់ ៣.១(ខ.៣)] | (១.២១៥.២៤៨) | (៦២៤.៣១៥) |
| គណនីអតិថិជនពាណិជ្ជកម្ម - សុទ្ធ | ៣៦.៥៥២.៦៦២ | ២៨.៩៦២.៥៣២ |
| បុរេប្រទានឱ្យក្រសួងសាធារណការ និងដឹកជញ្ជូន (*) | ១៤.២៨៧.៥៤៧ | ៩.៧៧១.៣០០ |
| បុរេប្រទានផ្សេងៗ | ១.៣៧៧.៧៤២ | ១.៩៧៤.៥៣០ |
| ឥណទានពន្ធកាត់ទុក | ១.១២៥.៧៩៧ | ១.០៣៣.៩០២ |
| ចំណាយបង់មុន | ៨៥.៨៣៦ | ១១៦.៧៤៧ |
| | ៥៣.៤២៩.៥៨៤ | ៤១.៨៥៩.០១១ |

អតិថិជនរបស់ ក.ស.ស គឺជាភ្នាក់ងារដឹកជញ្ជូនជាតិ និងអន្តរជាតិនានា។ គណនីអតិថិជនពាណិជ្ជកម្មមានរយៈពេលខ្លី។

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩**

## ១១. គណនីអតិថិជនពាណិជ្ជកម្ម និងគណនីអតិថិជនផ្សេងៗ (ត)

(*) នេះគឺជាសមតុល្យបុរេប្រទានសាច់ប្រាក់នៅសល់ដែលឱ្យក្រសួងសាធារណការ និងដឹកជញ្ជូន យោងទៅតាមលិខិតរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះថ្ងៃ២៩ ខែមករា ឆ្នាំ២០១៩ ក្នុងគោលបំណងដើម្បីសាងសង់ប្រព័ន្ធបូមទឹកកង្វក់បន្ថែម នៅក្នុងក្រុងព្រះសីហនុ និងនៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៩ ក្នុងគោលបំណងដើម្បីជួសជុលកែលម្អ និងពង្រីកផ្នែកខ្លះនៅក្នុងក្រុងផ្លូវលេខ២០០។ បុរេប្រទាននេះត្រូវបានទូទាត់ ដោយកាត់កងពីការបែងចែកភាគលាភ និងការទូទាត់សង ហើយមិនមានកាលបរិច្ឆេទសងពិតប្រាកដទេ។

| | ២០១៩<br>ពាន់រៀល | ២០១៨<br>ពាន់រៀល |
|---|---|---|
| សមតុល្យដើមគ្រា | ៩.៧៧១.៣០០ | ១០.៥៥០.០០០ |
| បុរេប្រទានបន្ថែមក្នុងឆ្នាំ | ១៣.០៦៦.២៤៧ | ៣.២២១.៣០០ |
| ការទូទាត់សងក្នុងអំឡុងឆ្នាំ | (២.០០០.០០០) | - |
| បានទូទាត់តាមរយៈការបែងចែកភាគលាភ (កំណត់សម្គាល់ ៣.២.១) | (៦.៥៥០.០០០) | (៤.០០០.០០០) |
| សមតុល្យចុងគ្រា | ១៤.២៨៧.៥៤៧ | ៩.៧៧១.៣០០ |

## ១២. ប្រាក់បញ្ញើរយៈពេលខ្លីនៅធនាគារ

ប្រាក់បញ្ញើរយៈពេលខ្លីនៅធនាគារ គឺជាប្រាក់បញ្ញើមានកាលកំណត់ ដែលបានផ្ញើនៅគ្រឹះស្ថានហិរញ្ញវត្ថុនានាក្នុងរយៈពេលពី៦ខែ និង១២ខែ ហើយទទួលបានការប្រាក់ចន្លោះពី ៣,០០% ទៅ ៤,៧៥% ក្នុងមួយឆ្នាំ (២០១៨ ៖ ៣,៥០% ទៅ ៤.៧៥% ក្នុងមួយឆ្នាំ) ។

## ១៣. សាច់ប្រាក់ និងសាច់ប្រាក់សមមូល

| | ២០១៩<br>ពាន់រៀល | ២០១៨<br>ពាន់រៀល |
|---|---|---|
| សាច់ប្រាក់ក្នុងដៃ | ២.៣១៦.០៣៨ | ១.៦៨៦.៦៧២ |
| សាច់ប្រាក់នៅធនាគារ៖ | | |
| គណនីចរន្ត | ២៥.៤៧៣.៥៥៩ | ៦០.៥០៤.៨៥៣ |
| | ២៧.៧៨៩.៥៩៧ | ៦២.១៩១.៥២៥ |

សាច់ប្រាក់នៅធនាគារត្រូវបានដាក់ផ្ញើនៅធនាគារពាណិជ្ជក្នុងស្រុក។ គណនីចរន្តមិនមានការប្រាក់ទេ។

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩**

## ១៤. ដើមទុន និងបុព្វលាភភាគហ៊ុន

| | ភាគហ៊ុនប្រភេទ ក (*) | | ភាគហ៊ុនប្រភេទ ខ (**) | | ភាគហ៊ុនប្រភេទ គ (***) | | ភាគហ៊ុន បុព្វលាភ | សរុប |
|---|---|---|---|---|---|---|---|---|
| | ចំនួនភាគហ៊ុន | ពាន់រៀល | ចំនួនភាគហ៊ុន | ពាន់រៀល | ចំនួនភាគហ៊ុន | ពាន់រៀល | ពាន់រៀល | ពាន់រៀល |
| **នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨** | ៣៦៤.៥៣០.៨៦១ | ៣៦៤.៥៣០.៨៦១ | ៦៤.៣២៨.៩៧៥ | ៦៤.៣២៨.៩៧៥ | ២១.៤៤២.៩៩២ | ២១.៤៤២.៩៩២ | ៦៧.៧១៥.២៣៥ | ៥១៨.០១៨.០៦៣ |
| **នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩** | ៣៦៤.៥៣០.៨៦១ | ៣៦៤.៥៣០.៨៦១ | ៦៤.៣២៨.៩៧៥ | ៦៤.៣២៨.៩៧៥ | ២១.៤៤២.៩៩២ | ២១.៤៤២.៩៩២ | ៦៧.៧១៥.២៣៥ | ៥១៨.០១៨.០៦៣ |

(*) យោងតាមមាត្រា ៥ នៃលក្ខន្តិកៈ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៧ ដើមទុនដែលមានស្រាប់ចំនួន ៤២៨.៨៥៩.៨៣៦.០០០ រៀល ត្រូវបានបែងចែកទៅជាភាគហ៊ុនប្រភេទ "ក" ចំនួន ៣៦៤.៥៣០.៨៦១ ហ៊ុន ដើមទុនប្រភេទ ខ ចំនួន ៦៤.៣២៨.៩៧៥ ហ៊ុន ដោយមានតម្លៃចារិក ១.០០០ រៀល ក្នុងមួយភាគហ៊ុន។ ទាំងភាគហ៊ុនប្រភេទ "ក" និងភាគហ៊ុនប្រភេទ "ខ" ត្រូវបានកាន់កាប់ដោយរាជរដ្ឋាភិបាលកម្ពុជា ដែលតំណាងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ភាគហ៊ុនប្រភេទ "ក" មិនមានសិទ្ធិទទួលបានភាគលាភទេ ហើយក៏មិនមានសិទ្ធិបោះឆ្នោតដែរ លើកលែងតែលក្ខខណ្ឌមួយចំនួនដូចបានលម្អិតក្នុងមាត្រា ៩ នៃលក្ខន្តិកៈចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៧។ ភាគហ៊ុនប្រភេទ "ខ" មានសិទ្ធិបោះឆ្នោត និងមានសិទ្ធិទទួលបានភាគលាភ នៅពេលដែលក្រុមប្រឹក្សាភិបាលបានអនុម័ត្ត។

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩**

## ១៤. ដើមទុន និងបុព្វលាភភាគហ៊ុន (ត)

(**) សេចក្តីលម្អិតនៃភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោតមានដូចខាងក្រោម៖

| **ភាគហ៊ុនិក** | **ភាគរយ** | **ចំនួនភាគហ៊ុន** | **ពាន់រៀល** |
|---|---|---|---|
| ភាគហ៊ុនប្រភេទ "ខ" | | | |
| រាជរដ្ឋាភិបាលកម្ពុជា | ៧៥% | ៦៤.៣២៨.៩៧៥ | ៦៤.៣២៨.៩៧៥ |
| ភាគហ៊ុនប្រភេទ "គ" | | | |
| Kamigumi | ១៣% | ១១.១៥០.៣២៤ | ១១.១៥០.៣២៤ |
| គម្រោងភាគហ៊ុនរបស់បុគ្គលិក | ២% | ២.១៩៤.២៩៩ | ២.១៩៤.២៩៩ |
| អ្នកវិនិយោគផ្សេងៗ | ១០% | ៨.១៩៨.៣៦៩ | ៨.១៩៨.៣៦៩ |
| | ២៥% | ២១.៤៤២.៩៩២ | ២១.៤៤២.៩៩២ |
| | ១០០% | ៨៥.៧៧១.៩៦៧ | ៨៥.៧៧១.៩៦៧ |

ចំនួនភាគហ៊ុនដែលបានបោះផ្សាយក្នុងប្រភេទ "គ" មានចំនួន ២១.៤៤២.៩៩២ ភាគហ៊ុន ដែលមានតម្លៃចារិក ១.០០០ រៀលក្នុងមួយភាគហ៊ុន។ ភាគហ៊ុនប្រភេទ "គ" ដែលបានបោះផ្សាយទាំងអស់ ត្រូវបានបង់ប្រាក់រួចរាល់ទាំងស្រុង។

(***) ភាគលាភធានាត្រូវបង់ទៅគ្រប់ភាគហ៊ុនប្រភេទ គ

ដើម្បីជាការលើកទឹកចិត្តសម្រាប់អ្នកវិនិយោគ ភាគហ៊ុនិកភាគហ៊ុនប្រភេទ "គ" (មានសិទ្ធិបោះឆ្នោតទាំងអស់) មានសិទ្ធិទទួលបានភាគលាភអប្បបរមាធានាត្រូវទទួលចំនួន ៥% ក្នុងមួយឆ្នាំ សម្រាប់រយៈពេលបីឆ្នាំ (ជាសាច់ប្រាក់ ឬ ជាភាគហ៊ុនទៅតាមការសម្រេចចិត្តរបស់ ក.ស.ស តែប៉ុណ្ណោះ) នៃភាគហ៊ុនប្រភេទ "គ" សរុប គុណនឹងតម្លៃដាក់លក់ពីកាលបរិច្ឆេទចុះបញ្ជីលក់ មូលបត្រលើកដំបូង ក្នុងខែមិថុនា ឆ្នាំ២០១៧។ ប្រសិនបើការទូទាត់ការបង់ភាគលាភជាភាគហ៊ុន គឺវាអាស្រ័យទៅលើតម្លៃទីផ្សារភាគហ៊ុនពេលបិទទ្វារ មុនពេល ex-dividend day។ មិនមានការធានាចំពោះចំនួនភាគហ៊ុនថេរទេ (មានតែចំនួនភាគហ៊ុនអថេរ)។ក្នុងករណីដែលមានមូលនិធិគ្រប់គ្រាន់ អភិបាលទាំងអស់ត្រូវប្រកាស និងបង់ភាគលាភទៅអ្នកវិនិយោគរបស់ខ្លួនក្នុងរយៈពេល ១២ខែពីកាលបរិច្ឆេទចុះបញ្ជីលក់មូលបត្រលើកដំបូង។ ក្នុងករណីដែលភាគលាភអប្បបរមាធានាត្រូវបង់ មិនត្រូវបានបង់/បែងចែក ពេញលេញក្នុងឆ្នាំណាមួយទេនោះ ចំនួនទឹកប្រាក់ដែលនៅសល់ត្រូវកត់ត្រាបង្គរទៅឆ្នាំក្រោយៗទៀត រហូតដល់ពេលដែលភាគលាភអប្បបរមាធានាត្រូវបង់ អាចទូទាត់បានពេញលេញ។

រាជរដ្ឋាភិបាលកម្ពុជា ដែលជាភាគហ៊ុនិកដើមទុនមានសិទ្ធិបោះឆ្នោតប្រភេទ "ខ" និង ភាគហ៊ុនិកដើមទុនមិនមានសិទ្ធិបោះឆ្នោតប្រភេទ "ក" មិនមានសិទ្ធិទទួលភាគលាភអប្បបរមាធានានេះទេ។

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩**

## ១៤. ដើមទុន និងបុព្វលាភភាគហ៊ុន (ត)

កាលផុតកំណត់នៃភាគលាភអប្បបរមាធានាត្រូវបង់ មានដូចខាងក្រោម៖

| | ២០១៩<br>ពាន់រៀល | ២០១៨<br>ពាន់រៀល |
|---|---|---|
| រយៈពេលខ្លី | ៥.២៥៦.៣៨០ | ៤.៩១២.៤៦៦ |
| រយៈពេលវែង | - | ៥.២៥៦.៣៣៩ |
| | ៥.២៥៦.៣៨០ | ១០.១៦៨.៨០៥ |

បម្រែបម្រួលភាគលាភអប្បបរមាធានាត្រូវបង់ មានដូចខាងក្រោម៖

| | ២០១៩<br>ពាន់រៀល | ២០១៨<br>ពាន់រៀល |
|---|---|---|
| សមតុល្យដើមគ្រា | ១០.១៦៨.៨០៥ | ១៤.៧៥៩.៨៩៤ |
| ចំណាយការប្រាក់បូកបន្ថែម (កំណត់សម្គាល់ ២៧) | ៤៩១.១៦៨ | ៨១២.៥៤៤ |
| ភាគលាភបានបង់ | (៥.៤០៣.៦៣៣) | (៥.៤០៣.៦៣៣) |
| សមតុល្យចុងគ្រា | ៥.២៥៦.៣៤០ | ១០.១៦៨.៨០៥ |

## ១៥. ទុនបម្រុងផ្សេងៗ

| | ២០១៩<br>ពាន់រៀល | ២០១៨<br>ពាន់រៀល |
|---|---|---|
| សមតុល្យដើមគ្រា | ២០.១៥៥.៨៤៦ | ១៧.៦៤១.៩១៤ |
| បន្ថែម : ទុនបម្រុងទូទៅ | ២.២៧៨.៤៣៨ | ១.២៥៦.៩៦៦ |
| បន្ថែម : ទុនបម្រុងតាមច្បាប់ | ២.២៧៨.៤៣៨ | ១.២៥៦.៩៦៦ |
| សមតុល្យចុងគ្រា | ២៤.៧១២.៧២២ | ២០.១៥៥.៨៤៦ |

មាត្រា ៣៤ នៃលក្ខន្តិកៈចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៧ បានចែងថា បន្ទាប់ពីកាត់កងការខាតយោង (ប្រសិនបើមាន) និងប្រាក់ចំណេញរួច ក.ស.សត្រូវបែងចែកប្រាក់ចំណេញរក្សាទុកទៅក្នុងទុនបម្រុងទូទៅចំនួន ៥% និងទុនបម្រុងតាមច្បាប់ ៥%។ នៅថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៩ ក្រុមប្រឹក្សាភិបាលបានអនុម័តផ្ទេរប្រាក់ចំណេញរក្សាទុកសម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១៨ ទៅជាទុនបម្រុងទូទៅចំនួន ២.២៧៨.៤៣៨ ពាន់រៀល និងទៅជាទុនបម្រុងតាមច្បាប់ចំនួន ២.២៧៨.៤៣៨ ពាន់រៀល។

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

### ១៦. ប្រាក់កម្ចី

| | ២០១៩<br>ពាន់រៀល | ២០១៨<br>ពាន់រៀល |
|---|---|---|
| ប្រាក់កម្ចីពី៖ | | |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ – (JBIC)– ឥណទានលេខ CP-P3 | ៧៥.០៧៤.៨២០ | ៧៩.៧៩៥.៥១៤ |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ – (JBIC) – ឥណទានលេខ CP-P4 | ១១៣.១៦២.០៨៧ | ១១៩.០១៨.១២៧ |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ – (JBIC) – ឥណទានលេខ CP-P6 | ៧.៩៥៩.៨៨៣ | ៨.២១២.០៨៤ |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ – (JBIC) – ឥណទានលេខ CP-P8 | ១២៣.១០០.២២១ | ១២៣.៩៤៥.២៦៣ |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ – (JICA) – ឥណទានលេខ CP-P10 | ២២០.៣៩៣.០០៩ | ២១៩.៦៥០.២៤១ |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ – (JICA) – ឥណទានលេខ CP-P21 | ៤.០១៤.២០៤ | - |
| | ៥៤៣.៧០៤.២២៤ | ៥៥០.៦២១.២២៩ |

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងប្រាក់កម្ចីជាមួយ JICA និង JBIC ទាក់ទិនទៅនឹងប្រតិបត្តិការដែលពាក់ព័ន្ធនឹង ក.ស.ស។ នៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៩ ក.ស.ស បានចុះហត្ថលេខាបន្ថែមលើកិច្ចព្រមព្រៀងប្រាក់កម្ចី ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់គម្រោងអភិវឌ្ឍន៍ចំណតផែកុងតឺន័រថ្មីរបស់កំពង់ផែក្រុងព្រះសីហនុ ដែលមានទឹកប្រាក់ចំនួន ២៣.៥០២.០០០.០០០ យ៉េន (ប្រមាណជា ៨៨៤.១៤៥ លានរៀល) ដោយប្រាក់កម្ចីត្រូវបាន JICA ទូទាត់ដោយផ្ទាល់ទៅឱ្យអ្នកផ្គត់ផ្គង់របស់ ក.ស.ស។ ក.ស.ស បានសងប្រាក់ដោយផ្ទាល់ទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទៅតាមកាលវិភាគសងប្រាក់។

កាលកំណត់របស់ប្រាក់កម្ចីទាំងនេះមានដូចខាងក្រោម៖

| | ២០១៩<br>ពាន់រៀល | ២០១៨<br>ពាន់រៀល |
|---|---|---|
| **ប្រាក់កម្ចីរយៈពេលខ្លី** | | |
| មិនលើសមួយឆ្នាំ | ៣៦.៤៣០.៥០២ | ២២.១៩៧.៣១១ |
| **ប្រាក់កម្ចីរយៈពេលវែង** | | |
| លើសមួយឆ្នាំ ប៉ុន្តែមិនលើសពីរឆ្នាំ | ៣២.៤១៣.៤១២ | ២៤.១៩៤.៧៨០ |
| លើសពីរឆ្នាំ ប៉ុន្តែមិនលើសប្រាំឆ្នាំ | ៩៧.២៤០.២៣៦ | ៨៨.៤១១.១១២ |
| លើសពីប្រាំឆ្នាំឡើងទៅ | ៣៧៧.៦២០.០៧៤ | ៤១៥.៨១៨.០២៦ |
| | ៥០៧.២៧៣.៧២២ | ៥២៨.៤២៣.៩១៨ |
| | ៥៤៣.៧០៤.២២៤ | ៥៥០.៦២១.២២៩ |

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩**

## ១៦. ប្រាក់កម្ចី (ត)

តម្លៃយោង និងតម្លៃសមស្របរបស់ប្រាក់កម្ចី មានដូចខាងក្រោម៖

| | ២០១៩ ពាន់រៀល | ២០១៨ ពាន់រៀល |
|---|---|---|
| តម្លៃយោង | | |
| រយៈពេលខ្លី | ៣៦.៤៣០.៥០២ | ២២.១៩៧.៣១១ |
| រយៈពេលវែង | ៥០៧.២៧៣.៧២២ | ៥២៨.៤២៣.៩១៨ |
| | ៥៤៣.៧០៤.២២៤ | ៥៥០.៦២១.២២៩ |
| តម្លៃសមស្រប | | |
| រយៈពេលខ្លី | ៣១.៩២១.៣៩៤ | ១៨.៤៨៧.៣១៨ |
| រយៈពេលវែង | ៣៨០.៥៩១.៥៨៦ | ៣៨១.៣៦៩.០៣៥ |
| | ៤១២.៥១២.៩៨០ | ៣៩៩.៨៥៦.៣៥៣ |

តម្លៃសមស្របត្រូវបានគណនាអាស្រ័យទៅតាមលំហូរសាច់ប្រាក់អប្បហារ ដោយប្រើអត្រាប្រាក់កម្ចីនាពេលបច្ចុប្បន្នរបស់អង្គភាព។ វាត្រូវបានចាត់ថ្នាក់ជាតម្លៃសមស្របកម្រិតទី៣ ក្នុងឋានានុក្រមតម្លៃសមស្រប ដោយសារមានការរួមបញ្ចូលនូវធាតុចូលដែលមិនអាចអង្កេតបាន រួមមាន ហានិភ័យឥណទានរបស់ភាគីដៃគូជាដើម។

ប្រាក់កម្ចីជារូបិយប័ណ្ណផ្សេងៗក្រៅពីរូបិយប័ណ្ណគោល មានដូចខាងក្រោម៖

| | ២០១៩ ពាន់រៀល | ២០១៨ ពាន់រៀល |
|---|---|---|
| ប្រាក់យ៉េន | ៤០២.០៨៨.៤៥៣ | ៤២០.១៩២.៩៤៣ |
| ប្រាក់ដុល្លារអាមេរិក | ១៤១.៦១៥.៧៧១ | ១៣០.៤២៨.២៨៦ |
| | ៥៤៣.៧០៤.២២៤ | ៥៥០.៦២១.២២៩ |

ប្រាក់កម្ចីទាំងអស់មានរយៈពេល៣០ឆ្នាំ ហើយអត្រាការប្រាក់ប្រចាំឆ្នាំនៃប្រាក់កម្ចីនីមួយៗ មានដូចខាងក្រោម៖

| | ២០១៩ | ២០១៨ |
|---|---|---|
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ – (JBIC) – ឥណទានលេខ CP-P3 | ៣,០០% | ៣,០០% |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ – (JBIC) – ឥណទានលេខ CP-P4 | ៣,៧០% | ៣,៧០% |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ – (JBIC) – ឥណទានលេខ CP-P6 | ៣,០០% | ៣,០០% |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ – (JBIC) – ឥណទានលេខ CP-P8 | ២,៦៥% | ២,៦៥% |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ – (JICA) – ឥណទានលេខ CP-P10 | ២,៦៥% | ១,៦៥% |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ – (JICA) – ឥណទានលេខ CP-P21 | ១,២៦% | - |

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

### ១៧. ភាគព្វកិច្ចអត្ថប្រយោជន៍សោធននិវត្តន៍

ចំនួនទឹកប្រាក់ដែលបានកត់ត្រានៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ មានដូចខាងក្រោម៖

| | **២០១៩** | **២០១៨** |
|---|---|---|
| | **ពាន់រៀល** | **ពាន់រៀល** |
| | | (បានរាយការណ៍ឡើងវិញ) |
| តម្លៃបច្ចុប្បន្ននៃកាតព្វកិច្ចអត្ថប្រយោជន៍ដែលបានកំណត់ | ៨៣.០៧៤.០៦១ | ៧៩.៥៣៧.៩៧៦ |
| ស្ថានភាពអធន (Unfunded status) | ៨៣.០៧៤.០៦១ | ៧៩.៥៣៧.៩៧៦ |
| បំណុលសុទ្ធដែលបានកត់ត្រាក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ | ៨៣.០៧៤.០៦១ | ៧៩.៥៣៧.៩៧៦ |

បម្រែបម្រួលនៃកាតព្វកិច្ចអត្ថប្រយោជន៍ដែលបានកំណត់ក្នុងឆ្នាំនេះ មានដូចខាងក្រោម៖

| | **២០១៩** | **២០១៨** |
|---|---|---|
| | **ពាន់រៀល** | **ពាន់រៀល** |
| សមតុល្យដើមគ្រា | ៧៩.៥៣៧.៩៧៦ | ៤៨.៣៤៧.២៥៥ |
| ចំណាយលើសេវាកម្មបច្ចុប្បន្ន | ១.៩៣៨.០០០ | ១.៤៩២.០០០ |
| ចំណាយការប្រាក់ | ៤.៥៩១.០០០ | ៣.៦៤៩.០០០ |
| ការកាត់បន្ថយប្រាក់សោធននិវត្តន៍ (*) | (៦៣៧.០០០) | - |
| អត្ថប្រយោជន៍បានបង់ | (៣.០១៦.៩១៥) | (៣.១០៧.២៧៩) |
| ការខាតបង់បណ្តាលមកពីការវាស់វែងឡើងវិញ (**) | ៦៦១.០០០ | ២៩.១៥៧.០០០ |
| សមតុល្យចុងគ្រា | ៨៣.០៧៤.០៦១ | ៧៩.៥៣៧.៩៧៦ |

(*) ការកាត់បន្ថយប្រាក់សោធននិវត្តន៍ដែលកើតឡើង គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ គឺដោយសារតែមានការធ្វើវិសោធនកម្មលើប្រាក់បំណាច់លើកទឹកចិត្ត ទៅលើចំនួនឆ្នាំដែលបានបម្រើការងារ ដោយរាប់គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ ដែលកើតឡើងក្នុងអំឡុងឆ្នាំ២០១៩។ ដូចនេះអាយុកាលធ្វើការនាពេលអនាគតដែលរំពឹងទុករបស់និយោជិក ក.ស.ស កំពុងតែត្រូវបានកាត់បន្ថយ (កំណត់សម្គាល់ ២.១៦.១ (ខ))។

(**) គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ការខាតបង់នៃការវាស់វែង បានកើតឡើងពីការខាតបង់បទពិសោធន៍ចំនួន ៦៦១.០០០ ពាន់រៀល គឺភាគច្រើនដោយសារតែខាតពីកំណើនប្រាក់ខែជាក់ស្តែងក្នុងឆ្នាំ២០១៩ ដែលខ្ពស់ជាងការប៉ាន់ស្មាន ៥% ក្នុងមួយឆ្នាំ ហើយមួយផ្នែកទៀតដោយសារខាតបង់ពីគ្មានអ្នកស្លាប់ និងគ្មានបម្រែបម្រួលបុគ្គលិកក្នុងឆ្នាំ។

| | **២០១៩** | **២០១៨** |
|---|---|---|
| | **ពាន់រៀល** | **ពាន់រៀល** |
| | | (បានរាយការណ៍ឡើងវិញ) |
| រយៈពេលខ្លី | ៧.៩៤៩.០០០ | ៣.០៥៧.០០០ |
| រយៈពេលវែង | ៧៥.១២៥.០៦១ | ៧៦.៤៨០.៩៧៦ |
| | ៨៣.០៧៤.០៦១ | ៧៩.៥៣៧.៩៧៦ |

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩**

### ១៧. ភាតព្វកិច្ចអត្ថប្រយោជន៍សោធននិវត្តន៍ (ត)

ចំណាយអត្ថប្រយោជន៍សោធននិវត្តន៍ ត្រូវបានកត់ត្រានៅក្នុងខ្ទង់ប្រាក់បៀវត្សរ៍ ប្រាក់ឈ្នួល និងចំណាយពាក់ព័ន្ធខ្ទង់ការវាស់វែងកាតព្វកិច្ចអត្ថប្រយោជន៍សោធននិវត្តឡើងវិញនៅក្នុងរបាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗសង្ខេបដូចខាងក្រោម៖

| | **២០១៩ ពាន់រៀល** | **២០១៨ ពាន់រៀល** |
|---|---|---|
| | | (បានរាយការណ៍ឡើងវិញ) |
| ចំណាយលើសេវាកម្មបច្ចុប្បន្ន | ១.៩៣៨.០០០ | ១.៤៩២.០០០ |
| ចំណាយការប្រាក់ | ៤.៥៩១.០០០ | ៣.៦៤៩.០០០ |
| ការកាត់បន្ថយប្រាក់សោធននិវត្តន៍ | (៦៣៧.០០០) | - |
| **ទឹកប្រាក់សរុបបានកត់ត្រាក្នុងចំណេញ-ខាត** | ៥.៨៩២.០០០ | ៥.១៤១.០០០ |
| ការខាតបង់បណ្ដាលមកពីការវាស់វែងឡើងវិញ | | |
| ខាតពីការផ្លាស់ប្ដូរការសន្មតប្រជាសាស្ត្រ | - | ៥៣៨.០០០ |
| ខាតពីការផ្លាស់ប្ដូរការសន្មតហិរញ្ញវត្ថុ | - | ៧.៥០៨.០០០ |
| ខាតបទពិសោធន៍ | ៦៦១.០០០ | ២១.១១១.០០០ |
| **ទឹកប្រាក់សរុបបានកត់ត្រាក្នុងលទ្ធផលលម្អិតផ្សេងៗ** | ៦៦១.០០០ | ២៩.១៥៧.០០០ |

ការសន្មតសំខាន់ជាចម្បង មានដូចខាងក្រោម៖

| | **២០១៩** | **២០១៨** |
|---|---|---|
| មធ្យមភាគនៃឆ្នាំបម្រើការងារ | ១៩ | ១៨ |
| អត្រាអប្បហារក្នុងមួយឆ្នាំ | ៦% | ៦% |
| អត្រាកំណើនប្រាក់បៀវត្សរ៍ក្នុងមួយឆ្នាំ | ៥% | ៥% |
| អត្រាបម្រែបម្រួលបុគ្គលិកក្នុងមួយឆ្នាំ | ០,៥% | ០,៥% |

**អត្រាមរណៈ**

ដោយសារមិនមានអត្រាមរណៈត្រូវបានចេញផ្សាយនៅក្នុងប្រទេសកម្ពុជា ក.ស.ស បានប្រើប្រាស់តារាងអត្រាអាយុកាលរំពឹងទុកនៃមរណៈរបស់ប្រទេសថៃឆ្នាំ២០១៧ ហើយបានកែសម្រួលដើម្បីឱ្យសមស្របទៅនឹងអាយុកាលរំពឹងទុករបស់ប្រជាជនកម្ពុជា។ តារាងអត្រាមរណៈរបស់ប្រទេសថៃឆ្នាំ២០១៧ គឺជាតារាងដែលមានការប៉ាន់ស្មានចុងក្រោយគេបំផុតនៃមរណភាពរបស់ប្រជាជនទូទៅនៅក្នុងប្រទេសថៃ ហើយអត្រានេះស្ថិតនៅដដែល គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩។

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩**

## ១៨. ភាតព្វកិច្ចការទូទាត់ប្រាក់បំណាច់អតីតភាពការងារ

ក.ស.ស បានធ្វើការវាយតម្លៃអំពីផលប៉ះពាល់ក្នុងឆ្នាំកន្លងមកនៃកាតព្វកិច្ចការទូទាត់ប្រាក់បំណាច់អតីតភាពការងារ និងបានប៉ាន់ស្មានទឹកប្រាក់បំណុលចំនួន ២.៦៨៦.២០៦ ពាន់រៀល ហើយបានទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

| | ២០១៩<br>ពាន់រៀល | ២០១៨<br>ពាន់រៀល |
|---|---|---|
| រយៈពេលខ្លី | ១.៥៨៩.៥០៥ | ៣៦៧.៩៥៣ |
| រយៈពេលវែង | ១.០៩៦.៧០១ | ១.៤៧១.៧៦៨ |
| | ២.៦៨៦.២០៦ | ១.៨៣៩.៧២១ |

ការសន្មតដែលបានប្រើប្រាស់ក្នុងការកំណត់ចំណាយចុងក្រោយ សម្រាប់កាតព្វកិច្ចការទូទាត់ប្រាក់បំណាច់អតីតភាពការងារ រួមមាន៖

| | ២០១៩ | ២០១៨ |
|---|---|---|
| អត្រាអប្បហារក្នុងមួយឆ្នាំ | ៦% | ៦% |
| អត្រាបម្រែបម្រួលក្នុងមួយឆ្នាំ | ០,៥% | ០,៥% |

## ១៩. ចំណូលពន្យារ

ក.ស.ស បានជួលផ្នែកខ្លះនៃដីរបស់ខ្លួនក្នុងតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ ក្រោមកិច្ចសន្យាភតិសន្យាប្រតិបត្តិ រយៈពេល៥០ឆ្នាំ និងបានជួលទីលានឃ្លាំងកំពង់ផែ ក្នុងរយៈពេល២ឆ្នាំ។ ចំណាយបង់មុនត្រូវបានកត់ត្រាក្នុងខ្ទង់គណនីទានក្នុងរបាយការណ៍ចំណេញ-ខាត តាមមូលដ្ឋានថេរលើរយៈពេលនៃភតិសន្យា។

| | ២០១៩<br>ពាន់រៀល | ២០១៨<br>ពាន់រៀល |
|---|---|---|
| រយៈពេលខ្លី | ១៣៤.៤៧៥ | ២៥១.៥២៧ |
| រយៈពេលវែង | ៥.៥៨០.៧១៣ | ៥.៦៣៥.២៤៥ |
| | ៥.៧១៥.១៨៨ | ៥.៨៨៦.៧៧២ |

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩**

## ១៩. ចំណូលពន្យារ (ត)

បម្រែបម្រួលចំណូលពន្យារក្នុងឆ្នាំ មានដូចខាងក្រោម៖

| | ២០១៩<br>ពាន់រៀល | ២០១៨<br>ពាន់រៀល |
|---|---|---|
| សមតុល្យដើមគ្រា | ៥.៨៨៦.៧៧២ | ៥.៩២៨.៣៣៥ |
| បន្ថែម | ២៣២.៦៨៨ | ៧៥១.៩៣៥ |
| កត់ត្រាក្នុងខ្លង់តណនាទានក្នុងចំណេញ-ខាត | (៤៨៨.១៨៥) | (៧៦៩.៦៩២) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | ៨៣.៩១៣ | (២៣.៨០៦) |
| សមតុល្យចុងគ្រា | ៥.៧១៥.១៨៨ | ៥.៨៨៦.៧៧២ |

## ២០. គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីអ្នកផ្គត់ផ្គង់ផ្សេងៗ

| | ២០១៩<br>ពាន់រៀល | ២០១៨<br>ពាន់រៀល |
|---|---|---|
| រយៈពេលខ្លី | | |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម | ៥.៩២៦.១៤២ | ៣.៣៧៨.១២៣ |
| ប្រាក់រង្វាន់បង្គរ | ១១.១១៦.៩២៦ | ១០.១៤៣.៨៣៣ |
| ប្រាក់កក់របស់អតិថិជន | ១.៧២៧.០០៩ | ១.២៦០.៥៣៧ |
| អាករលើតម្លៃបន្ថែមត្រូវបង់ | ១.០៤៥.៣១៧ | ១.៨៦៥.៧៥៥ |
| ពន្ធលើប្រាក់បៀវត្សរ៍ត្រូវបង់ | ៣៨២.១៣៦ | ៣៨១.៤៨៨ |
| បង្គរការចូលបរិច្ចាគក្នុងមូលនិធិសង្គម | ៤.១០១.១៥៤ | ២.៩៩០.៣១២ |
| បំណុលផ្សេងៗ | ៦០២.៥៤៨ | ៩២១.៨៥៦ |
| | ២៤.៩០១.២៣២ | ២០.៩៤១.៩០៤ |

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩**

## ២១. ចំណូល

| | ២០១៩<br>ពាន់រៀល | ២០១៨<br>ពាន់រៀល |
|---|---|---|
| ចំណូលបានពីការលើកដាក់ទំនិញពីនាវា/ចូលនាវា | ១៥១.១៥៣.៧១៧ | ១២៧.០៨៧.៥៣៨ |
| ចំណូលបានពីការលើកដាក់ទំនិញពីយានយន្ត/ចូលយានយន្ត | ៩០.៨៧៧.០៧៦ | ៧៥.១៣៨.៩៧៨ |
| ចំណូលបានពីសេវាប្រកចេញចូលកំពង់ផែ | ៦៥.៧១៩.៤៥២ | ៥៧.៦៩៤.០៣៤ |
| ចំណូលពីការរក្សាទុកកុងតឺន័រ | ២១.២៤៨.១២២ | ១០.១៩១.១០២ |
| ចំណូលបានមកពីការជួលតំបន់សេដ្ឋកិច្ចពិសេស | ២.៧៥១.៤៩៤ | ៣.០១៦.៣៦៥ |
| ចំណូលផ្សេងៗ | ២.១៦៣.៥១៦ | ២.៤៥៧.៦២៨ |
| | ៣៣៣.៩១៣.៣៧៧ | ២៧៥.៥៨៥.៦៤៥ |
| ពេលវេលានៃការទទួលស្គាល់ចំណូល | | |
| ទទួលស្គាល់នៅពេលតែមួយ | ៣០៩.៩១៣.៧៦១ | ២៦១.៦១៦.៥០១ |
| ទទួលស្គាល់តាមដំណាក់កាល | ២៣.៩៩៩.៦១៦ | ១៣.៩៥៩.១៤៤ |
| | ៣៣៣.៩១៣.៣៧៧ | ២៧៥.៥៧៥.៦៤៥ |

## ២២. ចំណាយសម្ភារប្រើប្រាស់

| | ២០១៩<br>ពាន់រៀល | ២០១៨<br>ពាន់រៀល |
|---|---|---|
| ចំណាយលើសម្ភារងាយឆេះ | ៤៤.១៦៥.៤២៧ | ៤១.៤៩៣.៧៧៤ |
| គ្រឿងបន្លាស់ | ៣៥.៧៥៩.៨២៩ | ២០.៧២២.៣៧៩ |
| សម្ភារឃ្លាំង | ៦.៦៥៧.០១៥ | ៧.៧០០.៧០៤ |
| ប្រេងឥន្ធនៈ និងប្រេងម៉ាស៊ីន | ៤.០៥៩.១៥៩ | ៣.១៦៦.១១៥ |
| សម្ភារផ្គត់ផ្គង់ការិយាល័យ | ២.៦៩១.៦៩១ | ២.២៦៣.១២៩ |
| សម្ភារប្រើប្រាស់ផ្សេងៗ | ១.៨៩៨.៦២០ | ៨៤៦.៧៤២ |
| | ៩៥.២៣១.៧៤១ | ៧៦.១៩២.៨៤៣ |

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩**

## ២៣. ចំណាយប្រាក់បៀវត្សរ៍ ប្រាក់ឈ្នួល និងចំណាយពាក់ព័ន្ធ

| | ២០១៩<br>ពាន់រៀល | ២០១៨<br>ពាន់រៀល<br>(បានរាយការណ៍ឡើងវិញ) |
|---|---|---|
| ប្រាក់បៀវត្សរ៍បុគ្គលិក | ៦១.៤០៣.៧០០ | ៥២.៤០១.១៧៥ |
| ប្រាក់រង្វាន់ | ១១.១១៦.៩២៦ | ១០.១៤៣.៨៣៣ |
| បង្គរការទូទាត់ប្រាក់បំណាច់អតីតភាពការងារ | ២.២៤៩.៤៣៣ | ១.៨៣៩.៧២១ |
| ចំណាយអត្ថប្រយោជន៍សោធននិវត្តន៍ (កំណត់សម្គាល់ ១៧) | ៥.៨៩២.០០០ | ៥.១៤១.០០០ |
| លាភការរបស់ក្រុមប្រឹក្សាភិបាល | ១.២២៤.០០០ | ១.៣១០.៤០០ |
| ចំណាយសន្តិសុខសង្គមផ្សេងៗ | ៧៦០.៨០៣ | ៥៧០.៦៨៦ |
| ប្រាក់ឈ្នួលសម្រាប់អ្នកម៉ៅការ | ២៨៤.១០០ | ២១៦.១០០ |
| ចំណាយផ្សេងៗពាក់ព័ន្ធនឹងបុគ្គលិក | ៥.១៩៧.០៣៩ | ៣.៩៤០.៤០៣ |
| | ៨៨.១២៨.០០១ | ៧៩.៥៦៣.៣១៨ |

## ២៤. ចំណាយរំលស់ទ្រព្យសម្បត្តិ និងបរិក្ខារ និងរំលស់ទ្រព្យសកម្មអរូបី

| | ២០១៩<br>ពាន់រៀល | ២០១៨<br>ពាន់រៀល |
|---|---|---|
| ទ្រព្យសម្បត្តិ និងបរិក្ខារ (កំណត់សម្គាល់ ៦) | ២៣.៦៥១.៣៨៩ | ២១.១០៧.៨៩៩ |
| ទ្រព្យសម្បត្តិវិនិយោគ (កំណត់សម្គាល់ ៧) | ៦.១៩៦.០១៤ | ៦.១០៤.៩៦១ |
| ទ្រព្យសកម្មអរូបី (កំណត់សម្គាល់ ៨) | ១.០៦២.៨៧១ | ១.០៦២.៨៧១ |
| | ៣០.៩១០.២៧៤ | ២៨.២៧៥.៧៣១ |

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩**

## ២៥. ចំណាយផ្សេងៗ

| | ២០១៩<br>ពាន់រៀល | ២០១៨<br>ពាន់រៀល |
|---|---|---|
| វិភាគទាន និងការធ្វើអំណោយ | ៩.០៦៨.៩៣៦ | ៩.៤៩០.៦១៨ |
| ការទទួលភ្ញៀវ និងបដិសណ្ឋារកិច្ច | ៤.៥១៣.២៦២ | ៣.៦៣០.០៩៩ |
| ចំណាយប្រតិបត្តិការតំបន់សេដ្ឋកិច្ចពិសេស | ២.៧៧៧.៨៤៧ | ៣.៤១៣.៣២៩ |
| ចំណាយរដ្ឋបាល | ២.៤៤៨.៣០៩ | ២.៤៤៨.២១៧ |
| ការបណ្ដុះបណ្ដាល និងសិក្ខាសាលា | ១.៥៦០.៥០២ | ១.១៧៣.៤០៧ |
| បេសកកម្ម | ១.៥៣៦.៥២៣ | ១.៦៧៩.០០៨ |
| សាធារណៈ | ១.០៨៦.៩៩២ | ៨៥១.៧៨៣ |
| ការខាតបង់ឥណទានរំពឹងទុក | ៨៧៧.២១៦ | ៣៣៥.៧៥២ |
| កម្រៃសេវាវិជ្ជាជីវៈ និងចំណាយពាក់ព័ន្ធ | ៧០១.៧៦៨ | ៥៦៣.៤៧៧ |
| សេវាប្រៃសណីយ៍ | ៤៤៤.៣៤៦ | ៦៣៦.៨៣៩ |
| ទឹកភ្លើង | ១៩៩.៤៩១ | ២០៤.៩៨៤ |
| សម្ភារថែទាំសុខភាព | ១៧៦.៦២៦ | ១៧២.៥៤២ |
| ការជួលឧបករណ៍ | ១០៤.០៦០ | ១០៥.៧៥៨ |
| ពន្ធផ្សេងៗ | ៨៤.៩៣៣ | ៩០.៥៨២ |
| ចំណាយផ្សេងៗ | ៥៣៣.៤៣១ | ១៦៨.៥៣៧ |
| | ២៦.១១៤.២៤២ | ២៤.៩៦៤.៩៣២ |

## ២៦. ខាតផ្សេងៗ - សុទ្ធ

| | ២០១៩<br>ពាន់រៀល | ២០១៨<br>ពាន់រៀល |
|---|---|---|
| ខាតពីការប្ដូររូបិយប័ណ្ណ-សុទ្ធ | (៤.១២៦.៩៧៧) | (៤២៧.៨១១) |
| ចំណេញពីការលក់ទ្រព្យសកម្មរយៈពេលវែង | ៦៩.២៨៤ | - |
| | (៤.០៥៧.៦៩៣) | (៤២៧.៨១១) |

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩**

## ២៧. ចំណាយហិរញ្ញវត្ថុ - សុទ្ធ

| | ២០១៩<br>ពាន់រៀល | ២០១៨<br>ពាន់រៀល |
|---|---|---|
| ចំណូលហិរញ្ញវត្ថុ៖ | | |
| ចំណូលការប្រាក់ពីប្រាក់បញ្ញើនៅធនាគារ (ក) | ៣.៤៩២.៨៤២ | ២.៧៦៣.៣៦៥ |
| ចំណូលការប្រាក់ពីការកត់ត្រាអប្បហារតណទានផ្តល់ឱ្យបុគ្គលិកត្រលប់មកវិញ | ៦៨២.៧៤៤ | ៩៤៨.៣០១ |
| | ៤.១៧៥.៥៨៦ | ៣.៧១១.៦៦៦ |
| ចំណាយហិរញ្ញវត្ថុ ៖ | | |
| ចំណាយការប្រាក់លើប្រាក់កម្ចី (ខ) | (១២.១៥០.៥៤៧) | (១០.៧៩៩.១៧៣) |
| ខាតពីការប្តូររូបិយវត្ថុរបស់ប្រាក់កម្ចី (គ) | (៧.៧១៨.៥៧៧) | (៧.៥០៥.៧៧៥) |
| ចំណាយការប្រាក់ពីការបូកបន្ថែមភាគលាភធានាត្រូវបង់ | (៤៩១.១៦៨) | (៨១២.៥៤៤) |
| | (២០.៣៦០.២៩២) | (១៩.១១៧.៤៩២) |
| ចំណាយហិរញ្ញវត្ថុ - សុទ្ធ | (១៦.១៨៤.៧០៦) | (១៥.៤០៥.៨២៦) |

(ក) ចំណូលការប្រាក់គឺជាចំណូលពីគណនីប្រាក់បញ្ញើសន្សំ និងប្រាក់បញ្ញើមានកាលកំណត់ ដែលផ្ញើនៅធនាគារក្នុងស្រុកក្នុងឆ្នាំ។

(ខ) ចំណាយការប្រាក់គឺជាការប្រាក់លើប្រាក់កម្ចី ដែលទទួលបានពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈប្រាក់កម្ចីដែលទទួលបានពី JICA និង JBIC។

(គ) ក.ស.ស មានប្រាក់កម្ចីជាប្រាក់យ៉េនជប៉ុន និងជាប្រាក់ដុល្លារអាមេរិក (កំណត់សម្គាល់១៦)។ ក.ស.ស ក៏មានប្រាក់បញ្ញើរយៈពេលខ្លីនៅធនាគារ ដែលទទួលបានជាប្រាក់ដុល្លារអាមេរិក។ ដោយសារតែការប្រែប្រួលប្រាក់រៀលធៀបនឹងប្រាក់យ៉េនជប៉ុន និងប្រាក់ដុល្លារអាមេរិក វាបណ្តាលឱ្យមានការចំណេញ/ខាតពីការប្តូររូបិយប័ណ្ណជាសារវន្តលើប្រាក់កម្ចី និងប្រាក់បញ្ញើរយៈពេលខ្លីនៅធនាគារ។ អត្រាប្តូររូបិយប័ណ្ណ គឺយោងទៅតាមអត្រាប្តូរប្រាក់ដែលត្រូវបានផ្សព្វផ្សាយដោយធនាគារជាតិ នៃ កម្ពុជា នាដំណាច់ឆ្នាំរាយការណ៍ មានដូចខាងក្រោម៖

| | ២០១៩ | ២០១៨ | ២០១៧ |
|---|---|---|---|
| ប្រាក់យ៉េន/ប្រាក់រៀល | ៣៧,៦២ | ៣៦,៥៩ | ៣៥,៩២ |
| ប្រាក់ដុល្លារអាមេរិក/ប្រាក់រៀល | ៤.០៧៥ | ៤.០១៨ | ៤.០៣៧ |

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

### ២៨. ចំណាយពន្ធលើប្រាក់ចំណូល
### (ក) ចំណាយពន្ធលើប្រាក់ចំណូល

| | ២០១៩<br>ពាន់រៀល | ២០១៨<br>ពាន់រៀល<br>(បានរាយការណ៍ឡើងវិញ) |
|---|---|---|
| ពន្ធលើប្រាក់ចំណូលក្នុងឆ្នាំ | ៨.៦២៤.៣៣៦ | ៦.៩៩៩.៣៣១ |
| ពន្ធពន្យារ | ១៣.០៩៧.៥៩២ | (៣.៤៦២.៣១៦) |
| ចំណាយពន្ធលើប្រាក់ចំណូល | ២១.៧២១.៩២៨ | ៣.៥៣៧.០១៥ |

នៅក្នុងចំណាយពន្ធពន្យារខាងលើ គឺមានពន្ធពន្យារទ្រព្យសកម្ម ដែលមកពីខាតជាប់ពន្ធបង្គរលើតំបន់សេដ្ឋកិច្ចពិសេស មានទឹកប្រាក់ចំនួន ៧.០៩៧.៦៧៧ ពាន់រៀល ត្រូវបានជម្រះចេញពីបញ្ជីទាំងស្រុងក្នុងឆ្នាំ ដោយសារមានភាពមិនច្បាស់លាស់នៃប្រាក់ចំណេញជាប់ពន្ធនាពេលអនាគត ដែល ក.ស.ស រំពឹងថានឹងប្រើប្រាស់ដើម្បីកាត់កងឱ្យអស់មុនពេលផុតកំណត់ (កំណត់សម្គាល់ ២៨ (គ) (១))។

### (ខ) ការផ្ទៀងផ្ទាត់ពន្ធលើប្រាក់ចំណេញ និងចំណេញគណនេយ្យ

| | ២០១៩<br>ពាន់រៀល | ២០១៨<br>ពាន់រៀល<br>(បានរាយការណ៍ឡើងវិញ) |
|---|---|---|
| ចំណេញគណនេយ្យមុនបង់ពន្ធលើប្រាក់ចំណេញ | ៦៥.១៨៥.៤២៨ | ៤៨.៧០២.៧៨៧ |
| ចំណាយពន្ធលើប្រាក់ចំណូល (*) | ៦.៥១៨.៥៤៣ | ៤.៨៧០.២៧៩ |
| ផលប៉ះពាល់ពន្ធនៃចំណាយមិនអាចកាត់កង | ២.១០៥.៧៩៣ | ២.១២៩.០៥២ |
| | ៨.៦២៤.៣៣៦ | ៦.៩៩៩.៣៣១ |
| ពន្ធលើប្រាក់ចំណូលក្នុងឆ្នាំ | ៨.៦២៤.៣៣៦ | ៦.៩៩៩.៣៣១ |

(*) យោងតាមច្បាប់សារពើពន្ធកម្ពុជា ក.ស.ស ត្រូវបង់ពន្ធលើប្រាក់ចំណូលក្នុងអត្រា ២០%។ អនុលោមតាមអនុក្រឹតលេខ ០១ អនក្រ.តត ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៥ អង្គភាពដែលបានចុះបញ្ជីក្នុងទីផ្សារភាគហ៊ុនកម្ពុជា ត្រូវបានទទួលការលើកទឹកចិត្តពន្ធចំនួនបីឆ្នាំ ដែលផ្តល់ដោយគណៈកម្មការមូលបត្រកម្ពុជា។ នៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ អគ្គនាយកដ្ឋានពន្ធដារ បានអនុម័តលើការលើកទឹកចិត្តផ្នែកពន្ធដារនេះ ដោយបានបន្ថយ ៥០% នៃអត្រាពន្ធលើប្រាក់ចំណូល (២០%) ដូចនេះ ក.ស.ស ត្រូវបង់ពន្ធលើប្រាក់ចំណូលតែ ១០% ប៉ុណ្ណោះ សម្រាប់ឆ្នាំ២០១៧ ដល់ឆ្នាំ ២០១៩។

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

### ២៨. ចំណាយពន្ធលើប្រាក់ចំណូល (ត)

### (គ) សមតុល្យពន្ធពន្យារ

| | ២០១៩<br>ពាន់រៀល | ២០១៨<br>ពាន់រៀល<br>(បានរាយការណ៍ឡើងវិញ) |
|---|---|---|
| ពន្ធពន្យារទ្រព្យសកម្ម | ២០.៩២២.៣៣០ | ២៦.៨៦៥.០០៣ |
| បំណុលពន្ធពន្យារ | (៣៦.៧០៧.០០៦) | (២៩.៥៥២.០៨៧) |
| បំណុលពន្ធពន្យារ-សុទ្ធ | (១៥.៧៨៤.៦៧៦) | (២.៦៨៧.០៨៤) |

បម្រែបម្រួលសមតុល្យពន្ធពន្យារ៖

| | ២០១៩<br>ពាន់រៀល | ២០១៨<br>ពាន់រៀល<br>(បានរាយការណ៍ឡើងវិញ) |
|---|---|---|
| នៅថ្ងៃទី០១ ខែមករា | (២.៦៨៧.០៨៤) | (៦.១៩៩.៤០០) |
| (ជាបន្ទុក)/ឥណទានក្នុងចំណេញ-ខាត | (១៣.០៩៧.៥៩២) | ៣.៥១២.៣១៦ |
| នៅថ្ងៃទី៣១ ខែធ្នូ | (១៥.៧៨៤.៦៧៦) | (២.៦៨៧.០៨៤) |

(១) ពន្ធពន្យារទ្រព្យសកម្ម

| | ភាតព្វកិច្ចអត្ថប្រយោជន៍សោធននិវត្តន៍<br>ពាន់រៀល | ភាតព្វកិច្ចការទូទាត់ប្រាក់បំណាច់អតីតភាពការងារ<br>ពាន់រៀល | បង្គរប្រាក់ខ្វាន់<br>ពាន់រៀល | សំវិធានធន<br>ពាន់រៀល | ចំណូលពន្យារ<br>ពាន់រៀល | ខាតដាច់ពន្ធយោងមកពីតំបន់សេដ្ឋកិច្ចពិសេស<br>ពាន់រៀល | សរុប<br>ពាន់រៀល |
|---|---|---|---|---|---|---|---|
| **នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ (បានរាយការណ៍ឡើងវិញ)** | ៩.៦៦៩.៤៥១ | ១.៧១៨.១៤៤ | ១៤៨.៥៩៩ | ១.១៨៥.៦៦៧ | - | ៥.៣១៨.៦១៩ | ១៨.០៤០.៤៨០ |
| កត់ត្រាជាឥណទាន/(បន្ទុក)ក្នុងចំណេញ-ខាត | ៦.២៣៨.១៤៤ | ៣១០.៦២៣ | ១៣៧.០៦៧ | (៨.៣១៣) | ៣៦៧.៩៤៤ | ១.៧៧៩.០៥៨ | ៨.៨២៤.៥២៣ |
| **នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ (បានរាយការណ៍ឡើងវិញ)** | ១៥.៩០៧.៥៩៥ | ២.០២៨.៧៦៧ | ២៨៥.៦៦៦ | ១.១៧៧.៣៥៤ | ៣៦៧.៩៤៤ | ៧.០៩៧.៦៧៧ | ២៦.៨៦៥.០០៣ |
| **នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩** | ១៥.៩០៧.៥៩៥ | ២.០២៨.៧៦៧ | ២៨៥.៦៦៦ | ១.១៧៧.៣៥៤ | ៣៦៧.៩៤៤ | ៧.០៩៧.៦៧៧ | ២៦.៨៦៥.០០៣ |
| កត់ត្រាជាឥណទាន/(បន្ទុក)ក្នុងចំណេញ-ខាត | ៧០៧.២១៨ | ១៩៤.៦១៨ | ១១៨.១៨៧ | (៣៤.៣១៦) | ១៦៩.២៩៧ | (៧.០៩៧.៦៧៧) | (៥.៩៤២.៦៧៣) |
| **នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩** | ១៦.៦១៤.៨១៣ | ២.២២៣.៣៨៥ | ៤០៣.៨៥៣ | ១.១៤៣.០៣៨ | ៥៣៧.២៤១ | - | ២០.៩២២.៣៣០ |

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩**

**២៨. ចំណាយពន្ធលើប្រាក់ចំណូល (ត)**

**(គ) សមតុល្យពន្ធពន្យារ (ត)**

(២) បំណុលពន្ធពន្យារ

| | **រៀលស់ពន្លឿនពន្ធ ពាន់រៀល** |
|---|---|
| **នៅថ្ងៃទី១ ខែមករា ឆ្នាំ២០១៨** | (២៤.១៨៩.៨៨០) |
| កត់ត្រាជាបន្ទុកក្នុងចំណេញ-ខាត | (៥.៣៦២.២០៧) |
| **នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨** | (២៩.៥៥២.០៨៧) |
| | |
| **នៅថ្ងៃទី១ ខែមករា ឆ្នាំ២០១៩** | (២៩.៥៥២.០៨៧) |
| កត់ត្រាជាបន្ទុកក្នុងចំណេញ-ខាត | (៧.១៥៤.៩១៩) |
| **នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩** | (៣៦.៧០៧.០០៦) |

**(ឃ) បញ្ហាពន្ធផ្សេងៗ**

ពន្ធត្រូវបានគណនាតាមមូលដ្ឋានបំណកស្រាយពន្ធបច្ចុប្បន្ននៃបទប្បញ្ញត្តិពន្ធដារ ដែលបានអនុម័តរួចជាស្ថាពរ នាកាលបរិច្ឆេទរបាយការណ៍។ គណៈគ្រប់គ្រងវាយតម្លៃអំពីស្ថានភាពដែលបានប្រកាសពន្ធ ជាមួយនឹងស្ថានភាពនៃបទប្បញ្ញត្តិពន្ធដារ។ ក្រុមហ៊ុនកត់ត្រាសំវិធានធនទៅតាមភាពសមស្រប អាស្រ័យទៅតាមមូលដ្ឋាននៃចំនួនប្រាក់ពន្ធ ដែលក្រុមហ៊ុនរំពឹងថាត្រូវបង់ជូនអាជ្ញាធរពន្ធដារ។

ទោះបីជាយ៉ាងណាក៏ដោយ បទប្បញ្ញត្តិពន្ធទាំងនេះមានការប្រែប្រួលពីមួយគ្រាទៅមួយគ្រា ហើយការកំណត់ចុងក្រោយលើចំនួនបំណុលពន្ធ នឹងធ្វើឡើងបន្ទាប់ពីមានការត្រួតពិនិត្យរបស់អាជ្ញាធរពន្ធដារ។ នៅពេលដែលលទ្ធផលពន្ធចុងក្រោយមានភាពខុសគ្នាពីការកត់ត្រាដំបូង ភាពខុសគ្នានេះនឹងធ្វើឱ្យប៉ះពាល់ដល់ចំនួនបំណុលពន្ធ និងសមតុល្យទឹកប្រាក់ ក្នុងការិយបរិច្ឆេទដែលការកំណត់ពន្ធនោះត្រូវបានធ្វើឡើង។

របាយការណ៍សនវកម្មពន្ធពេញលេញចុងក្រោយ បានចេញផ្សាយដោយអគ្គនាយកដ្ឋានពន្ធដារ គឺសម្រាប់ដំណាច់ឆ្នាំឆ្នាំ២០១៥ ហើយរាល់បំណុលពន្ធទាំងអស់ ត្រូវបានទូទាត់រួចរាល់ក្នុងឆ្នាំ២០១៧។

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩**

## ២៩. ចំណេញក្នុងមួយភាគហ៊ុន

### (ក) ចំណេញក្នុងមួយភាគហ៊ុនជាមូលដ្ឋាន (basic earnings per share)

ចំណេញក្នុងមួយភាគហ៊ុនជាមូលដ្ឋាន ត្រូវបានគណនាដោយយកប្រាក់ចំណេញរបស់ម្ចាស់ភាគហ៊ុនរបស់ ក.ស.ស ចែកនឹងចំនួនភាគហ៊ុនធម្មតាមធ្យមដែលបានបោះផ្សាយក្នុងឆ្នាំ។

| | ២០១៩ | ២០១៨ |
|---|---|---|
| | | (បានរាយការណ៍ឡើងវិញ) |
| ប្រាក់ចំណេញរបស់ភាគហ៊ុនិក (ពាន់រៀល) | ៤៣.៤៦៣.៥០០ | ៤៥.១៦៥.៧៧២ |
| ចំនួនភាគហ៊ុនមធ្យម | ៨៥.៧៧១.៩៦៧ | ៨៥.៧៧១.៩៦៧ |
| ចំណេញក្នុងមួយភាគហ៊ុនជាមូលដ្ឋាន (រៀល) | ៥០៦,៧៣ | ៥២៦,៥៨ |

### (ខ) ចំណេញក្នុងមួយភាគហ៊ុនថយចុះ (diluted earnings per share)

ចំណេញក្នុងមួយភាគហ៊ុនថយចុះ ត្រូវបានគណនាដោយកែប្រែចំនួនមធ្យមនៃភាគហ៊ុនធម្មតាដែលមាន ដោយសន្មតថាមានការផ្ទេរភាគហ៊ុនដែលមានសក្តានុពលទាំងអស់ទៅជាភាគហ៊ុនធម្មតា។ ក.ស.ស មិនមានភាគហ៊ុនដែលមានសក្តានុពលអាចផ្ទេរទៅជាភាគហ៊ុនធម្មតានោះទេ នាដំណាច់ឆ្នាំនេះ។ ដូចនេះ ចំណេញក្នុងមួយភាគហ៊ុនថយចុះ គឺមានតម្លៃស្មើនឹងចំណេញក្នុងមួយភាគហ៊ុនជាមូលដ្ឋាន។

## ៣០. សាច់ប្រាក់បានពីប្រតិបត្តិការ

| | កំណត់សម្គាល់ | ២០១៩ ពាន់រៀល | ២០១៨ ពាន់រៀល |
|---|---|---|---|
| | | | (បានរាយការណ៍ឡើងវិញ) |
| ចំណេញមុនបង់ពន្ធ | | ៦៥.១៨៥.៤២៨ | ៤៨.៧០២.៧៨៧ |
| *និយ័តកម្ម៖* | | | |
| រំលស់ទ្រព្យសម្បត្តិ និងបរិក្ខារ និងរំលស់ទ្រព្យសកម្មអរូបី | ២៤ | ៣០.៩១០.២៧៤ | ២៨.២៧៥.៧៣១ |
| ចំណេញពីការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ | | (៦៩.២៨៤) | - |
| ចំណាយហិរញ្ញវត្ថុ - សុទ្ធ | ២៧ | ១៦.១៨៤.៧០៦ | ១៥.៤០៥.៨២៦ |
| ចំណាយកាតព្វកិច្ចអត្ថប្រយោជន៍សោធននិវត្តន៍ | | ៥.៨៩២.០០០ | ៥.១៤១.០០០ |
| កាតព្វកិច្ចការទូទាត់ប្រាក់បំណាច់អតីតភាពការងារ | | ៨៤៦.៤៨៥ | ១.៨៣៩.៧២១ |
| ចំណាយបុគ្គលិកផ្សេងៗ ពាក់ព័ន្ធនឹងឥណទានផ្តល់ឱ្យបុគ្គលិក | | ៦៥៥.៤៥៦ | ៦៥៥.៤៥៦ |
| *បម្រែបម្រួលដើមទុនបង្វិល៖* | | | |
| សន្និធិ | | (៧.១៩៦.៦៣៧) | (២.៨៧៩.០៥២) |
| គណនីអតិថិជនពាណិជ្ជកម្ម និងគណនីអតិថិជនផ្សេងៗ | | (១១.៦៦២.៣៩២) | (២.៧៨០.១៣២) |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីអ្នកផ្គត់ផ្គង់ផ្សេងៗ | | ២.៧០៣.៩២៥ | (១៤.៩៨០.០៣៣) |
| កាតព្វកិច្ចអត្ថប្រយោជន៍សោធនិវត្តន៍ | | (៣.០១៦.៩១៥) | (៣.១០៧.២៧៩) |
| ចំណូលពន្យារ | | (១៧១.៥៨៤) | (៤១.៥៦៣) |
| សាច់ប្រាក់បានពីប្រតិបត្តិការ | | ១០០.២៦១.៤៦២ | ៧៦.២៣២.៤៦២ |

## ៣០. សាច់ប្រាក់បានពីប្រតិបត្តិការ (ត)

ផ្នែកនេះបង្ហាញពីការវិភាគបំណុលសុទ្ធ និងបម្រែបម្រួលបំណុលសុទ្ធ ក្នុងឆ្នាំនីមួយៗដែលបានបង្ហាញ។

| | **២០១៩ ពាន់រៀល** | **២០១៨ ពាន់រៀល** |
|---|---|---|
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | ២៧.៧៨៩.៥៩៧ | ៦២.១៩១.៥២៥ |
| ប្រាក់បញ្ញើនៅធនាគាររយៈពេលខ្លី | ១២៩.៦១៥.៦១៨ | ៧៤.៨៧៣.២៣៩ |
| ប្រាក់កម្ចី | (៥៤៣.៧០៤.២២៤) | (៥៥០.៦២១.២២៩) |
| បំណុលសុទ្ធ | (៣៨៦.២៩៩.០០៩) | (៤១៣.៥៥៦.៤៦៥) |
| | | |
| សាច់ប្រាក់ និងប្រាក់បញ្ញើនៅធនាគាររយៈពេលខ្លី | ១៥៧.៤០៥.២១៥ | ១៣៧.០៦៤.៧៦៤ |
| បំណុលដុល – អត្រាការប្រាក់ថេរ | (៥៤៣.៧០៤.២២៤) | (៥៥០.៦២១.២២៩) |
| បំណុលសុទ្ធ | (៣៨៦.២៩៩.០០៩) | (៤១៣.៥៥៦.៤៦៥) |

| | **ទ្រព្យសកម្មផ្សេងៗ** | | **បំណុលពីសកម្មភាពហិរញ្ញប្បទាន** | |
|---|---|---|---|---|
| | **សាច់ប្រាក់ និង សាច់ប្រាក់ សមមូល ពាន់រៀល** | **ប្រាក់បញ្ញើ នៅធនាគារ រយៈពេលខ្លី ពាន់រៀល** | **ប្រាក់កម្ចី ពាន់រៀល** | **សរុប ពាន់រៀល** |
| **បំណុលសុទ្ធនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨** | ៥១.០៨១.២២៩ | ៧៣.១៩៤.២០១ | (៥២៥.២៣៤.៨៨២) | (៤០០.៩៥៩.៤៥២) |
| លំហូរសាច់ប្រាក់ | ១១.១១០.២៩៦ | ១.៦៧៩.០៣៨ | (១៨.១១៦.៧២០) | (៥.៣២៧.៣៨៦) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | (៧.៥០៥.៧៧៥) | (៧.៥០៥.៧៧៥) |
| បម្រែបម្រួលមិនមែនសាច់ប្រាក់ផ្សេងៗ | - | - | ២៣៦.១៤៨ | ២៣៦.១៤៨ |
| **បំណុលសុទ្ធនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨** | ៦២.១៩១.៥២៥ | ៧៤.៨៧៣.២៣៩ | (៥៥០.៦២១.២២៩) | (៤១៣.៥៥៦.៤៦៥) |
| | | | | |
| **បំណុលសុទ្ធនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩** | ៦២.១៩១.៥២៥ | ៧៤.៨៧៣.២៣៩ | (៥៥០.៦២១.២២៩) | (៤១៣.៥៥៦.៤៦៥) |
| លំហូរសាច់ប្រាក់ | (៣៤.៤០១.៩២៨) | ៥៤.៧៤២.៣៧៩ | ១៧.៣៩៣.៣៦៥ | ៣៧.៧៣៣.៨១៦ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | (៧.៧១៨.៥៨៧) | (៧.៧១៨.៥៨៧) |
| បម្រែបម្រួលមិនមែនសាច់ប្រាក់ផ្សេងៗ | - | - | (២.៧៥៧.៧៧៣) | (២.៧៥៧.៧៧៣) |
| **បំណុលសុទ្ធនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩** | ២៧.៧៨៩.៥៩៧ | ១២៩.៦១៥.៦១៨ | (៥៤៣.៧០៤.២២៤) | (៣៨៦.២៩៩.០០៩) |

(*) បម្រែបម្រួលមិនមែនសាច់ប្រាក់ផ្សេងៗ រួមមាន ចំណាយបង្គរការប្រាក់ ដែលត្រូវបានបង្ហាញជាលំហូរសាច់ប្រាក់ប្រតិបត្តិការក្នុងរបាយការណ៍លំហូរសាច់ប្រាក់នៅពេលបានបង់។

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

### ៣១. ប្រតិបត្តិការភាគីពាក់ព័ន្ធ

ក.ស.ស ស្ថិតក្រោមការគ្រប់គ្រងផ្នែកហិរញ្ញវត្ថុដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងស្ថិតនៅក្រោមការគ្រប់គ្រងផ្នែកបច្ចេកទេសដោយក្រសួងសាធារណការ និងដឹកជញ្ជូន។ ប្រតិបត្តិការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង-សាធារណការ និងដឹកជញ្ជូន ត្រូវបានចាត់ទុកថាជាភាគីពាក់ព័ន្ធ។

### (ក) សមតុល្យភាគីពាក់ព័ន្ធ

(i) ទឹកប្រាក់ជំពាក់ទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

| | ២០១៩<br>ពាន់រៀល | ២០១៨<br>ពាន់រៀល |
|---|---|---|
| ប្រាក់កម្ចីពី៖ | | |
| MoEF – (JICA) | ២២៤.៤០៧.២១៣ | ២១៩.៦៥០.២៤១ |
| MoEF – (JBIC) | ៣១៩.២៩៧.០១១ | ៣៣០.៩៧០.៩៨៨ |
| | ៥៤៣.៧០៤.២២៤ | ៥៥០.៦២១.២២៩ |

(ii) ទឹកប្រាក់ត្រូវទារពីក្រសួងសាធារណការ និងដឹកជញ្ជូន

| | ២០១៩<br>ពាន់រៀល | ២០១៨<br>ពាន់រៀល |
|---|---|---|
| បុរេប្រទានទៅឱ្យក្រសួងសាធារណការ និងដឹកជញ្ជូន | ១៤.២៨៧.៥៤៧ | ៩.៧៧១.៣០០ |

### (ខ) ប្រតិបត្តិការភាគីពាក់ព័ន្ធ

| | ២០១៩<br>ពាន់រៀល | ២០១៨<br>ពាន់រៀល |
|---|---|---|
| ចំណាយការប្រាក់លើប្រាក់កម្ចីពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (កំណត់សម្គាល់២៧ (ខ)) | (១២.១៥០.៥៤៧) | (១០.៧៩៩.១៧៣) |

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩**

### ៣១. ប្រតិបត្តិការភាគីពាក់ព័ន្ធ (ត)

### (គ) ការទូទាត់ជូនគណៈគ្រប់គ្រងសំខាន់ៗ

| | ២០១៩<br>ពាន់រៀល | ២០១៨<br>ពាន់រៀល |
|---|---|---|
| **ក្រុមប្រឹក្សាភិបាល** | | |
| កម្រៃ និងចំណាយពាក់ព័ន្ធផ្សេងៗ | ១.៤២៨.០០០ | ១.៣១០.៤០០ |
| **បុគ្គលិកថ្នាក់គ្រប់គ្រងសំខាន់ៗ** | | |
| ប្រាក់បៀវត្សរ៍ និងចំណាយផ្សេងៗ | ២.៤៧៦.៨១៨ | ២.២៣៧.៧៤៤ |
| ចំណាយអត្ថប្រយោជន៍សោធននិវត្តន៍ (*) | ២០១.៩៤៣ | ១៨៧.៩៩៦ |

បុគ្គលិកថ្នាក់គ្រប់គ្រងសំខាន់ៗ រួមមានអគ្គនាយក និងនាយកប្រតិបត្តិ ដែលជាអ្នកសម្រេចចិត្តជាយុទ្ធសាស្ត្រ លើការដឹកនាំ លើផ្នែកហិរញ្ញវត្ថុ និងប្រតិបត្តិការរបស់ ក.ស.ស ។

(*) គម្រោងអត្ថប្រយោជន៍សោធននិវត្តន៍ ត្រូវបានដាក់ឱ្យប្រតិបត្តិក្នុងអង្គភាពទាំងមូល ក្នុងនោះបុគ្គលិកថ្នាក់គ្រប់គ្រងសំខាន់ៗក៏មានសិទ្ធិទទួលគម្រោងអត្ថប្រយោជន៍នេះ ដូចគ្នានឹងបុគ្គលិក ក.ស.ស ដទៃទៀតដែរ។

### (ឃ) ឥណទានផ្តល់ឱ្យគណៈគ្រប់គ្រងសំខាន់ៗ

ក.ស.ស បានផ្តល់ឥណទានឱ្យបុគ្គលិក រួមទាំងគណៈគ្រប់គ្រងសំខាន់ៗ និងក្រុមប្រឹក្សាភិបាលផងដែរ ដើម្បីទិញភាគហ៊ុនប្រភេទ "គ" របស់ខ្លួន នៅពេលបោះផ្សាយលក់មូលបត្រសាធារណៈលើកដំបូង នៅថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៧។ ឥណទាននេះមិនមានការប្រាក់ និងមានរយៈពេលបួនឆ្នាំ។ ឥណទាននេះនឹងត្រូវទូទាត់សងតាមមូលដ្ឋានប្រចាំខែ ដោយកាត់កងពីប្រាក់បៀវត្សរ៍ប្រចាំខែរបស់គណៈគ្រប់គ្រងសំខាន់ៗ។ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ឥណទានផ្តល់ឱ្យគណៈគ្រប់គ្រងសំខាន់ៗដែលនៅមិនទាន់ទូទាត់មានទឹកប្រាក់ចំនួន ១.៤៦៣ លានរៀល (៣១ ធ្នូ ២០១៨ ៖ ២.៤៣៩ លានរៀល)។

### ៣២. កិច្ចសន្យា

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ក.ស.ស មានកិច្ចសន្យាទាក់ទិននឹងចំណាយដើមទុនដែលមិនទាន់ទូទាត់ចំនួន ៨៨០.១៣២ លានរៀល (៣១ ធ្នូ ២០១៨ ៖ ៥៣១លានរៀល) សម្រាប់ការទិញសេវាកម្មសាងសង់ ទ្រព្យសម្បត្តិ និងបរិក្ខារ។

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

### ៣៣. ការធ្វើនិយ័តកម្មលើអត្ថប្រយោជន៍បុគ្គលិក

អំឡុងឆ្នាំ២០១៩ គណៈគ្រប់គ្រងរបស់ ក.ស.ស បានពិនិត្យឡើងវិញនូវគម្រោងអត្ថប្រយោជន៍បុគ្គលិក ហើយបានសម្គាល់ឃើញថា កាតព្វកិច្ចលើប្រាក់បំណាច់លើកទឹកចិត្ត ដែលត្រូវបានអនុម័តក្នុងឆ្នាំ២០០៤ មិនត្រូវបានកត់ត្រាបញ្ចូលក្នុងកាតព្វកិច្ចអត្ថប្រយោជន៍បុគ្គលិកទេ (កំណត់សម្គាល់ ២.១៦.១. (ii))។ ក.ស.ស បានធ្វើនិយ័តកម្មត្រឡប់ថយក្រោយចំពោះតួលេខឆ្នាំមុន។ ផលប៉ះពាល់ខ្ទង់គណនីនៃរបាយការណ៍ហិរញ្ញវត្ថុ មានដូចខាងក្រោម៖

| | ៣១ ធ្នូ ២០១៨<br>ពាន់រៀល | និយ័តកម្ម<br>ពាន់រៀល | ៣១ ធ្នូ ២០១៨<br>ពាន់រៀល<br>*(បានរាយការណ៍ឡើងវិញ)* | ១ មករា ២០១៨<br>ពាន់រៀល | និយ័តកម្ម<br>ពាន់រៀល | ១ មករា ២០១៨<br>ពាន់រៀល<br>*(បានរាយការណ៍ឡើងវិញ)* |
|---|---|---|---|---|---|---|
| **របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេប (ដកស្រង់)** | | | | | | |
| ចំណេញរក្សាទុក | ១១៩.០១៥.៥២៥ | (៧.៦៧៩.២០០) | ១១១.៣៣៦.៣២៥ | ១១០.៩៥០.៥៧៧ | (៥.៨៧១.២០០) | ១០៥.០៧៩.៣៧៧ |
| **មូលធនសរុប** | ៦៥៧.១៨៩.៤៣៤ | (៧.៦៧៩.២០០) | ៦៤៩.៥១០.២៣៤ | ៦៤៦.៦១០.៥៥៤ | (៥.៨៧១.២០០) | ៦៤០.៧៣៩.៣៥៤ |
| កាតព្វកិច្ចអត្ថប្រយោជន៍សោធននិវត្តន៍ | ៦៦.៨៨១.៩៧៦ | ៩.៥៩៩.០០០ | ៧៦.៤៨០.៩៧៦ | ៣៨.០១២.៤៧៥ | ៧.៣៣៩.០០០ | ៤៥.៣៥១.៤៧៥ |
| បំណុលពន្ធពន្យារ | ៤.៦០៦.៨៨៤ | (១.៩១៩.៨០០) | ២.៦៨៧.០៨៤ | ៧.៦១៧.២០០ | (១.៤៦៧.៨០០) | ៦.១៤៩.៤០០ |
| **បំណុលរយៈពេលវែង** | ៦១២.២៧៦.១៣០ | ៧.៦៧៩.២០០ | ៦១៩.៩៥៥.៣៣០ | ៥៦៤.៣១៨.៣៥៥ | ៥.៨៧១.២០០ | ៥៧០.១៨៩.៥៥៥ |
| **បំណុលសរុប** | ៦៧១.០០១.០៥៤ | ៧.៦៧៩.២០០ | ៦៧៨.៦៨០.២៥៤ | ៦៣៣.៨៩៩.៤៨៤ | ៥.៨៧១.២០០ | ៦៣៩.៧៧០.៦៨៤ |
| **មូលធន និងបំណុលសរុប** | ១.៣២៨.១៩០.៤៨៨ | - | ១.៣២៨.១៩០.៤៨៨ | ១.២៨០.៥១០.០៣៨ | - | ១.២៨០.៥១០.០៣៨ |

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

### ៣៣. ការធ្វើនិយ័តកម្មលើអត្ថប្រយោជន៍បុគ្គលិក (ត)

| | ២០១៨<br>ពាន់រៀល | និយ័តកម្ម<br>ពាន់រៀល | ២០១៨<br>ពាន់រៀល<br>*(បានរាយការណ៍ឡើងវិញ)* |
|---|---|---|---|
| **របាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗសង្ខេប (ដកស្រង់)** | | | |
| ប្រាក់បៀវត្សរ៍ ប្រាក់ឈ្នួល និងចំណាយពាក់ព័ន្ធ | (៧៤.៧០៨.៣១៨) | (៨៥៥.០០០) | (៧៥.៥៦៣.៣១៨) |
| **ចំណាយ** | (២១០.៦១២.០៣២) | (៨៥៥.០០០) | (២១១.៤៦៧.០៣២) |
| **ចំណេញប្រតិបត្តិការ** | ៦៤.៩៦៣.៦១៣ | (៨៥៥.០០០) | ៦៤.១០៨.៦១៣ |
| **ចំណេញមុនបង់ពន្ធលើប្រាក់ចំណូល** | ៤៩.៥៥៧.៧៨៧ | (៨៥៥.០០០) | ៤៨.៧០២.៧៨៧ |
| ចំណាយពន្ធលើប្រាក់ចំណូល | (៣.៩៨៩.០១៥) | ៤៥២.០០០ | (៣.៥៣៧.០១៥) |
| **ចំណេញក្នុងឆ្នាំ** | ៤៥.៥៦៨.៧៧២ | (៤០៣.០០០) | ៤៥.១៦៥.៧៧២ |
| **លទ្ធផលលម្អិតផ្សេងៗ** | | | |
| ខ្ទង់ដែលមិនចាត់ថ្នាក់ឡើងវិញក្នុងចំណេញ – ខាត៖ | | | |
| ការវាស់វែងកាតព្វកិច្ចអត្ថប្រយោជន៍សោធននិវត្តន៍ឡើងវិញ | (២៧.៧៥២.០០០) | (១.៤០៥.០០០) | (២៩.១៥៧.០០០) |
| **លទ្ធផលលម្អិតសរុបក្នុងការិយបរិច្ឆេទ** | (២៧.៧៥២.០០០) | (១.៤០៥.០០០) | (២៩.១៥៧.០០០) |
| **ចំណេញរបស់ភាគហ៊ុនិក** | ៤៥.៥៦៨.៧៧២ | (៤០៣.០០០) | ៤៥.១៦៥.៧៧២ |
| **លទ្ធផលលម្អិតចំណេញសរុបរបស់ភាគហ៊ុនិក** | ១៧.៨១៦.៧៧២ | (១.៨០៨.០០០) | ១៦.០០៨.៧៧២ |

ចំណេញក្នុងមួយភាគហ៊ុនមូលដ្ឋាន និងថយចុះ សម្រាប់ឆ្នាំមុនក៏ត្រូវបានរាយការណ៍ឡើងវិញផងដែរ។ ចំនួនទឹកប្រាក់កែតម្រូវសម្រាប់ចំណេញក្នុងមួយភាគហ៊ុនមូលដ្ឋាន និងថយចុះ មានតំហាយចំនួនទឹកប្រាក់ប្រហាក់ប្រហែល ៤,៧០ រៀល ក្នុងមួយភាគហ៊ុន។

| | ២០១៨<br>ពាន់រៀល<br>(បង្ហាញពីដំបូង) | ២០១៨<br>ពាន់រៀល<br>(បានរាយការណ៍ឡើងវិញ) |
|---|---|---|
| **ចំណេញរបស់ភាគហ៊ុនិក (ពាន់រៀល)** | ៤៥.៥៦៨.៧៧២ | ៤៥.១៦៥.៧៧២ |
| ចំនួនមធ្យមនៃភាគហ៊ុន | ៨៥.៧៧១.៩៦៧ | ៨៥.៧៧១.៩៦៧ |
| ចំណេញក្នុងមួយភាគហ៊ុនមូលដ្ឋាន (រៀល) | ៥៣១,២៨ | ៥២៦,៥៨ |
| ចំណេញក្នុងមួយភាគហ៊ុនថយចុះ (រៀល) | ៥៣១,២៨ | ៥២៦,៥៨ |

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩**

## ៣៣. ការធ្វើនិយ័តកម្មលើអត្ថប្រយោជន៍បុគ្គលិក (ត)

| | ២០១៨<br>ពាន់រៀល | និយ័តកម្ម<br>ពាន់រៀល | ២០១៨<br>ពាន់រៀល |
|---|---|---|---|
| | | | (បានរាយការណ៍ ឡើងវិញ) |
| **របាយការណ៍លំហូរសាច់ប្រាក់ (ដកស្រង់)** | | | |
| ចំណេញមុនបង់ពន្ធ | ៤៩.៥៥៧.៧៨៧ | (៨៥៥.000) | ៤៨.៧០២.៧៨៧ |
| និយ័តកម្ម៖ | | | |
| កាតព្វកិច្ចអត្ថប្រយោជន៍សោធននិវត្តន៍ | ៤.២៨៦.000 | ៨៥៥.000 | ៥.១៤១.000 |
| សាច់ប្រាក់បានពីប្រតិបត្តិការ | ៧៦.២៣២.៤៦២ | - | ៧៦.២៣២.៤៦២ |

## ៣៤. ព្រឹត្តិការណ៍បន្ទាប់ពីការិយបរិច្ឆេទរាយការណ៍

មេរោគ novel coronavirus (COVID-19) ត្រូវបានប្រកាសថាជាជំងឺរាតត្បាត ហើយបានរីករាលដល់ប្រទេសកម្ពុជា ចាប់តាំងពីចុងខែមករា ឆ្នាំ២០២០។ ចាប់តាំងពីពេលនោះមក ក្នុងប្រទេសកំពុងប្រឈមមុខនឹង ហានិភ័យនៃការរីករាលដាលបន្ថែមទៀតហើយវាបានបង្កឱ្យមានការរាំងស្ទះដល់សកម្មភាពអាជីវកម្ម និងសេដ្ឋកិច្ច។ ក.ស.ស បានចាត់ទុកថាការផ្ទុះមេរោគនេះឡើង គឺជាព្រឹត្តិការណ៍ដែលកើតឡើងក្រោយតារាងតុល្យការដែលមិនអាចកែតម្រូវបាន។ ដោយសារស្ថានភាពនេះកំពុងតែវិវត្តទៅយ៉ាងឆាប់រហ័ស គណៈគ្រប់គ្រង យល់ឃើញថា ក.ស.ស មិនអាចផ្តល់នូវការប៉ាន់ស្មានអំពីទំហំនៃផលប៉ះពាល់ដែលបណ្តាលមកពីការផ្ទុះឡើងនៃមេរោគនេះ ចំពោះ ក.ស.ស បានទេ។ គណៈគ្រប់គ្រងបានតាមដានយ៉ាងសកម្មនូវស្ថានភាព ហើយផលប៉ះពាល់នៃមេរោគ Covid-19 ចំពោះប្រតិបត្តិការអាជីវកម្មរបស់ ក.ស.ស នឹងត្រូវបានពិចារណាក្នុងឆ្នាំ២០២០។

# ផ្នែកទី ៧

# ព័ត៌មានអំពីប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ និងទំនាស់ផលប្រយោជន៍

**ក- ប្រតិបត្តិការសំខាន់ៗជាមួយភាគហ៊ុនិក ដែលមានភាគហ៊ុនចាប់ពី៥ (ប្រាំ) ភាគរយឡើងទៅ**

គិតត្រឹមឆ្នាំ២០១៩ នេះ ពុំមានប្រតិបត្តិការប្រភេទនេះកើតឡើងចំពោះ **កសស** ទេ ។

**ខ- ប្រតិបត្តិការសំខាន់ៗជាមួយអភិបាល និងបុគ្គលិកជាន់ខ្ពស់**

គិតត្រឹមឆ្នាំ២០១៩ នេះ ពុំមានប្រតិបត្តិការប្រភេទនេះកើតឡើងចំពោះ **កសស** ទេ ។

**គ- ប្រតិបត្តិការសំខាន់ៗជាមួយអភិបាល និងភាគហ៊ុនិកពាក់ព័ន្ធនឹងការទិញ-លក់ទ្រព្យសកម្ម និងសេវាកម្ម**

គិតត្រឹមឆ្នាំ២០១៩ នេះ ពុំមានប្រតិបត្តិការប្រភេទនេះកើតឡើងចំពោះ **កសស** ទេ ។

**ឃ-ប្រតិបត្តិការសំខាន់ៗ ជាមួយសមាជិកគ្រួសារផ្ទាល់របស់អភិបាល បុគ្គលិកជាន់ខ្ពស់ និងភាគហ៊ុនិកដែលមានភាគហ៊ុនចាប់ពី៥ (ប្រាំ) ភាគរយឡើងទៅ**

គិតត្រឹមឆ្នាំ២០១៩ នេះ ពុំមានប្រតិបត្តិការប្រភេទនេះកើតឡើងចំពោះ **កសស** ទេ ។

**ង- ប្រតិបត្តិការសំខាន់ៗ ជាមួយបុគ្គលដែលមានទំនាក់ទំនងជាមួយអភិបាលរបស់ កំពង់ផែស្វយ័តក្រុងព្រះសីហនុ ក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនហូលឌីងរបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ**

គិតត្រឹមឆ្នាំ២០១៩ នេះ ពុំមានប្រតិបត្តិការប្រភេទនេះកើតឡើងចំពោះ **កសស** ទេ ។

**ច- ប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលធ្លាប់ជាអភិបាល ឬបុគ្គលជាប់ពាក់ព័ន្ធជាមួយបុគ្គលធ្លាប់ជាអភិបាល**

គិតត្រឹមឆ្នាំ២០១៩ នេះ ពុំមានប្រតិបត្តិការប្រភេទនេះកើតឡើងចំពោះ **កសស** ទេ ។

**ឆ- ប្រតិបត្តិការសំខាន់ៗជាមួយអភិបាលកាន់មុខតំណែងណាមួយនៅក្នុងសមាគម ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ ឬនៅក្នុងក្រុមហ៊ុនណាមួយផ្សេងទៀតក្រៅពីកំពង់ផែស្វយ័តក្រុងព្រះសីហនុ**

គិតត្រឹមឆ្នាំ២០១៩ នេះ ពុំមានប្រតិបត្តិការប្រភេទនេះកើតឡើងចំពោះ **កសស** ទេ ។

**ជ- ប្រតិបត្តិការសំខាន់ៗ ជាមួយអភិបាលដែលទទួលបានផលប្រយោជន៍ពីកំពង់ផែស្វយ័តក្រុងព្រះសីហនុ ទោះជាហិរញ្ញវត្ថុ ឬមិនមែនហិរញ្ញវត្ថុ**

គិតត្រឹមឆ្នាំ២០១៩ នេះ ពុំមានប្រតិបត្តិការប្រភេទនេះកើតឡើងចំពោះ **កសស** ទេ ។

# ផ្នែកទី ៨

# ការពិភាក្សា និងការវិភាគ
# របស់គណៈគ្រប់គ្រង

## ក- ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

**កសស** គឺជាកំពង់ផែអន្តរជាតិសមុទ្រទឹកជ្រៅតែមួយគត់ នៃព្រះរាជាណាចក្រកម្ពុជា ដែលកំពុងធ្វើអាជីវកម្មលើផ្ទៃដីទំហំប្រមាណ ១២៥ ហិកតា ដែលមានទីតាំងនៅក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ហើយត្រូវបានតភ្ជាប់ដោយបណ្តាញដឹកជញ្ជូនចំរុះ។ កំណត់ក្នុង **អនុក្រឹត្យលេខ ៥០ អនក្រ/បក ចុះថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ ១៩៩៨ កសស** មានតួនាទីជាប្រតិបត្តិករផែ ដូចមានលម្អិតនូវអាជីវកម្ម និងសេវាកម្មក្នុងផ្នែកទី១ ចំណុចទី២ ខាងលើនៃរបាយការណ៍ឆ្នាំ២០១៩ នេះ ។

សម្រាប់ឆ្នាំ២០១៩ នេះ បរិមាណកុងតឺន័ររបស់ **កសស** មានការកើនឡើងចំនួន ៩៧.៩៨៣ TEUs ស្មើនឹង ១៨,១០% បើធៀបនឹងឆ្នាំ២០១៨។ ចំណែកបរិមាណទំនិញឆ្លងកាត់គិតជាតោនមានកំណើន ២២,៨៩% ស្មើនឹង ១.២១៩.៤០៨ តោន ដែលក្នុងនោះទំនិញរាយឆ្លងកាត់មានការកើនឡើងចំនួន ១៦៣.៩០៧ តោន ស្មើនឹង ៤៥,៩៤% ហើយទំនិញជាកុងតឺន័រគិតជាតោនមានកំណើន ២២,៤២% ស្មើនឹង ៧៥៩.៨០៦ តោន។ ចំពោះនាវាឆ្លងកាត់ **កសស** មានកំណើន ចំនួន ២១១ នាវា ប្រមាណជា ១៤,៥៤% និងចំណុះផ្ទុកនាវាកើនឡើង ១១,២៦% ស្មើនឹង ១.៧៧០.៩៤៤ តោន សម្រាប់ឆ្នាំ២០១៩ ធៀបនឹងឆ្នាំ២០១៨ ។

ការពិភាក្សា និងការវិភាគរបស់ថ្នាក់ដឹកនាំលើស្ថានភាពហិរញ្ញវត្ថុរបស់ **កសស** និងលទ្ធផលប្រតិបត្តិការខាងក្រោមនេះ ធ្វើឡើងផ្អែកលើរបាយការណ៍ព័ត៌មានហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចរាល់ដោយសវនករឯករាជ្យសម្រាប់ឆ្នាំ២០១៩ និងឆ្នាំ២០១៨ ដូចបង្ហាញក្នុងផ្នែកទី៦ នៃរបាយការណ៍ឆ្នាំ២០១៩ នេះ ។

**កសស មានប្រភពចំណូលសំខាន់ដូចខាងក្រោម ៖**

- **ចំណូលពីសេវាកម្មនាវាចរ** (Port Charges for Vessel Services)៖ គឺជាចំណូលដែលបានមកពីសេវាកម្មនាវាចរណ៍ និងការចូលចតនាវា រួមមាន ចំណូលលើចំណុះផ្ទុក សំចតផែ ប្រឡាយ ថ្លៃឈ្នួលកណ្តាធារកិច្ច ថ្លៃឈ្នួលនាវាសណ្តោង ថ្លៃឈ្នួលពាក់-ដោះពួរ ថ្លៃឈ្នួលបើក-បិទឃ្លប់នាវា និងថ្លៃឈ្នួលប្រមូលសំរាម ។
- **ចំណូលពីសេវាកម្មលើកដាក់កុងតឺន័រពីនាវាទៅទីលានកុងតឺន័រ** (Stevedoring Charges)៖ គឺជាចំណូលដែលបានមកពីសេវាកម្មលើកដាក់ទំនិញរាយ ឬកុងតឺន័រចូល ឬចេញពីនាវានៅលើស្ពានផែ ។
- **ចំណូលពីសេវាកម្មលើកដាក់កុងតឺន័រនៅលើទីលាន** (LOLO Charges)៖ គឺជាចំណូលដែលបានមកពីសេវាកម្មលើកដាក់ទំនិញរាយ ឬកុងតឺន័រ ចូល ឬចេញនៅលើទីលាន ។
- **ចំណូលពីថ្លៃឈ្នួលស្តុកទំនិញ ឬកុងតឺន័រ** (Storage Fees)៖ គឺជាចំណូលដែលបានមកពីការស្តុកទំនិញរាយ ឬកុងតឺន័រនៅក្នុងឃ្លាំង និងលើទីលាន ។
- **ចំណូលដឹកជញ្ជូន** (Transportation Charges)៖ គឺជាចំណូលដែលបានមកពីសេវាកម្មដឹកជញ្ជូនទំនិញ ឬកុងតឺន័រក្នុងបរិវេណផែ ។
- **ចំណូលពីតំបន់សេដ្ឋកិច្ចពិសេស** (Special Economic Zone)៖ គឺជាចំណូលដែលទទួលបានពីការជួលដីធ្វើរោងចក្រ អគារ ពីតំបន់សេដ្ឋកិច្ចពិសេសរបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ ។

**កសស** កត់ត្រាបញ្ជីគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុជាប្រាក់រៀល ដែលជារូបិយប័ណ្ណជាតិរបស់ខ្លួន ចំណែកប្រតិបត្តិការដែលជារូបិយប័ណ្ណអន្តរជាតិផ្សេងៗ ត្រូវបានបង្ហាញជាប្រាក់រៀលដោយប្រើអត្រាប្តូរផ្លូវការជាមធ្យមប្រចាំថ្ងៃរបស់ធនាគារជាតិនៃកម្ពុជា តាមកាលបរិច្ឆេទនៃប្រតិបត្តិការនីមួយៗ ។

## ក-ការវិភាគចំណូល

### ក.១. ការវិភាគចំណូល

សម្រាប់ដំណាច់ការិយបរិច្ឆេទ ឆ្នាំ២០១៩ ប្រៀបធៀបនឹងដំណាច់ការិយបរិច្ឆេទ ឆ្នាំ២០១៨

| បរិយាយ | សម្រាប់ការិយបរិច្ឆេទ ឆ្នាំ២០១៩ | សម្រាប់ការិយបរិច្ឆេទ ឆ្នាំ២០១៨ | បំរែបំរួល | |
|---|---|---|---|---|
| | ពាន់រៀល | ពាន់រៀល | ពាន់រៀល | % |
| ចំណូល (ពាន់រៀល) | ៣៣៣.៩១៣.៣៧៧ | ២៧៥.៥៧៥.៦៤៥ | ៥៨.៣៣៧.៧៣២ | ២១,១៧% |

សម្រាប់ឆ្នាំ២០១៩ នេះ ចំណូលរបស់ **កសស** បានកើនឡើងចំនួន ៥៨.៣៣៧.៧៣២.000 រៀល ស្មើនឹង ២១,១៧% ដោយកើនឡើងពី ២៧៥.៥៧៥.៦៤៥.000 រៀល សម្រាប់ឆ្នាំ២០១៨ និង ៣៣៣.៩១៣.៣៧៧.000 រៀល សម្រាប់ឆ្នាំ២០១៩ ។ ការកើនឡើងនៃចំណូលនេះបានមកពីសេវាកម្មលើកដាក់កុងតឺន័រពីនាវាទៅទីលាន (Stevedoring Charges) ចំណូលពីសេវាកម្មលើកដាក់កុងតឺន័រនៅលើទីលាន (LOLO Charges) ចំណូលពីសេវាកម្មនាវាចរ និងចំណូលពីថ្លៃឈ្នួលស្តុកទំនិញ ឬកុងតឺន័រជាដើម។

### ក.២. ការវិភាគចំណូលតាមផ្នែក

តារាងប្រៀបធៀបប្រាក់ចំណូលតាមផ្នែកទៅនឹងប្រាក់ចំណូលសរុបសម្រាប់ឆ្នាំ២០១៩ និងឆ្នាំ២០១៨

| បរិយាយ | សម្រាប់ការិយបរិច្ឆេទឆ្នាំ ២០១៩ | | សម្រាប់ការិយបរិច្ឆេទឆ្នាំ ២០១៨ | |
|---|---|---|---|---|
| | ពាន់រៀល | ភាគរយធៀបនឹងចំណូលសរុប | ពាន់រៀល | ភាគរយធៀបនឹងចំណូលសរុប |
| ចំណូលលើកដាក់ពីនាវាទៅទីលាន (Stevedoring) | ១៥១.១៥៣.៧១៧ | ៤៥,២៧% | ១២៧.០៨៧.៥៣៨ | ៤៦,១២% |
| ចំណូលលើកដាក់លើទីលាន (LOLO) | ៩០.៨៧៧.០៧៦ | ២៧,២២% | ៧៥.១៣៨.៩៧៨ | ២៧,២៧% |
| ចំណូលពីសេវាកម្មនាវាចរ | ៦៥.៧១៩.៤៥២ | ១៩,៦៨% | ៥៧.៦៩៤.០៣៤ | ២០,៩៤% |
| ចំណូលស្តុក ឃ្លាំង និងទីលាន | ២១.២៤៨.១២២ | ៦,៣៦% | ១០.១៨១.១០២ | ៣,៦៩% |
| ចំណូលដឹកជញ្ជូន | ១០២.០៨១ | ០,០៣% | ៦៨០.០០០ | ០,២៥% |
| ចំណូលនាវាទេសចរណ៍ | ៨២៣.៥៤៧ | ០,២៥% | ៦៤០.៥០៧ | ០,២៣% |
| ចំណូលពីតំបន់ សេដ្ឋកិច្ចពិសេស | ២.៧៥១.៤៩៤ | ០,៨២% | ៣.០១៦.៣៦៥ | ១,០៩% |
| ចំណូលជួលទីតាំង | ៩១៤.០៧០ | ០,២៧% | ៧៦១.៦៧៣ | ០,២៨% |
| ចំណូលផ្សេងៗទៀត | ៣២៣.៨១៨ | ០,១០% | ៣៧៥.៤៤៤ | ០,១៤% |
| **ចំណូលសរុប** | **៣៣៣.៩១៣.៣៧៧** | **១០០,០០%** | **២៧៥.៥៧៥.៦៤៥** | **១០០,០០%** |

សម្រាប់ឆ្នាំ២០១៩ ក៏ដូចជាឆ្នាំ២០១៨ មានចំណូលសំខាន់ ៤ ប្រភេទដែលមានចំនួនប្រមាណ ៩៨% នៃចំណូលអាជីវកម្ម និងសេវាកម្មសរុបរបស់ **កសស** ។ ចំណូលទាំងនោះរួមមាន ៖ ចំណូលលើកដាក់ពីនាវាទៅទីលាន (Stevedoring) ចំណូលលើកដាក់លើទីលាន (LOLO) ចំណូលពីសេវាកម្មនាវាចរ(Port Charges for Vessel Services) និងចំណូលស្តុកឃ្លាំង និងទីលាន ។

## សម្រាប់ដំណាច់ការិយបរិច្ឆេទ ឆ្នាំ២០១៩ ប្រៀបធៀបនឹងដំណាច់ការិយបរិច្ឆេទ ឆ្នាំ២០១៨

| បរិយាយ | សម្រាប់ការិយបរិច្ឆេទ ឆ្នាំ២០១៩ | សម្រាប់ការិយបរិច្ឆេទ ឆ្នាំ២០១៨ | បំរែបំរួល | |
|---|---|---|---|---|
| | ពាន់រៀល | ពាន់រៀល | ពាន់រៀល | % |
| ចំណូលលើកដាក់ពីនាវាទៅទីលាន (Stevedoring) | ១៥១.១៥៣.៧១៧ | ១២៧.០៨៧.៥៣៨ | ២៤.០៦៦.១៨០ | ១៨,៩៤% |
| ចំណូលលើកដាក់លើទីលាន (LOLO) | ៩០.៨៧៧.០៧៦ | ៧៥.១៣៨.៩៧៨ | ១៥.៧៣៨.០៩៨ | ២០,៩៥% |
| ចំណូលពីសេវាកម្មនាវាចរ | ៦៥.៧១៩.៤៥២ | ៥៧.៦៩៤.០៣៤ | ៨.០២៥.៤១៨ | ១៣,៩១% |
| ចំណូលស្តុក ឃ្លាំង និងទីលាន | ២១.២៤៨.១២២ | ១០.១៨១.១០២ | ១១.០៦៧.០២០ | ១០៨,៧០% |

ចំណូលពីការលើកដាក់ពីនាវាទៅទីលានកុងតឺន័រ (Steverdoring) មានកំណើន ២៤.០៦៦.១៨០.០០០ រៀល ស្មើនឹង ១៨,៩៤% សម្រាប់ឆ្នាំ២០១៩ ធៀបនឹងឆ្នាំ២០១៨ និងចំណូលពីការលើកដាក់នៅលើទីលាន (LOLO) មានការកើនឡើងប្រមាណ ២០,៩៥% ស្មើនឹង ១៥.៧៣៨.០៩៨.០០០ រៀល បើប្រៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០១៨។ កំណើនលើចំណូលលើកដាក់ពីនាវាទៅទីលាន និងចំណូលលើកដាក់លើទីលានគឺបណ្តាលមកពីការកើនឡើងនៃទំនិញកុងតឺន័រឆ្លងកាត់ **កសស** មានចំនួន ៩៧.៩៨៣ TEUs ស្មើនឹង ១៨,១០% សម្រាប់ឆ្នាំ២០១៩ នេះ ។

ចំពោះចំណូលសេវាកម្មនាវាចរ (Port Charges for Vessel Services) គឺអាស្រ័យលើចំនួន និងចំណុះផ្ទុកនាវាដែលឆ្លងកាត់ **កសស** ហើយសម្រាប់ឆ្នាំ២០១៩ នេះ នាវាសរុបដែលឆ្លងកាត់ **កសស** មានការកើនឡើង ២១១ នាវា ស្មើនឹង ១៤,៥៤% ហើយចំណុះផ្ទុកនាវាមានកំណើនប្រមាណ ១១,២៦% ស្មើនឹង ១.៧៧០.៩៤៤ តោន ដែលធ្វើឱ្យចំណូលពីសេវាកម្មផែមានការកើនឡើងពី ៥៧.៦៩៤.០៣៤.០០០ រៀល សម្រាប់ឆ្នាំ២០១៨ ដល់ ៦៥.៧១៩.៤៥២.០០០ រៀល សម្រាប់ឆ្នាំ២០១៩ គឺប្រមាណ ១៣,៩១% ស្មើនឹង ៨.០២៥.៤១៨.០០០ រៀល។ ចំពោះនាវាដឹកកុងតឺន័រដែលជាប្រភពចំណូលសំខាន់បំផុតរបស់កំពង់ផែ ក្នុងឆ្នាំ២០១៩នេះ ចំណុះផ្ទុកនាវាកុងតឺន័រមានការកើនឡើងប្រមាណ ០,៣៥% និងចំនួននាវាកុងតឺន័រកើនឡើង ៦.៨៨% រីឯចំណុះផ្ទុកនាវាដឹកទំនិញទូទៅមានកំណើន២៤,៨០% និងចំនួននាវាទំនិញទូទៅមានកំណើន ២៨,២៩% បើធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០១៨ ។

ចំណូលពីសេវាកម្មស្តុកឃ្លាំង និងទីលានមានការកើនឡើងចំនួន ១១.០៦៧.០២០.០០០ រៀល ស្មើនឹង ១០៨,៧០% បើប្រៀបធៀបចំណូលឆ្នាំ២០១៩ មាន ២១.២៤៨.១២២.០០០ រៀល និងឆ្នាំ២០១៨ មានចំណូល១០.១៨១.១០២.០០០ រៀល។ ការកើនឡើងនៃចំណូលស្តុកនេះ គឺបណ្តាលមកពីទំនិញដែលឆ្លងកាត់ឃ្លាំង និងទីលានរបស់ **កសស** មានកំណើន ១៨,៥៥% ស្មើនឹង ១.២៨២.៣៩៧ តោន សម្រាប់ឆ្នាំ២០១៩នេះ ។

## ខ-ការវិភាគគំលាតចំណេញដុល

**កសស** បានរៀបចំរបាយការណ៍លទ្ធផលរបស់ខ្លួន ក្នុងទម្រង់ជារបាយការណ៍លទ្ធផលតាមយថាប្រភេទ ដូចនេះពុំមានការបង្ហាញឱ្យឃើញនៅចំណេញដុលនោះទេ។ ប៉ុន្តែក្នុងទម្រង់របាយការណ៍នេះអាចឱ្យយើងធ្វើការពិភាក្សា និងវិភាគលើចំណេញប្រតិបត្តិការបានដោយទទួលបានពីចំណូលសរុប ដកនឹងចំណាយប្រតិបត្តិការ។

ចំណាយប្រតិបត្តិការនឹងលើកមកពិភាក្សា និងវិភាគនៅផ្នែកខាងក្រោមគឺ ចំណុច គ-ការវិភាគចំណេញមុនបង់ពន្ធ ។

## គ- ការវិភាគចំណេញមុនបង់ពន្ធ

ចំណេញមុនបង់ពន្ធគឺជាលទ្ធផលដែលទទួលបានពីចំណូលសរុបដកនឹងចំណាយប្រតិបត្តិ និងចំណូល ឬចំណាយការប្រាក់សុទ្ធ។ ក្នុងការវិភាគនៃចំណាយប្រតិបត្តិការ យើងនឹងលើកយកចំណាយសម្ភារៈផ្គត់ផ្គង់ ចំណាយប្រាក់បៀវត្សរ៍ ប្រាក់ឈ្នួល និងចំណាយពាក់ព័ន្ធ ចំណាយរំលស់ (ទ្រព្យសម្បត្តិ និងបរិក្ខារ និងទ្រព្យសកម្មអរូបី) ចំណាយជួសជុល និងថែទាំ ចំណាយផ្សេងៗ និងចំណេញ (ឬខាត) ផ្សេងៗ សុទ្ធ ដូចខាងក្រោម៖

## សម្រាប់ដំណាច់ការិយបរិច្ឆេទ ឆ្នាំ២០១៩ ប្រៀបធៀបនឹងដំណាច់ការិយបរិច្ឆេទ ឆ្នាំ២០១៨

| បរិយាយ | សម្រាប់ការិយបរិច្ឆេទ ឆ្នាំ២០១៩ | សម្រាប់ការិយបរិច្ឆេទ ឆ្នាំ២០១៨ | បំរែបំរួល | |
|---|---|---|---|---|
| | ពាន់រៀល | ពាន់រៀល | ពាន់រៀល | % |
| **ចំណូលសរុប** | **៣៣៣.៩១៣.៣៧៧** | **២៧៥.៥៧៥.៦៤៥** | **៥៨.៣៣៧.៧៣២** | **២១,១៧%** |
| ចំណាយសម្ភារៈផ្គត់ផ្គង់ | (៩៥.២៣១.៧៤១) | (៧៦.១៩២.៨៤៣) | ១៩.០៣៨.៨៩៨ | ២៤,៩៩% |
| ចំណាយប្រាក់បៀវត្ស ប្រាក់ឈ្នួល និង ចំណាយពាក់ព័ន្ធ | (៨៨.១២៨.០០១) | (៧៥.៥៦៣.៣១៨) | ១២.៥៦៤.៦៨៣ | ១៦,៦៣% |
| ចំណាយរំលស់(ទ្រព្យសម្បត្តិ និងបរិក្ខារ និងទ្រព្យសកម្មអរូបី) | (៣០.៩១០.២៧៤) | (២៨.២៧៥.៧៣១) | ២.៦៣៤.៥៤៣ | ៩,៣២% |
| ចំណាយជួសជុល និងថែទាំ | (៨.១០១.២៩២) | (៦.០៤២.៣៩៧) | ២.០៥៨.៨៩៥ | ៣៤,០៧% |
| ចំណាយផ្សេងៗ | (២៦.១១៤.២៤២) | (២៤.៩៦៤.៩៣២) | ១.១៤៩.៣១០ | ៤,៦០% |
| ខាត/(ចំណេញ)ផ្សេងៗ-សុទ្ធ | (៤.០៥៧.៦៩៣) | (៤២៧.៨១១) | ៣.៦២៩.៨៨២ | ៨៤៨,៤៨% |
| (ចំណាយ)/ចំណូលហិរញ្ញវត្ថុ-សុទ្ធ | (១៦.១៨៤.៧០៦) | (១៥.៤០៥.៨២៦) | ៧៧៨.៨៨០ | ៥,០៦% |
| **ចំណេញមុនបង់ពន្ធ** | **៦៥.១៨៥.៤២៨** | **៤៨.៧០២.៧៨៧** | **១៦.៤៨២.៦៤១** | **៣៣,៨៤%** |

សម្រាប់ឆ្នាំ២០១៩ **កសស** មានចំណាយសម្ភារៈផ្គត់ផ្គង់ ៩៥.២៣១.៧៤១.០០០ រៀល ដែលមានការកើនឡើងចំនួន ១៩.០៣៨.៨៩៨.០០០ រៀល ស្មើនឹង ២៤,៩៩% បើធៀបនឹងឆ្នាំ២០១៨ ដែលមានចំណាយ ៧៦.១៩២.៨៤៣.០០០ រៀល។ កត្តាចម្បងដែលបណ្តាលឱ្យមានកើនឡើងនេះ គឺ ចំណាយលើគ្រឿងបន្លាស់មានកំណើនចំនួន ៧២,៥៧% ស្មើនឹង ១៥.០៣៧.៤៥០.០០០ រៀល ហើយចំណាយសម្ភារៈប្រេងឥន្ធនៈមានកំណើនចំនួន ៦,៤៤% ស្មើនឹង ២.៦៧១.៦៥៣.០០០ រៀល ដោយសារបរិមាណទំនិញមានការកើនឡើង ធ្វើឱ្យប្រតិបត្តិការគ្រឿងចក្រដែលប្រើប្រាស់ប្រេងឥន្ធនៈមានការកើនឡើងសម្រាប់ឆ្នាំ២០១៩ ។ ចំណែកចំណាយសម្ភារៈឃ្លាំងមានការថយចុះ ១៣,៥៥% ស្មើនឹង ១.០៤៣.៦៨៩.០០០ រៀល បើធៀបនឹងឆ្នាំ២០១៨ ។

មូលដ្ឋានក្នុងការគណនាប្រាក់បៀវត្សរ៍របស់ **កសស** គឺយោងទៅលើទិន្នផល (ចំណូលពីការលើកដាក់) ពោលគឺនៅពេលចំណូលពីការលើកដាក់កើនឡើង ចំណាយបៀវត្សរ៍នឹងកើនឡើង ផ្ទុយទៅវិញបើចំណូលពីការលើកដាក់មានការថយចុះ ចំណាយលើប្រាក់បៀវត្សរ៍នឹងត្រូវថយចុះដូចគ្នា ហើយយើងសង្កេតឃើញថា ចំណូលលើកដាក់ពីនាវាទៅទីលាន (Stevedoring) មានកំណើនប្រមាណ ១៨,៩៤% និងចំណូលលើកដាក់លើទីលាន (LOLO) មានកំណើនប្រមាណ ២០,៩៥% សម្រាប់ឆ្នាំ២០១៩ នេះ។ ហេតុដូចនេះ ធ្វើឱ្យចំណាយប្រាក់បៀវត្សរ៍ ប្រាក់ឈ្នួល និងចំណាយពាក់ព័ន្ធ មានការកើនឡើងប្រមាណ ១៦,៦៣% ស្មើនឹង ១២.៥៦៤.៦៨៣.០០០រៀល បើប្រៀបធៀបចំណាយសម្រាប់ឆ្នាំ២០១៩ ដែលមានចំនួន ៨៨.១២៨.០០១.០០០ រៀល និងឆ្នាំ២០១៨ ដែលមានចំណាយ ៧៥.៥៦៣.៣១៨.០០០ រៀល ។

ចំណាយរំលស់រួមមាន រំលស់ទ្រព្យសម្បត្តិ និងបរិក្ខារ និងរំលស់ទ្រព្យសកម្មអរូបីនៅក្នុងឆ្នាំ២០១៩ មានចំនួន ៣០.៩១០.២៧៤.០០០ រៀល មានកំណើន ២.៦៣៤.៥៤៣.០០០ រៀល ស្មើនឹង ៩,៣២% បើធៀបនឹងឆ្នាំ២០១៨ ដែលមានចំនួន ២៨.២៧៥.៧៣១.០០០ រៀល។ កត្តាដែលធ្វើឱ្យមានការកើនឡើងនេះគឺដោយសារចំណាយរំលស់ទ្រព្យសម្បត្តិ និងបរិក្ខារមានកំណើន ២.៥៤៣.៤៩០.០០០ រៀល ស្មើនឹង១២,០៥% និងកំណើនលើចំណាយរំលស់ទ្រព្យសម្បត្តិវិនិយោគ ១,៤៩% ស្មើនឹង ៩១.០៥៣.០០០ រៀល ។

ចំណែកចំណាយជួសជុល និងថែទាំមានការកើនឡើង ២.០៥៨.៨៩៥.០០០ រៀល ស្មើនឹង ៣៤,០៧% ដោយមានចំណាយសរុបស្មើនឹង ៨.១០១.២៩២.០០០ រៀល សម្រាប់ឆ្នាំ២០១៩ និង ៦.០៤២.៣៩៧.០០០ រៀល សម្រាប់ឆ្នាំ២០១៨ ។

ចំពោះចំណាយផ្សេងៗសរុប មានការកើនឡើងប្រមាណ ៤,៦០% ស្មើនឹង ១.១៤៩.៣១០.០០០ រៀល ពោលគឺកើនឡើងពី ២៤.៩៦៤.៩៣២.០០០ រៀល សម្រាប់ឆ្នាំ២០១៨ ដល់ ២៦.១១៤.២៤២.០០០ រៀល សម្រាប់ឆ្នាំ២០១៩ ។

(ខាត)/ចំណេញផ្សេងៗ-សុទ្ធ (Realized Foreign Exchange Gain-Loss) គឺសំដៅលើការចំណេញ ឬខាតពីការប្តូររូបិយប័ណ្ណក្នុងការិយបរិច្ឆេទសម្រេច ដែលសម្រាប់ឆ្នាំ២០១៩នេះ មានការខាតចំនួន ៤.០៥៧.៦៩៣.០០០ រៀល បើធៀបនឹងឆ្នាំ២០១៨ មានការខាតចំនួន ៤២៧.៨១១.០០០ រៀល ធ្វើឱ្យមានការខាតកើនឡើងប្រមាណ ៨៤៨,៤៨% ស្មើនឹង ៣.៦២៩.៨៨២.០០០ រៀល ។

ចំណែក (ចំណាយ)/ចំណូលហិរញ្ញវត្ថុ-សុទ្ធ សម្រាប់ឆ្នាំ២០១៩ មានចំណាយហិរញ្ញវត្ថុ-សុទ្ធចំនួន ១៦.១៨៤.៧០៦.០០០ រៀល ដែលមានការកើនឡើង ៥,០៦% ស្មើនឹង ៧៧៨.៨៨០.០០០ រៀល បើធៀបនឹងឆ្នាំ២០១៨ ដែលមានចំណាយហិរញ្ញវត្ថុ-សុទ្ធចំនួន ១៥.៤០៥.៨២៦.០០០រៀល ។ កត្តាសំខាន់ដែលបណ្តាល

ឱ្យមានបំរែបំរួលលើ (ចំណាយ)/ចំណូល ហិរញ្ញវត្ថុ-សុទ្ធ គឺចំណាយហិរញ្ញវត្ថុសម្រាប់ឆ្នាំ២០១៩ មានកំណើន ១.២៤២.៨០០.០០០ រៀល ស្មើនឹង ៦,៥០% ធៀបនឹងឆ្នាំ២០១៨ ដោយសារក្នុងឆ្នាំ២០១៩នេះ **កសស** ដល់ពេលបង់ការប្រាក់បន្ថែមលើមួយគម្រោងទៀតដែលទើបបញ្ចប់ការសាងសង់ធ្វើឱ្យចំណាយការប្រាក់លើ ប្រាក់កម្ចីមានការកើនឡើងប្រមាណ ១២,៥១%ស្មើនឹង ១.៣៥១.៣៧៤.០០០រៀល បើធៀបនឹងឆ្នាំ២០១៨ ។

ជាសរុប ចំណេញមុនបង់ពន្ធសម្រាប់ឆ្នាំ២០១៩ របស់ **កសស** មានចំនួន ៦៥.១៨៥.៤២៨.០០០ រៀល កើនឡើងចំនួន ១៦.៤៨២.៦៤១.០០០ រៀល ប្រមាណជា ៣៣,៨៤% បើធៀបនឹងឆ្នាំ២០១៨ ចំណេញមុនបង់ពន្ធមានចំនួន ៤៨.៧០២.៧៨៧.០០០ រៀល ។

## ឃ- ការវិភាគចំណេញក្រោយបង់ពន្ធ

**កសស** ស្ថិតនៅក្រោមច្បាប់នៃក្រុមហ៊ុនពាណិជ្ជកម្មក្នុងវិស័យពន្ធដារ និងអាករ ហេតុដូចនេះ **កសស** មានកាតព្វកិច្ចក្នុងការបង់ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំក្នុងអត្រា ២០% ប៉ុន្តែក្រោយពី **កសស** បានបោះផ្សាយលក់មូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈ កាលពីថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៧ គឺ **កសស** ទទួលបានការលើកទឹកចិត្តដោយបានការបន្ធូរបន្ថយពន្ធលើប្រាក់ចំណេញចំនួន ៥០% នៃពន្ធលើប្រាក់ចំណេញត្រូវបង់ប្រចាំឆ្នាំក្នុងរយៈពេល៣ឆ្នាំ។

## សម្រាប់ដំណាច់ការិយបរិច្ឆេទ ឆ្នាំ២០១៩ ប្រៀបធៀបនឹងដំណាច់ការិយបរិច្ឆេទ ឆ្នាំ២០១៨

| បរិយាយ | សម្រាប់ការិយបរិច្ឆេទ ឆ្នាំ២០១៩ | សម្រាប់ការិយបរិច្ឆេទ ឆ្នាំ២០១៨ | បំរែបំរួល | |
|---|---|---|---|---|
| | ពាន់រៀល | ពាន់រៀល | ពាន់រៀល | % |
| ចំណេញមុនបង់ពន្ធ (ក) | ៦៥.១៨៥.៤២៨ | ៤៨.៧០២.៧៨៧ | ១៦.៤៨២.៦៤១ | ៣៣,៨៤% |
| ចំណាយពន្ធលើប្រាក់ចំណេញ (ខ) | (២១.៧២១.៩២៨) | (៣.៥៣៧.០១៥) | ១៨.១៨៤.៩១៣ | ៥១៤,១៣% |
| **ចំណេញក្នុងការិយបរិច្ឆេទ** | **៤៣.៤៦៣.៥០០** | **៤៥.១៦៥.៧៧២** | **(១.៧០២.២៧២)** | **-៣,៧៧%** |
| ការវាស់វែងកាតព្វកិច្ចអត្ថប្រយោជន៍សោធននិវត្តន៍ឡើងវិញ | (៦៦១.០០០) | (២៩.១៥៧.០០០) | (២៨.៤៩៦.០០០) | -៩៧,៧៣% |
| **លទ្ធផលលម្អិតសរុបរបស់ភាគហ៊ុនិក** | **៤២.៨០២.៥០០** | **១៦.០០៨.៧៧២** | **២៦.៧៩៣.៧២៨** | **១៦៧,៣៧%** |
| **អត្រាពន្ធប្រសិទ្ធភាពលើប្រាក់ចំណេញ** (ខ)/(ក) | **៣៣,៣២%** | **៧,២៦%** | | |

**កសស** មានចំណេញក្នុងការិយបរិច្ឆេទចំនួន ៤៣.៤៦៣.៥០០.០០០ រៀល សម្រាប់ឆ្នាំ២០១៩ ដែលមានការថយចុះចំនួន ១.៧០២.២៧២.០០០ រៀល ស្មើនឹង ៣,៧៧% ដោយមានចំនួន ៤៥.១៦៥.៧៧២.០០០ រៀល សម្រាប់ឆ្នាំ២០១៨។ កត្តាដែលធ្វើឱ្យចំណេញក្នុងការិយបរិច្ឆេទមានការថយចុះសម្រាប់ឆ្នាំ២០១៩នេះ គឺដោយសារចំណាយពន្ធពន្យារលើប្រាក់ចំណេញ (Deferred Tax Expense) មានការកើនឡើង ដែលធ្វើឱ្យចំណាយពន្ធលើប្រាក់ចំណេញសរុបមានចំនួន ២១.៧២១.៩២៨.០០០រៀល មានកំណើន ១៨.១៨៤.៩១៣.០០០រៀល ស្មើនឹង ៥១៤,១៣% បើធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០១៨ ។ បើសង្កេតទៅលើអត្រាពន្ធប្រសិទ្ធភាពលើប្រាក់ចំណេញមានការកើនឡើងពី ៧,២៦% សម្រាប់ឆ្នាំ២០១៨ ទៅ ៣៣,៣២% សម្រាប់ឆ្នាំ២០១៩ ។

## ង-ការវិភាគពីកត្តា និងនិន្នាការដែលប៉ះពាល់ស្ថានភាព និងលទ្ធផលហិរញ្ញវត្ថុ

កត្តាមួយចំនួនអាចមានឥទ្ធិពលលើស្ថានភាព និងលទ្ធផលហិរញ្ញវត្ថុរបស់ **កសស** ដូចជា៖

- **កត្តានានាដែលធ្វើឱ្យមានកំរិតលើការធ្វើពាណិជ្ជកម្មអន្តរជាតិ**

ដោយសារប្រភពចំណូលចម្បងរបស់ **កសស** បានមកពីចរាចរណ៍ទំនិញឆ្លងកាត់ដែលជាការធ្វើពាណិជ្ជកម្មអន្តរជាតិ ដូចនេះកត្តានានាដែលមានផលប៉ះពាល់ដល់ពាណិជ្ជកម្មអន្តរជាតិ និងមានឥទ្ធិពលលើអាជីវកម្មរបស់ **កសស** ដែលកត្តាទាំងនោះមានដូចជា ស្ថានភាពសេដ្ឋកិច្ចក្នុងស្រុក ក្នុងតំបន់ និងសាកលលោក ស្ថេរភាពសង្គម បញ្ហាសន្តិសុខ ឬកិច្ចសហប្រតិបត្តិការនាវាចរតាមសមុទ្រ។ យោងតាមមូលនិធិ រូបិយប័ណ្ណអន្តរជាតិ (IMF) សេដ្ឋកិច្ចពិភពលោកនឹងបន្តកំណើនជាមួយនឹងអត្រាប្រមាណ ៣,៣% សម្រាប់ឆ្នាំ ២០១៩ ចំណែកសេដ្ឋកិច្ចកម្ពុជានឹងមានកំណើនប្រមាណ ៧% សម្រាប់ឆ្នាំ២០១៩។ នេះបង្ហាញថាស្ថានភាពសេដ្ឋកិច្ចកម្ពុជា នៅតែមានភាពរឹងមាំងដែលជាកត្តាវិជ្ជមានចំពោះអាជីវកម្មកំពង់ផែ។ ម្យ៉ាងវិញទៀតគិតត្រឹមឆ្នាំ២០១៩ នេះ មិនមានកត្តាអវិជ្ជមានលើបញ្ហាសន្តិសុខក្នុងប្រទេស ឬក្នុងតំបន់ បញ្ហាការធ្វើចរាចរណ៍តាមផ្លូវសមុទ្រ ឬកិច្ចសហប្រតិបត្តិការនានារវាងកំពង់ផែក្នុងតំបន់កើតមានឡើយ ។

- **សមត្ថភាព និងប្រសិទ្ធភាពបំពេញការងាររបស់ កសស**

សម្រាប់ឆ្នាំ២០១៩ **កសស** មានសមត្ថភាពលើកដាក់កុងតឺន័ររហូតដល់ ៦៥0.000 TEUs បន្ទាប់ពីការដាក់ឱ្យប្រើប្រាស់រថចល័តលើគែមផែចំនួន ០២ គ្រឿង បន្ថែមទៀតកាលពីឆ្នាំ២០១៧។ កត្តានេះធ្វើឱ្យសមត្ថភាព និងប្រសិទ្ធភាពការងារមានការកើនឡើងក្នុងការបំពេញសេវាកម្មរបស់ខ្លួន ស្របទៅនឹងកំណើនទំនិញឆ្លងកាត់របស់ **កសស** ។

- **ស្ថានភាពបណ្តាញដឹកជញ្ជូនក្នុងស្រុក**

សម្រាប់ឆ្នាំ២០១៩ នេះ បណ្តាញដឹកជញ្ជូនក្នុងស្រុក ពិសេសផ្លូវជាតិលេខ៤ ដែលតភ្ជាប់ពី **កសស** ទៅរាជធានីភ្នំពេញ មានភាពមមាញឹកដោយទំនិញមានការកើនឡើង ជាពិសេសសម្ភារៈសំណង់ និងគ្រឿងចក្រមួយចំនួន ដែលធ្វើអោយចរាចរណ៍មានភាពចង្អៀត និងចំណាយពេលវេលាយូរជាងមុន ប៉ុន្តែការដឹកជញ្ជូនទំនិញឆ្លងកាត់តាមផ្លូវជាតិនេះដំណើរការជាធម្មតា។ រីឯការដឹកជញ្ជូនតាមផ្លូវដែកបច្ចុប្បន្នក្រុមហ៊ុន Royal Railway ឆ្លងកាត់ **កសស** មានយ៉ាងតិច ៤ ជើង ក្នុងមួយសប្តាហ៍ក្នុងការនាំទំនិញចេញចូល ហើយការដឹកជញ្ជូនតាមផ្លូវដែកនេះក៏ប្រព្រឹត្តទៅដោយរលូនតាមធម្មតាមិនមានបញ្ហាធ្វើឱ្យខកខានដំណើរនោះទេ ។

- **កិច្ចសហប្រតិបត្តិការរវាងផែក្នុងតំបន់**

កិច្ចសហប្រតិបត្តិការរវាងផែក្នុងតំបន់ ពិសេសគឺការតភ្ជាប់ជាមួយកំពង់ផែមេក្នុងតំបន់មានសារៈសំខាន់ក្នុងការសំរួលចរាចរណ៍ទំនិញរវាង **កសស** និងទីផ្សារអន្តរជាតិសំខាន់ៗ ដោយមានឥទ្ធិពលលើចំណាយ និងរយៈពេលដឹកជញ្ជូន ដែលជាលទ្ធផលធ្វើឱ្យមានផលប៉ះពាល់លើភាពប្រកួតប្រជែងរបស់ឧស្សាហកម្មនានា។ ក្នុងករណីនេះ **កសស** បានខិតខំរក្សាទំនាក់ទំនងល្អជាមួយបណ្តាកំពង់ផែសំខាន់ៗ ក្នុងតំបន់ដើម្បីធានាឱ្យប្រតិបត្តិការមានភាពរលូន។

- **រំលស់**

ដោយអាជីវកម្មរបស់ **កសស** មានការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធច្រើន ចំណាយលើរំលស់លើហេដ្ឋារចនាសម្ព័ន្ធផែដូចជា ចំណតនាវា គ្រឿងចក្រ អគារ មានទំហំធំដែលអាចប៉ះពាល់ដល់អាជីវកម្មរបស់ **កសស**។

ដូចនេះ **កសស** ចាំបាច់ត្រូវមានការត្រួតពិនិត្យលើគោលនយោបាយរបស់ខ្លួនឱ្យបានសមស្រប និងធ្វើការកែតម្រូវតាមការចាំបាច់រៀងរាល់ការិយបរិច្ឆេទរបាយការណ៍ហិរញ្ញវត្ថុ។ សម្រាប់ឆ្នាំ២០១៩នេះ ពុំមានការកែសម្រួល ឬការស្នើឱ្យមានការកែសម្រួលគោលនយោបាយរបស់នេះពីសវនករឯករាជ្យឡើយ។

## ខ- កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ

### ក- ការវិភាគពីលក្ខខណ្ឌនៃតម្រូវការ និងការផ្គត់ផ្គង់

សកម្មភាពអាជីវកម្មរបស់ **កសស** មានទំនាក់ទំនងដោយផ្ទាល់ជាមួយសេដ្ឋកិច្ចជាតិ សេដ្ឋកិច្ចតំបន់ និងសេដ្ឋកិច្ចសាកលលោក។ ជាពិសេសនៅពេលសេដ្ឋកិច្ចជាតិមានបម្រែបម្រួល និងមានឥទ្ធិពលដោយផ្ទាល់ទៅលើអាជីវកម្ម សេវាកម្មកំពង់ផែ ពោលគឺនៅពេលសេដ្ឋកិច្ចជាតិកើនឡើងនាំឱ្យអាជីវកម្ម សេវាកម្ម កំពង់ផែក៏កើនឡើងស្របនឹងនេះផលចំណូលរបស់ **កសស** ក៏មានកំណើនដូចគ្នា ផ្ទុយទៅវិញ បើសេដ្ឋកិច្ចជាតិថយចុះនឹងមានផលអវិជ្ជមានទៅលើផលចំណូល **កសស** ផងដែរ។ យោងតាមមូលនិធិរូបិយប័ណ្ណអន្តរជាតិ (IMF) សេដ្ឋកិច្ចកម្ពុជានៅតែបន្តកំណើនរបស់ខ្លួនដែលមានអត្រារំពឹងទុកប្រមាណ ៧% សម្រាប់ឆ្នាំ២០១៩ នេះ ចំណែកសេដ្ឋកិច្ចពិភពលោកមានកំណើនប្រមាណ ៣,៣% សម្រាប់ឆ្នាំ២០១៩។ ហេតុដូចនេះ សម្រាប់ឆ្នាំ ២០១៩ មិនមានផលប៉ះពាល់អវិជ្ជមាន លើអាជីវកម្មរបស់ **កសស** ឡើយ ។

### ខ- ការវិភាគពីការឡើងចុះនៃថ្លៃវត្ថុធាតុដើម

ប្រេងឥន្ធនៈ ជាវត្ថុធាតុដើមចម្បងបំផុតក្នុងការបម្រើសេវាកម្មកំពង់ផែ ដោយជាតម្រូវការសំខាន់សម្រាប់ប្រតិបត្តិការគ្រឿងចក្រ។ ការឡើងថ្លៃរបស់ប្រេងឥន្ធនៈនឹងប៉ះពាល់ដល់ផលចំណេញរបស់ **កសស** ដោយ **កសស** នៅតែរក្សាតម្លៃសេវារបស់ខ្លួនដដែល ទោះជាតម្លៃរបស់ប្រេងឥន្ធនៈមានការឡើងថ្លៃក៏ដោយ។ ហេតុដូចនេះ **កសស** បានអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវនីតិវិធីលទ្ធកម្ម ដើម្បីធានាឱ្យបាននូវតម្លៃរបស់វត្ថុធាតុដើមទាំងនេះមានភាពសមស្រប និងប្រកួតប្រជែងក្នុងតម្លៃទីផ្សារ ។

### គ- ការវិភាគលើពន្ធ

**កសស** ស្ថិតនៅក្រោមច្បាប់នៃក្រុមហ៊ុនពាណិជ្ជកម្មក្នុងវិស័យពន្ធដារ និងអាករ ហេតុដូចនេះ **កសស** មានកាតព្វកិច្ចត្រូវបង់ពន្ធអាករទៅតាមច្បាប់ និងបញ្ញត្តិជាធរមាន។ **កសស** ត្រូវបង់ពន្ធអាករទៅតាមរបបពិត និងជាសហគ្រាសជាប់ពន្ធធំដែលបានកំណត់ដោយអគ្គនាយកដ្ឋានពន្ធដារ។ ចំពោះពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ **កសស** ត្រូវមានកាតព្វកិច្ចបង់ក្នុងអត្រា ២០% ប៉ុន្តែដោយទទួលបានការលើកទឹកចិត្តក្នុងវិស័យមូលបត្រ **កសស** ទទួលបានការបន្ធូរបន្ថយពន្ធលើប្រាក់ចំណេញចំនួន ៥០% នៃពន្ធលើប្រាក់ចំណេញត្រូវបង់ប្រចាំឆ្នាំក្នុងរយៈពេល៣ឆ្នាំ។ ដូច្នេះ ក្រោយពីបញ្ចប់ការអនុគ្រោះនេះ **កសស** នឹងអនុវត្តកាតព្វកិច្ចពន្ធលើប្រាក់ចំណេញដូចធម្មតាវិញ។ ចំណែកពន្ធផ្សេងៗ **កសស** បានអនុវត្តតាមកាតព្វកិច្ចរបស់ខ្លួនតាមច្បាប់ពន្ធដាររបស់ព្រះរាជាណាចក្រកម្ពុជា ។

## គ- ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល

ចំណូលសំខាន់របស់ **កសស** មានចំណូលលើកដាក់ និងចំណូលពីសេវាកម្មផែដែលរួមចំណែកប្រមាណ ៩២% នៃចំណូលសរុបសម្រាប់ឆ្នាំ២០១៩ ហើយកត្តាចម្បងដែលជំរុញឱ្យមានការកើនឡើងនៃប្រាក់ចំណូល គឺ

កំណើននៃនាវា និងទំនិញឆ្លងកាត់កំពង់ផែ ជាពិសេសទំនិញកុងតឺន័រដែលជាប្រភពចំណូលដ៏សំខាន់របស់ **កសស**។ ការលូតលាស់ក្នុងវិស័យកសិកម្ម វិស័យពាណិជ្ជកម្ម វិស័យសំណង់ និងវិស័យឧស្សាហកម្ម គឺបានឆ្លុះបញ្ចាំងនូវស្ថានភាពសេដ្ឋកិច្ចជាតិរបស់ប្រទេសកម្ពុជា ហើយស្របនឹងនេះក៏មានឥទ្ធិពលជាវិជ្ជមានលើអាជីវកម្ម សេវាកម្ម និងផលចំណូលរបស់ **កសស** ផងដែរ ។

## ឃ- ផលប៉ះពាល់នៃការប្តូររូបិយបណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ

**- ផលប៉ះពាល់ពីអត្រាប្តូរប្រាក់**

**កសស** បានទទួលប្រាក់កម្ចីបន្តតាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពី JICA និង JBIC ដោយតម្រូវឱ្យ **កសស** សងប្រាក់ដើម និងការប្រាក់ជាប្រាក់យ៉េនជប៉ុន និងប្រាក់ដុល្លារអាមេរិក នៅពេលដែលរូបិយវត្ថុមុខងាររបស់ **កសស** គឺជាប្រាក់រៀល។ ដូចនេះ បំរែបំរួលអត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិក ប្រាក់រៀលធៀបនឹងប្រាក់យ៉េនជប៉ុន និងប្រាក់ដុល្លារធៀបនឹងប្រាក់យ៉េនជប៉ុន នឹងប៉ះពាល់ដល់កម្រិតប្រាក់ចំណេញរបស់ **កសស** ។

**- ផលប៉ះពាល់ពីអត្រាការប្រាក់**

បច្ចុប្បន្ន **កសស** មិនមានកម្ចីណាដែលមានអត្រាការប្រាក់ប្រែប្រួលនោះទេ។ **កសស** បានទទួលប្រាក់កម្ចីពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលជាកម្ចីបន្តពី JICA និង JBIC ក្នុងអត្រាការប្រាក់ចាប់ពី ២,៥% ដល់ ៣,៧%។ ហេតុដូចនេះ សម្រាប់ឆ្នាំ២០១៩ នេះ មិនមានផលប៉ះពាល់ពីបម្រែបម្រួលអត្រាការប្រាក់នេះទេ ។

**-ផលប៉ះពាល់ពីការប្រែប្រួលតម្លៃប្រេងឥន្ធនៈ**

ការប្រែប្រួលតម្លៃប្រេងឥន្ធនៈនឹងមានផលប៉ះពាល់ដល់ផលចំណេញរបស់ **កសស** ដោយប្រតិបត្តិការកំពង់ផែពឹងផ្អែកយ៉ាងខ្លាំងទៅលើគ្រឿងចក្រដែលប្រើប្រាស់ប្រេងឥន្ធនៈ។ ហេតុដូចនេះ **កសស** បានពង្រឹងប្រសិទ្ធភាពលើកដាក់ និងការគ្រប់គ្រងទីលានកុងតឺន័រ ដើម្បីកាត់បន្ថយការរើឬការបំលាស់ទីកុងតឺន័រដែលមិនចាំបាច់ ដើម្បីកាត់បន្ថយចំណាយប្រតិបត្តិការ និងលើកកំពស់សេវាកម្មរបស់ខ្លួន ។

## ង- ផលប៉ះពាល់នៃអតិផរណា

**កសស** បានរក្សានូវតម្លៃសេវាកម្មរបស់ខ្លួនថេរ ដោយមិនធ្វើការប្រែប្រួល ឬកែសម្រួលទៅតាមការប្រែប្រួលនៃអតិផរណាឡើយ ហើយនៅតែរក្សាបាននូវស្ថេរភាពហិរញ្ញវត្ថុបានយ៉ាងប្រសើរ ។

## ច- គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រាជរដ្ឋាភិបាល

គោលនយោបាយ សេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុ របស់រដ្ឋាភិបាលមានឥទ្ធិពលយ៉ាងខ្លាំងលើអាជីវកម្មរបស់ **កសស** ដោយសារគោលនយោបាយនេះមានទិសដៅគាំទ្រ និងលើកស្ទួយវិស័យពាណិជ្ជកម្មអន្តរជាតិ និងផ្តល់ផលវិជ្ជមានដល់អាជីវកម្មរបស់ **កសស**។ គោលនយោបាយសំខាន់ៗរបស់រាជរដ្ឋាភិបាលរួមមាន៖

- គោលនយោបាយលើកស្ទួយវិស័យឧស្សាហកម្ម រាជរដ្ឋាភិបាលមានគំរោងប្រែក្លាយខេត្តព្រះសីហនុឱ្យទៅជាមជ្ឈមណ្ឌលពាណិជ្ជកម្ម ឡូជីស្ទីក និងផលិតកម្ម តាមរយៈការកសាងហេដ្ឋារចនាសម្ព័ន្ធផែ

ពង្រីកផ្លូវជាតិលេខ ៤ **និងគម្រោងសាងសង់ផ្លូវល្បឿនលឿនពីភ្នំពេញ-ខេត្តព្រះសីហនុ** និងហេដ្ឋារចនាសម្ព័ន្ធព្រលានយន្តហោះអន្តរជាតិខេត្តព្រះសីហនុផងដែរ ។

- វិស័យឧស្សាហកម្មរ៉ែ ថាមពល ការរុករកប្រេងក្នុងដែនសមុទ្រកម្ពុជាកំពុងមានការអភិវឌ្ឍន៍ ហើយ **កសស** បានត្រៀមខ្លួនជាស្រេចក្នុងការគាំទ្រវិស័យទាំងនោះ
- គោលនយោបាយជម្រុញការដឹកជញ្ជូនតាមផ្លូវទឹក
- គោលនយោបាយនាំចេញអង្ករចេញទៅទីផ្សារក្រៅប្រទេស កំពុងផ្តល់ផលវិជ្ជមានដល់ **កសស**
- គោលនយោបាយលើកស្ទួយពាណិជ្ជកម្មអន្តរជាតិ ដោយខិតខំកាត់បន្ថយឧបសគ្គនានា ចំពោះការធ្វើពាណិជ្ជកម្មរវាងកម្ពុជានិងបណ្តាប្រទេសជាដៃគូក្នុងសាកលលោក
- រាជរដ្ឋាភិបាលតាមរយៈធនាគារជាតិ បានអនុវត្តគោលនយោបាយរូបិយវត្ថុតាមរយៈយន្តការ ទីផ្សារប្តូរប្រាក់សេរីតែស្ថិតនៅក្រោមអន្តរាគមន៍ ដើម្បីរក្សាស្ថេរភាពរូបិយប័ណ្ណជាតិ ហើយលំនឹងរូបិយវត្ថុនេះបាន រក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចកម្ពុជា ដែលបានកសាងទំនុកចិត្តចំពោះវិនិយោគិន និងជម្រុញការធ្វើអាជីវកម្មវិស័យឯកជន
- ការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រដល់សហគ្រាសបោះផ្សាយលក់មូលបត្រនៅកម្ពុជា បាននឹងកំពុងជម្រុញឱ្យសហគ្រាសរដ្ឋ និងក្រុមហ៊ុនឯកជនចូលទីផ្សារមូលបត្រកាន់តែច្រើនដែលចូលរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ។



# ផ្នែកទី ៩
# ព័ត៌មានចាំបាច់ផ្សេងទៀតសម្រាប់ការពារវិនិយោគិន

សម្រាប់ឆ្នាំ២០១៩ នេះ **កសស** មានព័ត៌មានចាំបាច់សម្រាប់ការពារវិនិយោគិនដូចខាងក្រោម ៖

**សម័យប្រជុំក្រុមប្រឹក្សាភិបាល អាណត្តិទី៧ លើកទី៣ នាថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៩**

កិច្ចប្រជុំបានពិនិត្យ ពិភាក្សា និងសម្រេចលើចំនុចដូចខាងក្រោម៖

- ក្រុមប្រឹក្សាភិបាលបានឯកភាពលើលទ្ធផលកិច្ចប្រជុំក្រុមប្រឹក្សាភិបាល អាណត្តិទី៧ លើកទី២ កាលពីថ្ងៃទី ០១ ខែតុលា ឆ្នាំ២០១៨ និងស្នើអោយ ដាក់បញ្ចូលបញ្ហារៀបចំ Disaster Recovery Data Centre ក្នុងRisk Management ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ និងឯកភាពលើរបាយការណ៍របស់ គណៈកម្មាធិការ គ្រប់គ្រងហានិភ័យ )Risk Committee ( និងគណៈកម្មាធិការសវនកម្ម (Audit Committee) ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តលើរបាយការណ៍បូកសរុបលទ្ធផលការងារអាជីវកម្ម **កសស** ២០១៨ ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ត្រីមាសទី៣ ឆ្នាំ២០១៨ ដែលបានត្រួតពិនិត្យដោយក្រុមហ៊ុនសវនកម្មឯករាជ្យ PWC (Financial Performance Review) ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ និងអនុម័តលើសំណើសុំជម្រះបញ្ជីអចលនទ្រព្យ (គ្រឿងចក្រ និងរថយន្តចាស់ៗ) ដោយរៀបចំនីតិវិធីសមស្រប ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តលើសំណើសុំកែសម្រួលផែថ្មី (៣៥០ម៉ែត្រ សាងសង់ឆ្នាំ១៩៦៧) ទៅជាចំណតផែកុងតឺន័រប្រវែង ២៤៣ម៉ែត្រ និងបំពាក់គ្រឿងចក្រលើកដាក់កុងតឺន័រ (QC) ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តលើសំណើសុំតបណ្តាញអគ្គីសនីកម្លាំង 2x20 MW ចូលកំពង់ផែស្វយ័តក្រុងព្រះសីហនុ និងតំបន់សេដ្ឋកិច្ចពិសេស **កសស** ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តលើគោលការណ៍គាំទ្រ Concept របស់ Free Port Policy និងស្នើសុំអោយ JICA និង **កសស** ជួយសិក្សាបន្ថែម ។
- សេចក្តីផ្សេងៗ ៖
  - ក្រុមប្រឹក្សាភិបាលបានពិនិត្យ និងពិភាក្សា ដោយមិនឯកភាពអោយនាវាឈ្មោះ Ji Mei របស់ក្រុមហ៊ុន ស្តារហាប៊ើរ អ៊ីនធើណេសិនណល ត្រាវែល ឯ.ក (Star Harbor International Travel Company Limited) បន្តកិច្ចសន្យាជួលចំណតផែ របស់ **កសស** ។
  - ក្រុមប្រឹក្សាភិបាលបានពិនិត្យ និងពិភាក្សា ហើយឯកភាពជាគោលការណ៍គាំទ្រនូវសំណើសុំផ្លាស់ប្តូរទីលំនៅរបស់ប្រជាជននៅតំបន់ទំនប់រលក ។
  - ក្រុមប្រឹក្សាភិបាលបានពិនិត្យ និងពិភាក្សា ហើយឯកភាពជាគោលការណ៍អោយ **កសស** ពិនិត្យកិច្ចព្រមព្រៀងក្របខណ្ឌស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការយុទ្ធសាស្ត្ររវាង **កសស** និងកំពង់

ផែ Qingdao ក្នុងគោលបំណងដើម្បីជួយសម្រួលដល់ការដឹកជញ្ជូនទំនិញពីកំពង់ផែ Qingdao មក **កសស** ប៉ុណ្ណោះ ។

**សម័យប្រជុំក្រុមប្រឹក្សាភិបាល អាណត្តិទី៧ លើកទី៤ នាថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៩**

កិច្ចប្រជុំបានពិនិត្យ ពិភាក្សា និងសម្រេចលើចំនុចដូចខាងក្រោម៖

- ក្រុមប្រឹក្សាភិបាលបានឯកភាពលើលទ្ធផលដែលបានសម្រេចបាន និងកំពុងអនុវត្តបន្តឆ្លើយតបទៅនឹងលទ្ធផលសម័យប្រជុំក្រុមប្រឹក្សាភិបាល អាណត្តិទី៧ លើកទី៣ កាលពីថ្ងៃទី ០៤ ខែមករា ឆ្នាំ២០១៩ កន្លងមក ។
- ក្រុមប្រឹក្សាភិបាលបានពិភាក្សាមាន សំនួរ-ចម្លើយ និងថ្លែងអំណរគុណដល់តំណាងក្រុមហ៊ុន PWC ដែលបានធ្វើបទបង្ហាញអំពីដំណើរការនៃការធ្វើសវនកម្ម ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងឯកភាពលើរបាយការណ៍របស់គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងគណៈកម្មាធិការសវនកម្ម ដែលបានស្នើឡើង និងការរៀបចំការបញ្ចុះតម្លៃឈ្នួលផែដោយចាប់ពីថ្ងៃទី ០១ ខែឧសភា ឆ្នាំ២០១៩ ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តដោយឯកភាពលើរបាយការណ៍បូកសរុបលទ្ធផលការងារអាជីវកម្ម ៣ខែ ដើមឆ្នាំ២០១៩ ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តដោយឯកភាពលើរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ត្រីមាសទី៤ និងសម្រាប់ដំណាច់ការិយបរិច្ឆេទ ១២ខែ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ ដែលបានត្រួតពិនិត្យដោយក្រុមហ៊ុនសវនកម្មឯករាជ្យ PWC ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តដោយឯកភាពលើការបែងចែកភាគលាភ (Dividend) ការកំណត់កាលបរិច្ឆេទកំណត់ទុកដែលត្រូវបែងចែកភាគលាភ (Record Date) និងកាលបរិច្ឆេទចាប់ផ្តើមទូទាត់ភាគលាភ (Payment Date) ជូនភាគហ៊ុនិកសម្រាប់ការិយបរិច្ឆេទ ឆ្នាំ២០១៨។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តដោយឯកភាពលើកាលបរិច្ឆេទមហាសន្និបាតភាគហ៊ុនិក លើកទី២ ឆ្នាំ២០១៩ នៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៩ នៅសាលប្រជុំធំ កំពង់ផែស្វយ័តក្រុងព្រះសីហនុ ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តលើសេចក្តីព្រាងលក្ខន្តិកៈ (AOI) ដែលស្នើសុំកែសម្រួល ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តដោយឯកភាពអោយ លុបបំណុលថ្លៃជួលទីតាំងស្តុកចំណាំងឈើអាកាសស្បានាំចេញ របស់ក្រុមហ៊ុន ADONIS International Group Ltd ដែលនៅជំពាក់ចំនួន ៧១.២៥០ ដុល្លារ តាំងពីឆ្នាំ២០១៣ ចេញពីបញ្ជីការគណនេយ្យរបស់ **កសស** ។
- សេចក្តីផ្សេងៗ ៖
  - ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តលើកាលបរិច្ឆេទរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាភិបាលដើម្បីពិនិត្យ និងសម្រេចលើរបាយការណ៍ហិរញ្ញវត្ថុរៀងរាល់ត្រីមាសនីមួយៗ ។

- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តអោយ **កសស** សហការជាមួយ JICA ដើម្បីសិក្សាពី New Business Model ឬបន្ថែមលើ Function របស់ SEZ និងឯកភាពឱ្យមានវិធានការបន្តអំពី "Free Port Concept" ដើម្បីធ្វើអោយប្រសើរឡើងនូវភាពប្រកួតប្រជែងរបស់ **កសស** ។

**សម័យប្រជុំក្រុមប្រឹក្សាភិបាល អាណត្តិទី៧ លើកទី៥ នាថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៩**

កិច្ចប្រជុំបានពិនិត្យ ពិភាក្សា និងសម្រេចលើចំនុចដូចខាងក្រោម៖

- ក្រុមប្រឹក្សាភិបាលបានឯកភាពលើលទ្ធផលដែលបានសម្រេចបាន និងកំពុងអនុវត្តបន្តឆ្លើយតបទៅនឹងលទ្ធផលសម័យប្រជុំក្រុមប្រឹក្សាភិបាល អាណត្តិទី៧ លើកទី៤ កាលពីថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៩ កន្លងមក ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងថ្លែងអំណរគុណដល់តំណាងក្រុមហ៊ុន PWC ដែលបានធ្វើបទបង្ហាញអំពីការងារ Result of reviewing and reporting timelines និងបានធ្វើការសម្រេចទៅលើ៖
  - ការអនុវត្តតាមប្រកាសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពីការទូទាត់ប្រាក់បំណាច់អតីតភាពការងារជូននិយោជិតសម្រាប់ឆ្នាំ២០១៩ ។
  - ឯកភាពលើ Reporting timetable ដែលបានស្នើឡើងខាងលើដោយក្រុមហ៊ុនសវនករឯករាជ្យ PWC និងសូមអោយនាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ សហការជាមួយ PWC ដើម្បីរៀបចំរបាយការណ៍ហិរញ្ញវត្ថុអោយបានទាន់ពេលវេលា និងជូនដំណឹងទៅលេខាធិការដ្ឋានដើម្បីស្នើសុំកំណត់កាលបរិច្ឆេទកិច្ចប្រជុំក្រុមប្រឹក្សាភិបាល។
  - ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តដោយឯកភាពលើរបាយការណ៍ហិរញ្ញវត្ថុត្រីមាសទី២ និងឆមាសទី១ ឆ្នាំ២០១៩ ដែលបានត្រួតពិនិត្យដោយក្រុមហ៊ុនសវនកម្មឯករាជ្យ PWC ។
  - ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងឯកភាពលើរបាយការណ៍របស់គណៈកម្មាធិការសវនកម្ម និងគណៈកម្មាធិការគ្រប់គ្រងហានិភ័យ ដែលបានលើកឡើង។ ទន្ទឹមហ្នឹងនេះផងដែរ អង្គប្រជុំបានស្នើសុំអោយ Mr. KUME ធ្វើការបន្តជាមួយ JICA ដើម្បីប្រែក្លាយប្រាក់បំណុលជប៉ុន ODA Loan ពីយ៉េនជប៉ុន ទៅដុល្លារអាមេរិក និងចរចារធ្វើយ៉ាងណាទទួលបានអត្រាការប្រាក់ទាបនៅពេលដែលបំណុល Convert មកជាប្រាក់ដុល្លារអាមេរិក។
  - ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តដោយឯកភាពលើរបាយការណ៍បូកសរុបលទ្ធផលការងារអាជីវកម្ម **កសស** ៧ខែ ដើមឆ្នាំ២០១៩ ។

- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តដោយឯកភាពលើវិធានការដោះស្រាយលើស្ថានភាពកំពង់ផែបច្ចុប្បន្ន និងការកែសម្រួលតារាងថ្លៃស្តុកកុងតឺន័រ ហើយអង្គប្រជុំបានសម្រេច និងជម្រុញបន្ថែមទៅលើចំណុចដូចខាងក្រោម ៖
  - បន្តជម្រុញនូវវិធានការជាបន្ទាន់របស់ **កសស** ក្នុងការកែសម្រួលចំណតផែទំនិញទូទៅនៅមុខឃ្លាំងលេខ៥ ទៅជាចំណតផែកុងតឺន័របន្ថែមប្រវែង ២៤៣ ម៉ែត្រ និងការបំពាក់គ្រឿងចក្របន្ថែមអោយសម្រេចបានឆាប់រហ័ស និងទាន់ពេលវេលា ។
  - ជម្រុញការតបណ្តាញអគ្គិសនី ៤០ មេហ្គាវ៉ាត់ (ពីអគ្គិសនីកម្ពុជា - EDC) ចូល **កសស** និងតំបន់សេដ្ឋកិច្ចពិសេស **កសស** ។
  - ពង្រីកទីលានស្តុកកុងតឺន័រ និងមធ្យោបាយលើកដាក់អោយកាន់តែមានប្រសិទ្ធភាព ដោយត្រៀមដោះស្រាយកំណើនកុងតឺន័រពីបច្ចុប្បន្នរហូតដល់ពាក់កណ្តាលឆ្នាំ២០២៤ (ផែកុងតឺន័រថ្មីធ្វើហើយ)។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តដោយឯកភាពលើបទបញ្ជា និងនីតិវិធីស្តីពីការជ្រើសតាំងតំណាងនិយោជិត កំពង់ផែស្វយ័តក្រុងព្រះសីហនុ ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តដោយអនុញ្ញាតអោយ **កសស** ពិភាក្សាដោយផ្ទាល់ជាមួយក្រុមហ៊ុនឯកជន ដែលមានបំណងចង់វិនិយោគលើទីតាំងដីសេះស ដែលស្ថិតនៅភូមិ៣ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ដោយក្រុមហ៊ុនត្រូវរៀបចំផែនការអភិវឌ្ឍន៍ (Master Plan) ផែនការអាជីវកម្ម (Business Plan) និងកិច្ចសន្យាវិនិយោគអោយបានច្បាស់លាស់ ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងអនុម័ត និងគោរពជម្រាបស្នើសុំគោលការណ៍សម្រេចពីឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តដោយឯកភាពអោយ **កសស** លក់ដីចំនួន ០១ កន្លែង ដែលស្ថិតនៅភូមិគគីរ ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ដើម្បីយកថវិកាមកវិនិយោគ និងពង្រីកសមត្ថភាពកំពង់ផែបន្ថែមទៀត ។

**សម័យប្រជុំក្រុមប្រឹក្សាភិបាល អាណត្តិទី៧ លើកទី៦ នាថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៩**

កិច្ចប្រជុំបានពិនិត្យ ពិភាក្សា និងសម្រេចលើចំនុចដូចខាងក្រោម៖

- ក្រុមប្រឹក្សាភិបាលបានឯកភាពលើលទ្ធផលដែលបានសម្រេចបាន និងកំពុងអនុវត្តបន្តឆ្លើយតបទៅនឹងស្មារតីសម័យប្រជុំក្រុមប្រឹក្សាភិបាល អាណត្តិទី៧ លើកទី៥ កាលពីថ្ងៃទី ០៩ ខែសីហា ឆ្នាំ ២០១៩ កន្លងមក ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងឯកភាពទៅលើរបាយការណ៍ស្តីពីស្ថានភាពបច្ចុប្បន្នរបស់ **កសស** និងតំបន់សេដ្ឋកិច្ចពិសេស និងស្នើអោយ **កសស** បន្តជម្រុញអនុវត្តនូវវិធានការដោះស្រាយនានាដែលបានលើកឡើង ។

- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តដោយឯកភាពលើរបាយការណ៍ហិរញ្ញវត្ថុត្រីមាសទី៣ ឆ្នាំ២០១៩ ដែលបានត្រួតពិនិត្យ ដោយក្រុមហ៊ុនសវនកម្មឯករាជ្យ PWC ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តដោយឯកភាពលើរបាយការណ៍បូកសរុបលទ្ធផលការងារអាជីវកម្ម **កសស** ៩ខែ ដើមឆ្នាំ២០១៩ ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងឯកភាពតាមរបាយការណ៍របស់ គណៈកម្មាធិការសវនកម្ម និងគណៈកម្មាធិការគ្រប់គ្រងហានិភ័យ ដែលបានលើកឡើងដោយស្នើអោយ **កសស** ត្រូវបន្តជម្រុញអនុវត្តៈ
  - លទ្ធផលរបស់គណៈកម្មាធិការសវនកម្ម និងគណៈកម្មាធិការគ្រប់គ្រងហានិភ័យ ដែលបានស្នើឡើង
  - រៀបចំលិខិតគោរពស្នើស្នើសុំគោលការណ៍សម្រេចដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** លើបញ្ហាបំណុលដែលក្រុមហ៊ុន អយស្ម័យយាន ថូល-រ៉ូយ៉ាល់ (Toll Royal (Cambodia)) ជំពាក់ **កសស**
  - ពិនិត្យ និងកែសម្រួលតារាងតម្លៃ (Tariff) របស់តំបន់សេដ្ឋកិច្ចពិសេសកំពង់ផែស្វយ័តក្រុងព្រះសីហនុ អោយស្របតាមស្ថានភាពវិវឌ្ឍន៍របស់ខេត្តព្រះសីហនុ ។
  - ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តដោយឯកភាពលើគម្រោងផែនការអាជីវកម្ម (សេវាកម្ម) ហិរញ្ញវត្ថុ **កសស** ឆ្នាំ២០២០ ។
  - ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តដោយឯកភាពលើ ៖
  - កែសម្រួល នាយកដ្ឋានបច្ចេកទេស សម្ភារៈ-សំណង់ ទៅជានាយកដ្ឋានចំនួន ០២ គឺនាយកដ្ឋានបច្ចេកទេស-សម្ភារៈ និងនាយកដ្ឋានសំណង់- វិស្វកម្ម
  - តែងតាំង **លោក ទី សាគុណ** ជានាយក នាយកដ្ឋានបច្ចេកទេស-សម្ភារៈ
  - តែងតាំង **លោក មាន គឹង** ជានាយក នាយកដ្ឋានសំណង់-វិស្វកម្ម ។
- ក្រុមប្រឹក្សាភិបាលបានពិនិត្យ ពិភាក្សា និងអនុម័តដោយឯកភាពបង្កើតគណៈកម្មាធិការតែងតាំង និងលាភការ ដោយតែងតាំង **ឯកឧត្តម សុខ សុភ័ក្រ្ត** តំណាងក្រសួងពាណិជ្ជកម្ម ជាប្រធាន ។

# ហត្ថលេខាអភិបាលរបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ

ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០
បានអាន និងឯកភាព

ហត្ថលេខា
**លូ គឹមឈន់**
ប្រធានអគ្គនាយក

ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០
បានអាន និងឯកភាព

ហត្ថលេខា
**ស៊ុយ សាន**
អភិបាល

ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០
បានអាន និងឯកភាព

ហត្ថលេខា
**ផាន់ ផល្លា**
អភិបាល

ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០
បានអាន និងឯកភាព

ហត្ថលេខា
**សុខ សុភ័ក្ត្រ**
អភិបាល

ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០
បានអាន និងឯកភាព

ហត្ថលេខា
**ហ៊ុន មុន្នីវណ្ណ**
អភិបាល

ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០
បានអាន និងឯកភាព

ហត្ថលេខា
Hidetoshi KUME
អភិបាល

ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០
បានអាន និងឯកភាព

ហត្ថលេខា
**លូ លីខេង**
អភិបាល

# កំពង់ផែស្វយ័តក្រុងព្រះសីហនុ

Sihanoukville Autonomous Port




**អាសយដ្ឋាន**

ផ្លូវ:វិថីសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ
ព្រះរាជាណាចក្រកម្ពុជា

**ទំនាក់ទំនង**

034 933 416 pasinfo@pas·gov·kh
034 933 511 pas.gov.kh
034 933 693 sihanoukville.autonomou